# អដ្ឋកថា ព្រះអភិធម្មបិដក

# បរមត្ថទីបនី បញ្ចបករណ៍
# កថាវត្ថុបករណ៍ តតិយភាគ



## ១០

ពុទ្ធសករាជ ២៥៥៧

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## តតិយភាគ

## ១០


រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែរៀបរៀងដោយខ្ញុំព្រះករុណា ខ្ញុំបាទ សុន្ទរ៍-សារម្សៀន



ព. ស. ២៥៥៧ គ. ស. ២០១៣

# បរមត្ថទីបនី

## តតិយភាគ

## ១០

ព. ស.

២៥៥៧

គ. ស.

២០១៣

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះថា  បញ្ចបករណ៍

## ( កថាវត្ថុបករណ៍)

## តតិយភាគ

## ១០

## រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្តើមប្រែរៀបរៀងដោយខ្ញុំព្រះករុណា ខ្ញុំបាទ សុន្ទរ៍-សារម្សៀន

ព. ស. ២៥៥៨ គ. ស. ២០១៣

## សេចក្ដីបញ្ជាក់

*គម្ពីរ* **អដ្ឋកថាព្រះអភិធម្ម** *ជាពាក្យអធិប្បាយសេចក្ដីក្នុងព្រះអភិ-ធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគ គឺ*

**១.បឋមភាគ** *ឈ្មោះ* **អដ្ឋសាលិនី** *អធិប្បាយគម្ពីរ* ***ធម្មសង្គណី***

**២.ទុតិយភាគ** *ឈ្មោះ* **សម្មោហវិនោទនី** *អធិប្បាយគម្ពីរ* ***វិភង្គ***

**៣.តតិយភាគ** *ឈ្មោះ* **បរមត្ថទីបនី** *អធិប្បាយគម្ពីរ* ***បញ្ចបករណ៍***

*តាំងពី* ***ធាតុកថា*** *រហូតដល់ចប់គម្ពីរ* ***បដ្ឋាន*** *ទាំងអស់ ។*

*បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ។ ឯសៀវភៅដែលលោកអ្នកកំពុងអាននេះ ជាគម្ពីរអដ្ឋ-កថា* ***អភិធម្មបិដក តតិយភាគ 10*** *កើតឡើងដោយស្នាព្រះហស្ដនៃ* ***ព្រះពុទ្ធឃោសាចារ្យ*** *ជាជនជាតិឥណ្ឌា បានរចនានៅឯប្រទេសសិរីលង្កា ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធជាង ៩០០ឆ្នាំ ។ ឯរូបខ្ញុំផ្ទាល់វិញ គ្រាន់តែជាអ្នកផ្ដើមប្រែសម្រួលរៀបរៀង ជាបណ្ដោះអាសន្ន សម្រាប់អ្នកដែលត្រូវការសិក្សារៀនសូត្រតែប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ខ្ញុំ* ***សូមបញ្ជាក់*** *និងសូមទោសជាមុន ចំពោះអ្នកអាន និងអ្នកសិក្សាជាទីគោរពថា ខ្ញុំពុំមានសមត្ថភាពនៃការចេះដឹងគ្រប់គ្រាន់ ដូចសេចក្ដីនៃធម៌ដែលមាននៅក្នុងសៀវភៅនេះទេ ថែមទាំងសមត្ថភាពនៃការប្រែសម្រួល និងរៀបរៀង*

នេះទៀត មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ ការខុសឆ្គាំឆ្គងទាំងនុ៎ះ មានដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ តែខ្ញុំយល់ឃើញថា **មានប្រសើរជាងគ្មាន** ព្រោះសៀវភៅដែលរផ្នូវព្រះអភិធម្មបិដកបែបនេះ មិនទាន់ដែលមានគ្រប់គ្រាន់ក្នុងប្រទេសយើងទេ ដូច្នេះយើងក៏អាចឧទាហរណ៍បានថា ៖

* សម័យណា ដែលមានភាពអន្ធការ សូម្បីតែពន្លឺអំពិលអំពែក ក៏អាចភ្លឺបានដែរ ។

* សម័យណា គ្មានដើមឈើ គេក៏អាចយកដើមល្ហុង ធ្វើជាដើមឈើបានដែរ ។ ល ។ (ស្រីហិតោបទេស) ។

ព្រោះហេតុដូច្នេះ ខ្ញុំសូមផ្ញើនូវគម្ពីរនេះ ដល់លោកអ្នកសិក្សា និងវិញ្ញូជនទាំងឡាយ ជួយកែសម្រួល សម្រាប់សិក្សាតរៀងទៅ ។ ដើម្បីសម្រួលដល់ការបូកសរុបមតិកែតម្រូវ ក្នុងអត្ថបទនេះ សូមមេត្តាជ្រាបដូចតទៅ ៖

១-សូមសរសេរឈ្មោះ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំ ដែលកែសម្រេចនៅលើក្រដាសដែលផ្ញើមក ។

២-ចុះលេខទំព័រ បន្ទាត់ ក្នុងតារាងលេខ ១ និងលេខ ២ ។ ចំពោះសេចក្តី ពាក្យ ឃ្លា ឬអក្ខរាវិរុទ្ធត្រង់ណា ដែលយល់ថា មិនទាន់ត្រឹមត្រូវ សូមសរសេរចុះក្នុងតារាងលេខ ៣ ។ ចំណែកពាក្យដែលយល់ថា គួរកែមកជាយ៉ាងណាវិញនោះ សូមសរសេរចុះក្នុងតារាងលេខ ៤ ។

៣-ប្រសិនបើ ការកែតម្រូវនោះ មានឯកសារបញ្ជាក់ សូមចុះឈ្មោះឯកសារនោះ ក្នុងតារាងលេខ ៥ ។

៤-នៅក្នុងតារាងលេខ ៦ សម្រាប់បញ្ជាក់បន្ថែម ចំពោះករណីពិសេសណា ដែលប្រាថ្នាចង់បញ្ជាក់បន្ថែម ។

៥-សូមផ្ញើកំណែមកខ្ញុំ ដោយការទាក់ទង តាមទូរសព្ទដែលមាននៅក្នុងសៀវភៅនេះស្រាប់ ។

* ប្រសិនបើ នៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀងអក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៣

**ខ្ញុំព្រះករុណា ខ្ញុំបាទ *សុន្ទរ៍ សាមៀន***

សូមអរព្រះគុណ និងអរគុណ

# តារាងកែតម្រូវ “ឮ”

# នាមឈ្មោះអ្នកជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួល

## អដ្ឋកថាតតិយភាគ ១០ នេះ មាន ៖

- ភិក្ខុសាមណេរជាពហូសូតក្នុង **វត្តធុតង្គ** (ចម្ការដូង) មាន ៩រូប
- ភិក្ខុសាមណេរជាពហូសូតក្នុង **វត្តនិគ្រោធវ័ន** មាន ៦ រូប
- ភិក្ខុខន្តិជាតិកោ **វ៉ៃ ភិរក្ស** -ធម្មាចារ្យ ធម្មានន្ទោ **សួង សឿ**
- ភិក្ខុធម្មរក្ខិតោ **គង់ វន** -ភិក្ខុជោតញ្ញាណោ **វ៉ែត សុផាន់**
- ឧបាសក **ពុង ស៊ីម** -ឧបាសក **ជាំ កុយ**
- ឧបាសក **សំរ៉ង ចំណ្ណា** -ឧបាសក **រឿង សិរីសុគន្ធ**
- អ្នកគ្រូ **ធី សុធី** -ឧបាសក **ទូ៉ច សុខុម**
- ឧបាសក **រៀម រដ្ឋា**។

## អ្នកមានឧបការៈក្នុងការងារធម្មទាននេះ

- ភិក្ខុបញ្ញាបទីបោ **ព្រឿង ប៊ុនធឿន** -ភិក្ខុខន្តិជាតិកោ **វ៉ៃ ភិរក្ស**
- ឧបាសិកា **លី ស៊ីវងូ** ជាដើម -ឧបាសិកា **ង៉ុន ស៊ូគី** ជាដើម
- ភិក្ខុសាមណេរ **វត្តគីរីម្យចាស់** ជាដើម
- លោក **បាន សុផាន** និងភរិយា
- លោក **ហេង សុវណ្ណារ៉ា** និងក្រុមគ្រួសារ

-ឧបាសក **ស្រេង ចាន់ណា** និងក្រុមគ្រួសារ

-ឧបាសក **ម៉ៅ ផុន** ហៅ **ពុយ** និងសហការី ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសន្ដានចិត្តដ៏ល្អរបស់គុណម្ចាស់ ញាតិញោមជាពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួល ព្រមទាំងចំណាយរូបិយវត្ថុជាដើម ដើម្បីជំរុញឲ្យគម្ពីរនេះចេញជារូបរាងឡើង ។

បន្ទាប់ពីតតិយភាគ ១០ នេះទៅ ខ្ញុំនឹងដំណើរការបោះពុម្ពនូវតតិយភាគ ១១ ជាបន្តទៀត ។

អាស្រ័យហេតុនេះ បើព្រះគុណម្ចាស់ ញាតិញោមត្រូវការចូលប្រាក់ដើម្បីជាធម្មទាន ឬយកផ្ទាល់ខ្លួន ឬក៏យកទៅតម្កល់តាមវត្តនានា ឬថា ចង់ចូលរួមជួយជាមតិយោបល់ ក្នុងន័យស្ថាបនា សូមមេត្តាទាក់ទងតាមរយៈទូរសព្ទដូចខាងក្រោមនេះ ៖

០៩២ ៩០ ៨២ ៦៥

០៩៧ ២៣ ៣០ ២១៥

០១៦ ៨៦ ៥២ ៣៨

## ឧទ្ទិសកថា

ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង ទាំងក្រៅប្រទេស, **អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន** រាជរដ្ឋាភិបាលដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស ទាំងក្រៅប្រទេស មានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូមទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗ រូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។

***ដោយអំណាចនៃមហាកុសលផលធម្មទាននេះ សូមឱ្យ ៖***

*-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ*

*-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា*

*-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ*

*-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ៕*

........................................................................................................................................

**តារាងកែតម្រូវ** ថ្ងៃទី ....... ខែ ..... ឆ្នាំ ...

**តតិយភាគ ១០** ឈ្មោះ .........................

សម្រាប់បោះពុម្ពលើកទី ៣ អាសយដ្ឋាន .................

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ឯកសារយោង | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ បញ្ចបករណ៍

## តតិយភាគ ១០

មាតិកាធម៌ ទំព័រ


ពណ៌នាអំពីបដិកម្មចតុក្កៈ *ពួក ៤ នៃការធ្វើតប* ..... ..... ..... ...... ១

**៣.កាលសត្តិកត្ត**

ពណ៌នាអំពីឧបនយនចតុក្កៈ (បឋមសត្តិកត្ត) ..... ..... ..... ..... ...... ២

**៤.អវយវសត្តិកត្ត**

ពណ៌នាអំពីនិគ្គហៈទី ៣ ..... ..... ..... ..... ..... ..... ..... ....... ៣

,, និគ្គហៈទី ៤ ..... ..... ..... ..... ..... ..... ..... ..... .. ៥

,, ,, ៥ ..... ..... ..... ..... ..... ..... ..... ....... ៦

,, ,, ៦
,, ,, ៧ (និគ្គហៈទី ៦, ៧, ៨) ..... ..... ..... ..... ៦
,, ,, ៨

**៥.សុទ្ធិកសំសន្ទនា** *ការប្រៀបផ្ទឹមសុទ្ធិកៈ* ..... ..... ..... ..... ..... ៧

**៦.ឱបម្មសំសន្ទនា** ,, *សច្ចិកត្ថដោយសេចក្តីឧបមា* ....... ៩

# អដ្ឋកថាព្រះអភិធម្មបិដក

មាតិកាធម៌ ទំព័រ


**៧.ចតុក្កនយសំសន្ទនា** ,, *ដោយន័យរបស់ចតុក្កៈ* ..... ..... ១១

**៨.លក្ខណាយុត្តិកថា** *ពោលអំពីការប្រកបលក្ខណៈ* ..... ..... ..... ..... ១៤

**៩.វចនសោធនៈ** *ការជម្រះពាក្យពេចន៍* ..... ..... ..... ..... ..... ..... ១៦

**១០.បញ្ញត្តានុយោគ** *ការសាកសួររឿងបញ្ញត្តិ* ..... ..... ..... .. ២១

**១១.គតិអនុយោគ** ,, *រឿងគតិ* ..... ..... ..... .....២៣

**១២.ឧបាទាបញ្ញត្តានុយោគ** *ការសាកសួរឧបាទាបញ្ញត្តិ* ..... ..... ..... ៣១

**១៣.កល្យាណវគ្គ** (ឬបុរិសការានុយោគ) *សាកសួរការធ្វើរបស់បុរស* .. ៣៩

**១៤.អភិញ្ញានុយោគ** *ការសាកសួរដល់អ្នកបានអភិញ្ញា* ..... ..... ..... ៤៧

**១៥.ញាតកានុយោគ** ,, *ដល់ពួកញាតិ* ..... ..... ..... ....... ៤៧

**១៦-១៩.បកិណ្ណកៈ** (ឬភវនិស្សាយបញ្ហាទិ) *បញ្ហាអាស្រ័យភពជាដើម* .. ៥០

សម្មតិកថា និងបរមត្ថកថា ..... ..... ..... ..... ..... ..... ..... .... ៥៤


## ២.បរិហានិកថា


**១.វាទយុត្តិបរិហានិ** ការសាបសូន្យនៃការប្រកបវាទៈ ..... ..... ..... ... ៥៧

**២.អរិយបុគ្គលសំសន្ទនា** *ការផ្ទៀងផ្ទាត់ព្រះអរិយបុគ្គល* ..... ..... ..... ៦០

## បរមត្ថទីបនី


**មាតិកាធម៌** ទំព័រ

**៧.សុត្តសោធនា** *ការជម្រះព្រះសូត្រ* ..... ..... ..... ..... ..... ..... ៦៣

### ៣.ព្រហ្មចរិយកថា

**១.សុទ្ធព្រហ្មចរិយកថា** *រឿងព្រហ្មចរិយៈបរិសុទ្ធ* ..... ..... ..... ..... ៦៦

**២.សំសន្ទនព្រហ្មចរិយកថា** *សម្ដែងអំពីការប្រៀបធៀបព្រហ្មចរិយៈ* ... ៧០

### ៤.ឱ្សធិសោកកថា

### ៥.ឋហាតិកថា (ឬបឋហាតិកថា)

**១.នសុត្តាហរណកថា** ..... ..... ...... ..... ..... ..... ..... .... .... ៧៣

### ៦.សព្វមគ្គីតិខានកថា

**១.វាទយុត្តិវណ្ណនា** *ពណ៌នាអំពីការប្រកបវាទៈ* ..... ..... ..... ..... ៧៦

**២.កាលសំសន្ទនាវណ្ណនា** *ពណ៌នាអំពីការប្រៀបធៀបពេលវេលា* ..... ៧៩

**វចនសោធនា** *ការជម្រះពាក្យពេចន៍* ..... ..... ..... ..... ..... ..... ៨១

### ៧.អតីតក្ខន្ធាតិអាធិកថា

**១.នសុត្តសាធនកថាវណ្ណនា** ..... ..... ..... ..... ..... ..... ..... ... ៩៣

**២.សុត្តសាធនកថា** *សម្ដែងអំពីការជម្រះព្រះសូត្រ* ..... ..... ..... ៩៤

### ៨.ឯកច្ចមគ្គីតិកថា

## អដ្ឋកថាព្រះអភិធម្មបិដក

មាតិកាធម៌ ទំព័រ

**១-២.អតីតាទិឯកច្ចកថាវណ្ណនា** ..... ..... ..... ..... ..... ..... ..... ៩៥

## ៩.សតិបដ្ឋានកថា

## ១០.ហេវត្ថិកថា

## វគ្គទី ២

**១.បរូបហារកថា** *សម្តែងអំពីអ្នកដទៃនាំមកឲ្យ* ..... ..... ..... ..... ១០៣

**២-៣-៤.អញ្ញាណ-កង្ខា-បរវិតារណាកថា** *សម្តែងអំពីការមិនដឹង ការសង្ស័យ និងការណែនាំរបស់អ្នកដទៃ* ..... ..... ..... ..... ..... ១០៦

**៥.វចីភេទកថា** *សម្តែងអំពីការបន្លឺវាចា* ..... ..... ..... ..... ..... ... ១០៧

**៦.ទុក្ខាហារកថា** ,, *ការពោលថា "ទុក្ខ"* ..... .. ១១០

**៧.ចិត្តដ្ឋិតិកថា** ,, *ការតាំងនៅនៃចិត្ត* ..... ..... ១១១

**៨.កុក្កុឡកថា** ,, *ផេះក្តៅ គឺសេចក្តីក្តៅគគុក* .. ១១៣

**៩.អនុបុព្វាភិសមយកថា** ,, *ការត្រាស់ដឹងដោយលំដាប់* .. ១១៤

**១០.វោហារកថា** ,, *វោហារ* ..... ..... ..... .... ១១៩

**១១.និរោធកថា** ,, *និរោធ* ..... ..... ..... ..... ១១៩

## បរមត្ថទីបនី

មាតិកាធម៌ ទំព័រ

### វគ្គទី ៣


| | | |
|---|---|---|
| ១.ពលកថា | ,, ពលៈ គឺកម្លាំង ..... ..... ... | ១២២ |
| ២.អរិយន្តិកថា | ,, អរិយៈ ..... ..... ..... ..... | ១២៧ |
| ៣.វិមុត្តិកថា (ឬវិមុច្ចតិកថា) | ,, វិមុត្តិ ..... ..... ..... ..... .. | ១៣០ |
| ៤.វិមុច្ចមានកថា | ,, ចិត្តរួចផុត ..... ..... ..... .. | ១៣២ |
| ៥.អដ្ឋមកកថា | សម្តែងអំពីបុគ្គលទី ៨ ..... ..... ..... | ១៣៦ |
| ៦.អដ្ឋមកឥន្ទ្រិយកថា | ,, ឥន្ទ្រិយរបស់បុគ្គលទី ៨ .... | ១៣៨ |
| ៧.ទិព្វចក្ខុកថា | ,, អំពីទិព្វចក្ខុ ..... ..... ........ | ១៣៩ |
| ៨.ទិព្វសោតកថា | ,, ទិព្វសោត ..... ..... ..... .. | ១៤២ |
| ៩.យថាកម្មូបគតញ្ញាណកថា | ,, យថាកម្មូបគតញ្ញាណ ..... | ១៤៣ |
| ១០.សំវរកថា | ,, ការសង្រួម ..... ..... ..... | ១៤៧ |
| ១១.អសញ្ញកថា | ,, អសញ្ញា គឺមិនមានសញ្ញា .. | ១៤៩ |
| ១២.នេវសញ្ញានាសញ្ញាយតនកថា | ,, នេវសញ្ញានាសញ្ញាយតនៈ .. | ១៥០ |


### វគ្គទី ៤


| | | |
|---|---|---|
| ១.គិហិអរហាតិកថា | ,, គ្រហស្ថបានជាព្រះអរហន្ត .. | ១៥១ |

# អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


**២.ឧប្បត្តិកថា** ,, ការកើតឡើង ..... ..... .... **១៥២**

**៣.អនាសវកថា** ,, អនាសវៈ ..... ..... ..... ... **១៥៥**

**៤.សមន្នាគតកថា** ,, អ្នកប្រកប ..... ..... ..... ... **១៥៦**

**៥.ឧបេក្ខាសមន្នាគតកថា** ,, អ្នកប្រកបដោយឧបេក្ខា ..... **១៥៩**

**៦.ពោធិយាពុទ្ធោតិកថា** ,, ពាក្យថា ពុទ្ធៈ ព្រោះពោធិ .. **១៦០**

**៧.លក្ខណកថា** ,, លក្ខណៈ ..... ..... ..... .... **១៦៤**

**៨.និយាមោក្កន្តិកថា** សម្តែងអំពីការស្កុងឈានចុះកាន់និយាម ..... **១៦៦**

**៩.អបរាបិសមន្នាគតកថា** ,, អ្នកប្រកបដោយរឿងផ្សេងមួយទៀត **១៦៨**

**១០.សព្វសញ្ញោជនប្បហានកថា** ,, ការលះសញ្ញោជនៈទាំងពួង ...... **១៦៩**


## វគ្គទី ៥


**១.វិមុត្តកថា** ,, វិមុត្តិ ..... ..... ..... ..... ....... **១៧០**

**២.អសេក្ខញ្ញាណកថា** ,, ញាណរបស់ព្រះអសេក្ខៈ ..... ... **១៧២**

**៣.វិបរិតកថា** ,, ញាណវិបរិត ..... ..... ..... .... **១៧៣**

**៤.និយាមកថា** ,, និយាម ..... ..... ..... ..... .... **១៧៥**

**៥.បដិសម្ភិទាកថា** ,, បដិសម្ភិទា ..... ..... ..... ....... **១៧៨**

**៦.សម្មតិញ្ញាណកថា** ,, សម្មតិញ្ញាណ ..... ..... ..... ..... **១៨០**

# បរមត្ថទីបនី


**មាតិកាធម៌** **ទំព័រ**

**៧.ចិត្តារម្មណកថា** ,, *ញាណមានចិត្តជាអារម្មណ៍* ....... **១៨១**

**៨.អនាគតញ្ញាណកថា** ,, *ញាណដឹងក្នុងអនាគត* ..... ...... .. **១៨៣**

**៩.បច្ចុប្បន្នញ្ញាណកថា** ,, *ញាណដឹងក្នុងបច្ចុប្បន្ន* ..... ....... **១៨៦**

**១០.ផលញ្ញាណកថា** ,, *ផលញ្ញាណ* ..... ..... ..... ....... **១៨៨**


## វគ្គទី ៦


១.និយាមកថា *សម្តែងអំពីនិយាម*..... ..... ..... ..... ..... ..... ...**១៩១**

២.បដិច្ចសមុប្បាទកថា *សម្តែងអំពីបដិច្ចសមុប្បាទ* ..... ..... ....... **១៩២**

៣.សច្ចកថា *សម្តែងអំពីសច្ចៈ* ..... ..... ..... ..... ..... ..... ..... **១៩៥**

៤.អារុប្បកថា *សម្តែងអំពីភពមិនមានរូប* ..... ..... ..... ..... ..... **១៩៦**

៥.និរោធសមាបត្តិកថា *សម្តែងអំពីនិរោធសមាបត្តិ* ..... ..... ..... **១៩៧**

៦.អាកាសកថា *សម្តែងអំពីអាកាស* ..... ..... ..... ..... ..... ..... **១៩៩**

៧.អាកាសោ សនិទស្សនោតិកថា *សម្តែងអំពីអាកាសជាលំហមើលឃើញបាន* .... ..... ..... ..... ..... ..... ..... ..... ..... . **២០០**

៨.បឋវីធាតុសនិទស្សនាតយាទិកថា *សម្តែងអំពីបឋវីធាតុជាដើមជាសនិទស្សនៈ* .... ..... ..... ..... ..... ..... ..... ..... ..... **២០១**

# អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**

## វគ្គទី ៧


១.សង្គហិតកថា *សម្ដែងអំពីធម៌ដែលសង្គ្រោះគ្នាបាន* ..... ..... .. ២០៣

២.សម្បយុត្តកថា *សម្ដែងអំពីសម្បយុត្តធម៌* ..... ..... ..... ...... ២០៤

៣.ចេតសិកកថា *សម្ដែងអំពីចេតសិកធម៌* ..... ..... ..... ..... ... ២០៥

៤.ទានកថា *សម្ដែងអំពីទាន* ..... ..... ..... ..... ..... ..... .... ២០៧

៥.បរិភោគមយបុញ្ញកថា *សម្ដែងអំពីបុណ្យសម្រេចពីការបរិភោគ* .. ២១១

៦.ឥតោទិន្នកថា *សម្ដែងអំពីទានដែលបុគ្គលឲ្យហើយអំពីលោកនេះ* ... ២១៦

៧.បឋវីកម្មវិបាកោតិកថា *សម្ដែងអំពីផែនដីជាកម្មវិបាក* ..... ..... ២១៧

៨.ជរាមរណវិបាកោតិកថា *សម្ដែងអំពីជរា និងមរណៈជាវិបាក* ... ២២១

៩.អរិយធម្មវិបាកកថា *សម្ដែងអំពីវិបាកនៃអរិយធម៌* ..... ..... ... ២២៣

១០.វិបាកោវិបាកធម្មធម្មោតិកថា *សម្ដែងអំពីវិបាកជាវិបាកធម្មធម៌* ... ២២៦


## វគ្គទី ៨


១.ឆគតិកថា *សម្ដែងអំពីគតិ ៦* ..... ..... ..... ..... ..... ..... ២២៩

២.អន្តរាភវកថា *សម្ដែងអំពីអន្តរាភព* ..... ..... ..... ..... ..... ២៣១

៣.កាមគុណកថា *សម្ដែងអំពីកាមគុណ* ..... ..... ..... ..... ..... ២៣៥

៤.កាមកថា *សម្ដែងអំពីកាម* ..... ..... ..... ..... ..... ..... ... ២៣៩

## បរមត្ថទីបនី

**មាតិកាធម៌** | **ទំព័រ**

**៥.រូបធាតុកថា** *សម្តែងអំពីរូបធាតុ* ..... ..... ..... ..... ..... .... **២៣៩**

**៦.អរូបធាតុកថា** *សម្តែងអំពីអរូបធាតុ* ..... ..... ..... ..... ...... **២៤០**

**៧.រូបធាតុយា អាយតនកថា** *សម្តែងអំពីអាយតនៈក្នុងរូបធាតុ* .... **២៤១**

**៨.អរូបេរូបកថា** *សម្តែងអំពីរូបក្នុងអរូបសត្វ* ..... ..... ..... .... **២៤៣**

**៩.រូបំ កម្មន្តិកថា** *សម្តែងអំពីពាក្យថា រូបជាកម្ម* ..... ..... ..... **២៤៤**

**១០.ជីវិតិន្ទ្រិយកថា** *សម្តែងអំពីជីវិតិន្ទ្រិយ* ..... ..... ..... ..... **២៤៦**

**១១.កម្មហេតុកថា** *សម្តែងអំពីហេតុនៃកម្ម* ..... ..... ..... ..... . **២៥០**

## វគ្គទី ៩

**១.អានិសង្សកថា** *សម្តែងអំពីអានិសង្ស* ..... ..... ..... ..... **២៥១**

**២.អមតារម្មណកថា** *សម្តែងអំពីសំយោជនៈ មានអមតៈជាអារម្មណ៍* .... **២៥៥**

**៣.រូបំ សារម្មណន្តិកថា** *សម្តែងអំពីរូបជាធម៌មានអារម្មណ៍* ..... ... **២៥៦**

**៤.អនុសយា អនារម្មណាតិកថា** *សម្តែងអំពីអនុស័យ ជាធម៌មិនមានអារម្មណ៍* . ..... ..... ..... ..... ..... ..... ..... ... **២៥៧**

**៥.ញាណំ អនារម្មណន្តិកថា** *សម្តែងអំពីញាណមិនមានអារម្មណ៍* ... **២៦៤**

**៦.អតីតានាគតារម្មណកថា** *សម្តែងអំពីចិត្តដែលមានអតីត និងអនាគត ជាអារម្មណ៍* . ..... ..... ..... ..... ..... ..... ..... ..... **២៦៥**

## អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


**៧.វិតក្កានុប្បត្តិកថា** *សម្តែងអំពីចិត្តប្រកបជាមួយនឹងវិតក្កៈ* ..... ... **២៦៦**

**៨.វិតក្កវិប្ផារសទ្ទកថា** *សម្តែងអំពីការផ្សាយទៅនៃវិតក្កៈជាសំឡេង* .... **២៦៧**

**៩.នយថាចិត្តស្សវាចាតិកថា** *សម្តែងអំពីអ្នកមិនមានការគិតយ៉ាងណា ក៏មានវាចាបាន* ..... ..... ..... ..... ..... ..... ...... **២៦៨**

**១០.នយថាចិត្តស្សកាយកម្មន្តិកថា** *សម្តែងអំពីអ្នកមិនមានការគិតយ៉ាងណា ក៏មានកាយកម្មបាន* ..... ..... ..... ..... ..... ..... ... **២៧០**

**១១.អតីតានាគតេហិ សមន្នាគតកថា** *សម្តែងអំពីបុគ្គលអ្នកប្រកបដោយអតីត និងអនាគត* ..... ..... ..... ..... ..... ..... ..... ..... .... **២៧១**


### វគ្គទី ១០


**១.និរោធកថា** *សម្តែងអំពីការរលត់* ..... ..... ..... ..... ..... .. **២៧៣**

**២.រូបំមគ្គោតិកថា** *សម្តែងអំពីរូបជាមគ្គ* ..... ..... ..... ..... .... **២៧៥**

**៣.បញ្ចវិញ្ញាណសមង្គិមគ្គភាវនាកថា** *សម្តែងអំពីអ្នកព្រមព្រៀងដោយបញ្ចវិញ្ញាណចម្រើនមគ្គ* .... ..... ..... ..... ..... ..... ... **២៧៥**

**៤.បញ្ចវិញ្ញាណាកុសលាបីតិកថា** *សម្តែងអំពីបញ្ចវិញ្ញាណជាកុសលក៏មាន ជាអកុសលក៏មាន* ..... ..... ..... ..... ..... ..... ..... .. **២៨០**

**៥.បញ្ចវិញ្ញាណាសាភោគាតិកថា** *សម្តែងអំពីបញ្ចវិញ្ញាណ*

## បរមត្ថទីបនី

**មាតិកាធម៌** **ទំព័រ**

*មានការសង្ខេប* ..... ..... ..... ..... ..... ..... ..... ..... ..... .. ២៨១

**៦.ទ្វិសីលសមន្នាគតោតិកថា** *សម្ដែងអំពីអ្នកប្រកបដោយសីល ២ យ៉ាង* ..... ..... ..... ..... ..... ..... ..... ..... ..... ..... **២៨២**

**៧.សីលំអចេតសិកន្តិកថា** *សម្ដែងអំពីសីលមិនមែនជាចេតសិក* ...... **២៨៣**

**៨.សីលំ ន ចិត្តានុបរិវត្តីតិកថា** *សម្ដែងអំពីសីលមិនប្រព្រឹត្តទៅតាមចិត្ត* .. ..... ..... ..... ..... ..... ..... ..... ..... ..... ..... **២៨៤**

**៩.សមាទានហេតុកថា** *សម្ដែងអំពីសីលមានការសមាទានជាហេតុ* ..... **២៨៤**

**១០.វិញ្ញត្តិ សីលន្តិកថា** *សម្ដែងអំពីវិញ្ញត្តិជាសីល* ..... ..... ..... .. **២៨៥**

**១១.អវិញ្ញត្តិ ទុស្សីល្យន្តិកថា** *សម្ដែងអំពីអវិញ្ញត្តិជាការទ្រុស្តសីល* ... **២៨៦**

### វគ្គទី ១១

**១-៣.តិស្សោបិ អនុសយាកថា** *សម្ដែងអំពីអនុស័យជាធម៌ទាំងបី* ... **២៨៨**

**៤.ញាណកថា** *សម្ដែងអំពីញាណ* ..... ..... ..... ..... ..... ..... **២៨៩**

**៥.ញាណំ ចិត្តវិប្បយុត្តន្តិកថា** *សម្ដែងអំពីញាណជាចិត្តវិប្បយុត្ត* .... **២៩០**

**៦.ឥទំ ទុក្ខន្តិកថា** *សម្ដែងអំពីការបញ្ចេញវាចាថា នេះទុក្ខ* ..... .... **២៩២**

**៧.ឥទ្ធិពលកថា** *សម្ដែងអំពីកម្លាំងនៃឫទ្ធិ* ..... ..... ..... ..... ..... **២៩៣**

**៨.សមាធិកថា** *សម្ដែងអំពីសមាធិ* ..... ..... ..... ..... ..... ..... **២៩៦**

# អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


**៩.ធម្មដ្ឋិតតាកថា** *សម្ដែងអំពីការតាំងនៅនៃធម៌* ..... ..... ..... ... **២៩៨**

**១០.អនិច្ចតាកថា** *សម្ដែងអំពីការមិនទៀង* ..... ..... ..... ..... ... **២៩៩**


## វគ្គទី ១២


**១.សំវរោ កម្មន្តិកថា** *សម្ដែងអំពីការសង្រួមជាកម្ម* ..... ..... ..... **៣០១**

**២.កម្មកថា** *សម្ដែងអំពីកម្ម* ..... ..... ..... ..... ..... ..... ..... **៣០២**

**៣.សទ្ទោវិបាកោតិកថា** *សម្ដែងអំពីសំឡេងជាវិបាក* ..... ..... .... **៣០៤**

**៤.សឡាយតនកថា** *សម្ដែងអំពីសឡាយតនៈ* ..... ..... ..... .... **៣០៥**

**៥.សត្តក្ខត្តុំបរមកថា** *សម្ដែងអំពីបុគ្គលជាសត្តក្ខត្តុំបរមៈ* ..... ..... **៣០៦**

**៦_៧.កោលំកោលឯកពីជីកថា** *សម្ដែងអំពីកោលំ កោលៈ និងឯកពីជី* **៣០៩**

**៨.ជីវិតាវោរោបនកថា** *សម្ដែងអំពីការក្លែងផ្ដាច់ជីវិត* ..... ..... ... **៣០៩**

**៩.ទុគ្គតិកថា** *សម្ដែងអំពីទុគ្គតិ* ..... ..... ..... ..... ..... ..... ... **៣១០**

**១០.សត្តមភវិកកថា** *សម្ដែងអំពីព្រះសោតាបន្នមានភពទីប្រាំពីរ* ... **៣១២**


## វគ្គទី ១៣


**១.កប្បដ្ឋកថា** *សម្ដែងអំពីអ្នកតាំងនៅរហូតកប្ប* ..... ..... ..... ... **៣១២**

**២.កុសលចិត្តបដិលាភកថា** *សម្ដែងអំពីការត្រឡប់បានកុសលចិត្ត* .... **៣១៤**

**បរមត្ថទីបនី**

**មាតិកាធម៌** **ទំព័រ**


**៣.អនន្តរាបយុត្តកថា** *សម្ដែងអំពីបុគ្គលអ្នកប្រើឲ្យធ្វើអនន្តរិយកម្ម* ..... **៣១៥**

**៤.និយតស្ស និយាមកថា** *សម្ដែងអំពីនិយាមរបស់អ្នកទៀងហើយ* ..... **៣១៩**

**៥.នីវុតកថា** *សម្ដែងអំពីអ្នកមានចិត្តដែលនីវរណៈគ្របសង្កត់ហើយ* ..... **៣២០**

**៦.សម្មុខីភូតកថា** *សម្ដែងអំពីអ្នកមានចិត្តសម្បូរដោយសញ្ញោជនៈ* ..... **៣២២**

**៧.សមាបន្នោ អស្សាទេតិកថា** *សម្ដែងអំពីអ្នកចូលសមាបត្តិ*

*រមែងត្រេកអរ* ..... ..... ..... ..... ..... ..... ..... ..... ..... . **៣២២**

**៨.អសាតរាគកថា** *សម្ដែងអំពីការត្រេកអរក្នុងវត្ថុដែលមិនពេញចិត្ត* **៣២៣**

**៩.ធម្មតណ្ហា អព្យាកតាតិកថា** *សម្ដែងអំពីធម្មតណ្ហាជាអព្យាក្រឹត* ..... **៣២៥**

**១០. ,, នទុក្ខសមុទយោតិកថា** *សម្ដែងអំពីធម្មតណ្ហា មិនមែនជា*

*ទុក្ខសមុទ័យទេ* ..... ..... ..... ..... ..... ..... ..... ..... ..... .. **៣២៧**


## **វគ្គទី ១៤**


**១.កុសលាកុសលបដិសន្ទហនកថា** *សម្ដែងអំពីការបន្តរបស់កុសល*

*និងអកុសល* .... ..... ..... ..... ..... ..... ..... ..... ...... .... **៣២៨**

**២.សឡាយតនុប្បត្តិកថា** *សម្ដែងអំពីការកើតឡើងនៃសឡាយតនៈ* ..... **៣២៩**

**៣.អនន្តរប្បច្ចយកថា** *សម្ដែងអំពីអនន្តរប្បច្ច័យ* ..... ..... ..... .... **៣៣១**

# អដ្ឋកថាព្រះអភិធម្មបិដក

**មាតិកាធម៌** **ទំព័រ**


**៤.អរិយរូបកថា** *សម្ដែងអំពីអរិយរូប* ..... ..... ..... ..... ..... .. **៣៣៣**

**៥.អញ្ញោ អនុសយោតិកថា** *សម្ដែងអំពីអនុស័យមានមុ្យ៉ាង* ..... ... **៣៣៤**

**៦.បរិយុដ្ឋានចិត្តវិប្បយុត្តន្តិកថា** *សម្ដែងអំពីបរិយុដ្ឋានក្កិលេស មិនប្រកបនឹងចិត្ត* ..... ..... ..... ..... ..... ..... ..... ..... ..... **៣៣៥**

**៧.បរិយាបន្នកថា** *សម្ដែងអំពីធម៌ដែលរាប់បញ្ចូលគ្នា* ..... ..... .... **៣៣៦**

**៨.អព្យាកតកថា** *សម្ដែងអំពីអព្យាក្រឹត* ..... ..... ..... ..... ..... **៣៣៨**

**៩.អបរិយាបន្នកថា** *សម្ដែងអំពីលោកុត្តរធម៌* ..... ..... ..... ..... **៣៣៩**


## វគ្គទី ១៥


**១.បច្ចយតាកថា** *សម្ដែងអំពីភាវៈជាបច្ច័យ* ..... ..... ..... ..... ... **៣៤០**

**២.អញ្ញមញ្ញបច្ចយកថា** *សម្ដែងអំពីអញ្ញមញ្ញប្បច្ច័យ* ..... ..... ..... **៣៤១**

**៣.អទ្ធាកថា** *សម្ដែងអំពីរយៈកាល* ..... ..... ..... ..... ..... ..... **៣៤២**

**៤.ខណលយមុហុត្តកថា** *សម្ដែងអំពីខណៈ លយៈ និងមុហុត្តៈ* ...... **៣៤៣**

**៥.អាសវកថា** *សម្ដែងអំពីអាសវៈ* ..... ..... ..... ..... ..... ..... **៣៤៣**

**៦.ជរាមរណកថា** *សម្ដែងអំពីជរា និងមរណៈ* ..... ..... ..... ..... **៣៤៤**

**៧.សញ្ញាវេទយិតកថា** *សម្ដែងអំពីសញ្ញាវេទយិតនិរោធ-សមាបត្តិទីមួយ* ..... ..... ..... ..... ..... ..... ..... ..... ..... **៣៤៥**

## បរមត្ថទីបនី

**មាតិកាធម៌** **ទំព័រ**

**៨.ទុតិយសញ្ញាវេទយិតកថា** *សម្ដែងអំពីសញ្ញាវេទយិតនិរោធទីពីរ* ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... .. **៣៤៦**

**៩.តតិយសញ្ញាវេទយិតកថា** *សម្ដែងអំពីសញ្ញាវេទយិតនិរោធទីបី* ...... **៣៤៦**

**១០.អសញ្ញសត្តូបិកាកថា** *សម្ដែងអំពីសមាបត្តិដែលឲ្យចូលដល់ភពអសញ្ញសត្វ* ..... ..... ..... ..... ..... ..... ..... ..... ... **៣៤៩**

**១១.កម្មូបចយកថា** *សម្ដែងអំពីការសន្សំកម្ម* ..... ..... ..... ....... **៣៥០**

# អក្សរសង្ខេប

## ដែលប្រើក្នុងអដ្ឋកថាតតិយភាគ ១០ នេះ

អភិ. = អភិធម្មបិដក

អំ. ចតុក្ក. = អង្គុត្តរនិកាយ ចតុក្កនិបាត

អំ. ឆក្ក. = អង្គុត្តរនិកាយ ឆក្កកនិបាត

អំ. ទសក. = អង្គុត្តរនិកាយ ទសកនិបាត

អំ. អដ្ឋក. = អង្គុត្តរនិកាយ អដ្ឋកនិបាត

អ. អ. ៥ = អដ្ឋកថាព្រះអភិធម្មបិដក ទុតិយភាគ ៥

ខុ. បេត. = ខុទ្ទកនិកាយ បេតវត្ថុ

ទី. សី. = ទីឃនិកាយ សីលក្ខន្ធវគ្គ

ទី. បា. = ទីឃនិកាយ បាដិកវគ្គ

ម. មូ. = មជ្ឈិមនិកាយ មូលបណ្ណាសកៈ

ម. ឧ. = មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ

វិនយ. = វិនយបិដក

សំ. ម. = សំយុត្តនិកាយ មហាវគ្គ

សំ. ស. = សំយុត្តនិកាយ សឡាយតនវគ្គ

សំ. និ. = សំយុត្តនិកាយ

សំ. សឡា. = សំយុត្តនិកាយ សឡាយតនវគ្គ ។

# បរមត្ថទីបនី

## អដ្ឋកថាព្រះអភិធម្មបិដក

### ឈ្មោះ បញ្ចបករណ៍

### តតិយភាគ ១០

### ព. ស. ២៥៥៧

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ បញ្ចបករណ៍

## តតិយភាគ

## កថាវត្ថុបករណ៍ (ត)

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

### ពណ៌នាអំពីបដិកម្មចតុក្កៈពួក ៤ នៃការធ្វើតប

*ឥឡូវនេះ ជាពាក្យសួររបស់សកវាទីក្នុងន័យរបស់អនុលោម ដើម្បីសម្ដែងដល់ការឈ្នះក្នុងវាទៈរបស់ខ្លួនដោយធម៌ ស្មើដោយការយល់ព្រមបញ្ហានោះដូច្នេះឯង ។ ពាក្យឆ្លើយយល់ព្រមរបស់បរវាទីអាស្រ័យលទ្ធិរបស់ខ្លួន ។ ការសោកសួរមិនឲ្យឱកាសដល់លទ្ធិរបស់បរវាទី ដោយអំណាចនៃបរមត្ថទៀត ជារបស់សកវាទី ។ ការបដិសេធជារបស់បរវាទី ព្រោះសភាពនៃបុគ្គលមិនមានដោយបរមត្ថ ។ ផ្ដើមតែប៉ុណ្ណោះ ពាក្យរបស់សកវាទីទាំងពួង មានពាក្យថា* ***"ចូរលោកដឹងបដិកម្មជាដើមនោះចុះ"*** *ដូច្នេះ គប្បីជ្រាបសេចក្ដីនៃបដិកម្មនិគ្គហៈ ឧបនយនៈ និងនិគ្គមចតុក្កៈទាំងពួង ដោយន័យដែលខ្ញុំពោលហើយ ក្នុងកាលខាងក្រោយនុ៎ះឯង ។ ត្រង់សេចក្ដីនេះឈ្មោះថា បច្ចនិកានុលោមបញ្ចកៈ គប្បីជ្រាបថា លោកបញ្ជាក់ហើយ*

*ដោយអំណាចនៃបដិកម្ម និគ្គហៈ ឧបនយនៈ និងនិគ្គមចតុក្កៈ ដែលមានពាក្យថា **"រមែងដឹងបាន"** ជាដើម នៃបច្ចនិកបញ្ចកៈ ពាក្យថា រមែងដឹងបុគ្គលមិនបានជាដើម ដោយប្រការដូច្នេះ ។ បញ្ចកៈ គឺពួក ៥ ទាំងពីរក្នុងបឋមសច្ចិកត្ថទាំងអស់នេះ លោកអធិប្បាយហើយ ដោយប្រការដូច្នេះ ។ ក្នុងបញ្ចកៈទាំងពីរនោះ បញ្ចកៈដំបូងសកវាទីធ្វើនិគ្គហៈដល់បរវាទី ឈ្មោះថាជានិគ្គហៈល្អ, តែការឈ្នះដែលបរវាទីអាស្រ័យវាទៈ មានលេសន័យធ្វើតបដល់សកវាទីដែលខ្លួនឲ្យសម្រេចហើយ ជាការឈ្នះដោយមិនល្អទេ, ក្នុងបញ្ចកៈទីពីរ បរវាទីធ្វើនិគ្គហៈដល់សកវាទី ជានិគ្គហៈដែលមិនល្អឡើយ ។ តែការឈ្នះដែលសកវាទីអាស្រ័យវាទៈជាធម៌ដែលខ្លួនឲ្យសម្រេច ហើយធ្វើតបដល់បរវាទី ជាការឈ្នះដែលល្អ ៕*

ចប់បដិកម្មចតុក្កៈ

......................

## ៣.កាលសច្ចិកត្ថ

### ពណ៌នាអំពីឧបនយនចតុក្កៈ (បឋមសច្ចិកត្ថ)

*ក្នុងបឋមសច្ចិកត្ថនោះ លោកពោលទុកថា ៖*

***បឋមបញ្ចកៈ សកវាទីធ្វើនិគ្គហៈដែលបរិសុទ្ធដល់បរវាទី, តែការឈ្នះក្នុងការធ្វើតប របស់បរវាទីក្នុងបញ្ហានោះ គឺមិន***

*បរិសុទ្ធ ។ ក្នុងទុតិយបញ្ហកៈ បរវាទីធ្វើនិគ្គហៈដល់សកវាទី ជានិគ្គហៈដែលមិនបរិសុទ្ធ, តែជ័យជម្នះក្នុងការធ្វើតបរបស់សកវាទីក្នុងទីនោះៗ បរិសុទ្ធវិសេសហើយ ។ ព្រោះហេតុដូច្នោះ សូម្បីក្នុងឋានទាំងពីរ ជាការឈ្នះរបស់សកវាទីមែនពិត, ឈ្មោះថា ឈ្នះដោយធម៌, ការឈ្នះដោយធម៌ របស់បរវាទីនឹងមានពីណា ។ ការឈ្នះ និងចាញ់ក្នុងសច្ចិកត្ថ ដែលប្រដាប់ដោយពួកពីរនៃបញ្ហកៈនេះ លោកពោលហើយ ដោយអំណាចនៃធម៌ និងអធម៌ដូច្នោះដែរ, ក្នុងសច្ចិកត្ថទាំងពួងផ្សេងពីនេះ បណ្ឌិតគប្បីញ៉ាំងសេចក្ដីឈ្នះ និងចាញ់ទាំងពីរឱ្យជាក់ច្បាស់ដូច្នោះៗ ហើយ យ៉ាងនេះឯង ៕*

ចប់និគ្គហៈទី ២

## ៤.អនុលោមបច្ចនីកៈ ពណ៌នាអំពីនិគ្គហៈទី ៣

*ពេលញ៉ាំងសច្ចិកត្ថដែលបរិសុទ្ធឱ្យពិស្ដារយ៉ាងនេះរួចហើយ ឥឡូវនេះ ដើម្បីនឹងញ៉ាំងសច្ចិកត្ថដែលបរិសុទ្ធនោះៗ ឱ្យពិស្ដារដោយន័យផ្សេងៗ មានឱកាសន័យជាដើម ទើបលោកផ្ដើមពាក្យថា* **“បុគ្គលោ ឧបលព្ភតិ”** *ជាដើម*

*ទៀត ។ ក្នុងនិគ្គហៈទីបីនេះ ពាក្យសួរជារបស់សកវាទី ។ ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ពាក្យសាកសួរសំដៅយកសរីរៈក្នុង ពាក្យថា **"ក្នុងទីទាំងពួង"** ជារបស់សកវាទីទៀត ។ ពាក្យបដិសេធជារបស់បរវាទី ព្រោះឃើញចំណុចធ្វេសប្រហែស ក្នុងការពិចារណាឃើញខ្លួនក្នុងរូបផង, ចំណុចធ្វេសប្រហែសដែលនឹងជួបប្រទះថា "ជីវៈផ្សេង, សរីរៈ ផ្សេងឬ ?" ដូច្នេះផង ពាក្យដែលនៅសល់ក្នុងទីនេះ គប្បីជ្រាបក្នុងអនុលោមបច្ចនិក-បញ្ចកៈ ដោយន័យដែលលោកពោលទុកក្នុងកាលជាខាងក្រោយនុ៎ះឯង ។ ក៏ក្នុងទីនេះ លោកសង្ខេបព្រះបាលីទុក ។*

***ពាក្យដែលលោកពោលទុកក្នុងនិគ្គហៈទី ៦ នេះថា "លោកមិនដឹងបុគ្គលក្នុងទីទាំងពួង" ដូច្នេះ លោកសំដៅយកសរីរៈ, បុគ្គលនោះ រមែងដឹងបានចំណែកខាងក្រៅអំពីសរីរៈ រមែងមិនត្រូវ ព្រោះហេតុណា, ព្រោះហេតុនោះ ក្នុងបច្ចនិកៈ ទើបសកវាទីបដិសេធ ។ បដិកម្មរបស់បរវាទី រមែងមានដោយអំណាចនៃវាទៈ ដែលមានលេសន័យ គួរលោកយល់ព្រមពាក្យដំបូងហើយ, ពេលក្រោយរមែងបន្ទោសដូច្នេះ ។ ពាក្យដ៏សេស ប្រាកដជាក់ច្បាស់ហើយមែនពិត ៕***

ចប់និគ្គហៈទី ៣

## ពណ៌នាអំពីនិគ្គហៈទី ៤

*ន័យទីពីរ ពាក្យថា **“ក្នុងកាលទាំងពួង”** ជាពាក្យសាកសួររបស់សកវាទីសំដៅដល់កាល គឺជាតិដែលមានមកពីមុន នឹងមានក្នុងពេលក្រោយ និងកាលដែលព្រះពុទ្ធគង់ព្រះជន្មនៅ និងបរិនិព្វានហើយ ។ ការបដិសេធជារបស់បរវាទី ព្រោះឃើញចំណុចខុសប្រហែសនៃពាក្យថា **“ក្សត្រ ក៏ជាមនុស្សដែរ, ព្រាហ្មណ៍ ក៏ជាមនុស្សដែរ”** ជាដើម និងឃើញទោស គឺសេចក្ដីភ្ញាំងភ្ញាត់ ព្រោះមិនមានអ្វីប្លែកគ្នារបស់កាល ដែលព្រះពុទ្ធគង់ព្រះជន្មនៅ ឬបរិនិព្វានហើយ ។ ពាក្យដ៏សេស ដូចនឹងពាក្យដែលខ្ញុំពោលហើយ ក្នុងន័យដំបូងនោះឯង ៕*

ចប់និគ្គហៈទី ៤

......................

## ពណ៌នាអំពីនិគ្គហៈទី ៥

*ន័យទី ៣ ពាក្យថា **“ក្នុងសភាវធម៌ទាំងពួង”** ជាពាក្យសាកសួររបស់សកវាទី សំដៅដល់ខន្ធ និងអាយតនៈទាំងឡាយជាដើម ។ ពាក្យបដិសេធ ជារបស់បរវាទី ព្រោះខ្លាចតែសេចក្ដីភ្ញាំងភ្ញាត់ក្នុងពាក្យថា **“អត្តាក្នុងរូប, អត្តាក្នុងចក្ខុ”** ជាដើម ។ ពាក្យដ៏សេសដូច្នោះនោះឯង មានប្រការដូច្នេះ ៕*

ចប់និគ្គហៈទី ៥

## ពណ៌នាអំពីនិគ្គហៈទី ៦, ទី ៧ ទី ៨

*ដើមសេចក្ដីដែលជាប្រធានទាំងបី (គឺនិគ្គហៈទី ៣, ទី ៤ និងទី ៥) នេះ លោកបែងចែកទុកក្នុងអនុលោមបច្ចនិកបញ្ចកៈតាមលំដាប់ ដោយអំណាចនៃអនុលោមល្មមប្រមាណមុននុ៎ះឯង ដើម្បីនឹងចែកបច្ចនិកានុលោម-បញ្ចកៈ ដោយអំណាចនៃបច្ចនិកៈដែលល្មមប្រមាណទៀត ទើបផ្ដើមពាក្យថា* **“បុគ្គលោ នូបលព្ភតិ”** *ជាដើម ។ ក្នុងពាក្យទាំងអស់នោះ បណ្ឌិតគប្បីជ្រាបអត្ថន័យដោយន័យដែលខ្ញុំពោលទុកក្នុងអនុលោម តាមដែលសង្ខេបទុកក្នុងព្រះបាលីនៃបច្ចនិកៈនុ៎ះដែរ ។ បណ្ឌិតគប្បីជ្រាបការប្រកបវាទៈនេះឈ្មោះថា អដ្ឋមុខតាមដែលលោកបញ្ឈាក់ទុកហើយ ដោយអំណាចនៃបច្ចនិកៈ ២ យ៉ាង គឺសច្ចិកត្ថទាំង ៤ គឺសុទ្ធិកសច្ចិកត្ថ ១* * *និងសច្ចិកត្ថទាំងបី* * *នេះផង នៃអនុលោមបច្ចនិក និងបច្ចនិកានុលោម ក្នុងសច្ចិកត្ថបែបមួយផង ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។ ការប្រកបវាទៈ ឈ្មោះថា អដ្ឋមុខឯណា ដែលលោកចារឹកក្នុងព្រះបាលីថា “និគ្គហៈ ៨ ក្នុងផ្នែកមួយៗ*

---

* ពាក្យថា **សុទ្ធិកសច្ចិកត្ថ** បានដល់ សច្ចិកត្ថសុទ្ធ គឺមិនលាយដោយយ៉ាងដទៃ ។

* ពាក្យថា **សច្ចិកត្ថ** ទាំងបី បានដល់ សច្ចិកត្ថដែលលោកពោលដល់ក្នុងទីទាំងពួង ក្នុងកាលទាំងពួង និងក្នុងធម៌ទាំងពួង ។

*រមែងមានដោយអំណាចនៃនិគ្គហៈម្យ៉ាងៗ ” ដូច្នេះ លោកពោលពាក្យនោះទុកក្នុងទីនេះថា ៖*

*ការប្រកបវាទៈដែលព្រះមានព្រះភាគប្រកាសហើយនេះ ឈ្មោះថា អដ្ឋមុខ ដោយប្រភេទនៃបញ្ចកៈទាំងពីរក្នុងបញ្ហា ៤ យ៉ាង មានប្រការដូច្នេះ ។ បណ្ដានិគ្គហៈទាំង ៨ ក្នុងទីនោះឯង និគ្គហៈដែលប្រកបដោយធម៌ ៤ មិនប្រកបដោយធម៌ ៤ សេចក្ដីឈ្នះចាញ់នៃសកវាទី និងបរវាទីមាននៅក្នុងទីទាំងពួង ៕*

**ចប់និគ្គហៈទី ៦, ទី ៧ និង ទី ៨ ត្រឹមនេះ**

.................................

## ៥.សុទ្ធិកសំសន្ទនា ការប្រៀបផ្ទឹមសុទ្ធិកៈ

*ឥឡូវនេះ ជាការប្រៀបផ្ទឹមសច្ចិកត្ថជាមួយរូបជាដើម ៖*

*ក្នុងពាក្យទាំងអស់នោះ ពាក្យថា “ **រូប** ” ជាពាក្យសួររបស់សកវាទី ដោយសំដៅយកពាក្យថា “ **លោកដឹងរូបបានដោយបរមត្ថ យ៉ាងណា**, ឯបុគ្គល លោកក៏ដឹងបានតាមលទ្ធិរបស់លោកយ៉ាងនោះឬ ? ” ដូច្នេះ ។ ពាក្យទទួលកាន់យកត្រឹមពាក្យថា “**បុគ្គលមាន**” ដូច្នេះ ជារបស់បរវាទី ។ ការសាកសួររបស់សកវាទីថា បើបុគ្គលមានអំពីរូបបរមត្ថ ហាក់ដូចជារូបតាមលទ្ធិរបស់លោកសោត សេចក្ដីជាយ៉ាងដទៃ គឺការកើតរលត់នៃបុគ្គល*

ក៏រមែងប្រាកដហាក់ដូចជាធម៌ទាំងឡាយ មានវេទនាជាដើមដូច្នោះ ការបដិសេធរបស់បរវាទី ព្រោះឃើញខុសចាកព្រះសូត្រដែលជាលទ្ធិ ។ ពាក្យដែលនៅសល់ ប្រាកដច្បាស់ហើយដោយអត្ថនោះមែនពិត ។ ក៏ក្នុងទីនេះពាក្យថា ***"ដោយធម៌"*** លោកសម្ដែងអនុលោមបញ្ចកៈ ៥៧ ប្រភេទ ក្នុងអនុលោមបញ្ចកៈដែលជាមូលក្នុងផ្នែកសកវាទី ដោយអំណាចនៃសច្ចិកត្ថ-បរមត្ថ ៥៧ ប្រភេទ ។ ពួក ៨ នៃបដិកម្ម លោកសង្ខេបទុកហើយលោកសម្ដែងបដិលោមបញ្ចកៈ ៥៧ ប្រភេទ ក្នុងអនុលោមនៃបច្ចនិកៈដែលជាមូលខាងបរវាទីទៀត ។ ពួក ៨ នៃបដិកម្មជាដើម លោកសង្ខេបទុក ។ ពាក្យសាកសួររបស់បរវាទីថា ព្រះមានព្រះភាគត្រាស់ហើយជាដើម ដើម្បីសម្ដែងដល់ភាពនៃបុគ្គលជារបស់មាន ដោយពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយផង ដោយរូបជាសភាវៈដែលដឹងបានដោយអំណាចនៃសច្ចិកត្ថ និងបរមត្ថផង ហើយទើបឲ្យសកវាទីយល់ព្រមនូវសេចក្ដីជាយ៉ាងដទៃម្នាក់ៗ នៃធម៌ទាំងពីរ ។ ពាក្យបដិសេធជារបស់សកវាទី ព្រោះភាវៈនៃបញ្ហាមានអត្ថដូចគ្នា និងមានអត្ថផ្សេងគ្នា នៃសម្មតិសច្ច និងបរមត្ថសច្ចទាំងឡាយដែលគួរវៀរចេញ ។ ពាក្យដែលនៅសល់ក្នុងទីនេះក៏ប្រាកដច្បាស់លាស់ហើយដោយអត្ថទាំងនោះមែនពិត ៕

## ចប់សុទ្ធិកសំសន្ទនា

---

## ៦.ឱបម្មសំសន្ទនា

## ការប្រៀបផ្ទឹមសច្ចិកត្ថដោយសេចក្ដីឧបមា

ឥឡូវនេះ ឈ្មោះថា ជាការប្រៀបផ្ទឹមសច្ចិកត្ថដោយអំណាចនៃការប្រៀបធៀប ជាមួយធម៌ទាំងឡាយមានរូបជាដើមនុ៎ះឯង ។ បណ្ដាពាក្យទាំងនោះ សូម្បីពាក្យសួរទាំងពីរ គឺពាក្យសួររូប និងវេទនាមួយៗ ដោយការឃើញទូទៅម្យ៉ាង, ពាក្យដែលសួរដល់សេចក្ដីឃើញទូទៅរបស់បុគ្គលជាមួយរូបម្យ៉ាង ជារបស់សកវាទី ។ ពាក្យឆ្លើយយល់ព្រមនៃបញ្ហាទាំងពីរ ជារបស់បរវាទី ។ ពាក្យសាកសួរដល់ភាពជាមនុស្សម្នាក់ៗ របស់រូបជាមួយបុគ្គលដូចរូបជាមួយវេទនាដោយការឃើញទូទៅ ដែលបរវាទីមិនឃើញផង ជារបស់សកវាទី ។ ពាក្យបដិសេធជារបស់បរវាទី ។ សូម្បីពាក្យដ៏សេស ក្នុងទីនេះ ជាក់ច្បាស់ហើយដោយអត្ថនុ៎ះឯង ។ ក៏កាលពោលដោយធម៌ ក្នុងសេចក្ដីនេះ សកវាទីដែលលោកសម្ដែងនិគ្គហបញ្ចកៈ គឺពួក ៥ នៃនិគ្គហៈ ទុកដល់ ៩២០ ន័យ ដោយអំណាចនៃការបន្ថិលបែរទៅរកធម៌ មានរូបជាមូលជាដើម ។ ***សួរថា “សម្ដែងអ្វី”*** ឆ្លើយថា សម្ដែងក្នុងខន្ធទាំងឡាយមុន គឺធម៌ដែលមានរូបជាមូលបន្ថិលទៅបាន ៤ ន័យ ក្នុងវេទនាជាមូលជាដើម ក៏ដូចគ្នា រួមជា ២០ ន័យ (៤ × ៥ =

២០) ។ ក្នុងអាយតនៈទាំងឡាយ ចក្ខាយតនមូល បង្វិលទៅបាន ១១ ន័យ ក្នុងអាយតនៈដែលនៅសល់ ក៏ដូច្នេះដែរ រួមត្រូវជា ១៣២ ន័យ (១១ × ១២ = ១៣២) ។ ក្នុងធាតុទាំងឡាយ ចក្ខុធាតុមូលបង្វិលទៅបាន ១៧ ន័យ ក្នុងធាតុដែលនៅសល់ ក៏ដូច្នេះដែរ រួមត្រូវជា ៣០៦ ន័យ (១៧x×១៨ = ៣០៦) ។ ក្នុងឥន្ទ្រិយទាំងឡាយ ចក្ខុន្ទ្រិយមូលបង្វិលទៅបាន ២១ ន័យ ក្នុងឥន្ទ្រិយដែលនៅសល់ ក៏ដូច្នេះដែរ រួមត្រូវជា ៤៦២ ន័យ (២១ × ២២ = ៤៦២) រួមទាំងអស់ត្រូវជានិគ្គហ-បញ្ចកៈ ៩២០ ន័យ ដោយប្រការយ៉ាងនេះ ។ ឯខាងបរវាទី លោកធ្វើឲ្យសកវាទីទទួល ពាក្យដល់ភាពជាមនុស្សម្នាក់ៗ នៃធម៌ទាំងឡាយ មានរូបជាមួយវេទនាជាដើម ដោយអំណាចនៃអនុលោមថា **"រូបំ ឧបលព្ភតិ** = លោកដឹងរូបបាន" ជាដើម ហើយទើបលើកយកសេចក្ដីយល់ឃើញទូទៅឡើងធ្វើការសាកសួរដល់ភាពជាមនុស្សម្នាក់ៗ ដោយធម៌ទាំងឡាយ មានរូបជាដើម ជាមួយបុគ្គល ដោយអំណាចនៃពាក្យដែលមានលេសន័យ ព្រោះអាស្រ័យ ព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ទុកថា ***"បុគ្គលមាន"*** ដូច្នេះទៀត ។ ឯពាក្យនៅសល់ក្នុងទីនេះ ជារបស់ងាយយល់ដោយសេចក្ដីទាំងអស់ ។ ពេលពោលដោយធម៌ លោកសម្ដែងបដិកម្មចតុក្កៈ គឺពួក ៤ នៃបដិកម្មទុក ៩២០ ន័យ ដោយន័យដែលពោលហើយក្នុងផ្នែកសកវាទី ។

*ការប្រៀបផ្ទឹមសច្ចិកត្ថ និងរូបជាដើម ដោយអំណាចនៃការឧបមា មានប្រមាណប៉ុណ្ណោះ ។*

ចប់ឱបម្មសំសន្ទនា

## ៧.ចតុក្កនយសំសន្ទនា *

## ការប្រៀបផ្ទឹមដោយន័យរបស់ចតុក្កៈ

*ឥឡូវនេះ ពាក្យណាដែលបរវាទីដឹងដោយសច្ចិកត្ថបរមត្ថ ក្នុងសច្ចិកត្ថបរមត្ថ ៥៧ យ៉ាង មានរូបជាដើម ដោយអាស្រ័យហើយនូវរូបជាដើម ឬវៀរចាករូបជាដើម ឬថាកំពុងអាស្រ័យរូបជាដើម យ៉ាងណាមួយនោះ គប្បីមាន ព្រោះហេតុនោះ ទើបលោកផ្ដើមការផ្ទៀងផ្ទាត់សច្ចិកត្ថដោយចតុក្កន័យ គឺដោយន័យរបស់ពួក ៤ នេះ ។*

*បណ្ដាពាក្យទាំងនោះ ពាក្យថា **"រូបជាបុគ្គលឬ ?"** ជាពាក្យសាកសួរ*

---

* ពាក្យថា **ចតុក្កនយៈ** បានដល់ ដោយន័យនៃពួក ៤ ដូចជា : ១-រូបជាបុគ្គលឬ ? ២-បុគ្គលក្នុងរូបឬ ? ៣-បុគ្គលក្រៅអំពីរូបឬ ? ៤-រូបក្នុងបុគ្គលឬ ? ។ បញ្ហាដូច្នេះ លោកហៅថា សកាយទិដ្ឋិបញ្ហា ដើម្បីឱ្យឃើញតាមសភាពពិតថា ការប្រកាន់ថា ជាបុគ្គល ជាអត្តា ជាសត្វមានច្រើន, ពេលលោកសាកសួរចាប់យកសេចក្ដីនេះតែមួយៗ ហើយ ក៏នឹងប្រាកដតែម្ដងថា មិនមានបុគ្គលឬអត្តា ដូចដែលប្រកាន់ស្អិតនោះឡើយ គ្រាន់តែជាសភាវធម៌យ៉ាងណាមួយប៉ុណ្ណោះ ។

*របស់សកវាទី ។ ពាក្យបដិសេធថា **"មិនគប្បីពោលយ៉ាងនេះទេ"** ជារបស់បរវាទី ព្រោះខ្លាចនឹងត្រូវពោលចោទថា ជាខច្ចេទទិដ្ឋិ ។ ការលើកនិគ្គហៈឡើងជារបស់សកវាទី សូម្បីលោកពោលថា **"ក៏សេចក្ដីនោះ ត្រឹមត្រូវហើយឬ នោះជារូប ជាវេទនា មិនមែនឬ ?"** ដូច្នេះ លោកបដិសេធទាំងអស់ ។ ឯពាក្យនោះ លោកគប្បីបដិសេធដោយទទួលថា បុគ្គលជាយ៉ាងដទៃ, មិនមែនរូប មិនមែនវេទនាទេ, តែមិនមែនក្រៅអំពីរូប និងវេទនាឡើយ; ក៏បរវាទីនេះ មិនប្រាថ្នាយកសេចក្ដីជាយ៉ាងដទៃរបស់បុគ្គលសូម្បីធម៌តែម្យ៉ាង ក្នុងបណ្ដាធម៌ទាំងឡាយមានរូបជាដើម, ព្រោះហេតុដូច្នោះទើបលោកយល់ព្រមថា **"មែន"** ។ ក៏ពាក្យសាកសួរថា **"រូបជាបុគ្គល ។ល។ អញ្ញាតាវិន្ទ្រិយជាបុគ្គល"** ដូច្នេះនេះ លោកប្រារព្ធសំដៅយកបរមត្ថសច្ចទាំងអស់, ប៉ុន្តែនរណាៗ មិនអាចពោលថា បរមត្ថធម៌ទាំងអស់តែម្យ៉ាង ដោយអំណាចនៃបច្ចត្តលក្ខណៈ គឺលក្ខណៈដែលមានចំពោះខ្លួនហៅថា* **បច្ចត្តលក្ខណៈ** *ព្រោះហេតុដូច្នោះ ពាក្យនេះលោកតាំងទុកហើយត្រឹមតែជាលក្ខណៈនៃការសាកសួរ ដោយអំណាចនៃបែបផែនប៉ុណ្ណោះ ព្រោះហេតុនោះ វិញ្ញូជនទាំងឡាយគួរញ៉ាំងធម៌នេះ ឲ្យជាក់ច្បាស់ ។ ផ្នែកសកវាទី នរណាដើម្បីនឹងពោលកាន់យកលក្ខណៈនេះ ហើយមិនឲ្យឱកាស*

ដល់បរវាទីដោយប្រការណាៗ គប្បីពោលដោយប្រការនោះៗ ។ ពាក្យនេះពិតជាត្រឹមត្រូវច្បាស់លាស់ណាស់ហើយ ព្រោះលក្ខណៈនៃការសាកសួរលោកតាំងទុកហើយដោយអំណាចនៃបែបផែន មានប្រការដូច្នេះ ។ គប្បីជ្រាបការសាកសួរទាំងពួងដោយន័យនេះចុះ ។ ក៏ប៉ុន្តែអត្ថន័យដែលប្លែកគ្នាក្នុងពាក្យទាំងឡាយថា ***"បុគ្គលក្នុងរូបឬ ?"*** ជាដើមនេះ គប្បីជ្រាបថាការពោលថា "មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ វិញ្ញាណក្នុងរូបអាស្រ័យវត្ថុរូប" ដូច្នេះ រមែងគួរ យ៉ាងណា បុគ្គលក្នុងរូប តាមលទ្ធិរបស់លោកយ៉ាងនោះ ឬការពោលថា "ក៏អរូបធម៌ទាំងពួង មានវេទនាជាដើម ឬក៏នាមក្ខន្ធ ៤ ឬថាព្រះនិព្វានទុំះឯង ដោយការញែកសភាវៈជាធម៌វៀរចាករូប" ដូច្នេះ រមែងគួរ យ៉ាងណា, បុគ្គលតាមលទ្ធិរបស់លោកយ៉ាងនោះ ឬការពោលថា "ដូចយ៉ាងរូបក្នុងវេទនា រូបក្នុងវិញ្ញាណ ដោយអំណាចនៃធម៌ ដែលជាទីអាស្រ័យនៃរូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋានរមែងគួរ យ៉ាងណា, បុគ្គលតាមលទ្ធិរបស់លោកយ៉ាងនោះឬ ?" ។ ក៏ក្នុងពាក្យសាកសួរទាំងពួង បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចជាខច្ចេទទិដ្ឋិ និងព្រោះខុសអំពីលទ្ធិ ។ ពាក្យដែលនៅសល់ក្នុងទីនេះ ជាក់ច្បាស់ហើយដោយអត្ថទាំងនោះ ។ ពោលដោយធម៌ គឺដោយរឿងដើមហើយ លោកសម្តែងពួក ៤ គឺអនុលោមបញ្ចកៈទុកដល់ ២២៨ ខ (៥៧ x ៤ =

៧២៨) ព្រោះធ្វើអត្ថមួយៗ ក្នុងសច្ចិកត្ថ ៥៧ ប្រភេទ ឲ្យជាពួក ៨ ដោយអំណាចនៃនិគ្គហៈដែលជាចំណែករបស់សកវាទីអ្នកបំបែក ។ សូម្បីតែខាងបរវាទី ក៏មានប្រមាណប៉ុណ្ណោះនុ៎ះឯង ដោយអំណាចនៃបដិកម្ម ។ ឯក្នុងទីនេះ ពាក្យដែលបរវាទីពោលថា ***"បុគ្គលមាន"*** ដូច្នេះ ពាក្យនោះ សកវាទីយល់ព្រមដោយអំណាចនៃសម្មតិដែលមានមកហើយក្នុងព្រះសូត្រ ។ ក្នុងពាក្យទាំងឡាយថា ***"រូបជាបុគ្គលឬ ?"*** ជាដើម លោកបដិសេធ ព្រោះសេចក្តីនៃបញ្ហាពោលដោយសក្កាយទិដ្ឋិ ជាបញ្ហាដែលមិនគួរឆ្លើយ ។ បដិកម្មរបស់បរវាទី រមែងមានដោយអំណាចនៃពាក្យដែលមានលេសន័យមែនពិត ៕

---

## ៨.លក្ខណយុត្តិកថា * ពោលអំពីការប្រកបលក្ខណៈ

ឥឡូវនេះ ឈ្មោះថា លក្ខណយុត្តិ គឺការប្រកបដោយលក្ខណៈ ៖ ក្នុងបញ្ហានោះ ពាក្យសាកសួរ ៨ ខ របស់សកវាទី មានពាក្យថា ***"បុគ្គលមានបច្ច័យឬ ?"*** ជាដើម ដោយសំដៅយកថា វៀរលែងតែព្រះនិព្វានចេញ សច្ចិកត្ថបរមត្ថដែលនៅសល់ ឈ្មោះថា ***មានបច្ច័យ*** ព្រោះអាស្រ័យ

---

* បាលីបិដកជានិយុត្តិកថា ។

បច្ច័យ, ឈ្មោះថា ***សង្ខតៈ*** ព្រោះបច្ច័យទាំងអស់នោះ ប្រជុំគ្នាតាក់តែងឡើង, ឈ្មោះថា ***មិនទៀង*** ព្រោះកើតហើយ រលត់ទៅមិនមានសល់ នៅក្នុងកាលទាំងអស់, ឈ្មោះថា ***មាននិមិត្ត*** ព្រោះសភាពនៃនិមិត្តប្រកបព្រមហើយថា ហេតុនៃការឧប្បត្តិមាន; ចំណែកព្រះនិព្វានមានលក្ខណៈនៃសច្ចិកត្ថដូច្នេះ គឺព្រះនិព្វាន ឈ្មោះថា ***មិនមានបច្ច័យ***, ឈ្មោះថា ***ជាអសង្ខតៈ***, ឈ្មោះថា ***ទៀង***, ឈ្មោះថា ***មិនមាននិមិត្ត*** ព្រោះមិនមានប្រការដូចពោលហើយ ដោយហេតុដូច្នេះ ប្រសិនបើបុគ្គលជាសច្ចិកត្ថបរមត្ថមែន សូម្បីបុគ្គលនោះ ក៏នឹងគប្បីមានលក្ខណៈដូចពោលមកនេះដែរ ។ ពាក្យបដិសេធជារបស់បរវាទី ។ ក៏ក្នុងពាក្យថា ***"លោកចូរដឹងនិគ្គហៈ"*** ជាដើមនេះ លោកសង្ខេបទុក ។ ចំណែកសកវាទី បណ្ឌិតគប្បីជ្រាបពួក ៥, និគ្គហៈ ៨ ទាំងអស់នេះ ដោយអំណាចត្រឹមតែអនុលោមក្នុងអនុលោមបច្ចនិកៈ ដោយប្រការដូច្នេះដែរ ។ សូម្បីខាងបរវាទី ក៏គប្បីជ្រាបពួក ៥, បដិកម្ម ៨ ដោយអំណាចត្រឹមតែបច្ចនិកៈក្នុងបច្ចនិកានុលោមនុ៎ះឯង ។ ក្នុងបច្ចនិកា-នុលោមនោះ បរវាទីធ្វើសម្មតិសច្ចឲ្យសម្រេចដោយអំណាចនៃព្រះសូត្រ, តែសភាវធម៌ដែលមានបច្ច័យជាដើម នៃសម្មតិសច្ច មិនមានទេ, ព្រោះហេតុដូច្នោះ ទើបសកវាទីបដិសេធតាមសេចក្តីពិត ។ ពាក្យថា ***"លោកចូរដឹង***

***បដិកម្ម"*** *ជាដើម ជាពាក្យដែលបរវាទីពោល ត្រឹមតែលេសន័យ; ពាក្យទាំងពួង លោកសង្កេបទុក សូម្បីក្នុងទីនេះ ក៏ប្រាកដច្បាស់លាស់ហើយ ៕*

ចប់លក្ខណយុត្តិកថា

## ៩.វចនសោធនៈ ការជម្រះពាក្យពេចន៍

*ឥឡូវនេះ ជាការជម្រះពាក្យពេចន៍ ៖*

*ក្នុងបញ្ហានោះ ពាក្យណាដែលពោលថា* ***"បុគ្គលជាសភាវៈដែលដឹងបាន"*** *ដូច្នេះ ដើម្បីជម្រះពាក្យនោះ ទើបសកវាទីសួរថា* ***"បុគ្គលជាសភាវៈដែលដឹងបាន, សភាវៈដែលដឹងបាន ក៏ជាបុគ្គលឬ ?"*** *។*

*ខ្លឹមសារនៃបញ្ហានោះ គប្បីជ្រាបដូចតទៅនេះ ៖*

*ពាក្យថា* ***"បុគ្គលជាសភាវៈដែលដឹងបាន"*** *នេះ មានពីរបទ ទាំងពីរបទនេះ មានអត្ថដូចគ្នា ឬមានអត្ថផ្សេងគ្នា ប្រសិនបើមានអត្ថផ្សេងគ្នាមែន ពាក្យនេះក៏រមែងប្រាកដដូចពាក្យដែលឧបមាថា រូបដទៃ វេទនាដទៃ យ៉ាងណា, បុគ្គលក៏ដទៃ សភាវៈដែលដឹងបាន ក៏ដទៃយ៉ាងនោះដែរ, បើសិនមានអត្ថដូចគ្នាមែន ត្រង់នេះរមែងប្រាកដដូចពាក្យឧបមាថា ចិត្តត្រឹមណា,*

មនោក៏ត្រឹមនោះ យ៉ាងណា; បុគ្គលនុ៎ះឯង ជាសភាវៈដែលដឹងបាន ក៏យ៉ាងនោះដែរ, ដោយហេតុនេះ ខ្ញុំនឹងពោលពាក្យក្រោយនេះថា “ប្រសិនបើបុគ្គលណា តាមលទ្ធិរបស់លោក, បុគ្គលនោះ ជាសភាវៈដែលដឹងបាន កាលបើមានសេចក្ដីដូច្នោះ សភាវៈណាៗ ដែលដឹងបាន សភាវៈនោះៗ ក៏ជាបុគ្គលដែលលោកយល់ព្រមពាក្យនោះឬ ?” បន្ទាប់អំពីនោះ សកវាទី ត្រូវការសួរនូវសេចក្ដីដែលបុគ្គល ជាសភាវៈដឹងបាន មិនត្រូវការសួរនូវសភាវៈនៃធម៌មានរូបជាដើម ដែលដឹងបានថា ជាបុគ្គល ព្រោះហេតុដូច្នេះ ទើបលោកពោលថា “បុគ្គលជាសភាវៈដែលដឹងបាន, សភាវៈដែលដឹងបាន ខ្លះជាបុគ្គល ខ្លះមិនមែនជាបុគ្គលឬ ?” ជាដើម ។ គប្បីជ្រាបសេចក្ដីសម្គាល់នៃបញ្ហានោះថា ក៏សភាវៈដែលដឹងបានឯណា ព្រោះព្រះតម្រាស់របស់ព្រះសាស្ដាថា “បុគ្គលរបស់យើង, បុគ្គលមាន” ដូច្នេះ សភាវៈដែលដឹងបានត្រឹមនោះ មិនមែនជាបុគ្គលទាំងអស់ទេ, ជាបុគ្គលខ្លះ មិនមែនជាបុគ្គលខ្លះឬ ?; ក្នុងបញ្ហានោះ **រេក** អក្សរ មានអត្ថជា **រេភា** អក្សរ, **ហិ** អក្សរ និង **ចិ** អក្សរ គ្រាន់តែជានិបាត ។ ក៏គប្បីជ្រាបនូវខ្លឹមសារក្នុងទីនេះថា “ជាបុគ្គលខ្លះ មិនមែនជាបុគ្គលខ្លះ” ។ ពាក្យថា

*“ បែបខ្លះ ជាបុគ្គល បែបខ្លះ មិនមែនជាបុគ្គល ” នេះ លោកអធិប្បាយទុកថា បុគ្គល គឺធម៌យ៉ាងណាមួយ ក្នុងធម៌ទាំងឡាយ មានរូបជាដើម ជាសភាវៈដែលដឹងបាននោះឯង, តែក្នុងធម៌ទាំងឡាយ មានរូបជាដើម ជាបុគ្គលនោះពិត គឺជាបុគ្គលណាមួយ, ចំណែកក្នុងរូបជាដើម បែបខ្លះ មិនមែនបុគ្គលដូច្នេះ ។ លំដាប់នោះ ទើបសកវាទីពោលថា “បុគ្គលបែបខ្លះ ជាសភាវៈដែលដឹងបាន, បែបខ្លះជាសភាវៈ ដែលដឹងមិនបានឬ ? ” ។ ខ្លឹមសារនៃបញ្ហានោះ ដោយអត្ថមាន ២ បទ គឺបុគ្គលជាមួយនឹងពាក្យថា សភាវៈដែលដឹងបាន បើក្នុងអត្ថជាមួយគ្នាមែន បុគ្គលក៏គឺធម៌ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយថា សភាវធម៌ដែលដឹងបាន បុគ្គលមិនមែនក្រៅអំពីធម៌នោះ ប៉ុន្តែសភាវធម៌នោះ បែបខ្លះ ជាបុគ្គល ទោះបីបែបខ្លះ ក៏មិនមែនបុគ្គល សូម្បីបុគ្គល ក៏រមែងប្រាកដថា បែបខ្លះជាសភាវៈដែលដឹងបាន បែបខ្លះជាសភាវៈដែលដឹងមិនបាន តាមលទ្ធិរបស់លោក, លោកយល់ព្រមពាក្យនោះឬ ? បរវាទីនោះ ពេលជាដើមទាំងអស់ លោកសង្ខេបទុក បណ្ឌិតគប្បីជ្រាបដោយពិស្ដារចុះ ។ សូម្បីក្នុងពាក្យថា* ***“បុគ្គលជាសច្ចិកត្ថ”*** *ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យទាំងពួងនេះ គឺសភាវៈដែលពិតប្រាកដ, សភាវៈដែលដួបប្រទះ, សភាវៈដែលប្រាកដ,*

*សភាវៈដែលមាន, សភាវៈដែលមិនមានទាំងអស់ ជាពាក្យវេវចនៈរបស់ពាក្យថា* ***“សភាវៈដែលដឹងបាន”*** *។ មួយវិញទៀត ពាក្យយល់ព្រមរបស់បរវាទីថា “បុគ្គលជាសភាវៈដែលដឹងបានដោយសច្ចិកត្ថ” នេះ ព្រោះលទ្ធិរបស់គេថា បុគ្គលជាសភាវៈដែលដឹងបានយ៉ាងណានោះឯង, ពាក្យថា* ***បុគ្គល*** *ក៏រមែងប្រាកដថា ជាសច្ចិកត្ថតាមលទ្ធិរបស់គេយ៉ាងនោះដូចគ្នា ។ ក៏លទ្ធិណារបស់បរវាទីថា “បុគ្គលមាន” ដូច្នេះ ពាក្យនេះ ជាវេវចនៈរបស់ពាក្យថា* ***“បុគ្គលជាសភាវៈដែលប្រសព្វ”*** *ព្រោះហេតុដូច្នេះ ទើបលោកជម្រះពាក្យវេវចនៈទាំងពួងនេះ ។*

*ក្នុងបញ្ហាទាំងនោះ ពាក្យណាដែលលោកពោលទុកក្នុងទីបំផុតថា “បុគ្គលជាសភាវៈដែលមាន មិនមែនជាបុគ្គលទាំងអស់” ជាដើម គប្បីជ្រាបពាក្យអធិប្បាយដូចតទៅ ៖*

*ពាក្យណាដែលបរវាទីពោលថា “បុគ្គលជាសភាវៈដែលមាន, តែសភាវៈដែលមាន បែបខ្លះជាបុគ្គល, ខ្លះមិនជាបុគ្គលទេ” ដូច្នេះ, ពាក្យនោះពោលដោយអត្ថហើយ ក៏មានពាក្យត្រឹមតែប៉ុណ្ណេះថា បុគ្គលជាសភាវៈដែលមាន, សភាវៈដែលមាន មិនជាបុគ្គលទាំងអស់; ព្រោះហេតុដូច្នោះ*

*ទើបសកវាទីឲ្យបរវាទីយល់ព្រមពាក្យនោះ ហើយប្រកបពាក្យសួរក្នុងបទថា* ***“លោកកាន់យកលទ្ធិថា ‘បុគ្គលមាន’ ព្រោះអាស្រ័យត្រឹមតែពាក្យថា ‘មានបុគ្គលអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ស្រោចស្រង់ដល់ខ្លួនតែប៉ុណ្ណោះ”*** *នេះ ;* *ក៏ព្រះមានព្រះភាគត្រាស់ទុកថា* ***“បុគ្គលមិនមានដោយន័យជាអាទិ៍ថា ‘ម្នាលមោឃរាជ ចូរអ្នកពិចារណាមើលលោក ដោយសភាពជារបស់សោះសូន្យ, ចូរជាអ្នកមានសតិគ្រប់ពេល ។ ល ។”*** *ដូច្នេះ, ព្រោះហេតុនោះ លទ្ធិរបស់លោកដែលសម្តែងថា* ***“បុគ្គលជាសភាវៈដែលមាន, សភាវៈដែលមានមិនជាបុគ្គលទាំងអស់ យ៉ាងណានោះឯង; ដោយប្រការនោះ បុគ្គលរមែងប្រាកដថា ជាសភាវៈដែលមិនមាន សភាវៈដែលមិនមាន មិនជាបុគ្គលទាំងអស់ យ៉ាងនោះទេ”*** *ដូច្នេះ លោកយល់ព្រមពាក្យនោះឬ ? លំដាប់នោះ បរវាទីពេលខ្លះមិនយល់ព្រមពាក្យនោះ ទើបបដិសេធថា មិនគប្បីពោលយ៉ាងនោះទេ ពាក្យដែលនៅសល់ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបច្បាស់ដល់ពាក្យថា* ***និគ្គហៈ*** *ជាដើម ដោយន័យដែលពោលហើយនុ៎ះឯង ៕*

ចប់វចនសោធនៈ

– – – –

## ១០.បញ្ញត្តានុយោគ ការសាកសួររឿងបញ្ញត្តិ

*ឥឡូវនេះ ឈ្មោះថារឿងការសាកសួរបញ្ញត្តិ ៖*

*ពិតណាស់ បុគ្គលវាទីរមែងបញ្ញត្តបុគ្គលមានរូប ដោយរូបធាតុ ដោយទំនងដូចគ្នា រមែងបញ្ញត្តបុគ្គលមិនមានរូប ដោយអរូបធាតុ; សូម្បីពាក្យសួរទាំងអស់ របស់សកវាទី ក៏ដើម្បីនឹងតាំងចិត្តទម្លាយលទ្ធិបុគ្គលវាទីនោះឯង ។ ពាក្យឆ្លើយយល់ព្រមផង ពាក្យបដិសេធផង ជារបស់បរវាទី ។ លុះពេលសកវាទីសួរថា* ***"បុគ្គល ឈ្មោះថា មានរូប"*** *ជាដើម បរវាទីក៏ឆ្លើយយល់ព្រម ព្រោះតែមានសភាពនៃរូបកាយ និងបញ្ញត្តិដូច្នោះ ។ កាលបើពោលពាក្យថា* ***"មានកាម"*** *ដែលសកវាទីសួរហើយ បរវាទីឆ្លើយបដិសេធ ព្រោះសភាពនៃវីតរាគៈ និងបញ្ញត្តិដូច្នោះ មិនមាន ។ សូម្បីពេលសកវាទីពោលសួរថា* ***"សត្វ ឈ្មោះថា មិនមានរូប"*** *បរវាទីឆ្លើយយល់ព្រម ព្រោះសភាពនៃអរូបក្ខន្ធ និងបញ្ញត្តិដូច្នោះ ជាសភាពមាន ។ ពាក្យថា* ***"សត្វ"*** *ក្នុងន័យទាំងពីរ លោកពោលហើយ ដោយអំណាចនៃពាក្យជាវេវចនៈរបស់បុគ្គល ។*

*ឥឡូវនេះ លោកប្រាថ្នាពាក្យថា* ***"កាយដទៃ បុគ្គលក៏ដទៃដែរ"*** *ក្នុងព្រះបាលីដែលមានមកហើយថា* **"ការយ ភាយានុបស្សី** *= ពិចារណាឃើញ*

*កាយក្នុងកាយ”* ដូច្នេះ ព្រោះហេតុនោះ ដើម្បីនឹងទម្លាយលទ្ធិនោះ ទើបសកវាទីសួរថា ***“បញ្ញត្តិថាកាយ ឬសរីរៈ”*** ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា ***“រួមសម្លឹង (ពិចារណា) ដល់កាយ”*** អធិប្បាយថា ខ្ញុំសួរដល់កាយដែលជា ***យនៈ*** ដែលសត្វប្រកាន់ទុក បង្អោនទៅដល់ភាពតែមួយដែលមិនគប្បីបែក ។ ពាក្យថា **“ឯសេ សេ”** បានដល់ **ឯសោ សោយេវ** = បញ្ញត្តិទាំងពីរនេះ ក៏ដូចគ្នាដែរ, ព្រះបាលីថា **“ឯសេ ឯសេ** = បញ្ញត្តិសព្វទាំងនោះឯង” ដូច្នេះខ្លះ អធិប្បាយថា បញ្ញត្តិសព្វទាំងនោះៗ ឯង ។ ពាក្យថា ***មានអត្ថដូចគ្នា*** បានដល់ អត្ថដូចគ្នា ។ ពាក្យថា ***ស្មើគ្នា ប៉ុនគ្នា ដូចគ្នា*** ក្នុងទីនេះ ផ្សេងគ្នាត្រឹមតែពាក្យប៉ុណ្ណោះ ។ ក៏ពោលដោយអត្ថហើយ សកវាទីរមែងសួរថា ***“កាយក៏ដូច្នោះឯង”*** បរវាទីពេលមិនឃើញសេចក្តីប្លែកផ្សេងគ្នា ទើបឆ្លើយយល់ព្រមថា ***“មែន”*** ។ សូម្បីក្នុងពាក្យសួរថា ***“បុគ្គល ឬជីវៈ”*** ក៏មានន័យដូចគ្នានេះដែរ ។ ម្យ៉ាងទៀត ត្រូវសកវាទីសួរថា ***“កាយដទៃ”*** បរវាទីក៏ឆ្លើយតប ព្រោះធ្វើ ***កាយានុបស្សនា*** ឲ្យជាលទ្ធិយ៉ាងនេះ ។ ពេលត្រូវសកវាទីសួរថា ***“ជីវៈដទៃ”*** បរវាទីពេលមិនអាចបដិសេធព្រះសូត្រដែលប្រកាន់ទុកសម្រាប់ពោល ទើបបដិសេធ ។ ពាក្យថា ***“ចូរទទួលដឹងនិគ្គហៈ”*** ជាដើម ខាងមុខពីនេះ មានអត្ថងាយយល់

*ទាំងអស់ ។ ចំណែកខាងបរវាទី លោកសួរថា **"កាយដទៃ បុគ្គលក៏ដទៃឬ ?"** សកវាទីបដិសេធ ព្រោះជាបញ្ហាដែលគួរលើកលែងចោល ។ ទើបបរវាទីធ្វើបដិកម្ម គឺការធ្វើនិគ្គហៈតបដល់សកវាទី ដោយអំណាចនៃលេសន័យ ។ សូម្បីពាក្យនោះ ក៏មានអត្ថងាយស្រួលទាំងអស់ ៕*

ចប់បញ្ញត្តានុយោគ

## ១១.គតិអនុយោគ ការសាកសួររឿងគតិ

*ឥឡូវនេះ ជាការសាកសួរដល់ចុតិ និងបដិសន្ធិ ដោយចំពោះការប្តូរគតិ គឺប្តូរភពថ្មី ៖*

*ក្នុងបញ្ហានោះ បុគ្គលវាទីអាស្រ័យព្រះសូត្រទាំងឡាយថា "បុគ្គលត្រាច់ទៅកាន់គតិអស់ ៧ ជាតិយ៉ាងច្រើន" ជាដើម ហើយចាប់យកលទ្ធិនោះ ពោលថា "បុគ្គលទៅកាន់គតិ" ដូច្នេះ ព្រោះហេតុនោះ ដើម្បីនឹងទម្លាយលទ្ធិរបស់បុគ្គលវាទីនោះ ទើបសកវាទីសួរថា **"បុគ្គលទៅកាន់គតិឬ ?"** បណ្តាពាក្យទាំងនោះ ពាក្យថា **"ទៅកាន់គតិ"** បានដល់ ការទៅកាន់គតិ គឺទៅមកៗ ក្នុងសង្សារ ។ ពាក្យឆ្លើយយល់ព្រម ជារបស់បរវាទីដោយ*

*អំណាចនៃលទ្ធិរបស់ខ្លួន ។ សូម្បីពាក្យសាកសួររបស់សកវាទីថា **"បុគ្គលនោះ"** ជាដើម, ពាក្យបដិសេធជារបស់បរវាទី ។ ក្នុងបញ្ហានោះ ពាក្យថា **"បុគ្គលនោះ"** អធិប្បាយថា បុគ្គលនោះឯង ។ ក៏សកវាទីប្រកបពាក្យសួរយ៉ាងនេះ ទើបបរវាទីឆ្លើយបដិសេធ ព្រោះខ្លាចត្រូវគេចោទថា ជាសស្សតទិដ្ឋិ ។ ត្រូវសកវាទីសួរថា **"បុគ្គលផ្សេង"** ក៏ឆ្លើយបដិសេធ ព្រោះខ្លាចត្រូវគេចោទថា ជាឧច្ឆេទទិដ្ឋិ ។ ត្រូវសកវាទីសួរថា បុគ្គលនោះផង បុគ្គលដទៃផង ក៏ឆ្លើយបដិសេធ ព្រោះខ្លាចចោទថា ជាឯកច្ចសស្សតទិដ្ឋិ គឺលទ្ធិយល់ឃើញថា ទៀងខ្លះ ។ ត្រូវសកវាទីសួរថា មិនមែនបុគ្គលនោះ មិនមែនបុគ្គលផ្សេង ក៏ឆ្លើយបដិសេធ ព្រោះខ្លាចចោទថា ជាអមរាវិក្ខេបទិដ្ឋិ គឺលទ្ធិដែលមានសេចក្តី យល់ឃើញមិនស្លាប់ខ្លួន ។ ត្រូវសកវាទីសួរបញ្ហាសូម្បីទាំង ៤ រួមគ្នាទៀត ក៏បដិសេធព្រោះខ្លាចចោទថា ជាទិដ្ឋិទាំង ៤ ។ ឯលទ្ធិរបស់បរវាទីនោះ អាស្រ័យព្រះសូត្រទាំងឡាយណាកើតឡើង, សកវាទីនោះ ពេលនឹងសម្តែង ព្រះសូត្រនោះទៀត ទើបពោលពាក្យថា **"បើយ៉ាងនោះ បុគ្គលត្រេចទៅ កាន់គតិឬ ?"** ជាដើម សកវាទីកំណត់ពាក្យថា **"បុគ្គលនោះឯង"** ហើយ សួរដោយការបញ្ជាក់ទៀតថា "បុគ្គលណាទៅកាន់គតិតាមលទ្ធិរបស់លោក, បុគ្គលនោះ ជាមនុស្សដូចៗ គ្នា ក្នុងលោកនេះផង ក្នុងលោកដទៃផងឬ ?" បរវាទីបដិសេធ ព្រោះខ្លាចចោទថា*

ជាសស្សតទិដ្ឋិ លុះត្រូវសកវាទីសួរបញ្ជាក់យ៉ាងនោះហើយ ទើបឆ្លើយតប ព្រោះខ្លាចព្រះសូត្រថា "បុគ្គលនោះ មិនមែនបុគ្គលផ្សេង ពេលគេឃ្លាត ចាកពីលោកនោះ ហើយកើតក្នុងលោកនេះ" ដូច្នេះជាដើម រមែងមាន ។ ត្រូវសកវាទីសួរថា ***"មនុស្សម្នាក់នោះ ជាទេវតាឬ ?"*** ក៏ឆ្លើយបដិសេធ ព្រោះមនុស្សនោះមិនមែនជាទេវតា ។ ត្រូវសកវាទីសួរ បញ្ជាក់ជាថ្មីទៀត ក៏ឆ្លើយតបតាមអំណាចនៃព្រះសូត្រថា "សម័យនោះ យើងជាសាស្តា ឈ្មោះសុនេត្តៈ" ជាដើម ។ ពេលនោះ សកវាទីពោលប្រកាសពាក្យនោះថា ***"ខុស"*** ព្រោះសេចក្តីផ្សេងគ្នានៃការកើតឡើងរបស់ទេវតា និងមនុស្ស ទើបពោលពាក្យថា ***"ជាមនុស្ស ក៏ដូចគ្នា"*** ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា ***"សេចក្តីស្លាប់នឹងមិនមាន"*** អធិប្បាយថា កាលបើមានហេតុដូច្នេះ សេចក្តីស្លាប់នឹងមិនមាន ។ តអំពីនេះទៅ ពាក្យថា ***"ជាយក្ស, ជាប្រេត"*** ជាដើម បណ្ឌិតគប្បីជ្រាបសេចក្តីផ្សេងគ្នានៃការសាកសួរ ដោយអំណាចនៃ សេចក្តីផ្សេងគ្នាត្រឹមតែអត្តភាព ។

ពាក្យថា ***"ក្សត្រ"*** ជាដើម សកវាទីពោលដោយអំណាចនៃជាតិ និងដោយអំណាចនៃការខូះនូវអវយវៈជាដើម ។ ពាក្យថា ***" មិនគប្បីពោល ថា ' បុគ្គលទៅអំពីលោកនេះ កាន់លោកខាងមុខ, អំពីលោកខាងមុខ មក***

***ដល់លោកនេះឬ ? ដូច្នេះទេ"*** គឺបរវាទីសួរបន្ថែមទៀត សកវាទីឆ្លើយតបថា " មែន បុគ្គលមិនត្រាច់ទៅកាន់គតិ ព្រោះការទៅកាន់បរលោករបស់អ្នកតាំងនៅក្នុងភពនេះ ដោយអំណាចនៃការកើតមិនមាន" ។ ទោះបីពាក្យឆ្លើយតបលើកទីពីរ ក៏ជារបស់សកវាទីនោះឯង ព្រោះមិនមានព្រះសោតាបន្ន សូម្បីក្នុងភពដទៃរបស់ព្រះសោតាបន្នទៀត ។ ពាក្យថា ***"ប្រសិនបើ"*** ជាដើម ជារបស់បរវាទី ។ ការសាកសួរដល់បុគ្គលអ្នកកើតក្នុងទេវលោក ដោយការសម្ដែងដល់អត្តភាពរបស់មនុស្ស ជារបស់សកវាទីទៀត ។ ខាងមុខពីនេះ ពាក្យថា ***" មិនជាដទៃទេ"*** ក្នុងពាក្យថា ***" មិនជាដទៃ មិនប្រែប្រួល"*** នេះ ដូចគ្នាដោយអាការទាំងពួង ។ ពាក្យថា ***" មិនប្រែប្រួល"*** អធិប្បាយថា មិនផ្លាស់ប្ដូរសូម្បីដោយអាការបន្តិចបន្តួច ។ ពាក្យថា ***" មិនគប្បីពោលយ៉ាងនេះទេ"*** អធិប្បាយថា បរវាទីពោលយ៉ាងនេះ ព្រោះភាវៈជាមនុស្សនៃព្រះសោតាបន្នអ្នកកើតក្នុងទេវលោក ។ សកវាទីសួរបញ្ហានោះទៀត បរវាទីក៏ឆ្លើយតបតាមលទ្ធិថា "បុគ្គលនោះឯងត្រាច់ទៅកាន់គតិ" ។ ពាក្យថា ***"មនុស្សមានដៃកំបុត"*** ជាដើម សកវាទីពោលដើម្បីទម្លាយលទ្ធិថា "បុគ្គលមិនផ្លាស់ប្ដូរវិលវល់ដោយការឲ្យឃើញដល់ការប្ដូរលក្ខណៈ" ។ ក្នុងពាក្យទាំងនោះ ពាក្យថា ***"ម្រាមដៃកំបុត"***

បានដល់ ម្រាមដៃ ម្រាមជើង របស់បុគ្គលណាដែលដាច់ហើយ ។ ពាក្យថា ***"សរសៃធំដាច់"*** បានដល់ សរសៃធំរបស់អ្នកណាដាច់ហើយ ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា ***"មានរូបត្រាច់ទៅ"*** ជាដើម បរវាទីឆ្លើយបដិសេធក្នុងបញ្ហាដំបូង សំដៅយកការមិនត្រាច់ទៅកាន់គតិជាមួយរូបកាយនេះ ។ ក្នុងបញ្ហាទីពីរ ឆ្លើយតបសំដៅយកបុគ្គលអ្នកមានភពក្នុងចន្លោះ; ពិតណាស់ក្នុងលទ្ធិរបស់គេនោះ បុគ្គលមានរូប ចូលទៅកាន់គភ៌របស់មាតា, ប៉ុន្តែ រូបរបស់អ្នកចូលទៅកាន់គភ៌មាតានោះ រមែងបែកធ្លាយទៅ នេះហៅថា មានភពក្នុងចន្លោះរបស់គេ ។ ពាក្យថា ***"ជីវៈ ក៏យ៉ាងនោះ"*** សេចក្តីថា សកវាទីសួរថា បុគ្គលរមែងទៅព្រមជាមួយ សរីរៈ ពោលគឺរូប យ៉ាងណា, ជីវៈរបស់គេ ក៏យ៉ាងនោះ សរីរៈ ក៏យ៉ាងនោះឬ ? បរវាទីឆ្លើយបដិសេធព្រោះត្រូវលះបង់សរីរៈក្នុងលោកនេះ ហើយព្រោះខុសអំពីព្រះសូត្រផង ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា ***"ជាអ្នកមានវេទនាទៅកាន់គតិឬ ?"*** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកការកើតឡើងនៃអសញ្ញាសត្វ ។ រមែងឆ្លើយតបសំដៅយកការកើតឡើងក្រៅអំពីអសញ្ញាសត្វនោះ ។ ពាក្យថា ***"ជីវៈ ក៏យ៉ាងនោះ"*** សេចក្តីថា សកវាទីរមែងសួរថា ជីវៈអន្ទោលទៅកាន់គតិ ព្រមជាមួយនឹងសរីរៈ ក៏យ៉ាងនោះឬ ? ដូច្នេះ, ដែលពិតពាក្យថា ***"សរីរៈ"*** ក្នុងលទ្ធិថា "ជីវៈយ៉ាងនោះ សរីរៈ ក៏យ៉ាងនោះ, ជីវៈ

ផ្សេង សរីរៈ ក៏ផ្សេង” នេះ លោកសំដៅយកសុម្បីខន្ធទាំង ៥ ។ បរវាទីឆ្លើយបដិសេធ ព្រោះខុសចាកព្រះសូត្រ ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា **“មិនមានរូបទៅកើតទៀតឬ ?”** ក្នុងបញ្ហាទីមួយ បរវាទីឆ្លើយបដិសេធសំដៅយកភពមានក្នុងចន្លោះតាមលទ្ធិ ។ ត្រូវសកវាទីសួរលើកទីពីរ ក៏ឆ្លើយតបសំដៅយកនាមដែលកើតក្នុងអរូបភព ។ ពាក្យថា **“ជីវៈផ្សេង”** សេចក្តីថា សកវាទីសួរថា “បុគ្គលមិនមានរូប លះសរីរៈ ពោលគឺរូបណា ទៅកើតទៀត សរីរៈនោះ ជាយ៉ាងដទៃ, ជីវៈនោះ ក៏ជាយ៉ាងដទៃតាមលទ្ធិរបស់លោកឬ ?” បរវាទីឆ្លើយបដិសេធ ព្រោះខុសចាកព្រះសូត្រ ។ ពាក្យសួរថា **“ជាអ្នកមិនមានវេទនាទៅកើតទៀត”** ជាដើម បរវាទីសំដៅយកភពដែលមានសញ្ញា ទើបឆ្លើយបដិសេធ ។ រមែងឆ្លើយតបសំដៅយកឧបបត្តិភពផ្សេងក្រៅអំពីសញ្ញីភពនោះ ។ ពាក្យសួរថា **“ជីវៈជាយ៉ាងដទៃ”** សេចក្តីថា សកវាទីសួរថា បុគ្គលមិនមានវេទនា មិនមានវិញ្ញាណ លះសរីរៈ ពោលគឺវេទនាជាដើម រមែងទៅកើតក្នុងគក៏ទៀត សរីរៈរបស់អ្នកនោះ ក៏ជាយ៉ាងដទៃ ជីវៈរបស់អ្នកនោះ ក៏ជាយ៉ាងដទៃឬ ? បរវាទីឆ្លើយបដិសេធ ព្រោះខុសចាកព្រះសូត្រ ។

ក្នុងពាក្យជាដើមថា **“រូបអន្តោលទៅកើតទៀតឬ ?”** សេចក្តីថា សកវាទីសួរថា ព្រោះអាស្រ័យខន្ធទាំងឡាយ មានរូបក្ខន្ធជាដើមឯណា

រមែងបញ្ញត្តនូវបុគ្គល កាលបុគ្គលនោះទៅកើតទៀត តាមលទ្ធិរបស់លោក រូបទាំងនោះ ក៏រមែងទៅកើតទៀតឬ ? បរវាទីឆ្លើយបដិសេធការទៅកើតទៀតនៃរូប, មិនបដិសេធការទៅកើតទៀតនៃសត្វ ដោយព្រះសូត្រដែលប្រកាន់យកជាលទ្ធិថា "ការកើតនៃសត្វទាំងឡាយ អ្នកមានអវិជ្ជាជាគ្រឿងបិទបាំង មានតណ្ហាជាគ្រឿងចងព័ន្ធ ត្រូវសកវាទីសួរម្តងទៀត ក៏ពោលតបថា "រូបទៅកើតទៀត" ដោយសេចក្តីសម្គាល់ថា បុគ្គលវៀរនូវធម៌ទាំងឡាយ មានរូបធម៌ជាដើម រមែងមិនមាន ព្រោះហេតុដូច្នោះលុះបុគ្គលនោះ ទៅកើតទៀត រូបនោះឯង ក៏ត្រូវទៅកើតទៀត ។ សូម្បីក្នុងធម៌ទាំងឡាយ មានវេទនាជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា "រូបមិនកើតទៀតឬ ?" ជាដើម អធិប្បាយថា លោកពោលថា រូបរបស់លោកមិនមែនបុគ្គលទេ, បុគ្គលប៉ុណ្ណោះ រមែងទៅកើតទៀត ព្រោះហេតុណា, ព្រោះហេតុនោះ ខ្ញុំសូមសួរលោកថា "រូបរបស់លោកនោះ មិនទៅកើតទៀតឬ ?" បរវាទីឆ្លើយបដិសេធ ដោយសំដៅយកថា បុគ្គលទៅកើតទៀត, មិនអាចទៅកើតទៀត ដោយរូបដែលជាឧបាទានរបស់អ្នកនោះ ពេលត្រូវសកវាទីសួរបញ្ជាក់ទៀត ក៏ឆ្លើយតបព្រោះការទៅកើតទៀតនៃសត្វទាំងឡាយនោះឯង ។ ពាក្យដែលនៅសល់មានខ្លឹមសារងាយស្រួលទាំងអស់ ។

*ម្យ៉ាងទៀត សេចក្តីនៃគាថាទាំងឡាយ គប្បីជ្រាបដូច្នេះ ៖*

*ពោលដោយមតិរបស់លោកមានអាយុ បុគ្គលអាស្រ័យខន្ធទាំងឡាយ ទើបមានដូចស្រមោលដើមឈើ អាស្រ័យដើមឈើ និងដូចភ្លើងអាស្រ័យ ឈើពំនូត លុះកាលធម៌ទាំងឡាយនេះ ទៅកើតទៀត រូបជាដើមមិនមាន ពេលខន្ធទាំងអស់នោះបែកធ្លាយទៅ ក៏បុគ្គលរបស់លោកមិនបែកធ្លាយទៅ បើយ៉ាងនោះ ការយល់ឃើញថា សូន្យ គឺឧច្ឆេទទិដ្ឋិ រមែងប្រាកដដល់គេ ។*

***សួរថា*** *ទិដ្ឋិណារមែងកើត ? ឆ្លើយថា អកុសលទិដ្ឋិណាដែលព្រះពុទ្ធជាម្ចាស់ ទ្រង់វៀរស្រឡះហើយ អកុសលទិដ្ឋិទាំងនោះ រមែងកើត ។ លោកតែងតែ សម្តែងថា " ក៏បរិយាយភាសិតឯណាដែលថា ព្រះសមណគោតម ជា ឧច្ឆេទវាទី " ពួកយើងទាំងឡាយរមែងមិនពោលនូវពាក្យនោះទេ ។*

*ម្យ៉ាងទៀត ពេលខន្ធទាំងនោះបែកធ្លាយទៅ បុគ្គលនោះរមែងមិន បែកធ្លាយទៅឡើយ, កាលបើមានដូច្នេះ បុគ្គលក៏ទៀង, បុគ្គលនោះ ក៏ស្មើគ្នា ជាមួយនឹងព្រះនិព្វានតាមទិដ្ឋិនោះដែរ ។ ពាក្យថា* ***"ស្មើគ្នា"*** *បានដល់ ស្មើ យ៉ាងក្រៃលែង, ហើយម្យ៉ាងទៀត ហៅថា* ***"ស្មើដោយស្មើ"*** *ឬ* ***"ស្មើដោយ ការស្មើនោះឯង"*** *, ដូចយ៉ាងថា ព្រះនិព្វានមិនកើត មិនរលត់ យ៉ាងណា; សូម្បីបុគ្គលនោះ ក៏រមែងមិនកើត រមែងមិនរលត់យ៉ាងនោះដែរ ។ បុគ្គលស្មើគ្នាដោយព្រះនិព្វាននោះ (តាមលទ្ធិនោះរមែងមាន) ដោយប្រការ*

ដូច្នេះឯង ៗ

ចប់គតិអនុយោគ

..............

## ១២.ឧបាទាបញ្ញត្តានុយោគ

## ការសាកសួរឧបាទាបញ្ញត្តិ

ឥឡូវនេះ ជាការសាកសួរឧបាទាបញ្ញត្តិ គឺបញ្ញត្តិ ព្រោះអាស្រ័យ ៖

ក្នុងរឿងនោះ ពាក្យសួរជារបស់សកវាទី, ពាក្យឆ្លើយតប ជារបស់បរវាទី ។ ពិតមែន ព្រោះអាស្រ័យចក្ខុរូបជាដើម ទើបបញ្ញត្តបុគ្គល ដូចការបញ្ញត្តស្រមោលដើមឈើ ព្រោះអាស្រ័យដើមឈើ, ដូចការបញ្ញត្តភ្លើង ព្រោះអាស្រ័យឈើក្តួតដូច្នោះ, លោកត្រូវការប្រកាសឲ្យដឹង ឲ្យចូលចិត្ត ដល់បញ្ញត្តិ ព្រោះហេតុដូច្នោះ ពេលត្រូវសកវាទីសួរថា ***"ការបញ្ញត្តនូវបុគ្គល ព្រោះអាស្រ័យរូបឬ ?"*** ទើបបរវាទីឆ្លើយតប ។ ត្រូវសកវាទីសួរខ្លឹមសារនេះទៀតថា ***"សូម្បីបុគ្គលក៏មិនទៀងដូចគ្នានឹងរូបដែរ"*** ជាដើម ប្រៀបដូចស្រមោលអាស្រ័យដើមឈើ ក៏ហាក់ដូចជាដើមឈើដែរ, ភ្លើងដែលអាស្រ័យឈើក្តួត ក៏ហាក់ដូចជាឈើក្តួតដែរ ដោយមានសេចក្តីមិនទៀងជាធម្មតា យ៉ាងណា; បុគ្គលរបស់លោកអាស្រ័យរូបជាដើម មានសេចក្តីមិនទៀង ដូចធម៌ទាំងឡាយ មានរូបជាដើម យ៉ាងនោះឬ ? ដូច្នេះ ទើប

បរវាទីឆ្លើយបដិសេធ ព្រោះតាំងនៅក្នុងលទ្ធិរបស់ខ្លួន ។ ក្នុងពាក្យទាំង-ឡាយ មានពាក្យថា ***“ព្រោះអាស្រ័យរូបខៀវ ទើបបញ្ញត្តបុគ្គលខៀវឬ ?”*** ជាដើម បរវាទីកាលមិនប្រាថ្នានូវភាវៈនៃបុគ្គលជាមួយគ្នានឹងរូបខៀវផង, នូវសេចក្ដីមានយ៉ាងច្រើននៃបុគ្គល ដោយអំណាចនៃរូបខៀវជាដើម ក្នុងសរីរៈមួយផង ទើបឆ្លើយបដិសេធ ។

សូម្បីក្នុងបញ្ហានេះថា ***“ការបញ្ញត្តនូវបុគ្គលដែលមានកុសល ព្រោះអាស្រ័យវេទនាជាកុសលឬ ?”*** ជាដើម បរវាទីកាលមិនប្រាថ្នានូវភាវៈនៃបុគ្គលជាមួយវេទនា និងសេចក្ដីមានយ៉ាងច្រើននៃបុគ្គល ដោយអំណាចនៃកុសលវេទនាដ៏ច្រើនក្នុងសន្ដានមួយ ទើបឆ្លើយបដិសេធ ។ ក្នុងន័យទីពីរ បរវាទីឆ្លើយតប ព្រោះសំដៅយកបុគ្គលអ្នកតាំងនៅក្នុងភាពជាអ្នកឈ្លាស ដោយសេចក្ដីនៃពាក្យថា ***“មគ្គកុសល”*** ជាដើម ។ ត្រូវសកវាទីសួរដល់បុគ្គលជាកុសលមានផលដើម ក៏ឆ្លើយបដិសេធ ព្រោះមិនមានវោហារដូច្នោះ ។ ក្នុងផ្នែកអកុសល បរវាទីឆ្លើយតប សំដៅយកអ្នកតាំងនៅក្នុងភាពជាអ្នកមិនឈ្លាស ។ ក្នុងផ្នែកអព្យាកតៈ លោកក៏ឆ្លើយតប សំដៅយកសេចក្ដីនៃអព្យាក្រឹត គឺមិនមានការព្យាករណ៍ ដោយអំណាចនៃពាក្យថា ***“លោកទៀង”*** ជាដើម ។ ពាក្យដែលនៅសល់ក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងខាងក្រោយនោះចុះ ។ ក្នុងពាក្យសួរទាំងឡាយថា

***“បុគ្គលអាស្រ័យចក្ខុ គេត្រូវហៅថា បុគ្គលមានចក្ខុឬ ?”*** ជាដើម បរវាទីរមែងឆ្លើយតប ព្រោះវោហារថា ***“អ្នកមានចក្ខុគប្បីវៀរចាបផ្សេងៗ”*** ជាដើម កាលមិនប្រាថ្នាការរលត់របស់បុគ្គល ព្រោះការរលត់នៃធម៌ មានត្រឹមតែចក្ខុជាដើម ទើបបដិសេធ ។ ក្នុងពាក្យសួរថា ***“ការបញ្ញត្តនូវបុគ្គលព្រោះអាស្រ័យរូប អាស្រ័យវេទនាឬ ?”*** នេះ បណ្ឌិតគប្បីជ្រាបសូម្បីនូវធម៌ពួកផ្សេង មានរូបជាមូល ដែលជាពួក ២, ពួក ៣ និង ពួក ៤ ។ ក៏ការបញ្ញត្តបុគ្គលព្រោះអាស្រ័យខន្ធទាំងឡាយ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបបរវាទីឆ្លើយតបនូវបញ្ញត្តិ ព្រោះអាស្រ័យខន្ធ ២ ខ្លះ, ខន្ធ ៣ ខ្លះ, ខន្ធ ៤ ខ្លះ និងខន្ធ ៥ ខ្លះ ។ ប៉ុន្តែឆ្លើយបដិសេធ ព្រោះមិនមានបុគ្គល ២ ឬបុគ្គល ៥ ក្នុងសន្តានមួយ; សូម្បីក្នុងអាយតនៈទាំងឡាយក៏មានន័យដូចគ្នានេះដែរ ។

ឥឡូវនេះ ដើម្បីសម្ដែងថា “ការបញ្ញត្តបុគ្គលណា ព្រោះអាស្រ័យខន្ធណា ទោះបីភាពមិនទៀងរបស់បុគ្គលនោះ ក៏ព្រោះតែភាពមិនទៀងទាត់របស់ខន្ធនោះ ហើយការសម្រេចម្យ៉ាងទៀត ព្រោះអាស្រ័យវត្ថុណាមួយ, ការសម្រេចនៃបុគ្គលនោះ ក៏រមែងប្រាកដយ៉ាងនោះឬ ?” ដូច្នេះ ទើបពោលថា “ព្រោះអាស្រ័យដើមឈើ ទើបបញ្ញត្តស្រមោលឈើឡើងយ៉ាងណា” ជាដើម ។ បណ្ដាពាក្យទាំងអស់នោះ ពាក្យថា ***“ព្រោះអាស្រ័យ”***

បានដល់ អាស្រ័យ គឺការមិនវៀរចាកវត្ថុនោះ ។ ក៏បរវាទីកាលមិនប្រាថ្នាពាក្យថា ***“ព្រោះអាស្រ័យដើមឈើ ទើបបញ្ញត្តស្រមោល, ព្រោះអាស្រ័យរូប ទើបបញ្ញត្តបុគ្គល”*** ដូច្នេះ ព្រោះការប្រកាន់មាំនៅក្នុងលទ្ធិរបស់ខ្លួនទើបឆ្លើយបដិសេធ ។ ពាក្យថា ***“ឃ្នាង ឬខ្នោះ”*** បានដល់ គ្រឿងចាប់ចងដ៏មាំទាំ ។ ពាក្យថា ***“អ្នកត្រូវជាប់ខ្នោះ”*** បានដល់ អ្នកត្រូវចាប់ចងដោយគ្រឿងចាប់ចងនោះ ។ ពាក្យថា ***“រូបមានដល់អ្នកណា អ្នកនោះ ផ្សេងត្រឹមតែឈ្មោះថា អ្នកមានរូប”*** អធិប្បាយថា រូបមានដល់បុគ្គលណាបុគ្គលនោះ ផ្សេងត្រឹមតែឈ្មោះថា អ្នកមានរូបដូចអ្នកដាក់ខ្នោះ មិនមែនត្រូវជាអ្នកជាប់ខ្នោះទេ គឺអ្នកដាក់ខ្នោះផ្សេង អ្នកជាប់ខ្នោះផ្សេង យ៉ាងណា, រូបផ្សេង អ្នកមានរូបផ្សេង ក៏យ៉ាងនោះដែរ ។

ក្នុងពាក្យសួរថា ***“ការបញ្ញត្តនូវបុគ្គល ព្រោះចិត្តមួយដួង ១ ឬ ?”*** បរវាទីសំដៅយកចិត្តមានរាគៈជាដើម ដោយអំណាចនៃបុគ្គលមានរាគៈជាដើម ទើបឆ្លើយតបដោយអំណាចនៃចិត្តានុបស្សនា ។ ត្រូវសកវាទីសួរដោយន័យថា ***“រមែងកើតចាស់ស្លាប់”*** ជាដើម កាលបរវាទីមិនប្រាថ្នានូវភាវៈនៃបុគ្គលកើតជាខណៈដូចចិត្ត ទើបបដិសេធ ។ ត្រូវសកវាទីសួរថា ***“បុគ្គលនោះ ឬថា បុគ្គលផ្សេង១”*** ព្រោះខ្លាចជាសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ទើប

បដិសេធ ។ ត្រូវសកវាទីសួរទៀតថា ***"ពេលចិត្តដួងទីពីរកើតឡើង មិនគប្បីពោលថា 'កុមារ ឬកុមារី"*** ទេ ព្រោះខ្លាចត្រូវដាច់ចាកវោហាររបស់សត្វលោក ទើបទទួលថា ***"គប្បីពោលបាន"*** ។ ពាក្យដ៏សេសក្នុងទីនេះប្រាកដជាក់ច្បាស់ហើយទាំងអស់ ។

ឥឡូវនេះ បរវាទីជាអ្នកប្រាថ្នាដើម្បីនឹងឲ្យលទ្ធិរបស់ខ្លួនតាំងនៅដោយអាការផ្សេងទៀត ទើបពោលពាក្យថា អ្នកមិនគួរពោលថា ***"បុគ្គលគេដឹងបាន"*** ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា ***"អ្នកមិនគួរពោល"*** អធិប្បាយថា បរវាទីពោលពាក្យនេះមុនថា អ្នកមិនគួរពោលថា ***"បុគ្គលគេដឹងបានដោយអត្ថដ៏ពិត ដោយអត្ថដ៏ឧត្តម"*** ដូច្នេះទេ ឬដោយការសាកសួរដល់ខបាទាបញ្ញត្តិដ៏ច្រើនយ៉ាងនេះ ។ តអំពីនោះ កាលបើមានពាក្យថា ***"មែន"*** ដែលសកវាទីឆ្លើយតបហើយ ទើបបរវាទីពោលថា ***"បុគ្គលណាឃើញ ឃើញរូបណា... មិនមែនឬ ?*** ជាដើម ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **"យោ"** បានដល់ បុគ្គលណា ។ ពាក្យថា **"យំ"** បានដល់ រូបណា ។ ពាក្យថា **"យេន"** បានដល់ ដោយចក្ខុណា ។ ពាក្យថា **"សោ"** បានដល់ បុគ្គលនោះ ។ ពាក្យថា **"តំ"** បានដល់ រូបនោះ ។ ពាក្យថា

**"តេន"** បានដល់ ដោយចក្ខុនោះ ។ លោកអធិប្បាយទុកថា បុគ្គលណា ឃើញ, ឃើញរូបណា, ឃើញដោយចក្ខុណា; បុគ្គលនោះ កាលឃើញរូប នោះ រមែងឃើញដោយចក្ខុនោះ មិនមែនឬ ? សកវាទីក៏ឆ្លើយតបថា **"មែន"** ដោយអំណាចនៃសម្មតិជាដើម ដោយពាក្យថា "ចក្ខុជានិស្សយ-ប្បច្ច័យដល់ចក្ខុវិញ្ញាណ ក៏ពិតមែនហើយ, តែថា បុគ្គលនោះ ក៏ឈ្មោះថា ឃើញនូវរូបនោះ; សោតៈក៏ដូចគ្នា, បុគ្គលនោះ ឈ្មោះថា ឮសំឡេង ។ ល ។ មនោវិញ្ញាណក៏ដូចគ្នា, បុគ្គលនោះ ឈ្មោះថា ដឹងច្បាស់នូវធម៌; ចក្ខុរបស់ព្រះអរហន្តមាន, ព្រះអរហន្តរមែងឃើញរូបនោះ ដោយចក្ខុនោះ" ដូច្នេះ ។ លំដាប់នោះ បរវាទីអាស្រ័យវាទៈដែលមានលេសន័យ ទើបប្តូរវាទៈនោះ ហើយពោលពាក្យជាដើមថា "ដោយហេតុនោះ លោកគប្បីពោលថា 'បុគ្គលគេដឹងបាន ព្រោះភាវៈនៃបុគ្គល ដែលលោកឲ្យសម្រេចហើយ ដោយសេចក្តីជាពាក្យដែលបុគ្គលគប្បីពោល" ។ ក្នុងពាក្យទាំងនោះ ពាក្យថា **"បុគ្គលណាមិនបានឃើញ"** អធិប្បាយថា ជាបុគ្គលខ្វាក់, អសញ្ញីសត្វដែលកើតក្នុងអរូបភព សូម្បីជាអ្នកមិនខ្វាក់ ចូលសមាបត្តិហើយ ក៏ឈ្មោះថា មិនឃើញរូបយ៉ាងណាមួយ ក្នុងខណៈនោះ ។ ទោះបីក្នុងវារៈ

ដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ ពោលដោយអត្ថ បណ្ឌិតគប្បីជ្រាបពាក្យដ៏សេស ដោយអំណាចនៃព្រះបាលីចុះ ។

ក្នុងការផ្ទៀងផ្ទាត់ព្រះសូត្រ បរវាទីពោលថា ***"ព្រះមានព្រះភាគទ្រង់ឃើញរូប ព្រោះរូបជាអារម្មណ៍ដល់ទិព្វចក្ខុ"*** ។ ក្នុងវារៈទីពីរពោលថា ***"ព្រះមានព្រះភាគទ្រង់ឃើញបុគ្គល"*** ព្រោះព្រះបាលីថា ***"តថាគតរមែងឃើញសត្វទាំងឡាយ"*** ដូច្នេះ, ក្នុងវារៈទីបីពោលថា ***"ព្រះមានព្រះភាគទ្រង់ឃើញទាំងពីរយ៉ាង"*** ព្រោះលទ្ធិថា ***"ព្រះមានព្រះភាគទ្រង់ឃើញរូបហើយ ទើបដឹងច្បាស់នូវបុគ្គល [*]"*** ។ ក៏រូបាយតនៈនោះ លោករួមទុកក្នុងរូបសង្គហៈ ៤ គឺ **ទិដ្ឋំ ១, សុតំ ១, មុតំ ១** និង **វិញ្ញាតំ ១,** ឈ្មោះថាជាធម៌គប្បីឃើញ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបសកវាទីបញ្ជាក់ថា រូប គឺបុគ្គល, បុគ្គល គឺរូប; ទាំងពីរយ៉ាង គឺរូប និងរូបាយតនៈជាដើម ៕

## ចប់ឧបាទាបញ្ញត្តានុយោគ

---

[*] ក្នុងវិភង្គប្បករណ៍ពោលទុកថា រូបាយតនៈ ជា **ទិដ្ឋំ** ជា **វិញ្ញាតំ**, សទ្ទាយតនៈ ជា **សុតំ** ជា **វិញ្ញាតំ**, គន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ ជា **មុតំ** ជា **វិញ្ញាតំ**, អាយតនៈ ៧ ដ៏សេស គឺចក្ខាយតនៈ, សោតាយតនៈ, ឃានាយតនៈ, ជិវ្ហាយតនៈ, កាយាយតនៈ, ធម្មាយតនៈ និងមនាយតនៈ ជា **វិញ្ញាតំ**; **ទិដ្ឋំ** បានដល់ ធម៌ដែលគេឃើញហើយ ។ល។ **វិញ្ញាតំ** បានដល់ ធម៌ដែលគេដឹងហើយ ។

## ១៣. កល្យាណវគ្គ (ឬបុរិសការានុះយោគ)

## សាកសួរការធ្វើរបស់បុគ្គល

*ឥឡូវនេះ ជាការសាកសួរដល់ការធ្វើរបស់បុគ្គល ៖*

*ក្នុងបញ្ហានោះ ពាក្យសួរដោយលទ្ធិថា* ***"កាលកម្មមាន ទោះបីអ្នកធ្វើកម្មនោះ ក៏ត្រូវតែមានយ៉ាងពិតប្រាកដ"*** *ដូច្នេះ ជារបស់បរវាទី ។ ពាក្យឆ្លើយតបថា* ***"មែន"*** *ជារបស់សកវាទី ព្រោះកម្មទាំងឡាយយ៉ាងនោះមាន ។ ពាក្យសួរទៀតថា* ***"អ្នកធ្វើ, អ្នកឱ្យធ្វើកម្ម"*** *ជារបស់សកវាទី ។ បណ្ដាពាក្យទាំងនោះ ពាក្យថា* ***"អ្នកធ្វើ"*** *បានដល់ អ្នកធ្វើកម្មទាំងឡាយនោះ ។ ពាក្យថា* ***"អ្នកឱ្យធ្វើកម្ម"*** *បានដល់ អ្នកប្រើឲ្យគេធ្វើកម្មដោយឧបាយទាំងឡាយ មានការបញ្ជា និងការសម្ដែងឲ្យយល់ជាដើម ។*

*ក្នុងពេលនេះ បរវាទីសំដៅយកបុគ្គល ទើបសួរដល់អ្នកធ្វើ មិនសួរហេតុត្រឹមតែការធ្វើ ព្រោះហេតុដូច្នោះ ទើបសកវាទីឆ្លើយបដិសេធ ។ ក្នុងពាក្យថា* ***"អ្នកធ្វើ អ្នកឱ្យធ្វើកម្មនោះ"*** *នេះ អធិប្បាយថា សកវាទីសួរថា "បើលោកដឹងនូវកម្មណាៗ, លោកក៏ដឹងនូវបុគ្គលអ្នកធ្វើកម្មនោះៗ រមែងដឹងបុគ្គលតាមលទ្ធិរបស់លោកនោះឯង, លោកក៏ដឹងបុគ្គលអ្នកធ្វើ, អ្នកឲ្យធ្វើកម្មនោះដែរឬ ?" បរវាទីពេលមិនប្រាថ្នាដូច្នោះ ទើបឆ្លើយបដិសេធ*

ព្រោះខ្លាចត្រូវគេពោលចោទថា ជាលទ្ធិនៃព្រះជាម្ចាស់អ្នកសាងលោក ។ កាលសួរដដែលទៀត បរវាទីក៏ឆ្លើយតប ព្រោះសំដៅយកខ្លឹមសារនេះថា "មាតាបិតារមែងឲ្យបុត្រកើត រមែងតាំងឈ្មោះ រមែងចិញ្ចឹម ព្រោះហេតុដូច្នេះ មាតាបិតានោះ ទើបឈ្មោះថា អ្នកធ្វើ, ចំណែកកល្យាណមិត្រ ឬអាចារ្យពួកណា តែងតែឲ្យសិស្សសិក្សាវិជ្ជាការ និងរៀនសិល្បៈទាំងឡាយនោះៗ, កល្យាណមិត្រ ឬអាចារ្យនោះ ឈ្មោះថា អ្នកឲ្យធ្វើ" ដូច្នេះ ។ អធិប្បាយថា កម្មចាស់ប៉ុណ្ណោះ លោកប្រាថ្នាយកថា ជាអ្នកធ្វើ ជាអ្នកឲ្យធ្វើកម្មនោះៗ លោកពោលពាក្យនេះថា ***"បើអ្នកធ្វើ របស់អ្នកធ្វើកម្មទាំងឡាយមានមែន, សូម្បីអ្នកធ្វើតៗ គ្នាមកនោះ ក៏មានដែរ"*** ដោយពាក្យថា ***"ដល់បុគ្គលនោះៗ ឯង"*** ដូច្នេះនេះ កាលបើមានហេតុយ៉ាងនេះ បុគ្គលអ្នកកើតមុនៗ ក៏គប្បីធ្វើបុគ្គលអ្នកកើតចំណែកខាងក្រោយដោយពិត សូម្បីត្រឹមតែពាក្យនេះ បុគ្គលអ្នកធ្វើកម្មនោះ គប្បីធ្វើបុគ្គលផ្សេងៗ តទៅ ។ សូម្បីបុគ្គលនោះ ក៏គប្បីធ្វើបុគ្គលផ្សេងៗ ។ សកវាទីសួរថា "និព្វានណាគឺការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន, ការកាត់ផ្តាច់វដ្តៈមិនមាន, សេចក្តីរលត់ដោយជុំវិញមិនមាន, បច្ច័យក៏មិនមាន, និព្វាននោះ មិនមានដល់បុគ្គលនោះៗ ព្រោះមិនមានបច្ច័យ ព្រោះមិនមានទុក្ខដទៃជាប់ជំពាក់ដោយបច្ច័យឬ ?", ម្យ៉ាងទៀត ពាក្យថា ***"ដល់បុគ្គលនោះៗ ឯង"*** អធិប្បាយថា បើមានការ

ជាប់គ្នាមករបស់បុគ្គលយ៉ាងនេះថា **“កម្មគ្រាន់តែធ្វើមិនមានទេ, មានតែបុគ្គលប៉ុណ្ណោះជាអ្នកធ្វើ, បុគ្គលឯណោះ ៗ ត ៗ គ្នាមក”** ។ បើដូច្នោះ កាលពោលថា **“ការធ្វើនូវទីបំផុតនៃទុក្ខ ព្រោះហេតុដែលមិនឱ្យប្រព្រឹត្តទៅនៃកម្មវដ្ដៈយ៉ាងណានោះ ក៏មិនមានដល់បុគ្គលនោះៗ”** ដូច្នេះ ។ បរវាទីមិនប្រាថ្នាពាក្យនោះ ទើបបដិសេធ ។ ពាក្យថា **“អ្នកធ្វើ, អ្នកឱ្យធ្វើ”** ក្នុងពាក្យសួរនៃអ្នកធ្វើទាំងឡាយ តាមពាក្យសម្គាល់ដែលដឹងបាន ទោះបីក្នុងបញ្ហាដទៃអំពីនេះទៀត លោកក៏សំដៅយកចំពោះបុគ្គលប៉ុណ្ណោះ, មិនបានសំដៅយកបច្ច័យទាំងឡាយឡើយ ។ ពិតណាស់ បច្ច័យនៃវត្ថុទាំងពួងដូចជាមហាប្រឹថពីជាដើម នឹងមិនមាន ក៏មិនបាន ។ បញ្ហាដែលសកវាទីសួរថា **“អ្នកធ្វើកម្មល្អ កម្មអាក្រក់ទាំងឡាយ ក៏ជាដទៃឬ ?”** បញ្ហានោះបរវាទីឆ្លើយ បដិសេធហើយ ព្រោះខ្លាចជាទិដ្ឋិថា **“បុគ្គលមានសង្ខារ ឬមានអត្តា”** ជាដើម ។

ពាក្យថា **“វិបាក (នៃកម្មល្អ និងអាក្រក់) គេដឹងបានឬ ?”** ជាដើម លោកពោលដើម្បីទម្លាយលទ្ធិរបស់អ្នកសម្ដែងបុគ្គល ដោយអំណាចនៃបុគ្គលអ្នកសោយវិបាក ។ ក្នុងពាក្យថា **“អ្នកសោយវិបាក”** ជាពាក្យសាកសួររបស់បរវាទី ។ ពាក្យបដិសេធជារបស់សកវាទី ព្រោះមិនមានអ្នកសោយ

ដទៃក្រៅអំពីការប្រព្រឹត្តទៅនៃវិបាកឡើយ ។ ពាក្យសួរទៀត ជារបស់សកវាទី, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា ***"បុគ្គលជាអ្នកសោយវិបាកនោះ"*** បានដល់ អ្នកសោយរបស់វិបាកនោះៗ, ក៏វិបាក ឈ្មោះថា គប្បីសោយ, បុគ្គលមិនមែនវិបាក ព្រោះហេតុដូច្នេះ ទើបបរវាទីបដិសេធថា ***" មិនគប្បីពោលថា បុគ្គលជាអ្នកសោយ"*** ទេ ។ ត្រូវសកវាទីសួរបន្ថែមទៀត ក៏ឆ្លើយតបថា ***"បុគ្គលជាអ្នកសោយវិបាក"*** ព្រោះការតាំងនៅក្នុងផលនៃបុណ្យ ដោយសំដៅយកមាតាដែលលះបង់បុត្រ ឬភរិយាដែលលះបង់ស្វាមីជាអ្នកសោយវិបាក ដែលហាក់ដូចជាការសោយរបស់បុគ្គលដែរ ។ ពាក្យសួរថា ***"ការធ្វើនូវទីបំផុតនៃទុក្ខមិនមាន ។ល ។ ដល់បុគ្គលនោះៗ"*** អធិប្បាយថា ប្រសិនបើសេចក្តីតភ្ជាប់គ្នារបស់បុគ្គលមានមកយ៉ាងនេះថា ***" វិបាកដែលគ្រាន់តែជាវិបាកមិនមាន, មានតែបុគ្គលជាអ្នកសោយផលនៃកម្មនោះតៗ គ្នាមក"*** បើដូច្នោះ កាលពោលថា ***"ការធ្វើនូវទីបំផុតនៃទុក្ខ ដោយហេតុដែលមិនប្រព្រឹត្តទៅនៃវិបាកវដ្តៈនេះឯង ក៏រមែងមិនមាន"*** ដូច្នេះ ។ តពីនោះ គប្បីជ្រាបខ្លឹមសារក្នុងពាក្យសួរដល់អ្នកសោយ ដោយពាក្យជាធម្មតាថា ***"លោកដឹងបាន"*** ខាងមុខនេះ ដោយន័យដែលពោលហើយខាងក្រោយនុ៎ះឯង ។

បញ្ហាដែលសកវាទីសួរថា ***“បុគ្គលសោយវិបាកនៃកម្មល្អ កម្មអាក្រក់ក៏ជាវេទែឬ ?”*** បរវាទីឆ្លើយបដិសេធ ព្រោះខ្វាចលទ្ធិដែលយល់ឃើញខុសថា ***“បុគ្គលមានវេទនា ឬបុគ្គលមានអត្តា”*** ។ ពាក្យថា ***“សុខដ៏ជាទិព្វ”*** ជាដើម ជាពាក្យដែលបរវាទីផ្តើមចែកផលនៃកម្មល្អ និងកម្មអាក្រក់ ដោយអំណាចនៃលទ្ធិ ។ ពាក្យទាំងអស់នោះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងខាងក្រោយនុ៎ះឯង ។ ឯក្នុងពាក្យបុច្ឆាដែលបរវាទីសួរថា ***“លោកដឹងបុគ្គលអ្នកសោយសុខដ៏ជាទិព្វឬ ?”*** នេះ គប្បីជ្រាបថា សកវាទី ឆ្លើយបដិសេធថា ***“បុគ្គលមិនជាអ្នកសោយទេ”*** គឺមិនបដិសេធវិបាកខន្ធ ដែលសោយសុខដ៏ជាទិព្វឡើយ ។ ពិតណាស់ ការកើតឡើងនៃវិបាកដែលធ្វើកម្មដ្ឋានទាំងឡាយ និងយកមហាប្រឹថពីជាដើម ឲ្យជាអារម្មណ៍ហើយសោយផល រមែងជាការសម្រេចដែលប្រៀបមិនបាន ។ ពាក្យថា ***“អ្នកធ្វើ អ្នកឱ្យធ្វើ ជាអ្នកសោយផលនៃកម្មល្អ និងកម្មអាក្រក់”*** ជាដើម ជាពាក្យដែលលោកពោលប្រារព្ធន័យលាយគ្នា គឺមានទាំងបញ្ញត្តិ មានទាំងបរមត្ថ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ***“បុគ្គលនោះធ្វើ”*** ជាពាក្យសាកសួររបស់សកវាទី លោកពោលថា ***“បុគ្គលអ្នកធ្វើកម្មណា និងអ្នកសោយកម្ម***

***ណា បុគ្គលនោះឯង ធ្វើបុគ្គលនោះឯង ឱ្យជាអ្នកសោយឬ ?”*** *ពាក្យបដិសេធជារបស់បរវាទី ព្រោះខ្លាចខុសចាកព្រះសូត្រ ។ ត្រូវសកវាទីសួរទៀត ក៏ឆ្លើយតបដោយអំណាចនៃព្រះសូត្រថា* ***“បុគ្គលរមែងរីករាយក្នុងលោកនេះ លុះលះលោកនេះទៅហើយ រមែងរីករាយក្នុងលោកខាងមុខជាដើម”*** *។ លំដាប់នោះ សកវាទីពោលបដិសេធឱកាសនៃពាក្យ ដែលនឹងពោលរបស់បរវាទីនោះ ទើបពោលពាក្យថា* ***“សុខទុក្ខធ្វើដោយខ្លួនឯងឬ ?”*** *ក្នុងពាក្យទាំងនោះ ពាក្យថា* ***“អ្នកដទៃធ្វើ”*** *សកវាទីពោលដោយអំណាចនៃសេចក្តីដទៃ ដល់អ្នកធ្វើ និងអ្នកសោយ ។ បន្ទាប់អំពីនោះ ទើបបរវាទីបដិសេធ ឱកាសដែលនឹងនិយាយ ព្រោះខ្លាចខុសចាកព្រះសូត្រ ។ ត្រូវសកវាទីសួរទៀត កាលបើមានសេចក្តីសម្គាល់ថា* ***“បុគ្គលអ្នកកើតជាមនុស្សហើយ កើតជាទេវតាហើយ រមែងសោយ”*** *ដូច្នេះ ទើបឆ្លើយតប ។ ត្រូវសកវាទីសួរដោយអំណាចនៃវាទៈយ៉ាងនេះថា* ***“សុខ និងទុក្ខដែលបុគ្គលដទៃធ្វើហើយ រមែងប្រាកដឬ ?”*** *ដូច្នេះ ក៏បដិសេធទៀត ។ ពាក្យថា* ***“បុគ្គលនោះធ្វើ បុគ្គលដទៃសោយ”*** *សកវាទីពោលដោយអំណាចនៃពាក្យសួរដល់ភាពជាបុគ្គលម្នាក់ដូចគ្នានឹងភាវៈ នៃបុគ្គលដទៃរបស់អ្នកធ្វើ និងអ្នកសោយ ។ លំដាប់នោះ បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសអំពីព្រះសូត្រ*

ត្រូវសកវាទីសួរទៀត ក៏ឆ្លើយតប ព្រោះរួមន័យទាំងពីរមុនៗ ចូលគ្នាផង ។ ត្រូវសកវាទីសួរដោយអំណាចនៃបញ្ហានោះ របស់អ្នកមានវាទៈយ៉ាងនេះថា **"សុខទុក្ខដែលខ្លួនឯងធ្វើផង ដែលបុគ្គលដទៃធ្វើផង រមែងប្រាកដឬ ?"** ក៏ឆ្លើយបដិសេធទៀត ។ ពាក្យថា **"មិនមែនអ្នកដទៃធ្វើទេ"** ជាពាក្យដែលសកវាទីពោលដោយអំណាចនៃការបដិសេធ ក្នុងសេចក្ដីជាបុគ្គលតែម្នាក់ធ្វើ ឬអ្នកដទៃធ្វើដល់អ្នកធ្វើ និងអ្នកសោយ ។ លំដាប់នោះ បរវាទីឆ្លើយបដិសេធដោយអំណាចនៃពាក្យដែលខុសពីព្រះសូត្រនោះពិតៗ, ត្រូវសកវាទីសួរទៀត កាលបើមានសេចក្ដីសម្គាល់ថា "មនុស្សធ្វើកម្មទុក ព្រោះការកើតឡើងក្នុងទេវលោក ទើបមនុស្សនោះ មិនបានសោយ អ្នកណាធ្វើកម្មណាទុក, អ្នកដទៃ សោយក៏ទេ ព្រោះហេតុដូច្នោះ ទើបបុគ្គលនោះមិនមែនជាអ្នកសោយ ព្រោះជាអ្នកធ្វើ ទាំងបុគ្គលដទៃ ក៏មិនបានសោយដែរ" ដូច្នេះ ទើបឆ្លើយតប ។ ពាក្យនោះ ត្រឹមតែជាលទ្ធិប៉ុណ្ណោះ ។ ត្រូវសកវាទីសួរដោយអំណាចនៃបញ្ហានោះ របស់អ្នកមានវាទៈយ៉ាងនេះថា **"ក៏សុខទុក្ខដែលមិនមែនជាការធ្វើរបស់ខ្លួន, មិនមែនជាការធ្វើរបស់អ្នកដទៃកើតឡើងដោយប្រាសចាកហេតុរមែងប្រាកដឬ ?"** បរវាទីឆ្លើយបដិសេធទៀត ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបខ្លឹមសារក្នុងមិស្សកន័យនេះ ចាប់ផ្ដើមអំពីមុនមក ដោយន័យនេះចុះ ។ ពិតណាស់ អ្នកមានវាទៈថា "បុគ្គលមាននេះ រមែងប្រាថ្នាបុគ្គលអ្នកធ្វើកម្មទាំងឡាយផង បុគ្គលអ្នក

សោយផង ព្រោះហេតុនោះ សេចក្ដីនេះ ទើបប្រាកដយ៉ាងនេះថា "បុគ្គលណា ជាអ្នកធ្វើកម្ម បុគ្គលនោះប៉ុណ្ណោះ គប្បីជាអ្នកសោយ, ឬអ្នកផ្សេងសោយ ឬថា ទោះបីទាំងពីរជាអ្នកសោយ, ឬក៏ទោះបីទាំងពីរ មិនគប្បីជាអ្នកសោយទេ" ដូច្នេះ ។ សកវាទីសួរប្រកបដោយពាក្យសាកសួរបញ្ហាដែលប្រាកដយ៉ាងនេះឯង ហើយទើបពោលដល់បញ្ហាដែលគួរសួរ សូម្បីទាំង ៤ យ៉ាង មានពាក្យថា មិនមែនបុគ្គលនោះទេ ដែលជាអ្នកធ្វើជាដើម ។ ពាក្យដែលនៅសល់ មានប្រការដូចដែលពោលមកហើយនុ៎ះឯង ។ ក៏ក្នុងទីបំផុត បានសួរបញ្ហាទាំង ៤ រួមគ្នា ។ ក្នុងបញ្ហានោះ ការបដិសេធ ការឆ្លើយតប និងការដល់ (ដាក់) ទោស មានពាក្យថា ***"នឹងធ្វើដោយខ្លួនឯង"*** ជាដើម បណ្ឌិតគប្បីជ្រាបដោយន័យមុននុ៎ះចុះ ។ ចំណែកខាងមុខនេះ ន័យដែលពោលហើយក្នុងកាលក្រោយ មិនបានពោលពាក្យថា ***"កម្មល្អ និងអាក្រក់ លោកសម្ដែងបញ្ហាដែលគួរកំណត់ទុក"*** ជាដើម មានតែកម្មប៉ុណ្ណោះ ។ បណ្ឌិតគប្បីជ្រាបខ្លឹមសារនៃធម៌ទាំងឡាយនោះ តាមន័យដែលពោលហើយក្នុងពេលក្រោយនុ៎ះឯង៕

## ចប់បុរិសការានុយោគ

ពាក្យថា ***"ទោះបីកល្យាណវគ្គ"*** ដូច្នេះ ជាឈ្មោះរបស់បុរិស-ការានុយោគនេះឯង៕

# ១៤.អភិញ្ញានុយោគ

## ការសាកសួរដល់អ្នកបានអភិញ្ញា

ខាងមុខបន្ទាប់អំពីនេះទៅ ជាការជម្រះព្រះអរហន្តដោយអំណាចនៃពាក្យសាកសួរដល់អ្នកបានអភិញ្ញាជាដើម ។ ក្នុងបញ្ហានោះ កាលសកវាទីឆ្លើយតបដោយពាក្យថា **“មែនហើយ”** បរវាទីអ្នកមានសេចក្ដីសម្គាល់ថា “បុគ្គលអ្នកសម្រេចគុណវិសេសមានឫទ្ធិជាដើម មិនមានក្នុងអនិន្ទ្រិយពទ្ធរូបខាងក្រៅទេ, មានតែខាងក្នុងបុគ្គល ព្រោះហេតុដូច្នោះ គប្បីមានបុគ្គលអ្នកឲ្យឫទ្ធិជាដើម កើតឡើង” ទើបពោលពាក្យជាដើមថា **“មានបុគ្គលពួកខ្លះដែលសម្ដែងឫទ្ធិបាន មិនមែនឬ ?”** ពាក្យទាំងអស់នោះ មានខ្លឹមសារដោយងាយស្រួលហើយ ៕

ចប់អភិញ្ញានុយោគ

................

# ១៥.ញាតកានុយោគ ការសាកសួរដល់ពួកញាតិ

ឥឡូវនេះ ពាក្យថា **“ មាតា ”** ជាដើម ជាការសាកសួរដល់ពួកញាតិ ។ ពាក្យថា **“ក្សត្រ”** ជាដើម ជាការសាកសួរដល់ជាតិ ។ ពាក្យថា **“គ្រហស្ថ និងបព្វជិត”** ជាការសាកសួរដល់ឧបដិបត្តិ ។ ពាក្យថា **“ទេវតា និងមនុស្ស”** ជាការសាកសួរដល់ឧប្បត្តិ ។ ពាក្យថា **“សោតាបន្ន”**

ជាដើម ជាការសាកសួរដល់បដិវេធ ។ សេចក្ដីនេះ លោកពោលថា ជាការសាកសួរដល់ព្រះអរិយៈខ្លះ ។ ពាក្យទាំងអស់នោះ មានអត្ថងាយស្រួលហើយ ។

ក្នុងពាក្យថា ***“ជាព្រះអរហន្តហើយ ត្រឡប់មិនជាព្រះអរហន្ត”*** នេះ លោកមិនពោលសួរទេ ព្រោះជាមោឃបញ្ហា ។ ពាក្យថា ***“គូនៃបុរសមាន ៤ គូ”*** ជាដើម ជាការសាកសួរដល់ព្រះសង្ឃ, ឯការសាកសួរនោះក៏មានខ្លឹមសារងាយស្រួលដូចគ្នា ។ ពាក្យថា ***“សង្ខត:”*** ជាដើម ជាការសាកសួរដល់សេចក្ដីនៃសច្ចិកត្ថ ។

បណ្ដាពាក្យទាំងនោះ ពាក្យថា ***“ចំណែកទី ៣ ដទៃទៀត វៀរលែងតែសង្ខត: និងអសង្ខត:ចេញមានឬ ?”*** ជាពាក្យសួររបស់សកវាទី, ពាក្យបដិសេធថា ***“អ្នកមិនគួរពោលយ៉ាងនេះទេ”*** ជារបស់បរវាទី ព្រោះមិនមានសច្ចិកត្ថដូច្នោះឡើយ ។ ពេលត្រូវសកវាទីសួរបញ្ជាក់ទៀត បរវាទីក៏ឆ្លើយតបថា ***“មែន ចំណែកបំផុតទី ៣ មាន ដោយសំដៅយកបុគ្គលជាចំណែកបំផុតទី ៣”*** ។ ទោះបីក្នុងបញ្ហាថា ***“បុគ្គល ក៏ដទៃឬ ?”*** ការបដិសេធ ជារបស់បរវាទីនោះៗ ព្រោះមិនប្រាថ្នាយកបុគ្គលដទៃក្រៅអំពីសង្ខតក្ខន្ធទាំងឡាយ ។ ពាក្យថា ***“ខន្ធដែលជាសង្ខត:”*** ជាដើម

*ជាពាក្យដែលសកវាទីសម្តែងសង្ខតៈ និងអសង្ខតៈទាំងឡាយទុកដោយសង្ខេប ដើម្បីសួរសេចក្តីយ៉ាងដទៃនៃបុគ្គល ។ ពាក្យសួរថា* ***"រូបជាសង្ខតៈ"*** *ជាដើម ជាពាក្យដែលសកវាទីសម្តែងខន្ធទាំងឡាយដោយវិភាគ ហើយពោលសួរសេចក្តីជាមនុស្សម្យ៉ាងៗ ជាមួយបុគ្គល ។ ពាក្យសួរថា* ***"ការកើតឡើងនៃបុគ្គល"*** *ដូច្នេះ ជាពាក្យសួររបស់សកវាទី, ពាក្យឆ្លើយតបថា* ***"មែន"*** *ជារបស់បរវាទី ដោយអំណាចនៃព្រះសូត្រ ដែលលោកពោលទុកក្នុងទីទាំងឡាយ មានពាក្យថា* ***"សត្វទាំងឡាយមានការកើតឡើងជាធម្មតា មានការចាស់ជាធម្មតា"*** *។ ម្យ៉ាងទៀត ពេលកំពុងតាំងនៅ ក៏មានសេចក្តីស្លាប់ជាធម្មតា, តែបរវាទីនោះ រមែងមិនប្រាថ្នានូវភាវៈនៃបុគ្គលជាសង្ខតធម៌ទេ, ព្រោះហេតុដូច្នោះ ទើបបដិសេធ ។ ត្រូវសកវាទីសួរដោយន័យជាដើមទៀតថា* ***"ការកើតឡើងនៃបុគ្គលរមែងប្រាកដឬ ?"*** *ក៏ឆ្លើយតបដោយពាក្យថា "ក៏ឈ្មោះថា ការកើតឡើងនៃបុគ្គលជាដើមនោះ" រមែងមិនគួរ ព្រោះមានព្រះបាលីថា "ទុក្ខប៉ុណ្ណោះរមែងកើតឡើង, ទុក្ខប៉ុណ្ណោះ រមែងតាំងនៅផង រមែងរលត់ទៅផង ក្រៅអំពីទុក្ខ មិនមានអ្វីកើតទេ, ក្រៅអំពីទុក្ខ មិនមានអ្វីរលត់ឡើយ" ។*

*ពាក្យសួរថា* ***"បុគ្គលបរិនិព្វានហើយ គង់មាននៅក្នុងព្រះនិព្វានឬ ?"***

ក្នុងសេចក្ដីនេះ លោកហៅព្រះនិព្វានថា **“អត្ថំ = ធម៌ដែលរកទីតាំងមិនបាន”** ។ ក្នុងបញ្ហានោះ សកវាទីសួរថា ***“បុគ្គលមាននៅក្នុងព្រះនិព្វានឬ ?”*** អធិប្បាយថា បុគ្គលឈ្មោះថា ***ទៀង*** ព្រោះបុគ្គលនោះ មាននៅក្នុងព្រះនិព្វាន, ឈ្មោះថា ***ដាច់សូន្យ*** ព្រោះបុគ្គលនោះ មិនមាននៅក្នុងព្រះនិព្វាន, បរវាទីពេល មិនប្រាថ្នាពាក្យថា ***“បុគ្គលទៀង និងដាច់សូន្យ សូម្បីទាំង ២ នោះ”*** ទើបបដិសេធថា ***“ មិនគប្បីពោលយ៉ាងនេះទេ ”*** ៕

ចប់ញាតកានុយោគ

## ១៦-១៩.បកិណ្ណកៈ (ឬកថំនិស្សាយបញ្ហាធិ) បញ្ហាអាស្រ័យភពជាដើម

ក្នុងបញ្ហាអាស្រ័យភព ពាក្យថា ***“ភព”*** បានដល់ ឧប្បត្តិភព បានដល់ ភព គឺការកើត ។ ក្នុងបញ្ហារបស់អ្នកសោយវេទនា អធិប្បាយថា ព្រះយោគាវចរអ្នកសោយនូវវេទនា អ្នកមានវេទនាដែលកំណត់ហើយពិតរមែងដឹងច្បាស់, ចំណែកពាលបុថុជ្ជនរមែងមិនដឹងច្បាស់ទេ ។ បញ្ហានេះ ពាក្យថា **“ កាយានុបស្សនា ”** ជាដើម មានសេចក្ដីងាយស្រួលទាំងអស់ ក្នុងព្រះពុទ្ធដីកាដើមថា ***“មោឃរាជ ចូរជាអ្នកមានសតិគ្រប់ពេល ឃើញលោកដោយភាពជារបស់សូន្យ”*** ជាដើម អធិប្បាយថា ចូរពិចារណាលោក

***គឺខន្ធ*** *ដោយអំណាចនៃភាពជារបស់ទទេចាកសត្វ ។*

*ពាក្យថា* ***"បុគ្គលដឹងឬ ?"*** *ជាពាក្យសួររបស់សកវាទី, ពិតណាស់ លទ្ធិរបស់បរវាទីថា អ្នកណារមែងពិចារណាដោយគាថា ថា* ***"អ្នកចូរពិចារណាមើលលោកដោយភាពជារបស់ទទេ"*** *ដូច្នេះ អ្នកនោះ ជាបុគ្គល ព្រោះហេតុដូច្នោះ ទើបសកវាទីសួរបញ្ហានោះៗ ឯង ។*

*ពាក្យថា* ***"រួមជាមួយរូប"*** *អធិប្បាយថា រួមជាមួយរូបកាយ, មិនមែនជាអ្នកអាស្រ័យរូបកាយនោះទេ ។ ព្រោះការកំណត់ដឹងរូបនេះដោយអំណាចនៃបញ្ចវោការភូមិ ទើបសកវាទីសួរថា* ***"ជីវៈក៏យ៉ាងនោះ"*** *ដូច្នេះទៀត, បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសចាកព្រះសូត្រ ។ ពាក្យថា* ***"វៀរចាករូប"*** *សេចក្ដីថា ព្រោះតាមដឹងរូបនេះមិនបានដោយអំណាចនៃចតុវោការភូមិ, ទើបសកវាទីសួរទៀតថា* ***"ជីវៈជាយ៉ាងដទៃ"*** *ដូច្នេះ, ក៏បដិសេធ ព្រោះខ្លាចខុសចាកព្រះសូត្រ ។ ពាក្យថា* ***"នៅផ្នែកខាងក្នុងផង ចេញទៅផ្នែកខាងក្រៅផង"*** *នេះ ជាលក្ខណៈពាក្យពេចន៍របស់សកវាទីពោលខាងក្រោយអំពីពាក្យថា* ***"រួមជាមួយនឹងរូបឬវៀរចាករូប"*** *។*

*បណ្ដាពាក្យទាំងនោះ ពាក្យថា* ***"នៅផ្នែកខាងក្នុង"*** *បានដល់ នៅផ្នែកខាងក្នុងនៃរូប អធិប្បាយថា មិនចេញទៅខាងណោះ ខាងណោះ ជា*

សភាពតាំងនៅដោយអំណាចនៃរូបបរិច្ឆេទនោះឯង ។ ពាក្យថា **“ចេញទៅ”** បានដល់ ការឈានកន្លងរូបបរិច្ឆេទ អធិប្បាយថា មិនបានអាស្រ័យរូប ។ ពាក្យថា **“អនត្តា”** បានដល់ វៀរចាកខ្លួន វៀរចាកជីវៈ វៀរចាកបុគ្គល អធិប្បាយថា សូម្បីធម៌នីមួយៗ ឈ្មោះថា ជាបុគ្គលរមែងមិនមាន ។ បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងអដ្ឋកថា ដែលមានមកក្នុងព្រះសូត្រទាំងពួង ដោយន័យដែលពោលហើយនុ៎ះឯង មានប្រការដូច្នេះ ។ ឯខ្ញុំសំដៅយកខ្លឹមសារនុ៎ះ នឹងពោលពាក្យដែលជាភាសិតនុ៎ះដូចគ្នាដែរ ។

ពាក្យជាដើមថា **“ព្រះមានព្រះភាគទ្រង់ត្រាស់ថា ថ្នាំងទឹកដោះថ្លា ឬ ?”** ជាពាក្យដែលសកវាទីនាំមកដើម្បីសម្ដែងថា “ទេសនាទាំងពួងដូចគ្នា បណ្ឌិតមិនគប្បីកាន់យកតែសេចក្ដីដោយអំណាចនៃពាក្យ ដែលព្រះមាន-ព្រះភាគទ្រង់ត្រាស់ទុកប៉ុណ្ណោះ ដូចឆ្នាំងជាវិការៈនៃមាសដែលគេយកមាសមកធ្វើ ប្រជាជនទាំងឡាយរមែងហៅថា ឆ្នាំងមាស យ៉ាងណា ក៏ឈ្មោះថា ឆ្នាំងទឹកដោះថ្លាជាវិការៈនៃទឹកដោះថ្លា ដែលគេយកទឹកដោះថ្លា មកធ្វើ យ៉ាងនោះក៏ទេ” ក្នុងពាក្យនេះ គប្បីជ្រាបខ្លឹមសារយ៉ាងនេះថា ក៏ទឹកដោះថ្លា ដែលបុគ្គលណាដាក់ទៅក្នុងឆ្នាំងណា, ឆ្នាំងនោះ ទើបបានឈ្មោះថា ឆ្នាំងទឹកដោះយ៉ាងនោះ ។ សូម្បីក្នុងពាក្យថា **“ឆ្នាំងប្រេង”** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ដូចយ៉ាងថា ព្រះនិព្វានជាធម្មជាតិទៀងជានិច្ច យ៉ាងណា, ភគ្គ ប្ចុយាគូ រមែងជាធម្មជាតិទៀងជានិច្ចយ៉ាងនោះក៏ទេដែរ,

ក្នុងសេចក្ដីនេះ គប្បីជ្រាបថា **និច្ចភត្ត** គឺភត្តដែលជាប់ជានិច្ច ឬសំដៅដល់ភត្តដែលគេថ្វាយប្រចាំជានិច្ច ។ **ធុវយាគូ** គឺបបរដែលជាប់ជានិច្ច លោកហៅដោយពាក្យដែលជាបញ្ញត្តិ ដូចជាពាក្យថា "ក៏ពួកយើងទាំងឡាយមិនកំណត់កាលថ្វាយនិច្ចភត្ត និងធុវយាគូរាល់ៗ ថ្ងៃទេ" ។

គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងពាក្យថា ***"មានបុគ្គលអ្នកប្រតិបត្តិហើយដើម្បីប្រយោជន៍ស្រោចស្រង់ដល់ខ្លួន"*** ជាដើម ធម៌ទាំងឡាយមានរូបជាដើម ដោយអំណាចនៃបច្ចត្តលក្ខណៈ គឺលក្ខណៈដែលមានចំពោះខ្លួន និងសាមញ្ញលក្ខណៈ យ៉ាងណា, បុគ្គលយ៉ាងនោះ ក៏ទេ, ក៏កាលបើធម៌ទាំងឡាយមានរូបធម៌ជាដើម មានការហៅថា យ៉ាងនេះជាឈ្មោះ យ៉ាងនេះជាគោត្រជាដើម ក៏រមែងមាន យ៉ាងនោះ, ក្នុងសេចក្ដីនេះ គប្បីជ្រាបខ្លឹមសារយ៉ាងនេះថា ឈ្មោះថា មានបុគ្គល ព្រោះជាវោហារសម្រាប់លោក ព្រោះការសន្មតសម្រាប់លោក ព្រោះជាភាសាសម្រាប់លោកនេះ ដោយប្រការដូច្នេះ, សមពិតដូចដែលព្រះសាស្ដាត្រាស់ទុកថា ***"ធម៌ទាំងឡាយនេះឯង គឺចិត្តជាសាមញ្ញាសម្រាប់លោក ជាភាសាសម្រាប់លោក ជាវោហារសម្រាប់លោក ជាបញ្ញត្តិសម្រាប់លោក"*** ត្រង់នេះ លោកអធិប្បាយថា ***"ក៏ធម៌ទាំងឡាយ មានរូបធម៌ជាដើម សូម្បីវៀរនូវការសន្មតសម្រាប់លោក ក៏នៅឈ្មោះថា មាន ព្រោះសភាវៈឱ្យដឹងបានដោយអំណាចនៃបច្ចត្តលក្ខណៈ***

*និងសាមញ្ញលក្ខណៈ"* ៕

---

## សម្មតិកថា និងបរមត្ថកថា

*ម្យ៉ាងទៀត* **កថា** *គឺពុទ្ធដីការបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ មានពីរ គឺសម្មតិកថា និងបរមត្ថកថា ក្នុងកថាទាំងពីរនោះ ពាក្យថា* ***"សត្វ បុគ្គល ទេវតា និងព្រហ្ម"*** *ជាដើម ឈ្មោះថា* **សម្មតិកថា**, *ពាក្យថា* **"អនិច្ចំ ទុក្ខំ អនត្តា ខន្ធ ធាតុ អាយតនៈ សតិបដ្ឋាន** *និង* **សម្មប្បធាន"** *ជាដើម ឈ្មោះថា* **បរមត្ថកថា** *។ បណ្ដាកថាទាំងពីរនោះ បុគ្គលណា កាលបើ ពោលពាក្យថា សត្វ ។ល។ ឬព្រហ្មជាដើម ដែលព្រះអង្គទ្រង់ត្រាស់ ហើយដោយទេសនាដែលជាសម្មតិ រមែងអាចដើម្បីត្រាស់ដឹងនូវធម៌ ដើម្បី ចាក់ធ្លុះ ដើម្បីចេញចាកសំសារវដ្ដ ដើម្បីកាន់យកជ័យ គឺព្រះអរហត្តបាន ព្រះមានព្រះភាគរមែងត្រាស់ដល់ពាក្យថា សត្វ ឬបុគ្គល ឬថាបុរស ឬក៏ ព្រហ្ម ចាប់ផ្ដើមពីដើមមែនពិត សម្រាប់អ្នកនោះ ។ ចំណែកអ្នកណាស្ដាប់ ពាក្យថា* **"អនិច្ចំ ទុក្ខំ"** *ជាដើម យ៉ាងណាមួយ ដោយបរមត្ថទេសនា ហើយ ក៏អាចដើម្បីត្រាស់ដឹង ដើម្បីចាក់ធ្លុះ ដើម្បីចេញចាកសំសារ ដើម្បី កាន់យកជ័យ គឺព្រះអរហត្តបាន ព្រះមានព្រះភាគរមែងត្រាស់ពាក្យយ៉ាង ណាមួយ ក្នុងពាក្យថា* **"អនិច្ចំ"** *ជាដើម ដើម្បីអ្នកនោះឯង ។ ដោយ*

ទំនងដូចគ្នានេះ ព្រះមានព្រះភាគរមែងមិនត្រាស់បរមត្ថកថាជាមុនទេ សម្រាប់សត្វដែលនឹងត្រាស់ដឹងដោយសម្មតិកថា, តែព្រោះការត្រាស់ដឹងនៃសត្វដោយសម្មតិកថា ទើបព្រះអង្គទ្រង់ត្រាស់បរមត្ថកថាក្នុងចំណែកខាងក្រោយ ។ ពេលសត្វអ្នកនឹងត្រាស់ដឹង ដោយបរមត្ថកថាបាន ព្រះអង្គក៏មិនត្រាស់សម្មតិកថាមុនទេ, ព្រោះការត្រាស់ដឹងរបស់សត្វទាំងឡាយ អាស្រ័យបរមត្ថកថាបាន ទើបព្រះអង្គទ្រង់ត្រាស់សម្មតិកថាមុនមែនពិតហើយ ទើបត្រាស់បរមត្ថកថាក្នុងចំណែកខាងក្រោយ ។ ម្យ៉ាងទៀត ដោយប្រក្រតីព្រះអង្គទ្រង់ត្រាស់ សម្មតិកថាជាមុន រួចហើយទើបត្រាស់បរមត្ថកថាខាងក្រោយ ព្រោះជាការទេសនាដែលធ្វើបានដោយងាយ ព្រោះហេតុដូច្នោះបានជាព្រះពុទ្ធទាំងឡាយ ទ្រង់សម្តែងសម្មតិកថាមុនហើយ ក៏ត្រាស់បរមត្ថកថាជាខាងក្រោយ ។ ព្រះពុទ្ធទាំងឡាយអង្គនោះៗ សូម្បីត្រាស់នូវសម្មតិកថា ឈ្មោះថា រមែងត្រាស់នូវសច្ចៈជាសភាវៈនោះឯង និងឈ្មោះថា ជាអ្នកត្រាស់មិនពិត ក៏មិនមែនឡើយ, សូម្បីពេលត្រាស់បរមត្ថកថា ក៏ឈ្មោះថា រមែងត្រាស់នូវសច្ចៈនូវសភាវៈនោះដែរ និងឈ្មោះថា ជាអ្នកពោលពាក្យមិនពិត ក៏មិនមែនទេ, ពិតណាស់ បណ្ឌិតគប្បីជ្រាបសេចក្តីនេះថា ៖

**ទុវេ សច្ចានិ អក្ខាសិ សម្ពុទ្ធោ វទតំ វរោ**
**សម្មុតឹ បរមត្ថញ្ច តតិយំ នូបលព្ភតិ ។**

*បណ្ដាអ្នកពោលកថាទាំងឡាយ ព្រះសម្ពុទ្ធ*
*ដ៏ប្រសើរ បានត្រាស់ប្រាប់ហើយនូវសច្ចៈ ២*
*គឺសម្មតិសច្ចៈ និងបរមត្ថសច្ចៈ, មិនត្រាស់ប្រាប់*
*សច្ចៈទី ៣ ថា ជាសភាវៈដែលដឹងបានទេ ។*

*បណ្ដាសច្ចៈទាំងពីរនោះ សម្មតិសច្ចៈជាពាក្យសម្រាប់កំណត់ និងជាហេតុនៃការសម្មតិសម្រាប់លោក, ចំណែកបរមត្ថសច្ច ជាពាក្យបរមត្ថជាលក្ខណៈនៃធម៌ទាំងឡាយ ។ ន័យមួយទៀត ទេសនារបស់ព្រះមានព្រះភាគ មានពីរ គឺជាបរមត្ថទេសនា ដោយអំណាចនៃពាក្យថា* **“ខន្ធ”** *ជាដើម, និងជាសម្មតិទេសនាដោយពាក្យថា* ***“ផ្ទាំងទឹកដោះថ្លា”*** *ជាដើម ។ ព្រះមានព្រះភាគទ្រង់មិនបានជម្រះពាក្យបញ្ញត្តិចេញទៅទេ ព្រោះហេតុណា, ព្រោះហេតុនោះ បណ្ឌិតមិនគប្បីធ្វើសេចក្ដីប្រកាន់ពាក្យត្រឹមតែថា* ***“មានបុគ្គល”*** *ដូច្នេះឡើយ ។ ពិតណាស់ ព្រះបរមសាស្ដាទ្រង់មិនបានលះបញ្ញត្តិ ហើយប្រកាសបរមត្ថ, និងទ្រង់មិនបានជម្រះពាក្យបញ្ញត្តិ ព្រោះហេតុដូច្នោះ បណ្ឌិតឯទៀតៗ ពេលប្រកាសបរមត្ថ ក៏មិនគប្បីជម្រះពាក្យបញ្ញត្តិដូច្នោះទេ ។ ពាក្យក្នុងទីទាំងពួង មានអត្ថងាយស្រួលទាំងអស់ ៕*

ចប់បញ្ហាអាស្រ័យភពជាដើម

## ២.បរិហានិកថា សម្តែងអំពីការសាបសូន្យ

### ១.វាទយុត្តិបរិហានិ ការសាបសូន្យនៃការប្រកបវាទៈ

*ឥឡូវនេះ ឈ្មោះថា រឿងភាពសាបសូន្យ ៖*

*ក៏និកាយសមិតិយៈ វជ្ជីបុត្តកៈ សព្វត្ថិកវាទី និងមហាសង្ឃិកៈពួកខ្លះ អាស្រ័យព្រះសូត្រទាំងឡាយថា* “**បរិហានិធម្មោ អបរិហានិធម្មោ ទ្វេមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ បញ្ចិមេ ភិក្ខវេ ធម្មា សមយវិមុត្តស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ** = *ម្នាលភិក្ខុទាំងឡាយ ធម៌ ២ យ៉ាងនេះ គឺបរិហានិធម៌ និងអបរិហានិធម៌ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យជុំវិញ ដល់ភិក្ខុដែលជាសេក្ខបុគ្គល, ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ នេះ (គឺសេចក្តីត្រេកអរក្នុងការងារ, សេចក្តីត្រេកអរក្នុងការសន្ទនា, សេចក្តីត្រេកអរក្នុងការដេកលក់, សេចក្តីត្រេកអរក្នុងការនៅប្រឡូកប្រឡល់, សេចក្តីរួចផុតនៃចិត្តមានយ៉ាងណា មិនពិចារណាយ៉ាងនោះ), រមែងប្រព្រឹត្តទៅព្រមដើម្បីសេចក្តីវិនាសសាបសូន្យជុំវិញ ដល់ភិក្ខុដែលជាសមយវិមុត្តបុគ្គល” ដោយប្រការដូច្នេះជាដើម រមែងប្រាថ្នាសេចក្តីសាបសូន្យជុំវិញ ទោះបីដល់ព្រះអរហន្ត ព្រោះហេតុដូច្នោះ ការសាបសូន្យទាំងនោះ ឬផ្សេងពីនោះ ចូរលើកទុកសិនចុះ, លទ្ធិ គឺសេចក្តីប្រកាន់ខុសនេះ រមែងមានដល់ជនពួកណា ដើម្បីទម្លាយលទ្ធិនៃជនទាំងនោះ ទើបសកវាទីសួរបរវាទីថា* ***“ព្រះអរហន្តសាបសូន្យចាកភាពជាព្រះអរហន្ត***

***ឬ ?”*** *ក្នុងពាក្យសួរទាំងនោះ ពាក្យថា* ***“សេចក្ដីសាបសូន្យ”*** *បានដល់សេចក្ដីសាបសូន្យពីរយ៉ាង គឺ* **បត្តបរិហានិ** *= សេចក្ដីសាបសូន្យចាកធម៌ដែលធ្លាប់ចាក់ធុះហើយ និង* **អប្បត្តបរិហានិ** *= សេចក្ដីសាបសូន្យចាកធម៌ដែលមិនបានចាក់ធុះ ។*

*ក្នុងសេចក្ដីសាបសូន្យទាំងនោះ ព្រះគោធិកៈរមែងសាបសូន្យចាកចេតោវិមុត្តិ ដែលប្រព្រឹត្តអាក្រក់គ្រានោះ សូម្បីលើកទីពីរនេះ ក៏ហៅថា* **បត្តបរិហានិ** *គឺសាបសូន្យចាកធម៌ដែលធ្លាប់សម្រេចហើយ ។ កាលជនទាំងឡាយអ្នកមានសេចក្ដីត្រូវការវត្ថុទៅ សេចក្ដីត្រូវការនោះ រមែងវិនាសសាបសូន្យទៅ នេះហៅថា* **អប្បត្តបរិហានិ** *គឺសេចក្ដីសាបសូន្យចាកធម៌ដែលខ្លួនមិនទាន់សម្រេច គឺនៅមិនធ្លាប់បានសម្រេចមក ។ ក្នុងសេចក្ដីសាបសូន្យទាំងពីរនោះ ក្នុងទីនេះ លោកបំណងយកសេចក្ដីសាបសូន្យចាកធម៌ដែលធ្លាប់សម្រេចហើយ គឺ* **បត្តបរិហានិ** *។*

*ក៏ពាក្យឆ្លើយតបរបស់បរវាទីថា* ***“មែន”*** *ព្រោះសំដៅយកសេចក្ដីសាបសូន្យចាកធម៌ដែលសម្រេចហើយនេះ, ឯបរវាទីនោះ រមែងប្រាថ្នាយកឈ្មោះសេចក្ដីសាបសូន្យចាកធម៌ដែលសម្រេចហើយនេះ អំពីលោកិយ-សមាបត្តិក្នុងលទ្ធិរបស់ខ្លួនប៉ុណ្ណោះ, មិនប្រាថ្នាយកសេចក្ដីសាបសូន្យចាកសាមញ្ញផលទាំងឡាយ មានអរហត្តផលជាដើមទេ, ទោះបីក្នុងលទ្ធិដទៃ លោក*

ក៏មិនប្រាថ្នាយកសេចក្ដីសាបសូន្យនោះ ដល់បុគ្គលទាំងពួង ក្នុងសាមញ្ញផលទាំងពួង ក្នុងភពទាំងពួង ក្នុងកាលទាំងពួង ដែលលទ្ធិនោះ ក៏ត្រឹមតែជាលទ្ធិរបស់លោកប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ ដើម្បីទម្លាយអន្ទាក់សំណាញ់គឺលទ្ធិដែលប្រកាន់ខុសទាំងពួង ទើបបញ្ហារបស់សកវាទី កើតឡើងដោយន័យជាដើមថា ***“ព្រះអរហន្តសាបសូន្យចាកអរហត្តផលបាន ក្នុងទីទាំងពួង ឬ ?”*** ទៀត ។ ក្នុងបញ្ហានោះ បរវាទីមិនប្រាថ្នាយកសេចក្ដីសាបសូន្យចាកអរហត្តផលរបស់ព្រះអរហន្តអ្នកសាបសូន្យ មកដោយលំដាប់ហើយក៏ឈប់នៅក្នុងសោតាបត្តិផល រមែងប្រាថ្នាសេចក្ដីសាបសូន្យរបស់ព្រះអរិយៈអ្នកតាំងនៅក្នុងផលទាំងឡាយ ចំណែកខាងលើប៉ុណ្ណោះ ។ មួយទៀតមិនប្រាថ្នាយកសេចក្ដីសាបសូន្យ របស់ព្រះអរហន្តអ្នកតាំងនៅក្នុងអរូបភពទាំងឡាយ, ប៉ុន្តែ រមែងប្រាថ្នាយកសេចក្ដីសាបសូន្យរបស់ព្រះអរហន្តដែលតាំងនៅក្នុងកាមភព ព្រោះសេចក្ដីនៃធម៌ទាំងឡាយដែលជាទីតាំងនៃសេចក្ដីសាបសូន្យ មានសេចក្ដីត្រេកអរក្នុងការផ្សារជាដើម ព្រោះហេតុដូច្នោះទើបត្រូវសកវាទីសួរថា ***“ព្រះអរហន្តសាបសូន្យចាក... ក្នុងភពទាំងពួង ឬ ?”*** លោកក៏បដិសេធ, លុះត្រូវសកវាទីសួរបញ្ឆោកទៀត លោកក៏ឆ្លើយតប ព្រោះមិនមានសេចក្ដីសាបសូន្យយ៉ាងនោះទេ, លំដាប់នោះទើបសកវាទីសួរបញ្ហា ដែលគួរសួរក្នុងបញ្ហាទីពីរ ដែលជាលទ្ធិកើតឡើងដល់បរវាទីនោះ យ៉ាងនេះថា ***“សូម្បីព្រះអរហន្ត ក៏រមែងមិនសាបសូន្យ***

***ចាកផល ៤ ឡើយ"*** *បរវាទីពេលមិនឃើញការដាក់លាក់នៃភាវៈដែលមិនគួរជាសេដ្ឋី ទើបឆ្លើយតប ត្រូវសកវាទីសួរបញ្ឈាក់ដល់ភាពជាអ្នកគួរនឹងសាបសូន្យចាកផលទាំង ៤ របស់ព្រះអរហន្ត បរវាទីដែលតាំងនៅក្នុងលទ្ធិ កាន់យកខ្លឹមសារដោយមិនពិចារណាពាក្យពេចន៍ថា* ***"ជាអ្នកទៀងនឹងត្រាស់ដឹងខាងមុខ"*** *ដូច្នេះ ទើបបដិសេធ សំដៅយកសេចក្ដីមិនគួរដើម្បីនឹងសាបសូន្យចាកសោតាបត្តិផល ។ ក៏ពាក្យនោះ ត្រឹមតែជាលទ្ធិរបស់លោកប៉ុណ្ណោះ ។ ឈ្មោះថា* **ខានយុត្តិ** *គឺការប្រកបវាទៈ សម្រេចហើយដោយពាក្យមានប្រមាណប៉ុណ្ណោះឯង ៕*

## ២.អរិយបុគ្គលសំសន្ទនា

## ការផ្ទៀងផ្ទាត់ព្រះអរិយបុគ្គល

*ឥឡូវនេះ ជាការចាប់ផ្ដើមផ្ទៀងផ្ទាត់ព្រះអរិយបុគ្គល ៖*

*ក្នុងបញ្ហានោះ ជនពួកខ្លះ រមែងប្រាថ្នាសេចក្ដីសាបសូន្យរបស់ព្រះអរហន្តប៉ុណ្ណោះ, ពួកខ្លះ ប្រាថ្នាសេចក្ដីសាបសូន្យ សូម្បីដល់ព្រះអនាគាមី, ពួកខ្លះទៀត ប្រាថ្នាសេចក្ដីសាបសូន្យដល់ព្រះសកទាគាមីដែរ, ប៉ុន្តែ ជនទាំងនោះ រមែងប្រាថ្នាសេចក្ដីសាបសូន្យរបស់ព្រះសោតាបន្ននោះដូចគ្នា ។ ជនទាំងឡាយណា រមែងប្រាថ្នាសេចក្ដីសាបសូន្យរបស់ព្រះអរហន្ត ដែល*

*សាបសូន្យចាកភាពជាព្រះអរហន្ត ហើយតាំងនៅក្នុងភាវៈនៃព្រះអនាគាមី និងព្រះសកទាគាមីភូមិ, ប៉ុន្តែ មិនប្រាថ្នាសេចក្ដីសាបសូន្យរបស់ព្រះអនាគាមី និងព្រះសកទាគាមីក្រៅពីនេះ, សូម្បីជនទាំងនោះឯង រមែងមិនប្រាថ្នា សេចក្ដីសាបសូន្យរបស់ព្រះសោតាបន្ន សូម្បីក្នុងកាលទាំងពួង ព្រោះ ហេតុដូច្នោះ ទើបលោកធ្វើពាក្យសួរដោយគ្រឿងសំអាងសម្រាប់សេចក្ដី នីមួយៗ ទុកជាសម្គាល់ ។ ក្នុងបញ្ហាទាំងនោះ បណ្ឌិតគប្បីជ្រាបពាក្យ បដិសេធ ដោយអំណាចនៃលទ្ធិរបស់លោកទាំងនោះ ។ ក៏ក្នុងបញ្ហាថា* ***"ព្រះអនាគាមីរមែងសាបសូន្យចាកព្រះអនាគាមិផលឬ ?"*** *បរវាទីឆ្លើយ បដិសេធ ដោយអំណាចនៃជនអ្នកមិនប្រាថ្នាសេចក្ដីសាបសូន្យរបស់ព្រះ អនាគាមីទាំងនោះ ។ ក្នុងសេចក្ដីថា "ជនទាំងឡាយណា រមែងប្រាថ្នា សេចក្ដីសាបសូន្យរបស់ព្រះអនាគាមីជាប្រក្រតី ឬព្រះអនាគាមីសាបសូន្យ ចាកភាពជាព្រះអរហន្ត ហើយតាំងនៅក្នុងភាវៈនៃអនាគាមិភូមិ" នេះ ពាក្យ ឆ្លើយតបរបស់បរវាទីរមែងមាន ដោយអំណាចនៃជនទាំងនោះ នេះជា សេចក្ដីសំខាន់ ។ បណ្ឌិតគប្បីជ្រាបបេយ្យាល (។ល។) គឺគ្រឿងសំអាង សម្រាប់សេចក្ដីនីមួយៗ ទាំងអស់ នៃខ្លឹមសារដោយទំនងនៃបញ្ហានុ៎ះចុះ ។*

*ម្យ៉ាងទៀត ពាក្យណាដែលលោកពោលហើយក្នុងបញ្ហាថា* ***"បន្ទាប់ អំពីសោតាបត្តិផលទៅ លោកក៏ធ្វើឱ្យជាក់ច្បាស់នូវអរហត្តផលតែម្ដងឬ ?"***

នេះ ពាក្យនោះ លោកពោលសំអាងយកការកើតឡើងនៃព្រះអរហន្ត ព្រោះសេចក្ដីព្យាយាមទៀត របស់ព្រះអរហន្តអ្នកសាបសូន្យហើយ ។ បរវាទីឆ្លើយបដិសេធពាក្យនោះ ព្រោះមិនមានភាពជាព្រះអរហន្តក្នុងលំដាប់នៃសោតាបត្តិផល ។ ខាងមុខអំពីនេះ ដើម្បីប្រកបពាក្យជាដើមថា ***“ឈ្មោះថាសេចក្ដីសាបសូន្យនេះនឹងគប្បីមាន ព្រោះសេចក្ដីល្ងង់ខ្លៅរបស់អ្នកលះកិលេស ឬព្រោះការមិនត្រាស់ដឹងដោយមគ្គភាវនា”*** ជាដើម ឬសូម្បីមិនឃើញសច្ចធម៌ទាំងឡាយនេះ ដោយប្រការដូច្នេះជាដើម ទើបសកវាទីពោលថា ***“នរណាលះកិលេសបានច្រើនជាងគ្នា”*** ជាដើម ។ ពាក្យទាំងអស់នោះ ជាពាក្យអធិប្បាយងាយស្រួលទាំងអស់មែនពិត ។ ឯខ្លឹមសារក្នុងព្រះសូត្រទាំងឡាយ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងអដ្ឋកថាទាំងឡាយនុ៎ះចុះ ។

ក្នុងពាក្យថា ***“ព្រះអរហន្តជាសមយវិមុត្តិ សាបសូន្យចាកអរហត្តផលបាន”*** នេះ ជាលទ្ធិរបស់ពួកគេថា “ព្រះអរហន្តអ្នកមានឥន្ទ្រិយទន់ខ្សោយឈ្មោះថា ***សមយវិមុត្តបុគ្គល***, ព្រះអរហន្តអ្នកមានឥន្ទ្រិយចាស់ក្លា ឈ្មោះថា ***អសមយវិមុត្តបុគ្គល”*** ដូច្នេះ, ប៉ុន្តែ ក្នុងលទ្ធិសកវាទីដែលធ្វើការសន្និដ្ឋានទុកថា “អ្នកជាឈានលាភីមិនសម្រេចវសី ឈ្មោះថា ***សមយវិមុត្តបុគ្គល***, អ្នកជាឈានលាភីសម្រេចវសីហើយផង ព្រះអរិយបុគ្គលទាំងអស់ក្នុងវិមោក្ខដែលជាអរិយៈផង ឈ្មោះថា ***អសមយវិមុត្តបុគ្គល”*** ។ ក៏បរវាទីនោះ

កាន់យកលទ្ធិរបស់ខ្លួនពោលថា ***“ព្រះអរហន្តជាសមយវិមុត្តិរមែងសាបសូន្យ, ព្រះអរហន្តក្រៅពីនេះ មិនសាបសូន្យទេ”*** ពាក្យដែលនៅសល់ក្នុងទីនេះ មានខ្លឹមសារងាយស្រួលទាំងអស់ ៕

ចប់អរិយបុគ្គលសំសន្ទនា

## ៣.សុត្តសោធនា ការជម្រះព្រះសូត្រ

*ឥឡូវនេះ ជាការជម្រះព្រះសូត្រ ៖*

*ក្នុងពាក្យទាំងនោះ ពាក្យថា* ***“ខ្ពស់ និងទាប”*** *បានដល់* ***ភាពខ្ពស់ដោយភាពទាប*** *ព្រោះវៀរចាកប្រភេទដែលលើស និងខ្វះ ។ ពាក្យថា* **“បដិបទា”** *បានដល់ ការបដិបត្តិ ។ ពាក្យថា* ***“ដែលសមណៈប្រកាសហើយ”*** *បានដល់ សមណៈ គឺព្រះពុទ្ធជាម្ចាស់ឲ្យរុងរោចន៍ហើយ ។ ក៏បដិបទាងាយសម្រេចរួចផុតរហ័ស ឈ្មោះថា* ***ជាបដិបទាខ្ពស់,*** *បដិបទាលំបាកគ្រាស់ដឹងយឺតយូរ ឈ្មោះថា* ***បដិបទាទាប,*** *បដិបទាដែលនៅសល់ពីរក្រៅអំពីនេះ ជាបដិបទាខ្ពស់មួយ និងទាបមួយ ។ លោកពោលបដិបទាដំបូងប៉ុណ្ណោះថា បដិបទាខ្ពស់, ឯបដិបទាដែលនៅសល់ទាំង ៣ លោកពោលថា ជាបដិបទាទាប, អធិប្បាយថា ព្រះអរិយៈទាំងឡាយ រមែងទៅដល់ត្រើយ គឺព្រះនិព្វានបានពីរដង ដោយបដិបទាទាំងខ្ពស់ ទាំងទាបនោះៗ*

*ក៏មិនមែន គឺសំដៅសេចក្ដីថា មិនទៅព្រះនិព្វានពីរដង ដោយមគ្គមួយទេ ។ **សួរថា** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះកិលេសឯណា ដែលមគ្គណាលះបានហើយ, មិនគប្បីលះកិលេសទាំងនោះ ដោយមគ្គនោះទៀតឡើយ; លោករមែងសម្ដែងភាវៈនៃធម៌ គឺសេចក្ដីមិនសាបសូន្យដោយមគ្គនេះ ។ ពាក្យថា **"ត្រើយនេះ ដែលអ្នកបដិបត្តិនឹងបានដឹងតែម្ដង ក៏មិនមែន"** សេចក្ដីថា ត្រើយ គឺព្រះនិព្វាននេះ សូម្បីគួរដល់ការសម្រេចអស់ម្ដងក៏មិនមាន, **សួរថា** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមិនមានការលះកិលេសទាំងពួង ដោយមគ្គតែមួយ ។ លោកសម្ដែងភាពជាព្រះអរហន្តដោយមគ្គ ១ ប៉ុណ្ណោះ ។*

*ពាក្យថា **"បណ្ដាកិលេសវដ្ដៈដែលព្រះអរហន្តផ្ដាច់ហើយ នៅមានខ្លះដូចដែលនឹងត្រូវផ្ដាច់ទៀតឬ ?"** សេចក្ដីថា សកវាទីសួរថា ពេលកិលេសវដ្ដៈដាច់ហើយ ព្រះអរិយៈនឹងគប្បីផ្ដាច់កិលេសអ្វីៗ ទៀតមានឬ ? បរវាទីសំដៅយកព្រះអរហន្តដែលមានឥន្ទ្រិយចាស់ក្លា ទើបឆ្លើយបដិសេធ ។ ត្រូវសកវាទីសួរបន្ថែមទៀត សំដៅយកអ្នកមានឥន្ទ្រិយទន់ខ្សោយ ទើបឆ្លើយតបថា **"មែន"** ។ ទើបសកវាទីនាំព្រះសូត្រមក ហើយសម្ដែងភាពមិនមាននៃកិលេសអ្វីៗ ដែលព្រះអរហន្តនឹងត្រូវកាត់ផ្ដាច់តទៅទៀត ។*

*ក្នុងបញ្ហាថា ពាក្យថា* **"ឱឃបារសា** *= អន្លង់ទឹក និងអន្ទាក់"*

បានដល់ អន្ទង់ទឹក គឺកិលេស និងអន្ទាក់ គឺកិលេស ។ ពាក្យថា ***"ការត្រឡប់សាងសន្សំកិច្ចដែលធ្វើហើយ"*** បានដល់ ចម្រើនមគ្គដែលបានចម្រើនហើយថែមទៀត ។ សូម្បីពាក្យក្នុងទីនេះ បណ្ឌិតគប្បីជ្រាបពាក្យបដិសេធ និងពាក្យឆ្លើយតបដោយន័យដែលពោលមកហើយ ក្នុងកាលមុនន៉ុះចុះ ។

ពាក្យថា ***"រមែងប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីសាបសូន្យជុំវិញ"*** សេចក្តីថា ធម៌ ៥ យ៉ាង មានសេចក្តីត្រេកអរក្នុងការងារជាដើម ក្នុងព្រះសូត្រដែលបរវាទីនាំមកអាង រមែងប្រព្រឹត្តទៅព្រមដើម្បីសេចក្តីសាប-សូន្យចាកធម៌ ដែលនៅមិនទាន់សម្រេច និងដើម្បីសេចក្តីវិនាសសាបសូន្យចាកលោកិយសមាបត្តិ, ប៉ុន្តែសកវាទីនោះ មិនឃើញសេចក្តីសាបសូន្យនៃព្រះអរហន្តដែលសម្រេចហើយ ដោយហេតុនោះឯង ទើបសួរថា ***"ព្រះអរហន្តមានសេចក្តីត្រេកអរក្នុងការងារឬ ?"*** បរវាទីសំដៅយកព្រះអរហន្តដែលជាអសមយវិមុត្តបុគ្គល ទើបឆ្លើយបដិសេធ សំដៅយកព្រះអរហន្តក្រៅពីនេះ ទើបឆ្លើយតប ។ ម្យ៉ាងទៀត រមែងបដិសេធការងារដែលប្រព្រឹត្តទៅជាមួយកាមរាគៈ, រមែងឆ្លើយតបការងារដែលប្រព្រឹត្តទៅ ក្រៅអំពីកាមរាគៈ ។ ពេលត្រូវសកវាទីសួរដល់ព្រះអរហន្តមានរាគៈជាដើម ក៏មិនអាចឆ្លើយតបបាន ។

ពាក្យថា ***"ត្រូវអ្វីហ៊ុមពទ្ធទើបសាបសូន្យ"*** សេចក្តីថា កិលេសអ្វីៗ

គ្របសង្កត់ចិត្ត អធិប្បាយថា កិលេសជាគ្រឿងចង ឬកិលេសជាគ្រឿងលិចលង់ខាងក្នុង ។ សូម្បីក្នុងពាក្យសួរថា ***“ដោយអនុស័យកិលេស”*** បណ្ឌិតគប្បីជ្រាបពាក្យបដិសេធ និងពាក្យឆ្លើយតប ដោយអំណាចនៃព្រះអរិយៈអ្នកមានឥន្ទ្រិយទន់ខ្សោយ ។ ម្យ៉ាងទៀត តែងឆ្លើយតបដោយពាក្យធម្មតាថា ***“អនុស័យរបស់កល្យាណបុថុជ្ជននៅមាន”*** ។

ពាក្យថា ***“រាគៈកើតឡើង”*** សេចក្ដីថា បរវាទីពោលសំដៅយករាគៈដែលលះដោយភាវនា ។ សូម្បីក្នុងទោសៈ និងមោហៈខាងមុខ ក៏មានន័យដូចគ្នានេះដែរ ។ ក៏ការកើតឡើងនៃកិលេសទាំងឡាយ មានសក្កាយ-ទិដ្ឋិជាដើម រមែងមិនមាន ព្រោះកិលេសទាំងនោះ គឺព្រះសោតាបន្នលះបានហើយ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយស្រួលមែនពិត ។

ចប់សុត្តសោធនា

ចប់បរិហានិកថា

...............

## ៣.ព្រហ្មចរិយកថា សំដែងអំពីការប្រព្រឹត្តព្រហ្មចរិយធម៌

### ១.សុទ្ធព្រហ្មចរិយកថា រឿងព្រហ្មចរិយបរិសុទ្ធ

*ឥឡូវនេះ ឈ្មោះថា រឿងប្រព្រឹត្តព្រហ្មចរិយធម៌ ៖*

ក្នុងបញ្ហានោះ ការប្រព្រឹត្តព្រហ្មចរិយធម៌មាន ២ យ៉ាង គឺការចម្រើនមគ្គ ១ និងបព្វជ្ជា ១ ។ បព្វជ្ជារមែងមិនមានក្នុងទេវតាទាំងឡាយទេ ។ វៀរអសញ្ញីសត្វចេញ ការចម្រើនមគ្គ លោកមិនបដិសេធក្នុងទេវតាទាំងឡាយដ៏សេសឡើយ ។

ក្នុងបញ្ហានោះ ជនទាំងនោះមានសេចក្តីយល់ឃើញខុស ដូចនិកាយសមិតិយៈទាំងឡាយ អ្នកមានសេចក្តីយល់ឃើញខុស មិនប្រាថ្នាការចម្រើនមគ្គក្នុងទេវតាទាំងឡាយ ដែលខ្ពស់ជាងជាន់បរនិម្មិតវសវត្តី, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា ***“ការប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងពួកទេវតាមិនមានឬ ?”*** ពាក្យឆ្លើយតបរបស់បរវាទីថា ***“ មែន ”*** ដោយអំណាចនៃលទ្ធិដែលកើតឡើងហើយថា ***“ការប្រព្រឹត្តព្រហ្មចរិយៈ សូម្បីទាំងពីរ មិនមានក្នុងទេវតាទាំងឡាយ”*** ព្រោះអាស្រ័យព្រះសូត្រនេះថា “ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សនៅក្នុងជម្ពូទ្វីប គ្របសង្កត់នូវពួកមនុស្សក្នុងឧត្តរកុរុទ្វីប និងពួកទេវតាជាន់តាវត្តិង្សដោយហេតុ ៣ យ៉ាង” ។ ហេតុទាំង ៣ នោះ តើដូចម្តេចខ្លះ ? ហេតុ ៣ គឺ

**១.សូរា** ពួកមនុស្សជាអ្នកក្លៀវក្លា

**២.សតិមន្តោ** មានសតិ

**៣.ព្រហ្មចរិយវាសោ** ប្រព្រឹត្តព្រហ្មចរិយធម៌ ។

ពាក្យសួររបស់សកវាទីទៀតថា ពួកទេវតាទាំងអស់ សុទ្ធតែល្ងង់ខ្លៅ ដោយអំណាចនៃធម៌ដែលជាអន្តរាយ ដល់ការប្រព្រឹត្តព្រហ្មចរិយៈ សូម្បីទាំងពីរឬ ? ក្នុងពាក្យទាំងនោះ ពាក្យថា ***“ប្រើភាសាគ”*** បានដល់ អ្នកពោលដោយដៃ និងក្បាល ដូចមនុស្សគ ។

ពាក្យសួររបស់បរវាទីខាងមុខថា ***“ការប្រព្រឹត្តព្រហ្មចរិយធម៌មានក្នុងពួកទេវតាឬ ?”*** ពាក្យឆ្លើយតបរបស់សកវាទី សំដៅយកការចម្រើនមគ្គ ។ ពាក្យសាកសួរដោយអំណាចនៃបព្វជ្ជា ព្រោះមិនកំណត់ប្រាថ្នាយកពាក្យឆ្លើយតបជារបស់បរវាទី ។ ក្នុងបញ្ហាថា ***“បព្វជ្ជាមិនមានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ?”*** ពាក្យបដិសេធថា ***“មិនគួរពោលយ៉ាងនេះទេ”*** ដូច្នេះ ជារបស់សកវាទីនោះដែរ ព្រោះសំដៅយកការបានចំពោះនូវមគ្គរបស់គ្រហស្ថ និងរបស់ទេវតាទាំងឡាយពួកខ្លះ ។ ត្រូវសកវាទីសួរបញ្ឈាក់ទៀត បរវាទីនោះឯង ក៏ឆ្លើយតបសំដៅយកមនុស្សអ្នកនៅជាយដែន ដែលព្រះសាសនាផ្សាយទៅមិនដល់ និងអសញ្ញីសត្វ ។ សូម្បីក្នុងពាក្យសួរទាំងឡាយ មានពាក្យជាដើមថា ***“អ្នកណាបព្វជ្ជា”*** ក៏មានន័យដូចគ្នានេះដែរ ។ សូម្បីក្នុងពាក្យសួរទៀតថា ***“ការប្រព្រឹត្តព្រហ្មចរិយធម៌នៅមានក្នុងពួកទេវតាឬ ?”*** ពាក្យឆ្លើយតបថា ***“មាន”*** ជារបស់សកវាទី ព្រោះសំដៅយកការចម្រើនមគ្គប៉ុណ្ណោះ ។

លុះបរវាទីបញ្ជាក់ថា ***"មានក្នុងពួកទេវតាគ្រប់ពួកឬ ?"*** ពាក្យបដិសេធជារបស់សកវាទីនោះឯង ព្រោះសំដៅយកអសញ្ញីសត្វដែលប្រព្រឹត្តព្រហ្មចរិយធម៌មិនបាន ។ បញ្ហាថា ***"ការប្រព្រឹត្តព្រហ្មចរិយៈមានក្នុងពួកមនុស្សឬ ?"*** ពាក្យឆ្លើយតបសំដៅយកជនជម្ពូទ្វីបជាអ្នកចម្រើន ។ បណ្ឌិតគប្បីជ្រាបពាក្យបដិសេធ ព្រោះសំដៅយកមនុស្សនៅជាយដែនដែលមិនមានសេចក្តីចម្រើន ។ ត្រង់ពាក្យថា ***"មានក្នុងទីណា មិនមានក្នុងទីណា ?"*** ដូច្នេះ ពាក្យវិសជ្ជនាជារបស់សកវាទី ដោយបទដែលញែក គឺសត្វ និងប្រទេស យ៉ាងនេះថា ***"ទេវតាទាំងនោះមានក្នុងទីណា ឬប្រទេសទាំងនោះនៅមានត្រង់ទីណា"*** ។ ដោយន័យនេះ បណ្ឌិតគប្បីជ្រាបបញ្ហាទាំងពួងថាជាឯកន្តិកបញ្ហា គឺជាបញ្ហាដែលសួរឆ្លាស់គ្នា ។ ក្នុងការសាកសួរព្រះសូត្រថា ***"ផលកើតឡើងក្នុងទីណា ?"*** ជាពាក្យសួររបស់សកវាទីថា ***"ការកើតឡើងនៃអរហត្តផលរបស់ព្រះអនាគាមីនោះ មានក្នុងទីណា ?"*** , ពាក្យឆ្លើយថា ***"ក្នុងពួកទេវតានុ៎ះឯង"*** អធិប្បាយថា ក្នុងជាន់សុទ្ធាវាសទាំងឡាយ ។ ពាក្យថា **"ហន្ទ ហិ"** ជានិបាតចុះក្នុងអត្ថនៃហេតុ ។ ពាក្យនេះ លោកអធិប្បាយទុកថា ព្រោះព្រះអនាគាមីបុគ្គលធ្វើឲ្យជាក់ច្បាស់នូវផលក្នុងសុទ្ធាវាសទាំងនោះ ដោយមគ្គដែលលោកឲ្យកើតហើយ ក្នុងលោកនេះ

*មិនបានចម្រើនមគ្គដទៃ ក្នុងសុទ្ធាវាសនោះទេ ព្រោះហេតុដូច្នោះ ការប្រព្រឹត្ត ព្រហ្មចរិយធម៌ គឺការបព្វជ្ជាក្នុងទេវតាទាំងឡាយ ទើបមិនមានឡើយ ៕*

---

## ២. សំសន្ទនព្រហ្មចរិយកថា

## សម្តែងអំពីការប្រៀបធៀបព្រហ្មចរិយៈ

*ឥឡូវនេះ ពាក្យសួរប្រៀបធៀបថា **“ព្រះអនាគាមី”** ជាដើម ទៀត ជារបស់សកវាទី ដើម្បីសម្តែងសេចក្តីនេះថា “បើការធ្វើឲ្យច្បាស់ នូវផលក្នុងទីដទៃ ដោយមគ្គដែលធ្លាប់អប់រំហើយក្នុងទីដទៃមាន ព្រោះហេតុ ដូច្នោះ ការធ្វើឲ្យជាក់ច្បាស់នូវផលដោយមគ្គដែលធ្លាប់អប់រំហើយ ក៏គប្បី មានសូម្បីដល់ព្រះសោតាបន្នជាដើម” ។ ការបេ្តជ្ញាធ្វើឲ្យជាក់ច្បាស់នូវផល នៃព្រះអនាគាមីក្នុងបញ្ហានោះ, ប៉ុន្តែ បដិសេធក្នុងការធ្វើឲ្យច្បាស់នូវផល នៃព្រះអរិយៈដ៏សេស ជារបស់បរវាទី, ក៏លទ្ធិរបស់លោកថា **“ព្រះអនាគាមី វៀរការចម្រើនមគ្គ រមែងធ្វើឱ្យច្បាស់នូវអរហត្តផលបាន ដោយអំណាច នៃការឧបបត្តិឡើងនុ៎ះឯង”** ព្រោះព្រះបាលីថា “ព្រះអនាគាមីដែលមានមគ្គ អប់រំហើយក្នុងលោកនេះ រមែងឈ្មោះថា ជាអ្នកដល់សេចក្តីសម្រេច ដោយការលះកិលេសក្នុងលោកនេះ (ឥធវិហាយនិដ្ឋោ) ក៏លោកចម្រើន*

*អនាគាមិមគ្គក្នុងលោកនេះ ហើយឃ្លាតចាកលោកនេះ ក៏ជាឱបបាតិកៈនឹងបរិនិព្វានក្នុងទេវលោកនោះ, ចំណែកព្រះសោតាបន្ន និងព្រះសកទាគាមីឈ្មោះថា ឱបបាតិកៈ នៅមានក្នុងទេវលោក ព្រោះញ៉ាំងមគ្គឲ្យកើត ក្នុងទេវលោកនោះ, ប៉ុន្តែការមកកាន់លោកនេះ របស់ព្រះអរិយៈទាំងនោះរមែងមិនមានឡើយ" ដូច្នេះ, ពេលត្រូវសកវាទីសួរដល់ការធ្វើឲ្យច្បាស់នូវអរហត្តផលនៃព្រះអនាគាមី ក៏ឆ្លើយតប, ប៉ុន្តែ បដិសេធការធ្វើឲ្យច្បាស់នៃព្រះអរិយៈទាំងឡាយក្រៅអំពីនេះ ។*

*ក្នុងបញ្ហាថា* ***"ព្រះអនាគាមីបុគ្គលធ្វើឱ្យច្បាស់នូវផល ក្នុងពួកទេវតានោះ ដោយមគ្គដែលលោកឱ្យកើតហើយក្នុងពួកទេវតានោះឬ ?"*** *បរវាទីឆ្លើយបដិសេធ ព្រោះទាស់ជាមួយនឹងលទ្ធិថា* ***"ការចម្រើនមគ្គរបស់ព្រះអនាគាមីក្នុងទេវលោក មិនមានទេ"*** *។ ពាក្យសួរថា* ***"នឹងមិនញ៉ាំងមគ្គឱ្យកើត នឹងលះកិលេសទាំងឡាយទៀតឬ ?"*** *ជារបស់សកវាទី ។ ពាក្យឆ្លើយតបជារបស់បរវាទី ព្រោះសំដៅយករូបាវចរមគ្គ ។ ពិតណាស់ព្រះអនាគាមីនោះ ឈ្មោះថា ដល់នូវសេចក្តីសម្រេចដោយការលះកិលេសក្នុងលោកនេះ ជាអ្នកកើតឡើងហើយក្នុងទេវលោកដោយរូបាវចរមគ្គ ។*

*ក្នុងបញ្ហាថា* ***"ព្រះអនាគាមីបុគ្គលមានករណីយកិច្ចដែលធ្វើហើយ"*** *បរវាទីឆ្លើយតបថា* ***"មែន"*** *ដូច្នេះ សំដៅយកការមានករណីយកិច្ចដែល*

*ព្រះអនាគាមីនោះ ឆ្លើយហើយដោយការឧបបត្តិជាដើម ព្រោះកាន់យកព្រះបាលីថា* ***“ព្រះអនាគាមីដែលជាឱបបាតិកៈបរិនិព្វានហើយ ក្នុងទេវលោកនោះ ”*** *។ ក្នុងបញ្ហាថា* ***“ព្រះអនាគាមីលែងកើតជាព្រះអរហន្តឬ ?”*** *ឆ្លើយបដិសេធ ដោយអំណាចនៃព្រះអរហន្តដែលបរិនិព្វានក្នុងលោកនេះ ។ ត្រូវសកវាទីសួរទៀតថា* ***“ព្រះអនាគាមីលែងកើតជាព្រះអរហន្តឬ ?”*** *ក៏ឆ្លើយយល់ព្រមថា* ***“មែន”*** *ដោយអំណាចនៃព្រះអរហន្តដែលបរិនិព្វានហើយ ក្នុងទេវលោកនោះ ។ សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា* ***“ព្រះអរហន្តមានភពថ្មីឬ ?”*** *ជាដើម បណ្ឌិតគប្បីជ្រាបខ្លឹមសារ ដោយអំណាចនៃព្រះអរហន្តទាំងឡាយ ដែលបរិនិព្វានហើយក្នុងទេវលោកនោះ ឬបរិនិព្វានហើយ ក្នុងលោកនេះឯង ។ ត្រូវសកវាទីសួរថា* ***“ជាអ្នកមានអកុប្បធម៌ដែលមិនចាក់ធ្លុះ ហើយបរិនិព្វានក្នុងពួកទេវតានោះឬ ?”*** *ពេលបរវាទីមិនប្រាថ្នាការចាក់ធ្លុះអកុប្បធម៌របស់ព្រះអរហន្ត ដោយមគ្គដែលអប់រំហើយ ក្នុងលោកនេះឯង ទើបឆ្លើយបដិសេធថា* ***“ មិនគប្បីពោលយ៉ាងនេះទេ”*** *។ ឧទាហរណ៍ដំបូងថា ដូចម្រឹគដែលត្រូវគេបាញ់ដោយកូនសរ ជាពាក្យឧបមារបស់បរវាទី, ឧទាហរណ៍ទីពីរ ជារបស់សកវាទី ។ ពាក្យដែលនៅសល់ ក្នុងទីទាំងពួងមានអត្ថអណ្ដែតឡើងមែនពិត ៕*

ចប់ព្រហ្មចរិយកថា

# ៣. ឱធិសោកថា

## សម្តែងអំពីការលះកិលេសចំណែកខ្លះ

*ឥឡូវនេះ ឈ្មោះថា រឿងចំណែកខ្លះ ៖*

*ក្នុងបញ្ហានោះ ជនទាំងឡាយណា រមែងប្រាថ្នាការលះកិលេសបាន ចំណែកខ្លះៗ គឺដោយមួយផ្នែកៗ អំពីការឃើញទុក្ខជាដើម ដោយអំណាច ការត្រាស់ដឹងផ្សេងៗ នៃព្រះសោតាបន្នជាដើម ដូចនិកាយសមិតិយៈទាំង ឡាយ ក្នុងខណៈនេះ, ដើម្បីនឹងទម្លាយលទ្ធិនិកាយទាំងនោះ ទើបសកវាទី សួរថា* ***"បុគ្គលលះកិលេសបានជាចំណែកខ្លះឬ ?"*** *ពាក្យយល់ព្រមថា* ***"មែន"*** *ជារបស់បរវាទី ។ ការសាកសួរទៀត ជារបស់សកវាទី ។ ពាក្យ បដិសេធ ជារបស់បរវាទី ព្រោះមិនមានភាពជាព្រះសោតាបន្នជាដើម ដោយឯកទេស គឺផ្នែកខ្លះ ។ បណ្ឌិតគប្បីជ្រាបអត្ថន័យក្នុងវារៈទាំងពួង ដោយឧបាយនេះចុះ ៕*

ចប់ឱធិសោកថា

# ៤. ជហតិកថា (ឬបជហតិកថា)

## សម្តែងអំពីការលះកិលេស

### ១. នសុត្តាហរណកថា

*ឥឡូវនេះ ឈ្មោះថា រឿងលះកិលេស ៖*

*ក៏ក្នុងបញ្ហានោះ ជនទាំងឡាយណាមានសេចក្តីយល់ឃើញខុស ដូចនិកាយសមិតិយៈជាដើម ក្នុងទីនេះថា “បុថុជ្ជនអ្នកបានឈានព្រមនឹងការត្រាស់ដឹងសច្ចៈ រមែងជាអ្នកឈ្មោះថា ព្រះអនាគាមីហើយ ក្នុងឱកាសដែលលោកនៅជាបុថុជ្ជននោះឯង ជាអ្នកលះកាមរាគៈ និងព្យាបាទបានហើយ” ដូច្នេះ ដើម្បីនឹងទម្លាយលទ្ធិនេះ របស់ជនទាំងនោះ ទើបសកវាទីសួរថា* ***“បុថុជ្ជនលះកាមរាគៈ និងព្យាបាទបានឬ ?”*** *ពេលបរវាទីមិនឃើញនូវបរិយុដ្ឋានកិលេសរបស់លោក អ្នកបង្ក្រាំងទុកដោយឈាន ទើបឆ្លើយយល់ព្រម ។ ក៏ការលះកិលេសបានដោយសព្វគ្រប់ របស់ឈានលាភីបុគ្គលទាំងនោះ សូម្បីបង្ក្រាំងទុកដោយអនាគាមិមគ្គនុ៎ះឯងនៅមាន ព្រោះហេតុដូច្នោះពាក្យសាកសួររបស់សកវាទីថា* ***“លះកិលេសបានដោយអស់រលីង”*** *ដូច្នេះទៀត, ការបដិសេធជារបស់បរវាទី ព្រោះមិនមានការលះដូច្នោះ ។ ពាក្យថា* ***“បុថុជ្ជនបង្ក្រាំង”*** *ជាពាក្យសួររបស់សកវាទី សំដៅយកការបង្ក្រាំងកិលេសទុកដោយមិនអស់រលីងប៉ុណ្ណោះ ។ តពីនេះទៅ ជាការប្រៀបធៀបបុថុជ្ជនជាមួយនឹងព្រះអរិយបុគ្គលដែលតាំងនៅក្នុងអនាគាមិមគ្គ ពាក្យនេះមានខ្លឹមសារងាយស្រួលទាំងអស់ ។*

*ខាងមុខពីនេះ ត្រូវសកវាទីសួរថា* ***“បុថុជ្ជនជាអ្នកប្រាសចាកសេចក្តីត្រេកអរក្នុងកាមទាំងឡាយ តាំងនៅក្នុងអនាគាមិផលឬ ?”*** *ក៏ឆ្លើយ*

*យល់ព្រម សំដៅយកបុថុជ្ជនជាព្រះអនាគាមីដោយឈាន ។ ត្រូវសកវាទីសួរថា* ***“តាំងនៅក្នុងអរហត្តផលឬ ?”*** *ដូច្នេះ, ក៏ឆ្លើយបដិសេធ ព្រោះមិនមានការលះខុទ្ទម្ភាគិយសំយោជនៈ ដោយមគ្គដែលជាគ្រឿងឃើញ ។ ត្រូវសកវាទីសួរថា* ***“ញុំាងមគ្គទាំង ៣ ឱ្យកើត មិនមុន មិនក្រោយគ្នាឬ ?”*** *ក៏ឆ្លើយបដិសេធ ព្រោះមិនមានការចម្រើនដូច្នោះ ។ ត្រូវសកវាទីសួរទៀតថា* ***“ញុំាងមគ្គទាំង ៣ ឱ្យកើត មិនមុន មិនក្រោយឬ ?”*** *ក៏ឆ្លើយយល់ព្រម សំដៅយកសភាវកិច្ចនៃមគ្គទាំង ៣ ។ សូម្បីក្នុងពាក្យសួរដល់សាមញ្ញផលទាំងឡាយ ក៏មានន័យដូចគ្នានេះដែរ ។*

*ត្រូវសកវាទីសួរថា* ***“ដោយមគ្គណា ?”*** *ឆ្លើយថា ដោយអនាគាមិមគ្គ, លោកពោលសំដៅយកបុថុជ្ជនជាព្រះអនាគាមីដោយឈាន ។ ត្រូវសកវាទីសួរដល់* ***ការលះសញ្ញោជនៈមានសក្កាយទិដ្ឋិ*** *ជាដើមទៀត, បរវាទីក៏បដិសេធ ព្រោះកិលេសទាំងឡាយនោះ ព្រះអនាគាមិមគ្គមិនបានលះទេ ។ ត្រូវសកវាទីសួរលើកទីពីរ ក៏ឆ្លើយយល់ព្រម សំដៅយកភាពជាព្រះអនាគាមិមគ្គ ដោយឈាននៃបឋមមគ្គនុ៎ះឯង ។ ពាក្យដែលនៅសល់ក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕*

ចប់បជហាតិកថា

……………

# ៦.សព្វមត្ថីតិវាទកថា

## សម្តែងអំពីវត្ថុទាំងពួងមាន

### ១.វាទយុត្តិវណ្ណនា ពណ៌នាអំពីការប្រកបវាទៈ

*ឥឡូវនេះ ឈ្មោះថា រឿងវាទៈថា វត្ថុទាំងពួងមាន ៖*

*ក្នុងបញ្ហានោះ ជនទាំងឡាយណាមានសេចក្តីយល់ឃើញខុស ដូចលទ្ធិនៃនិកាយសព្វមត្ថីតិវាទៈ ក្នុងទីនេះថា “ធម៌ទាំងឡាយដែលផ្សេងគ្នា ដោយអតីតជាដើម សូម្បីទាំងអស់ រមែងមិនរំលងនូវសភាវៈនៃខន្ធ ព្រោះបាលីថា រូបយ៉ាងណាមួយ ជាអតីត គឺកន្លងទៅហើយក្តី ជាអនាគត គឺមិនទាន់មកដល់ក្តី ជាបច្ចុប្បន្ន គឺកើតឡើងចំពោះមុខក្តី ។ល។ នេះ ព្រះតថាគតត្រាស់ហៅថា* ***រូបក្ខន្ធ’*** *ជាដើម ព្រោះហេតុដូច្នោះ វត្ថុទាំងពួង ទើបឈ្មោះថា មានមែនពិត” ដូច្នេះ, ដើម្បីជម្រះលទ្ធិដែលយល់ឃើញខុស របស់ជនទាំងនោះ ទើបសកវាទីសួរថា “វត្ថុទាំងពួងមានឬ ?” ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ព្រោះតាំងនៅក្នុងលទ្ធិមានប្រការដូចពោលហើយ ។*

*ពាក្យថា* ***“ក្នុងសរីរៈទាំងពួងឬ ?”*** *អធិប្បាយថា សកវាទីរមែងសួរដោយពាក្យថា* ***“វត្ថុទាំងពួងមានក្នុងសរីរៈទាំងពួងឬ ?”*** *។ ពាក្យថា* ***“មានក្នុងកាលទាំងពួងឬ ?”*** *អធិប្បាយថា សកវាទីរមែងសួរថា* ***“វត្ថុ***

***ទាំងពួង រមែងមានក្នុងកាលទាំងពួងឬ ?”*** ។ ពាក្យថា **“សព្វេន សព្វំ”** អធិប្បាយថា សកវាទីសួរថា ***“វត្ថុទាំងពួងមានដោយអាការទាំងពួងឬ ?”*** ។ ពាក្យថា **“សព្វេសុ”** អធិប្បាយថា សកវាទីរមែងសួរថា ***“វត្ថុទាំងពួងមានក្នុងធម៌ទាំងពួងឬ ?”*** ។ ពាក្យថា ***“មិនប្រកបឬ ?”*** បានដល់ មិនប្រកបហើយ អធិប្បាយថា ធម៌ដែលប្រកបគ្នាបាន របស់សភាវធម៌ផ្សេងៗ មាន, ប៉ុន្តែមិនមានដល់សភាវធម៌តែមួយាំងទេ ។ ព្រោះហេតុនោះ ក្នុងបញ្ហានេះ ទើបសកវាទីនាំរូបជាមួយវេទនា ឬញុំាងវេទនាជាមួយរូបមិនឲ្យផ្សេងគ្នា គឺឲ្យមានលក្ខណៈដូចគ្នានុ៎ះឯង ហើយទើបសួរថា ***“វត្ថុទាំងពួង មានឬ ?”*** ត្រង់សេចក្តីថា ***“សូម្បីវត្ថុណា ដែលមិនមានក៏ឈ្មោះថា មានឬ ?”*** នេះ អធិប្បាយថា សកវាទីសួរថា “សូម្បីវត្ថុណាមួយ មានពាក្យថា ***ខន្ធទី ៦*** ជាដើម ឬពាក្យថា ***ស្នែងទន្សាយ*** ជាដើម រមែងមិនមាន ព្រោះហេតុដូច្នេះ សូម្បីពាក្យដែលលោកឲ្យសម្រេចហើយនេះ ឈ្មោះថា ***មានឬ*** ? ។ ពាក្យថា ***“វត្ថុទាំងពួងមានឬ ?”*** ដូច្នេះ សេចក្តីថា សកវាទីរមែងសួរពាក្យនេះត្រឹមតែពាក្យថា “ទិដ្ឋិណាមាន ទិដ្ឋិនោះ ហៅថា មិច្ឆាទិដ្ឋិ, និងទិដ្ឋិណាមាន ទិដ្ឋិនោះ ហៅថា សម្មាទិដ្ឋិ, យ៉ាងនេះឯង ហៅថា វត្ថុទាំងពួងមាន, ឬក្នុងលទ្ធិរបស់លោកថា ទិដ្ឋិណា

ដែលថា វត្ថុទាំងពួងមាន, ទិដ្ឋិនោះ ឈ្មោះថា មិច្ឆាទិដ្ឋិ” នេះ ព្រោះមិនធ្វើតាមសេចក្ដីពិត ទិដ្ឋិឯណាមាន, ទិដ្ឋិនោះ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះមានសេចក្ដីយល់ឃើញត្រូវតាមសេចក្ដីពិតយ៉ាងនេះ ដោយប្រការដូច្នេះ ទើបពោលថា ***“វត្ថុទាំងពួងនេះមានឬ ?”*** ។ បរវាទីបដិសេធថា ***មិនគប្បីពោលយ៉ាងនេះទេ*** ព្រោះមិនមានធម៌ ដូចប្រការដែលពោលមកហើយក្នុងន័យសូម្បីទាំងអស់នុ៎ះ ។ ក៏សូម្បីក្នុងន័យទាំងអស់នេះ បណ្ឌិតគប្បីជ្រាបប្រភេទកថាមគ្គទាំងពួងដោយពិស្ដារ ព្រោះធ្វើពាក្យថា ***“លោកចូរដឹងនិគ្គហៈគឺកំហុសចុះ”*** ជាដើម ដោយប្រការដូច្នេះឯង ។ នេះឈ្មោះថា **ខាធយុត្តិ** គឺការប្រកបវាទៈក្នុងទីនេះ មានត្រឹមតែប៉ុណ្ណេះសិន ៕

## ២. កាលសំសន្ទនាវណ្ណនា

## ពណ៌នាអំពីការប្រៀបធៀបពេលវេលា

*ឥឡូវនេះ ជាការប្រៀបធៀបវេលាថា **"អតីតមានឬ ?"**៖*

*ក្នុងបញ្ហានោះ ពាក្យជាដើមថា **"អតីតនៅមានឬ ? "**ជាពាក្យប្រៀបធៀប ដើម្បីឲ្យសេចក្តីយល់ឃើញនោះបរិសុទ្ធ ។ ពាក្យជាដើមថា **"រូបអតីតមានឬ ? "** ជាការប្រៀបធៀបកាលជាមួយនឹងខន្ធជាដើម ។ ត្រង់សេចក្តីថា **"រួមសម្ពឹងដល់រូបបច្ចុប្បន្ន"** សេចក្តីថា លះរូបនីមួយៗដែលជាអតីត និងអនាគតចេញហើយ ទើបសម្ពឹងដល់រូបបច្ចុប្បន្នប៉ុណ្ណោះដែលមិនគប្បីចែក ។ ក្នុងបញ្ហាថា **"រមែងលះភាវៈជារូបឬ ?"** បរវាទីរមែងឆ្លើយបដិសេធ ព្រោះភាវៈនៃរូបសូម្បីរលត់ទៅហើយ លោកក៏សង្គ្រោះចូលជារូបក្ខន្ធដែរ ។ ក្នុងបញ្ហាបដិលោមថា **"រមែងមិនលះភាវៈជារូបឬ ?"** បរវាទីឆ្លើយតប ព្រោះភាវៈនៃរូបនោះ លោកសង្គ្រោះចូលជារូបក្ខន្ធ ។ ក្នុងសេចក្តីថា **"រួមសម្ពឹងដល់សំពត់ស"** នេះ សេចក្តីថា ពេលបរវាទីពោលថា **"រួមសម្ពឹងដល់សំពត់ស"** ព្រោះមិនពោលពាក្យបញ្ញត្តិថា **"សំពត់ទាំងអស់ ជាពណ៌ស ក៏មិនមាន"** , ប៉ុន្តែពោលដល់សំពត់ ជាមួយពណ៌សនេះ, ទើបសកវាទីឆ្លើយយល់ព្រមដោយសេចក្តីជាអត្តដូចគ្នា ។*

*ក្នុងបញ្ហាថា* ***“រមែងលះភាវៈជាសំពត់សឬ ?”*** *ពាក្យយល់ព្រមនេះ ជារបស់សកវាទី សំដៅយកសំពត់ដែលប្រាសចាកពណ៌ ក៏ក្នុងពាក្យថា* ***“រមែងលះភាវៈជាសំពត់ឬ ?”*** *នេះ ជាពាក្យបដិសេធរបស់សកវាទីនុ៎ះឯង ព្រោះប្រាសចាកពាក្យបញ្ញត្តិ ។ សូម្បីក្នុងបដិលោម ក៏មានន័យដូចគ្នានេះដែរ ។ ក៏បរវាទីនោះ ត្រូវសកវាទីសួរថា* ***“អតីតរមែងមិនលះភាវៈជាអតីតឬ ?”*** *ពោលសម្គាល់ថា* ***“បើគប្បីលះអនាគត ឬបច្ចុប្បន្នមែន អតីតនោះ ក៏គប្បីមានដែរ”*** *ដូច្នេះ ទើបយល់ព្រមថា* ***“មែន”*** *ក៏ត្រូវសកវាទីសួរថា* ***“អនាគតរមែងមិនលះភាវៈជាអនាគតឬ ?”*** *បរវាទីសម្គាល់ថា* ***“បើគប្បីលះអនាគតចេញហើយ ក៏នឹងមិនគប្បីលះបង់ភាពជាបច្ចុប្បន្ន”*** *ទើបបដិសេធ ។ សូម្បីក្នុងបញ្ហាថា* ***“ដោយភាវៈជាបច្ចុប្បន្ន”*** *ក៏បដិសេធថា* ***“ទោស គឺការមិនដល់ភាពជាអតីត នឹងគប្បីមាន”*** *។ សូម្បីក្នុងបញ្ហាអនុលោមទាំងឡាយ បណ្ឌិតក៏គប្បីជ្រាបខ្លឹមសារ ដោយន័យនេះចុះ ។ លុះពោលសុទ្ធិកន័យយ៉ាងនេះហើយ ដើម្បីសម្តែងដោយអំណាចនៃខន្ធទៀត ទើបលោកពោលថា* ***“រូបអតីត”*** *ជាដើម ពាក្យទាំងអស់នោះ អាចនឹងគប្បីដឹងដោយទំនងនៃព្រះបាលីនុ៎ះឯង ៕*

ចប់កាលសំសន្ទនា

## វចនសោធនា ការជម្រះពាក្យពេចន៍

*ឥឡូវនេះ ឈ្មោះថា* **សោធនា** *គឺការជម្រះពាក្យពេចន៍ ព្រោះព្រះបាលីថា* ***"អតីតមិនមែនសភាវៈដែលមាន"*** *ជាដើម, ក្នុងបញ្ហានោះ ពាក្យថា* ***"ប្រសិនបើអតីតមិនមែនសភាវៈដែលមាន"*** *អធិប្បាយថា បើអតីតមិនមានទេ ។ ពាក្យថា* ***"អតីតមាន ក៏ខុស"*** *ដូច្នេះ អធិប្បាយថា អតីតនោះ ដោយសភាវៈដែលមានផង ដូច្នេះខុសទាំងអស់ ។ ត្រូវសកវាទីសួរថា* ***"អនាគតក៏យ៉ាងនោះឯង បច្ចុប្បន្នក៏យ៉ាងនោះឯងឬ ?"*** *បរវាទីឆ្លើយបដិសេធ សំដៅយកការមិនមានអនាគតដែលកំពុងជាបច្ចុប្បន្ន ក្នុងខណៈនៃអនាគតនុ៎ះឯង ដោយការផ្សេងគ្នានៃវេលា ។ ត្រូវសកវាទីសួរលើកទីពីរ ក៏ឆ្លើយយល់ព្រមព្រោះសេចក្ដីដែលអនាគតណា បានមានហើយក្នុងកាលមុន, ប៉ុន្តែ កាលកើតឡើងនោះ ជាបច្ចុប្បន្នដែលកំពុងប្រាកដ ។ ពាក្យថា* ***"វត្ថុដែលជាអនាគតហើយ ជាបច្ចុប្បន្ន ឈ្មោះថា រស់នៅហើយ ទើបរស់នៅឬ?"*** *អធិប្បាយថា ពាក្យណាដែលលោកពោលថា ជាអនាគតហើយជាបច្ចុប្បន្ននេះ សម្គាល់សេចក្ដីថា ជាអនាគត ឬជាបច្ចុប្បន្ន ឈ្មោះថា រស់នៅហើយ ដោយអំណាចនៃលទ្ធិថា* ***"អនាគតក៏យ៉ាងនោះឯង បច្ចុប្បន្នក៏យ៉ាងនោះដែរ"*** *ដូច្នេះ ពាក្យនោះ ក៏ឈ្មោះថា រស់នៅរួចហើយតាមលទ្ធិ*

របស់លោកឬ ? បរវាទីបដិសេធថា ***មិនគប្បីពោលយ៉ាងនេះទេ"*** ព្រោះវត្ថុដែលរស់នៅហើយ ជាសភាវៈដែលមិនមានដល់ធម៌ដែលទៅកើតហើយមានហើយ ។ ត្រូវសកវាទីសាកសួរលើកទីពីរ លោកក៏ឆ្លើយយល់ព្រម ព្រោះអនាគតនោះនឹងកន្លងហើយ, ប៉ុន្តែ បច្ចុប្បន្នកំពុងប្រព្រឹត្តទៅ ទើបរាប់ថា ***"កន្លងហើយ ទើបនឹងកន្លង"*** ។ លំដាប់នោះ ទើបសកវាទីសួរបញ្ហានឹងបរវាទីថា ***"រឿងដែលជាអនាគត ហើយជាបច្ចុប្បន្ន ឈ្មោះថាកន្លងហើយមិនរស់នៅ"*** ដូច្នេះ ដោយបំណងថា ប្រសិនបើលទ្ធិរបស់លោក អនាគតនោះកន្លងហើយ ចិត្តបច្ចុប្បន្នគ្មានរស់នៅ ដែលរាប់ថា ***"រស់នៅរួចហើយ"*** ។ ក៏អនាគតណា មិនកន្លងហើយ បច្ចុប្បន្នណា មិនរស់នៅ ដែលដល់នូវការរាប់ថា ***"មិនកន្លងហើយ មិនរស់នៅ"*** ដូចស្នែងទន្សាយ សេចក្តីប្លែកផ្សេងគ្នាមិនកន្លងហើយ មិនរស់នៅ ទោះបីនៅមានទៀតឬ? បរវាទីសម្គាល់ថា "វត្ថុណាដែលមិនជាអនាគត មិនជាបច្ចុប្បន្ន ព្រោះសេចក្តីមិនមានទុំះឯង ព្រោះហេតុដូច្នោះ វត្ថុនោះ ទើបឈ្មោះថាមិនកន្លងហើយ មិនរស់នៅ សេចក្តីនោះ ចូរលើកទុកសិនចុះ, ក៏ប៉ុន្តែសភាពនៃធម៌ដែលមិនកន្លង មិនរស់នៅនៃវត្ថុនោះ នឹងមានត្រង់ទីណា" ដូច្នេះ ទើបឆ្លើយបដិសេធ ។ សូម្បីក្នុងបញ្ហាថា ***"បច្ចុប្បន្ន ក៏យ៉ាង***

***នោះ អតីតក៏យ៉ាងនោះឬ ?"*** បរវាទីឆ្លើយបដិសេធ សំដៅយកសេចក្ដីមិនមាននៃភាពជាអតីតក្នុងលក្ខណៈនៃភាពជាបច្ចុប្បន្ននោះឯង ព្រោះការផ្សេងគ្នានៃពេលវេលា ។

ត្រូវសកវាទីសួរក្នុងបញ្ហាទីពីរ បរវាទីឆ្លើយតបដោយធម៌ណាជាបច្ចុប្បន្ន ក៏ព្រោះជាអតីតមកពីមុន សំដៅសេចក្ដីថា បច្ចុប្បន្ននោះឯងជាអតីត ។ ពាក្យថា ***"វត្ថុដែលកើតហើយ ឈ្មោះថា កើតហើយ ទើបរស់នៅ"*** អធិប្បាយថា ពេលលោកពោលថា "បច្ចុប្បន្ន ឬអតីត ឈ្មោះថា កន្លង ហើយរស់នៅដោយអំណាចនៃលទ្ធិថា "ធម៌ណាជាបច្ចុប្បន្ន លោកពោលថា ធម៌នោះជាអតីត" ព្រោះហេតុដូច្នោះ បច្ចុប្បន្ន ***ក៏យ៉ាងនោះ អតីត ក៏ដូច្នោះដែរ*** ដូច្នេះ សូម្បីពាក្យនោះ ឈ្មោះថា វត្ថុដែលជាបច្ចុប្បន្ន ហើយជាអតីត ឈ្មោះថា កើតហើយទើបរស់នៅឬ ? បរវាទីឆ្លើយបដិសេធថា ***"មិនគប្បីពោលយ៉ាងនេះទេ"*** ព្រោះធម៌ដែលកន្លងហើយ ក៏គង់ជាសភាពកន្លងហើយ, ប៉ុន្តែមិនរស់នៅទៀត ។ ក្នុងបញ្ហាទីពីរ បរវាទីឆ្លើយតបថា ***"បច្ចុប្បន្នកន្លងហើយ អតីតរស់នៅ ដែលដល់នូវការរាប់ថារស់នៅរួចហើយ"*** ។ លំដាប់នោះ ទើបសកវាទីសួរបញ្ហានោះថា ***"វត្ថុដែលមិនជាបច្ចុប្បន្ន ហើយមិនជាអតីត ឈ្មោះថា មិនរស់នៅហើយ***

***មិនរស់នៅឬ ?"*** ដោយបំណងយកថា ប្រសិនបើបច្ចុប្បន្នរស់នៅហើយ ក៏ជាអតីត ដែលដល់នូវការរាប់ថា ***"មិនកន្លងហើយទើបមិនកើត"*** ដូច ស្នែងទន្សាយ ឈ្មោះថា គ្មានកន្លងហើយ ទើបគ្មានកើតសេចក្តីនោះ សូម្បី ឈ្មោះថា គ្មានរស់នៅ ហើយគ្មានរស់នៅតាមលទ្ធិរបស់លោកឬ ? បរវាទី នៅមានសេចក្តីសម្គាល់ថា "វត្ថុណាមិនមាន វត្ថុនោះមិនជាបច្ចុប្បន្ន និង មិនជាអតីតដែរ ព្រោះសេចក្តីមិនមាននោះដូចគ្នា ហេតុនោះ វត្ថុនោះ ទើបឈ្មោះថា គ្មានរស់នៅហើយ ទើបគ្មានរស់នៅ សេចក្តីដែលប្លែក ផ្សេងគ្នានោះ ចូរលើកទុកសិន, ក៏សេចក្តីដែលធម៌ណាគ្មានរស់នៅហើយ គ្មានរស់នៅ, ធម៌នោះ នឹងមានអំពីទីណា" ដូច្នេះ ទើបឆ្លើយបដិសេធ ។ បណ្ឌិតគប្បីធ្វើការប្រកបសូម្បីក្នុងបញ្ហាទី ៣ ដែលមានមកហើយដោយការ រួមបញ្ហាទាំង ២ ចូលគ្នា ដោយឧបាយនេះ ។

ន័យមួយទៀត បើថាអនាគតក៏យ៉ាងនោះ បច្ចុប្បន្នក៏យ៉ាងនោះមែន ភាវៈ គឺការរស់នៅដែលលោកពោលអនាគតក្នុងបច្ចុប្បន្នហើយ និងភាវៈ គឺសេចក្តីរស់នៅហើយ ដែលលោកពោលបច្ចុប្បន្នក្នុងអនាគតរមែងប្រាកដ កាលបើមានសេចក្តីដូច្នេះ សូម្បីអនាគត ក៏ឈ្មោះថា រស់នៅហើយ, សូម្បី បច្ចុប្បន្ន ក៏ឈ្មោះថា រស់នៅរួចហើយដែរ ។ ដោយហេតុនោះ ខ្ញុំសូម សួរថា លទ្ធិរបស់លោកថា ***"បណ្តាធម៌ទាំងនោះ ធម៌នីមួយៗ រស់នៅ***

***ហើយ អនាគត បច្ចុប្បន្ន ឈ្មោះថា កើតហើយទើបរស់នៅឬ ?”*** *បរវាទីបដិសេធ ដោយន័យដែលលោកបដិសេធហើយក្នុងបញ្ហាថា អនាគតក៏យ៉ាងនោះ បច្ចុប្បន្នក៏យ៉ាងនោះ, ត្រូវសកវាទីសួរទៀត ក៏ឆ្លើយតបដោយន័យដែលឆ្លើយក្នុងបញ្ហាទី ២ ។ លំដាប់នោះ សកវាទីពោលនឹងបួរបញ្ហាសំណួរដែលបរវាទីឆ្លើយតបថា* ***“បណ្ដាធម៌ទាំងនោះ ធម៌មួយៗ រស់នៅហើយ ឈ្មោះថា រស់នៅហើយ ទើបរស់នៅ”*** *ដោយអំណាចនៃបញ្ហាថា “អនាគត ក៏យ៉ាងនោះឯង បច្ចុប្បន្នក៏យ៉ាងនោះដែរ ” ធ្វើឲ្យជាបញ្ហាបដិសេធសិន ទើបសួរថា* ***“វត្ថុដែលគ្មានជាអនាគត ហើយគ្មានជាបច្ចុប្បន្នឈ្មោះថា គ្មានរស់នៅហើយ គ្មានរស់នៅឬ ? ”*** *។*

*ខ្លឹមសារនៃបញ្ហានោះ គប្បីជ្រាបថា កាលបើមានពាក្យថា* ***“អនាគត ក៏យ៉ាងនោះឯង បច្ចុប្បន្នក៏យ៉ាងនោះដែរ”*** *លោកបដិសេធ បញ្ហាដំបូងក៏ ជាការដែលលោកបដិសេធនូវសេចក្ដីរស់នៅនៃអនាគត និងសេចក្ដីរស់នៅហើយនៃបច្ចុប្បន្នមិនមែនឬ? ដោយហេតុនោះ អនាគត ក៏ឈ្មោះថា គ្មានរស់, បច្ចុប្បន្ន ក៏ឈ្មោះថា គ្មានរស់នៅហើយ ។ ប៉ុន្តែក្នុងបញ្ហាទី ២ លោកទទួលតាមលទ្ធិរបស់លោកថា* ***“អនាគត ក៏យ៉ាងនោះឯង បច្ចុប្បន្ន ក៏យ៉ាងនោះដែរ”*** *កាលបើមានសេចក្ដីដូច្នេះ សូម្បីអនាគត ក៏*

ឈ្មោះថា គ្មានរស់នៅហើយ គ្មានរស់នៅ សូម្បីបច្ចុប្បន្ន ក៏ឈ្មោះថា មិនកន្លង មិនរស់នៅនោះ ដោយហេតុនោះ ខ្ញុំសូមសួរតាមលទ្ធិរបស់លោកថា **"បណ្ដាធម៌ទាំងនោះ ធម៌នីមួយៗ មិនកន្លងហើយ មិនរស់នៅឬ?"** បរវាទីពេលមិនឃើញនូវសេចក្ដីដែលធម៌ទាំងនោះ មិនរស់នៅហើយ មិនកំពុងរស់នៅ ហាក់បីដូចជាបុគ្គលដែលមានភាពងងឹតគ្របសង្កត់ហើយ ដោយប្រការទាំងពួង ទើបឆ្លើយបដិសេធថា **"មិនគប្បីពោលយ៉ាងនេះទេ"** សូម្បីក្នុងលើកទីពីរ ពោលថា "បើបច្ចុប្បន្នយ៉ាងនោះឯង អតីតក៏យ៉ាងនោះដែរ ភាវៈ គឺការរស់នៅដែលលោកពោលបច្ចុប្បន្នក្នុងអតីត និងភាវៈ គឺការរស់នៅហើយ ដែលលោកពោលអតីតក្នុងបច្ចុប្បន្ន ក៏រមែងប្រាកដ"។ ក៏កាលបើមានសេចក្ដីដូច្នេះ សូម្បីបច្ចុប្បន្ន ក៏ឈ្មោះថា កន្លងហើយរស់នៅ សូម្បីអតីត ក៏ឈ្មោះថា កន្លងហើយ រស់នៅដែរ ។ ដោយហេតុនោះ ខ្ញុំសូមសួរលោកថា **"បណ្ដាធម៌ទាំងនោះ ធម៌មួយៗ ដែលកើតហើយរស់នៅ ឈ្មោះថា កើតហើយរស់នៅឬ ?"** បរវាទីបដិសេធហើយ ដោយន័យដែលលោកពោលទុកក្នុងបញ្ហាដែលថា "បច្ចុប្បន្នក៏យ៉ាងនោះឯង អតីតក៏យ៉ាងនោះដែរ", ត្រូវសកវាទីសួរទៀត ក៏ឆ្លើយតបដោយន័យដែលលោកទទួលហើយ ក្នុងបញ្ហាទី ២ ។ លំដាប់នោះ សកវាទីកាលនឹងត្រឡប់

សួរបញ្ហាដែលអះអាងថា ***"បណ្តាធម៌ទាំងនោះ ធម៌មួយៗដែលកើតហើយរស់នៅ ឈ្មោះថា កើតហើយរស់នៅ"*** ដោយអំណាចនៃបញ្ហាថា ***"បច្ចុប្បន្ន ក៏យ៉ាងនោះ អតីតក៏យ៉ាងនោះដែរ"*** ធ្វើឲ្យជាបញ្ហាបដិសេធសិន ទើបសួរថា ***"វត្ថុដែលមិនជាបច្ចុប្បន្ន ហើយមិនជាអតីត ឈ្មោះថា មិនរស់នៅហើយ មិនរស់នៅឬ ?"*** ។

ខ្លឹមសារនៃបញ្ហានោះ គប្បីជ្រាបថា កាលបើពាក្យថា បច្ចុប្បន្ន ក៏យ៉ាងនោះឯង អតីតក៏យ៉ាងនោះដែរ លោកបដិសេធបញ្ហាដំបូងចេញហើយ ក៏ចាត់ថា លោកបដិសេធនូវភាវៈ គឺការរស់នៅនៃបច្ចុប្បន្ន និងភាវៈ គឺការរស់នៅហើយ នៃអតីតមិនមែនឬ ? ដោយពាក្យនោះ បច្ចុប្បន្ន ឈ្មោះថា មិនមាន, អតីត ក៏ឈ្មោះថា មិនមានហើយ ។ ប៉ុន្តែ ក្នុងបញ្ហាទី ២ លោកយល់ព្រមតាមលទ្ធិថា ***"បច្ចុប្បន្នយ៉ាងនោះឯង អតីត ក៏យ៉ាងនោះដែរ"*** ដូច្នេះ កាលបើមានសេចក្តីយ៉ាងនេះ សូម្បីបច្ចុប្បន្ន ក៏ឈ្មោះថា មិនកន្លង ហើយមិនរស់នៅ សូម្បីអតីត ក៏ឈ្មោះថា មិនកន្លងហើយ មិនរស់នៅដែរ ដោយហេតុនោះ ខ្ញុំសូមសួរលោកថា ***"ធម្មតាធម៌ទាំងនោះ ធម៌មួយមិនកន្លងហើយមិនរស់នៅ ឈ្មោះថា មិនកន្លងហើយមិនរស់នៅ តាមលទ្ធិរបស់លោកឬ ?"*** បរវាទីពេលមិនឃើញនូវសេចក្តី

នៃធម៌ទាំងនោះ មិនកន្លងហើយទើបមិនរស់នៅ ប្រសិនបើបុគ្គលដែលមានភាពងងឹតគ្របសង្កត់ចិត្តហើយ ដោយប្រការទាំងពួង ទើបបដិសេធថា ***“មិនគប្បីពោលយ៉ាងនេះទេ”*** ។ សូម្បីក្នុងវារៈទី ៣ ពោលថា ***“បើអនាគតក៏យ៉ាងនោះឯង បច្ចុប្បន្នក៏យ៉ាងនោះដែរ”*** , អតីតក៏យ៉ាងនោះមែន ភាវៈ គឺសេចក្ដីនៅមាន ដែលលោកពោលដល់អនាគត និងបច្ចុប្បន្នក្នុងបច្ចុប្បន្ន និងអតីត និងភាវៈ គឺសេចក្ដីកន្លងហើយ ដែលលោកពោលបច្ចុប្បន្ន និងអតីត ក្នុងអនាគត និងបច្ចុប្បន្ន ក៏រមែងប្រាកដ, កាលបើមានសេចក្ដីដូច្នេះ សូម្បីអនាគត ក៏ឈ្មោះថា កន្លងហើយទើបរស់នៅ, សូម្បីបច្ចុប្បន្ន សូម្បីអតីត ក៏ឈ្មោះថា កន្លងហើយ ទើបរស់នៅដែរ ដោយពាក្យនោះ ទើបខ្ញុំសួរលោកថា ***“សូម្បីក្នុងធម៌ទាំង ៣ នោះ ធម៌នីមួយៗ ជាវត្ថុដែលរស់នៅរួចហើយ ឈ្មោះថា កន្លងហើយ ទើបរស់នៅតាមលទ្ធិរបស់លោកឬ?”*** បរវាទីឆ្លើយបដិសេធថា ***“អនាគត ក៏យ៉ាងនោះ បច្ចុប្បន្នក៏យ៉ាងនោះឯង អតីតក៏យ៉ាងនោះដែរ”*** ដោយន័យដែលបដិសេធហើយនុ៎ះឯង ត្រូវសកវាទីសួរទៀត ក៏ឆ្លើយយល់ព្រមក្នុងបញ្ហាទី ២ ដោយន័យនៃការយល់ព្រមនុ៎ះឯង ។ លំដាប់នោះ សកវាទីពោលនឹងប្ដូរសំណួរបញ្ហាដែលបរវាទីយល់ព្រមថា ***“បណ្ដាធម៌ទាំងនោះ ធម៌នីមួយៗ ជាវត្ថុដែលកន្លងហើយ រស់នៅ ឈ្មោះថា កន្លងហើយទើបរស់នៅ”*** ដោយអំណាចនៃបញ្ហាថា ***“អនា***

***គតក៏យ៉ាងនោះឯង បច្ចុប្បន្នក៏យ៉ាងនោះឯង អតីត ក៏យ៉ាងនោះឯងឬ ?"*** ដូច្នេះ ធ្វើបញ្ហាឲ្យបដិសេធជាមុន ទើបសួរថា ***"វត្ថុដែលមិនកន្លង ហើយ មិនរស់នៅ ឈ្មោះថា គ្មានកើតហើយ គ្មានរស់នៅឬ ?"*** ។

*ខ្លឹមសារនៃបញ្ហានោះ គប្បីជ្រាបដូច្នេះ កាលបើពោលពាក្យថា "អនាគត ក៏យ៉ាងនោះឯង បច្ចុប្បន្នក៏យ៉ាងនោះដែរ អតីតក៏យ៉ាងនោះ លោកបដិសេធបញ្ហាដំបូងហើយ ភាវៈ គឺការនៅមាននៃអនាគត បច្ចុប្បន្ន និងភាវៈ គឺការកើតហើយនៃបច្ចុប្បន្ន និងអតីតទាំងឡាយរស់នៅ ដែល លោកបដិសេធហើយមិនមែនឬ ? " ដោយពាក្យនោះ អនាគត និងបច្ចុប្បន្ន ក៏ឈ្មោះថា គ្មានរស់នៅ បច្ចុប្បន្ន និងអតីត ក៏ឈ្មោះថា គ្មានរស់នៅ ហើយ ។ តែក្នុងបញ្ហាទីពីរ លោកឆ្លើយយល់ព្រមតាមលទ្ធិថា* ***"អនាគត ក៏យ៉ាងនោះឯង បច្ចុប្បន្នក៏យ៉ាងនោះឯង អតីតក៏យ៉ាងនោះឯង"*** *, កាលបើ មានសេចក្តីដូច្នោះ សូម្បីអនាគត ក៏ឈ្មោះថា គ្មានកើតឡើងហើយ ទើប គ្មានរស់នៅ បច្ចុប្បន្នក្តី អតីតក្តី ក៏ឈ្មោះថា មិនកើតឡើងហើយ មិន រស់នៅដូចគ្នា ដោយហេតុនោះ ទើបខ្ញុំសួរលោកថា* ***"ក្នុងធម៌ទាំងនោះ ធម៌មួយៗ មិនកើតឡើងហើយ មិនកើត ឈ្មោះថា មិនកើតហើយ មិន រស់នៅ តាមលទ្ធិរបស់លោកឬ ?"*** *បរវាទីពេលមិនឃើញនូវសេចក្តី នៃធម៌ទាំងនោះមិនកើត ហើយមិនរស់នៅ ហាក់ដូចជាអ្នកត្រូវភាពងងឹត*

*គ្រប់សង្កត់ហើយដោយប្រការទាំងពួង ទើបឆ្លើយបដិសេធថា* ***"មិនគប្បីពោលយ៉ាងនេះឡើយ"*** *។*

ចប់វចនសោធនា

*ឯពាក្យនិគ្គហៈជាដើមក្នុងទីនេះ បណ្ឌិតគប្បីប្រកបសេចក្ដីតាមន័យដែលពោលហើយក្នុងពេលក្រោយនុ៎ះឯង ។ សូម្បីក្នុងបញ្ហាថា ចក្ខុអតីតមានជាដើម បរវាទីឆ្លើយយល់ព្រមអតីត ដោយការមិនវៀរចាកសភាពនៃចក្ខុជាដើម ត្រូវសកវាទីសួរថា* ***"បុគ្គលដឹងរូបអតីត"*** *ជាដើម ក៏ឆ្លើយបដិសេធ ដោយអំណាចនៃភាវៈមិនមានកិច្ចរបស់វិញ្ញាណទាំងនោះទៀត ។*

*ក្នុងបញ្ហាថា* ***"បុគ្គលធ្វើកិច្ចដែលគប្បីធ្វើដោយញាណបានដោយញាណអតីតនោះឬ?"*** *បរវាទីពេលមិនឃើញនូវញាណនោះ មានកិច្ចដែលគប្បីធ្វើ ព្រោះញាណនោះរលត់ទៅហើយ ទើបឆ្លើយបដិសេធ ។ ត្រូវសកវាទីសួរទៀតថា បរវាទីធ្វើបច្ចុប្បន្ននោះឯង ឲ្យជាអតីតញ្ញាណដោយលេសន័យរបស់អ្នកមានអតីតញ្ញាណ គឺអ្នកដឹងបច្ចុប្បន្នញ្ញាណ ដែលមានអតីតជាអារម្មណ៍របស់ធម៌ដែលជាអតីតារម្មណ៍ទាំងឡាយ ហើយទើបឆ្លើយយល់ព្រម ព្រោះភាវៈនៃកិច្ចនោះ ដែលបុគ្គលគប្បីធ្វើញាណបានដោយញាណនោះ ។ ពេលនោះ សកវាទីមិនឲ្យឱកាសដែលមានលេសន័យដល់បរវាទីនោះ ទើបពោលពាក្យថា* ***"បុគ្គលកំណត់ដឹងទុក្ខបាន លះសមុទ័យបាន***

***ធ្វើនិរោធឱ្យជាក់ច្បាស់ បានញុំាងមគ្គឱ្យកើតបានដោយញាណអតីតនោះឬ ?"*** បរវាទីឆ្លើយ បដិសេធ ព្រោះមិនមានកិច្ច ៤ របស់អរិយសច្ចទាំងនេះ ដោយញាណដែលមានអតីតជាអារម្មណ៍ ។ សូម្បីក្នុងបញ្ហារបស់អនាគត ក៏មានន័យដូចគ្នានេះដែរ ។ បញ្ហាពោលដោយបច្ចុប្បន្ន និងបញ្ហាពោលដោយការប្រៀបធៀប មានអត្ថន័យស្រួលហើយ ។

ទោះបីក្នុងបញ្ហាថា ***"រាគៈក្នុងអតីតរបស់ព្រះអរហន្តនៅមានឬ ?"*** ជាដើម បរវាទីឆ្លើយយល់ព្រមយ៉ាងនោះ ព្រោះភាពជាអ្នកមិនវៀរចាកភាវៈជាអ្នកមានរាគៈជាដើម ។ ក្នុងបញ្ហាថា ***"ព្រះអរហន្ត ឈ្មោះថាមានរាគៈ"*** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសចាកព្រះសូត្រ និងខ្លាចខុស ចាកការប្រកបពាក្យពេចន៍ ។ សូម្បីពាក្យទាំងអស់យ៉ាងនេះប្រាកដច្បាស់ហើយ ខាងមុខគប្បីចូលចិត្តតាមទំនងព្រះបាលីនុ៎ះចុះ ។

ក្នុងពាក្យថា ***"វត្ថុដែលនៅមានជាអតីតក៏មាន មិនជាអតីតក៏មាន"*** នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ធម៌ណាជាអតីតនោះឯង ជាសភាពដែលមាន, តែសភាពដែលមាននោះ ជាអតីត, ធម៌ណាជាបច្ចុប្បន្ន និងអនាគតជាសភាពដែលមាន, ប៉ុន្តែ សភាពដែលមាននោះ មិនជាអតីតទេ ។ ត្រង់សេចក្តីថា ***"ដោយហេតុនោះ អតីតក៏មិនជាអតីត, វត្ថុដែលមិនមែនអតីត ក៏ជាអតីត"*** អធិប្បាយថា ដោយហេតុនោះ អតីតក៏ជាសភាពដែល

មិនមែនអតីត, ប៉ុន្តែសភាពដែលមិនមែនអតីត ក៏ជាអតីតដូច្នេះ ។ សូម្បីក្នុងពាក្យបុច្ឆាថា ដោយអនាគត និងបច្ចុប្បន្ន ក៏មានន័យដូចគ្នានេះដែរ ។

ពាក្យសួរដោយជម្រះព្រះសូត្ររបស់បរវាទីថា **“មិនគប្បីពោលថាអតីតមាន អនាគតមានទេឬ ?”** ពាក្យឆ្លើយបដិសេធជារបស់សកវាទី ។ ការសាកសួររបស់បរវាទី អាស្រ័យលទ្ធិរបស់ខ្លួនតាមព្រះសូត្រទៀតថា **“ម្នាលភិក្ខុទាំងឡាយ រូបណាមួយជាអតីត អនាគត និងបច្ចុប្បន្ន ដែលជាផ្នែកខាងក្នុងក្តី ខាងក្រៅក្តី”** ជាដើម ។ ក្នុងន័យទីពីរជាពាក្យសួររបស់សកវាទី, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ពាក្យសួរក្តី ពាក្យបដិសេធក្តី និងពាក្យឆ្លើយយល់ព្រមក្តី ក្នុងឋានទាំងពួង បណ្ឌិតគប្បីជ្រាបដោយប្រការដូច្នេះ ។

ក៏ពាក្យឯណាថា **“ការកើតក្នុងភពថ្មីតទៅ ក៏នៅមានក្នុងទីនោះ”** ជាដើម ដែលបរវាទីសម្តែងក្នុងទីបំផុតរបស់ព្រះសូត្រ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា **“ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសេចក្តីរីករាយ សេចក្តីភ្លើតភ្លើន សេចក្តីប្រាថ្នា នៅមានក្នុងកពឡីការាហារ”** ដូច្នេះជាដើមនោះ ក៏ដើម្បីនាំមកអាងដោយប្រកបពាក្យថា អនាគតជាសភាពដែលមាន, ប៉ុន្តែព្រះសូត្រដែលនាំមកអាងនោះ មិនសម្រេចនូវសេចក្តីដែលអនាគតជាសភាពនៅមានទេ ។ ពិតណាស់ ព្រះសូត្រដែលព្រះមានព្រះភាគត្រាស់

*ទុកក្នុងទីនោះ សំដៅយកធម៌ដែលបុគ្គលចម្រើនហើយ ព្រោះហេតុទាំងឡាយជាសភាពដល់សេចក្ដីសម្រេចហើយ ។ នេះជាការអធិប្បាយព្រះសូត្រ ។ ពាក្យដែលនៅសល់ក្នុងទីទាំងពួង មានអត្ថងាយស្រួលទាំងអស់ ៕*

*ចប់សព្វមត្ថីតិវាទកថា*

................

## ៧.អតីតក្ខន្ធាតិអាទិកថា *សម្ដែងអំពីខន្ធអតីតជាដើម

## ១.នសុត្តសាធនកថាវណ្ណនា

*ឥឡូវនេះ ឈ្មោះថា រឿងអតីតក្ខន្ធជាដើម ៖*

*ក្នុងបញ្ហានោះ ពាក្យសួរថា* ***"អតីតជាខន្ធ"*** *ជាដើម ជារបស់បរវាទីអ្នកប្រាថ្នានូវការមាននៃខន្ធទាំងឡាយ ដែលជាអតីត និងអនាគត ព្រោះមិនវៀរចាកភាវៈនៃខន្ធជាដើម ។ ពាក្យយល់ព្រមថា* ***"មែន"*** *ជារបស់សកវាទី ព្រោះភាវៈនៃខន្ធជាអតីត ក៏សង្គ្រោះជាខន្ធដែរ ។ ពាក្យសួររបស់បរវាទីទៀតថា* ***"អតីត (ខន្ធ) មានឬ ?"*** *ពាក្យបដិសេធជារបស់សកវាទី ព្រោះភាវៈនៃអតីតក្ខន្ធ លោកបដិសេធពាក្យថា* ***មាន*** *ដោយព្រះសូត្រដែលជាគន្លងនៃភាសា ។ ក្នុងពាក្យសួរថា ដោយអាយតនៈ និងធាតុក្ដី*

---

* បាលីបិដកជា **អតីតក្ខន្ធាតិកថា ។**

ក្នុងបញ្ហា ពោលដោយអនាគតក្ដី ក្នុងបញ្ហានៃអនាគត ដោយអនុលោម និងបដិលោម ដែលផ្សៀងផ្ទាត់ជាមួយបច្ចុប្បន្នក្ដី ក្នុងបញ្ហាពោលដោយពាក្យជាដើមថា ***"រូបអតីតជាខន្ធក្ដី"*** បណ្ឌិតគប្បីជ្រាបខ្លឹមសារដោយឧបាយនេះចុះ ៕

.................................

## ២-សុត្តសាធនកថា សម្ដែងអំពីការជម្រះព្រះសូត្រ

ឯក្នុងការជម្រះព្រះសូត្រ ពាក្យសួរថា ***"មិនគប្បីពោលទេ"*** ជារបស់សកវាទី ។ បណ្ដាពាក្យទាំងនោះ ពាក្យថា ***"ខន្ធជាដើមនេះ មិនមានទេឬ ?"*** អធិប្បាយថា ធម៌ទាំងឡាយនោះមិនមានឬ ? កាលបើខន្ធជាដើមមាន បរវាទីមិនប្រាថ្នានូវភាវៈនៃអតីត និងអនាគតទាំងនោះមិនមាន ទើបទទួលឆ្លើយថា ***"មែន"*** ។ លំដាប់នោះ ទើបសកវាទីនាំព្រះសូត្រមក ដើម្បីជម្រះនូវភាវៈនៃខន្ធដែលជាអតីត និងអនាគតទាំងនោះជាសភាពដែលមិនមាន ។ សូម្បីពាក្យសួរទីពីរ ក៏ជារបស់បរវាទី ។ ពាក្យយល់ព្រមជារបស់សកវាទី ។ ការនាំព្រះសូត្រមកជារបស់បរវាទី ។ ការនាំព្រះសូត្រមកនោះ រមែងសម្រេចនូវភាវៈនៃអតីត និងអនាគតធម៌ទាំងនោះជាខន្ធជាដើម, ប៉ុន្តែមិនសម្រេចនូវធម៌ទាំងនោះថា ***"មាន"*** ដូច្នេះទេ,

*ព្រោះហេតុដូច្នោះ ទោះបីបរវាទីនាំព្រះសូត្រមកហើយ ក៏មិនដូចគ្នា (នឹងន័យ) ដែលនាំមកនោះឡើយ ។*

***ចប់អតីតក្ខន្ធាតិអាទិកថា***

= = = =

## ៧.ឯកច្ចមត្ថីតិកថា សម្ដែងអំពីមានរឿងបែបខ្លះ

## ១-២.អតីតាទិឯកច្ចកថាវណ្ណនា

*ឥឡូវនេះ ឈ្មោះថា មានរឿងបែបខ្លះ ៖*

*ក្នុងបញ្ហាទាំងនោះ ជនទាំងឡាយណា រមែងសម្គាល់ថា មានអតីតធម៌បែបខ្លះ ដូចនិកាយកស្សបិកៈ ។ ដើម្បីទម្លាយលទ្ធិនៃជនទាំងនោះ ទើបសកវាទីសួរថា* ***“អតីតមានឬ ?”*** *ពាក្យវិសជ្ជនាថា* ***“អតីតបែបខ្លះមាន”*** *ជាដើម ជារបស់បរវាទី ។ គប្បីជ្រាបសេចក្ដីសម្គាល់នៃពាក្យវិសជ្ជនារបស់បរវាទីនោះថា* ***“ វិបាកធម៌ដែលមិនឱ្យផលមាន វិបាកធម៌ដែលឱ្យផលហើយ មិនមានទេ”*** *។ ពាក្យសាកសួរថា* ***“អតីតបែបខ្លះ រលត់ទៅហើយ”*** *ជារបស់សកវាទី ។*

*អធិប្បាយខ្លឹមសារនៃបញ្ហានោះថា ប្រសិនបើអតីតធម៌បែបខ្លះមាន បែបខ្លះមិនមាន តាមលទ្ធិរបស់លោកមែន កាលបើមានសេចក្ដីដូច្នេះ*

អតីតធម៌បែបខ្លះដែលរលត់ទៅ និងអតីតធម៌បែបខ្លះដែលមិនទាន់រលត់ទៅ ក៏នឹងប្រាកដតាំងនៅដូចគ្នា ។ សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា ***"បែបខ្លះប្រាសចាកទៅហើយ"*** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យថា ***"ធម៌ដែលមិនឱ្យផល ជាអតីតបែបខ្លះ"*** នេះ លោកសកវាទីពោលហើយដើម្បីនឹងជំទាស់ថា លោកតែងប៉ងសេចក្ដីនៅមាននៃវិបាកដែលមិនទាន់ឲ្យផលទាំងឡាយ, ប៉ុន្តែសូម្បីធម៌នោះ ក៏ជាអតីតធម៌ទាំងអស់ដែរ, ព្រោះហេតុដូច្នោះ តាមលទ្ធិរបស់លោក អតីតធម៌បែបខ្លះ មាន យ៉ាងណា, ធម៌ទាំងឡាយ សូម្បីជាវិបាកដែលនៅមិនឲ្យផលបែបខ្លះ មាន បែបខ្លះ មិនមាន យ៉ាងនោះឬ ? ។ ពាក្យថា ***"ធម៌ដែលឱ្យផលហើយ"*** នេះ លោកពោលដើម្បីនឹងជំទាស់ដោយអំណាចនៃវិបាកធម៌ ដែលបរវាទីនោះ ប្រាថ្នាការមិនមាននៃធម៌ទាំងនោះ ។ ពាក្យថា ***"មិនមានវិបាក"*** នេះ លោកពោលដើម្បីនឹងជំទាស់ដោយអំណាចនៃសេចក្ដីជាអព្យាក្រឹតទាំងឡាយ ។ ពាក្យស្របផង ពាក្យបដិសេធផង ក្នុងអនុលោម និងបដិលោមទាំងពួង បណ្ឌិតគប្បីជ្រាបដោយ អំណាចនៃរាសីទាំង ៣ នេះ មានប្រការដូច្នេះ ។

ធម៌ គឺវិបាកដែលឲ្យផលហើយមួយចំណែក, នៅមិនឲ្យផលមួយចំណែក ដែលជាអតីត ធម៌ទាំងនោះ លោកហៅថា វិបាកដែលឲ្យផលមិនទាន់អស់ ។ ពិតណាស់ **បដិសន្ធិ** កើតហើយដោយកម្មណា, ភវង្គចិត្តក្តី

ចុតិចិត្តក្តី ក៏ជាវិបាករបស់កម្មនោះៗ ដែរ ព្រោះហេតុដូច្នោះ វិបាកនោះ តាំងពីបដិសន្ធិ រហូតដល់ចុតិ ទើបឈ្មោះថា ជាវិបាកដែលឲ្យផលមិនអស់ ។ ត្រង់សេចក្តីនេះ លោកពោលសំដៅយកធម៌ដូច្នោះ ។ ពាក្យសួរថា ***“ធម៌ទាំងនោះ ឈ្មោះថា មាន ព្រោះធ្វើអធិប្បាយថា នៅឱ្យផលឬ ?”*** ជារបស់សកវាទី ។ ធម៌ទាំងឡាយដែលប្រព្រឹត្តទៅដោយច្រើន លោកពោលថា សូម្បីមានដល់បុគ្គលអ្នកទ្រទ្រង់ធម៌ សូម្បីដល់អ្នកដេកលក់យ៉ាងណា, ពាក្យទទួលរបស់បរវាទី សំដៅយកសេចក្តីដែលនៅមាននៃធម៌ទាំងនោះ ដោយអំណាចនៃវោហារសម្រាប់លោក (ភាសានិយាយ) យ៉ាងនោះ ។ ក្នុងបញ្ហាទីពីរ ***“ឈ្មោះថា បច្ចុប្បន្ន ព្រោះធ្វើអធិប្បាយថា នៅឱ្យផលឬ ?”*** ពាក្យយល់ព្រមជារបស់បរវាទី ព្រោះតាំងនៅក្នុងលទ្ធិថា ឈ្មោះថា កម្មប្បច្ច័យណា មួយដែលបណ្ឌិតរាប់ហើយថា សេចក្តីវិនាសទៅមានហើយដល់កម្មទាំងឡាយ ។ សូម្បីក្នុងពាក្យជាដើមថា ***“អនាគតមានឬ?”*** សកវាទីពោលសំដៅយកធម៌ទាំងឡាយ ដែលនឹងកើតឡើងថា បែបខ្លះមាន ។ ពាក្យដែលនៅសល់ក្នុងទីទាំងពួង មានខ្លឹមសារងាយស្រួលទាំងអស់ ព្រោះមានន័យដូចបានពោលមកហើយក្នុងពេលមុន ៕

<u>ចប់ឯកច្ចមត្ថីតិកថា</u>

## ៩.សតិបដ្ឋានកថា សម្ដែងអំពីសតិបដ្ឋាន

*ឥឡូវនេះ ឈ្មោះថា រឿងសតិបដ្ឋាន ៖*

*ក្នុងរឿងនោះ លទ្ធិនៃជនទាំងឡាយណា យល់ឃើញថា ធម៌ទាំងពួងជាសតិបដ្ឋាន ព្រោះកាន់យកធម៌ទាំងឡាយមានកាយជាដើម ជាអារម្មណ៍ដោយសតិ តាមន័យដែលព្រះមានព្រះភាគត្រាស់ទុក ក្នុងសតិបដ្ឋានសំយុត្តថា* **“ចតុន្នំ សតិបដ្ឋានានំ ភិក្ខវេ សមុទយញ្ច អត្ថង្គមញ្ច ទេសិស្សាមិ** *= ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងហេតុកើតឡើង និងសេចក្ដីរលត់ទៅនៃសតិបដ្ឋានទាំង ៤” ដូចលទ្ធិនិកាយអន្ធកៈក្នុងខណៈនេះ ។ និកាយទាំងនោះ គឺ* ***បុព្វសេលិយៈ, អបរសេលិយៈ, រាជគិរិយៈ និងសិទ្ធត្ថិកៈ*** *ទាំងឡាយនេះ ឈ្មោះថា និកាយអន្ធកៈ ដែលជានិកាយកើតឡើង ក្នុងផ្នែកខាងក្រោយ ។ ពាក្យសួរដើម្បីតិះដៀលលទ្ធិនៃជនទាំងនោះ ជារបស់សកវាទី ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។*

*បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ពាក្យថា* ***សតិបដ្ឋាន*** *ដូច្នេះ ៖*

*ឈ្មោះថា* **បដ្ឋាន** *ព្រោះអត្ថថា តាំងមាំក្នុងធម៌ទាំងឡាយ មានកាយជាដើម ។* ***សួរថា*** *អ្វីរមែងតាំងមាំ ?, ឆ្លើយថា* ***សតិ,*** *ការតាំងមាំនៃសតិទាំងឡាយ សូម្បីមានសតិជាអារម្មណ៍ ក៏រមែងតាំងមាំ ដោយអត្ថនេះថា* ***“សតិយា បដ្ឋានា សតិបដ្ឋានា*** *= ការតាំងមាំនៃសតិ ឈ្មោះថា*

***សតិបដ្ឋាន"*** នេះ ព្រោះហេតុដូច្នោះ ការតាំងមាំនៃសតិទាំងនោះ ទើបឈ្មោះថា **បដ្ឋាន**, ***សួរថា*** បដ្ឋានអ្វីរមែងតាំងមាំ ? ឆ្លើយថា (បដ្ឋាន) គឺសតិរមែងតាំងមាំ ។ បដ្ឋាន គឺសតិ ឈ្មោះថា **សតិបដ្ឋាន** រមែងបាន ដោយអត្ថថា **"សតិយា ច បដ្ឋានា សតិបដ្ឋានា** = បដ្ឋាន គឺសតិ ឈ្មោះថា សតិបដ្ឋាន" នេះ ព្រោះហេតុណា, ព្រោះហេតុនោះ សូម្បីវាទៈទាំងពីរ គឺវាទៈរបស់សកវាទី និងបរវាទី រមែងត្រឹមត្រូវដោយបរិយាយ ។ ឯជនណាលះបរិយាយនេះ ហើយពោលថា ***"ធម៌ទាំងពួងជាសតិបដ្ឋាន"*** ដោយមួយផ្នែកប៉ុណ្ណោះ ពាក្យសួររបស់សកវាទីសំដៅដល់ជន ទាំងនោះ ពាក្យឆ្លើយយល់ព្រមដោយអំណាចនៃអារម្មណ៍ជារបស់បរវាទី ។ ប៉ុន្តែ ពេលសកវាទីសួរថា ***"ធម៌ទាំងពួងជាសតិឬ ?"*** ជាដើម បរវាទីក៏ឆ្លើយ បដិសេធ ព្រោះសភាវៈនៃធម៌ទាំងពួង មិនមែនជាសតិទាំងអស់ទេ ។

បណ្តាពាក្យទាំងនោះ ពាក្យថា **"ខយគាមី** = ជាហេតុឲ្យដល់សេចក្តីអស់ទៅ" ជាដើម ជាឈ្មោះពិសេសនៃមគ្គមែនពិត, **ឯកាយនមគ្គ** ឈ្មោះថា **ខយគាមី** ព្រោះអត្ថថា សម្រេចព្រះនិព្វានដែលជាហេតុអស់ទៅនៃកិលេសទាំងឡាយ ។ ឈ្មោះថា **ពោធគាមី** ជាហេតុឲ្យដល់ការត្រាស់ដឹង ព្រោះអត្ថថា ដល់ការត្រាស់ដឹងសច្ចៈ ៤ ។ ឈ្មោះថា **អបចយគាមី** ជាហេតុឲ្យដល់ព្រះនិព្វាន ព្រោះអត្ថថា ដល់ការទម្លាយវដ្តៈចេញ ។ សកវាទីសួរបទ

ទាំងនេះ ដោយសំដៅយកយ៉ាងនេះថា “ធម៌ទាំងឡាយ ជាឯកាយនមគ្គ មានហើយតាមលទ្ធិរបស់លោកយ៉ាងនេះឬ ?” ពាក្យទាំងឡាយ សូម្បីមានពាក្យថា ***“ធម៌ដែលមិនជាអារម្មណ៍របស់អាសវៈ ដែលមិនជាអារម្មណ៍របស់សញ្ញោជនៈ”*** ជាដើម សកវាទីពោលដើម្បីត្រូវការសួរដោយសេចក្តីជាលោកុត្តរ ។ ពាក្យទាំងឡាយថា **“ពុទ្ធានុស្សតិ ”** ជាដើម លោកពោលដោយពាក្យដែលចែកប្រភេទពីលោកុត្តរ ។ ពាក្យជាដើមថា ***“ចក្ខាយតនៈជាសតិបដ្ឋាន”*** លោកពោលដោយអំណាចនៃពាក្យសួរដែលជាប្រភេទនៃធម៌ទាំងពួង ។ សូម្បីក្នុងបញ្ហាទាំងនោះ បណ្ឌិតគប្បីជ្រាបសេចក្តីយ៉ាងនេះថា ***ពាក្យឆ្លើយបដិសេធមានហើយដោយអំណាចនៃសតិ, ពាក្យឆ្លើយតបមានហើយ ដោយអំណាចនៃអារម្មណ៍*** ។ ការជម្រះព្រះសូត្រមានសេចក្តីងាយស្រួលទាំងអស់ ដោយប្រការដូច្នេះឯង ៕

***ចប់សតិបដ្ឋានកថា***

## ១០.ហេវត្ថិតិកថា

## សម្តែងអំពីការមានដោយភាវៈយ៉ាងនេះ

ឥឡូវនេះ ឈ្មោះថា រឿងមានដោយភាវៈយ៉ាងនេះ ៖

ក្នុងរឿងនោះ លទ្ធិនៃជនទាំងឡាយណា ដូចលទ្ធិនិកាយអន្ធកៈ ក្នុងខណៈនេះ ដែលមានប្រភេទតាមដែលពោលមកហើយថា “ធម៌ទាំងឡាយដែលផ្សេងដោយអតីតធម៌ជាដើម សូម្បីទាំងអស់ មានដោយអំណាចនៃធម៌មានរូបធម៌ជាដើម ឬពេលអតីតធម៌ មិនមានដោយអំណាចនៃអនាគតនិងបច្ចុប្បន្ន ឬក៏អនាគត និងបច្ចុប្បន្ន មិនមានដោយអំណាចនៃអតីតធម៌ជាដើម ព្រោះហេតុដូច្នោះ ទើបវត្ថុទាំងពួងនោះៗ យ៉ាងនេះ មានយ៉ាងនេះ មិនមានឡើយ ” ដូច្នេះ, សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរបរវាទីថា “អតីតមានឬ ? ” ពាក្យវិសជ្ជនាថា {មានដោយភាវៈយ៉ាងនេះ មិនមានដោយភាវៈយ៉ាងនេះ ” ជារបស់បរវាទី ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **“ហេវ ”** លោកកែថា បានដល់ **ឯវំ** = យ៉ាងនេះ ឬដោយភាវៈយ៉ាងនេះ ។ លំដាប់នោះ សកវាទីពេលនឹងសួរថា បើអតីតធម៌យ៉ាងនេះមាន យ៉ាងនេះមិនមានមែន លុះកាលបើមានសេចក្ដីយ៉ាងនោះ អតីតធម៌នោះៗ ឈ្មោះថា មានអតីតធម៌នោះៗ ឈ្មោះថា មិនមាន ទើបពោលថា “មានក៏យ៉ាងនោះឯង មិនមាន ក៏យ៉ាងនោះឯងឬ ? ” បរវាទីសំដៅយកសេចក្ដីមាន នៃធម៌ទាំងនោះដោយសភាវៈនោះប៉ុណ្ណោះ ហើយសំដៅយកសេចក្ដីមិនមាន នៃធម៌ទាំងនោះដោយសភាវៈនោះប៉ុណ្ណោះ ទើបឆ្លើយបដិសេធ ។ ត្រូវសកវាទីសួរលើកទី ២

កំឆ្លើយយល់ព្រមសំដៅយកសេចក្តីមាន ដោយសភាវៈរបស់ខ្លួន និងសេចក្តីមិនមានដោយសភាវៈផ្សេង ។ ខាងមុខអំពីនេះទៅ ពាក្យថា ***"អត្ថថា មាន ក៏គឺអត្ថថា មិនមាន"*** អធិប្បាយថា សកវាទីសួរថា ភាវៈដែលជារបស់ខ្លួនមាន ភាវៈដែលជារបស់ខ្លួនមិនមាន ឈ្មោះថា រមែងមានឬ ? បណ្ឌិតគប្បីជ្រាបខ្លឹមសារក្នុងវារៈទាំងពួង ដោយឧបាយនេះចុះ ។ ក៏ក្នុងទីបំផុតទើបបរវាទីពោលពាក្យថា "បើដូច្នោះ អតីតក៏មានដោយភាវៈយ៉ាងនេះ, មិនមានដោយភាវៈយ៉ាងនេះទេ" ដូច្នេះ និងពាក្យជាដើមថា "បើដូច្នេះ រូបក៏មានដោយភាវៈយ៉ាងនេះ មិនមានដោយភាវៈយ៉ាងនេះ" ដូច្នេះ ដើម្បីឲ្យលទ្ធិតាំងទុក ក៏ពិតមែនហើយ, សូម្បីដូច្នោះ លទ្ធិនោះ ក៏ជាលទ្ធិដែលតាំងនៅមិនបានមែនពិត, ព្រោះជាលទ្ធិដែលតាំងទុកដោយប្រាសចាកយោនិសោមនសិការដូច្នេះដែរ ៕

## រួមកថាដែលមានក្នុងវគ្គនេះគឺ

១.បុគ្គលកថា, ២.បរិហានិកថា, ៣.ព្រហ្មចរិយកថា, ៤.ឱធិសោកថា, ៥.បជហតិកថា, ៦.សព្វមត្ថីតិវាទកថា, ៧.អតីតក្ខន្ធាតិអាទិកថា, ៨.ឯកច្ចមត្ថីតិកថា, ៩. សតិបដ្ឋានកថា, ១០. ហេវត្ថីតិកថា ។

**ចប់មហាវគ្គទី ១**

# វគ្គទី ២

## ១.បរូបហារកថា សម្តែងអំពីអ្នកផ្សេងនាំមកឱ្យ

ឥឡូវនេះ ឈ្មោះថា អ្នកផ្សេងនាំមកឲ្យ ៖

ក្នុងរឿងនោះ ជនពួកណារមែងសម្គាល់ថា “ទេវតាជាប់ជំពាក់ក្នុងពពួកមារនាំទៅដោយសេចក្តីគោរពទឹកសុក្កៈ គឺទឹកអសុចិចូលទៅដល់ព្រះអរហន្តបាន ព្រោះឃើញការធ្លាក់ទឹកសុក្កៈ គឺអសុចិរបស់ជនទាំងឡាយអ្នកបដិញ្ញាណខ្លួនថា ជាព្រះអរហន្ត’ អ្នកបោកបញ្ឆោត អ្នកក្រអឺតក្រទម អ្នកសម្គាល់ក្នុងធម៌ដែលខ្លួនមិនបានសម្រេចថា សម្រេចហើយ’ ឬអ្នកបដិបត្តិដើម្បីភាពជាព្រះអរហន្ត ដូចនិកាយបុព្វសេលិយៈ និងអបរសេលិយៈទាំងឡាយ ក្នុងពេលនេះ* ” សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរបរវាទីថា “ការបញ្ចេញសុក្កៈ គឺអសុចិរបស់ព្រះអរហន្តមានឬ ?” ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។

ឥឡូវនេះ ឈ្មោះថា ការបញ្ចេញទឹកសុក្កៈ រមែងមានព្រោះរាគៈជាសមុដ្ឋាន ព្រោះហេតុណា, ព្រោះហេតុនោះ ទើបសកវាទីផ្តើមសាកសួរថា

---

* ពាក្យថា នេះ តាមទំនង ប្រហែលជាលោកប្រើនៅក្នុងសម័យដែលកំពុងរចនាគម្ពីរនេះ ។

***"រាគៈរបស់ព្រះអរហន្តមានឬ ?"*** *សូម្បីខ្ទឹមសារទាំងអស់នោះ មានអត្ថងាយស្រួលណាស់ ។*

*ក្នុងបញ្ហាថា* ***"ទេវតាបក្ខពួកមារនាំចូលទៅនូវការបញ្ចេញទឹកសុក្កៈគឺអសុចិដល់ខ្លួនបាន"*** *ជាដើម សេចក្តីថា ក៏ឈ្មោះថា ការក្លែងទឹកសុក្កៈរបស់ទេវតាទាំងនោះ រមែងមិនមាន, ទាំងពួកទេវតានោះ កាន់យកទឹកសុក្កៈរបស់ជន សូម្បីពួកផ្សេងបង្អោននាំចូលទៅ ក៏មិនមាន, ទាំងទឹកសុក្កៈរបស់ព្រះអរហន្តនោះ ក៏មិនមានដែរ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបបរវាទីបដិសេធថា* ***" មិនគប្បីពោលយ៉ាងនេះទេ"*** *។*

*ក្នុងបញ្ហាថា* ***"ទេវតាបក្ខពួកមារនាំចូលទៅនូវការបញ្ចេញទឹកសុក្កៈគឺអសុចិពីខ្លួន ក៏មិនមាន"*** *សេចក្តីថា បរវាទីនោះរមែងឆ្លើយយល់ព្រម ព្រោះលទ្ធិថា ក៏ទេវតានិមិត្តហើយនាំចូលទៅ ក្នុងបញ្ហាថា* ***"នាំចូលទៅតាមរន្ធរោមឬ ?"*** *បរវាទីបដិសេធ ព្រោះយល់ឃើញថា មិនមានការនាំចូលទៅតាមរន្ធរោមទាំងឡាយ ដូចការនាំទឹកដោះថ្លា និងប្រេងទាំងឡាយទេ ។*

*ពាក្យថា* **"ហន្ទ ហិ"** *ជានិបាត ចុះក្នុងអត្ថដែលប្រព្រឹត្តទៅដោយអំណាចនៃសេចក្តីពិសេស ។ អធិប្បាយថា ពួកទេវតាអ្នករាប់អានក្នុងពួកមារគិតថា "យើងនឹងកាន់យកសេចក្តីសង្ស័យយ៉ាងនេះថា លោកជាព្រះអរហន្ត*

ឬមិនមែនជាព្រះអរហន្តហ្ន៎ ?” ហើយនាំចូលទៅធ្វើឲ្យប្រព្រឹត្តទៅ ក្នុងអំណាចនៃសេចក្តីពិសេសយ៉ាងនេះ ។ ត្រូវសកវាទីសួរថា ***“សេចក្តីសង្ស័យរបស់ព្រះអរហន្តមានឬ ?”*** បរវាទីសំដៅយកសេចក្តីសង្ស័យមានវត្ថុ ៨ ប្រការ ទើបឆ្លើយបដិសេធ ។ ត្រូវសកវាទីសួរលើកទីពីរ ក៏ឆ្លើយយល់ព្រម ព្រោះសំដៅយកមិនមានការធ្លាក់ចិត្តចុះ គឺមិនដឹងក្នុងនាម និងគោត្រជាដើម នៃស្ត្រី និងបុរសជាដើម ។

ពាក្យថា ***“សេចក្តីប្រាថ្នារបស់លោកនៅមានឬ ?”*** សេចក្តីថា សកវាទី សួរថា ឱកាសដែលជាទីតាំងនៅនៃទឹកសុក្កៈនោះមាន ដូចឱកាសជាទីតាំងនៅនៃឧច្ចារៈ និងបស្សាវៈឬ ?

ពាក្យថា ***“អ្នកឈ្លាសក្នុងធម៌របស់ខ្លួន”*** បានដល់ អ្នកឈ្លាសត្រឹមតែធម៌ដែលជាព្រះអរហន្តរបស់ខ្លួនប៉ុណ្ណោះ, ត្រង់នេះ លោកសំដៅយកព្រះអរហន្តអ្នករួចផុតដោយបញ្ញា ទើបពោលដូច្នោះ ។ ពាក្យថា ***“អ្នកឈ្លាសក្នុងធម៌ដទៃ”*** បានដល់ អ្នកឈ្លាសសូម្បីក្នុងធម៌ដែលជាសមាបត្តិ ៨ ផ្សេងក្រៅអំពីព្រះសទ្ធម្ម, ត្រង់នេះ លោកសំដៅយកព្រះអរហន្តជាឧភតោ-ភាគវិមុត្ត ទើបពោលយ៉ាងនោះ ។ ពាក្យដែលនៅសល់ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយទំនងដែលពោលហើយក្នុងព្រះបាលីនុ៎ះឯង ៕

***ចប់បរូបហារកថា***

## ២-៣-៤.អញ្ញាណ-កង្ខា-បរវិតរណកថា *

## សម្តែងអំពីការមិនដឹង ការសង្ស័យ និងការណែនាំរបស់អ្នកដទៃ

*ឥឡូវនេះ ឈ្មោះថា រឿងទាំង ៣ គឺរឿងការមិនដឹង ១ ការសង្ស័យ ១ និងការណែនាំរបស់អ្នកដទៃ ១ ៖*

*ក្នុងរឿងទាំងនោះ ជនណាមានលទ្ធិ គឺមានសេចក្តីយល់ឃើញខុសដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយក្នុងខណៈនេះថា “* **អញ្ញាណ** *គឺសេចក្តីមិនដឹងរបស់ព្រះអរហន្តមាន ព្រោះមិនមានញាណកើតឡើង ក្នុងឈ្មោះ និងគោត្រជាដើមនៃជនទាំងឡាយ មានស្ត្រី និងបុរសជាដើមផង ។* **កង្ខា** *គឺការសង្ស័យរបស់ព្រះអរហន្តមាន ព្រោះមិនមានការសន្និដ្ឋាន គឺការដាក់ចិត្តចុះក្នុងរឿងនោះៗ ផង, ឯជនពួកផ្សេងរមែងណែនាំ រមែងប្រកាស រមែងប្រាប់រឿងទាំងឡាយដល់ព្រះអរហន្តទាំងនោះ, ព្រោះហេតុនោះ ការណែនាំដល់ព្រះអរហន្តទាំងនោះ ទើបមាន ដូច្នេះ សូម្បីពាក្យសួរក្នុងរឿងទាំង ៣ របស់សកវាទី គឺដើម្បីទម្លាយនូវលទ្ធិនៃជនទាំងនោះ ។ ពាក្យឆ្លើយយល់ព្រម និងពាក្យបដិសេធជារបស់បរវាទី ។ សូម្បីក្នុងបញ្ហា និងពាក្យវិសជ្ជនាទាំងពួង បណ្ឌិតគប្បីជ្រាបខ្លឹមសារតាម*

---

* បាលីបិដកជា **បរវិតារណាកថា។**

ព្រះបាលីដែលមានមកហើយដោយលំដាប់នុ៎ះចុះ ។

**ចប់អញ្ញាណ-កង្ខា-បរវិតរណកថា**

======================

## ៥.វចីភេទកថា សម្តែងអំពីការបន្លឺវាចា

ឥឡូវនេះ ឈ្មោះថា រឿងការបន្លឺវាចា ៖

ក្នុងបញ្ហានោះ ជនណាមានលទ្ធិ គឺសេចក្តីយល់ឃើញខុស ដូចនិកាយទាំងឡាយ មាននិកាយបុព្វសេលិយៈជាដើម ក្នុងខណៈនេះថា "ពេលបុគ្គលចូលបឋមជ្ឈានក្នុងខណៈនៃសោតាបត្តិមគ្គកើត គេរមែងបន្លឺវាចាថា ទុក្ខ" ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា ***"ការបន្លឺវាចារបស់អ្នកចូលឈានមានឬ ?"*** , ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ព្រោះតាំងនៅក្នុងលទ្ធិ ។ ត្រូវសកវាទីសួរសំដៅយកភពទាំង ៣ ដោយពាក្យថា ***"ក្នុងភពទាំងពួង"*** ដូច្នេះទៀត បរវាទីឆ្លើយបដិសេធសំដៅយកអរូបភព ។ ត្រូវសកវាទីសួរដល់កាលដោយពាក្យថា ***"ក្នុងកាលទាំងពួង"*** ដូច្នេះ បរវាទីបដិសេធ ព្រោះសំដៅយកកាលជាទីចូលឈានទាំងពួង ផ្សេងក្រៅអំពីការចូលឈានដែលប្រកបដោយបឋមជ្ឈានក្នុងខណៈនៃសោតាបត្តិមគ្គ ។ ត្រូវសកវាទីសួរដោយពាក្យថា ***"របស់អ្នកចូលឈានទាំងពួងឬ ?"*** , បរវាទី

*បដិសេធសំដៅយកអ្នកចូលឈានជាលោកិយសមាបត្តិ ។ ត្រូវសកវាទីសួរថា* ***“ក្នុងសមាបត្តិទាំងពួងឬ ?”*** *ក៏ឆ្លើយបដិសេធសំដៅយកលោកុត្តរដែលសម្បយុត្តដោយទុតិយជ្ឈាន និងលោកិយសមាបត្តិទាំងពួង ។ ពាក្យថា* ***“ការកម្រើកកាយ”*** *បានដល់ កាយវិញ្ញត្តិ គឺការកម្រើកផ្លូវកាយ ដែលប្រព្រឹត្តទៅដោយអំណាចនៃឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម ។ សកវាទីនោះ រមែងសួរដើម្បីព្រមានដោយពាក្យថា “ ចិត្តណារមែងញុំាងវចីវិញ្ញត្តិឲ្យកើតឡើង, ចិត្តនោះៗ រមែងញុំាងកាយវិញ្ញត្តិឲ្យកើតឡើងដូចគ្នា; កាលបើមានសេចក្ដីដូច្នេះ ព្រោះហេតុអ្វី សូម្បីការកម្រើកកាយទើបមិនមាន ។ បរវាទីឆ្លើយបដិសេធផង ឆ្លើយយល់ព្រមផងដោយអំណាចនៃលទ្ធិ (របស់ខ្លួន) ។*

*ឥឡូវនេះ លោកពោលបញ្ហាទាំងឡាយ មានពាក្យថា* ***“ពេលដឹងថាទុក្ខ”*** *ជាដើម ដើម្បីព្រមានដោយពាក្យថា “បើបុគ្គលនោះ ពោលវាចាក្នុងខណៈនៃមគ្គថា* ***ទុក្ខ*** *ដូច្នេះមែន, គេក៏គប្បីពោលសូម្បីនូវពាក្យថា* ***សមុទ័យ*** *ជាដើមដែរ, ឬថា បើគេមិនពោលពាក្យនោះទេ, គេក៏មិនគប្បីពោលពាក្យសូម្បីក្រៅពីនេះដែរ” ។ ចំណែកបរវាទីឆ្លើយយល់ព្រមផងឆ្លើយបដិសេធផង ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ ពិតណាស់ លទ្ធិ*

របស់គេថា "បុគ្គលចូលលោកុត្តរបឋមជ្ឈានហើយ រមែងឃើញច្បាស់នូវទុក្ខថា ជាទុក្ខមែន" ។

ពាក្យថា **"ញាណំ"** បានដល់ សច្ចញ្ញាណ ៤ ដែលជាលោកុត្តរ ។ ពាក្យថា **"សោតំ"** លោកប្រាថ្នាយកសោតវិញ្ញាណ អធិប្បាយថា រមែងស្តាប់សំឡេងនោះ ដោយចិត្តបាន ។

ពាក្យថា ***"ការប្រជុំនៃផស្សៈទាំង ២"*** បានដល់ ត្រង់សោតសម្ផស្សនិងមនោសម្ផស្ស ។ ត្រង់ពាក្យថា ***"ក៏មិនត្រូវពោលថា"*** អធិប្បាយថា បើការបន្លឺវាចាមានដល់អ្នកចូលឈានយ៉ាងណាមួយមែន, ក៏មិនត្រូវពោលថា ការបន្លឺវាចា មានដល់អ្នកចូលឈានយ៉ាងណាមួយផងដែរ ។ ពាក្យដែលនៅសល់ក្នុងទីនេះ ព្រមទាំងការជម្រះព្រះសូត្រ មានខ្លឹមសារងាយស្រួលទាំងអស់ ។

៦ ព្រះសូត្រដែលបរវាទីនាំមកក្នុងទីបំផុតនៃបញ្ហាថា ***"ម្នាលអានន្ទ សាវក ឈ្មោះថា អភិភូ របស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ព្រះនាមថា សិខី ស្ថិតនៅក្នុងព្រហ្មលោក បានប្រកាសមួយម៉ឺនលោកធាតុដោយសំឡេងថា លោកទាំងឡាយ ចូរផ្តើម ចូរឧស្សាហ៍ ចូរប្រកបសេចក្តី***

*ព្យាយាមក្នុងព្រះពុទ្ធសាសនា ចូរកម្ចាត់សេនានៃស្តេចមច្ចុរាជ ។ល។” ។*

ក្នុងព្រះសូត្រនេះ ការបន្លឺវាចានេះ រមែងកើតឡើងដោយចិត្តនៃសមាបត្តិណា, សូម្បីកាយភេទ គឺការកម្រើកកាយ ក៏រមែងកើតឡើងដោយចិត្តនៃសមាបត្តិនោះៗ ; ប៉ុន្តែចិត្តដែលធ្វើឲ្យវចីវិញ្ញត្តិ និងកាយវិញ្ញត្តិកើតឡើង មិនមែនបឋមជ្ឈានចិត្តដែលជាលោកុត្តរ ព្រោះហេតុដូច្នោះ ព្រះសូត្រដែលបរវាទីនាំមកនោះ ទើបមិនសម្រេចជាប្រយោជន៍ឡើយ ៕

ចប់វចីភេទកថា

## ៦.ទុក្ខាហារកថា សម្តែងអំពីការពោលថា “ទុក្ខ”

ឥឡូវនេះ ឈ្មោះថា រឿងការពោលថា “ទុក្ខ” ៖

ក្នុងបញ្ហានោះ លទ្ធិនៃជនពួកណា ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយ ក្នុងខណៈនេះថា “ពេលមាននរណាមួយ ពោលវាចាថា ទុក្ខ ទុក្ខ’ ដូច្នេះ អ្នកនោះ ឈ្មោះថា រមែងនាំមកនូវញាណក្នុងទុក្ខនេះ, លោកហៅថា ទុក្ខាហារ ហើយទុក្ខាហារនោះឯង លោកហៅថា ជាមគ្គង្គៈ គឺអង្គនៃមគ្គ និងទាក់ទងដោយមគ្គ” ដូច្នេះ សកវាទីសំដៅយកជនទាំងនោះ ទើបសួរបរវាទីថា “ការពោលថា ទុក្ខ ការនាំមកនូវញាណក្នុងទុក្ខ” ដូច្នេះ ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ក្នុងបញ្ហាដំបូងថា “នរណាមួយ” បរវាទី

សំដៅយកអ្នកមិនឃើញច្បាស់ ទើបឆ្លើយបដិសេធ, ក្នុងបញ្ហាខទី ២ បរវាទីឆ្លើយយល់ព្រមសំដៅយកអ្នកឃើញច្បាស់ ។ ក៏ការឃើញច្បាស់ ឬការមិនឃើញច្បាស់នោះ គ្រាន់តែជាលទ្ធិរបស់បរវាទីនោះប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ ដើម្បីទម្លាយវាទៈថា "ជនទាំងនោះឃើញច្បាស់ ឬមិនឃើញច្បាស់" របស់បរវាទីនោះ ទើបសកវាទីសួរថា "ពាលបុថុជ្ជន" ជាដើម ។ ត្រង់សេចក្ដីនោះ មានអត្ថងាយស្រួលមែនពិត ៕

ចប់ទុក្ខាហារកថា

## ៧.ចិត្តដ្ឋិតិកថា សម្ដែងអំពីការតាំងនៅនៃចិត្ត

ឥឡូវនេះ ឈ្មោះថា រឿងការតាំងនៅនៃចិត្ត ៖

ក្នុងបញ្ហានោះ លទ្ធិនៃជនពួកណាថា " ចិត្ត ១ ដួងប៉ុណ្ណោះ រមែងតាំងនៅអស់កាលយូរ" ព្រោះឃើញចិត្តនៃសមាបត្តិ និងភវង្គចិត្តដែលប្រព្រឹត្តទៅជាប់តគ្នាដោយលំដាប់ ដូចលទ្ធិនិកាយអន្ធកៈទាំងឡាយ ក្នុងខណៈនេះ ដែលមានប្រភេទតាមដែលពោលហើយក្នុងគ្រាក្រោយ ដើម្បីជម្រះលទ្ធិនោះ ទើបសកវាទីសួរបរវាទីថា **"ចិត្ត ១ ដួងតាំងនៅបានស្ទើមួយថ្ងៃឬ ?"** ជាដើម បរវាទីឆ្លើយយល់ព្រមថា **"មែន"** ។

ក្នុងបញ្ហាថា **"កន្លះថ្ងៃជាខណៈកើត"** នេះ លោកធ្វើពាក្យសួរ

ដោយអំណាចនៃការកើត និងការរលត់ដោយន័យទេសនាថា **“សង្ខារទាំងឡាយ មិនទៀងហ្ន៎ ! មានការកើតឡើងហើយ មានសេចក្ដីសាបសូន្យទៅជាធម្មតា”** ដោយមិនប្រកាន់យកខណៈតាំងនៅនៃចិត្ត ។

ត្រូវសកវាទីសួរថា **“ធម៌ទាំងនោះ ផ្លាស់ប្ដូរទៅរហ័សជាងចិត្តឬ ?”** បរវាទីនោះ ពេលមិនឃើញធម៌ទាំងឡាយកើតរលត់រហ័សជាងចិត្ត ទើបឆ្លើយបដិសេធ, ត្រូវសកវាទីសួរគ្រាទីពីរ លោកប្រាថ្នាយកការតាំងនៅ ដែលជាវេលាយូរនៃចិត្តណា, ដោយសំដៅយកចិត្តនោះ ទើបឆ្លើយយល់ព្រម ។

ក្នុងបញ្ហាទាំងឡាយថា **“ចិត្តមួយដួងតាំងនៅរហូតអស់អាយុឬ ?”** សេចក្ដីថា បរវាទីរមែងឆ្លើយបដិសេធដោយវៀរអរូប និងរមែងឆ្លើយយល់ព្រមអ្នកដែលកើតក្នុងអរូបដោយអំណាចនៃព្រះបាលីថា “ទេវតាទាំងឡាយណា រមែងតាំងនៅរហូត ៨៤.០០០ កប្បជាដើម” ។

ក្នុងបញ្ហាថា **“ចិត្តរមែងកើតឡើងមួយស្របក់”** ជារបស់បរវាទី សកវាទីយល់ព្រម ព្រោះខ្លាចខុសចាកព្រះសូត្រថា **“សង្ខារទាំងឡាយមានការកើតឡើង ហើយមានសេចក្ដីសាបសូន្យទៅជាធម្មតា”** ជាដើម, ប៉ុន្តែបរវាទីនោះ រមែងប្រាថ្នាការតាំងនៅនៃចិត្ត ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ ពាក្យដែលនៅសល់ក្នុងទីនេះ មានអត្ថងាយស្រួលទាំងអស់ ៕

**ចប់ចិត្តដ្ឋិតិកថា**

## ៨.កុក្កុឡកថា សម្តែងអំពីផេះក្តៅ គឺសេចក្តីក្តៅគគុក

*ឥឡូវនេះ ឈ្មោះថា រឿងផេះក្តៅ ៖*

*ក្នុងរឿងនោះ ជនពួកណាមានលទ្ធិ គឺមានសេចក្តីយល់ឃើញខុស ដូចនិកាយគោលិកៈទាំងឡាយ ក្នុងខណៈនេះថា* ***“សង្ខារទាំងពួង ដូចផេះក្តៅ គឺស្មើគ្នានឹងធារិកនរកដែលលាយដោយរងើកភ្លើង យ៉ាងពិតប្រាកដ”*** *ព្រោះមិនពិចារណា កាន់យកព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ទុកថា* ***“ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជារបស់ក្តៅ សង្ខារទាំងពួងជាទុក្ខ”*** *ជាដើម ពាក្យសួររបស់សកវាទីដើម្បីរិះគន់ គឺទិតៀនលទ្ធិនោះ ដោយការឈ្លបបញ្ឆោកដល់សេចក្តីសុខមានប្រការផ្សេងៗ របស់សង្ខារទាំងនោះ ។ ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ក្នុងបញ្ហានោះ មានពាក្យថា* ***“ មិនមានឱកាសទំនេរឬ ?”*** *បានដល់ ធ្វើខេត្តដែនចំណែកមួយ គឺសំដៅសេចក្តីថា មិនធ្វើវត្ថុទាំងពួងនោះៗ ឲ្យប្លែកគ្នា ។ ពាក្យដែលនៅសល់ក្នុងទីទាំងពួង គប្បីជ្រាបដោយន័យដែលសម្តែងទុកហើយ ក្នុងបាលី ព្រមទាំងការជម្រះព្រះសូត្រនុ៎ះចុះ ៕*

ចប់កុក្កុឡកថា

## ៩.អនុបុព្វាភិសមយកថា សម្តែងអំពីការត្រាស់ដឹងដោយលំដាប់

*ឥឡូវនេះ រឿងការត្រាស់ដឹងដោយលំដាប់ ៖*

*ក្នុងរឿងនោះ លទ្ធិនៃការត្រាស់ដឹងផ្សេងៗ របស់ជនពួកណា ដូចលទ្ធិរបស់និកាយអន្ធកៈ និកាយសព្វត្ថិកៈ និកាយសមិតិយៈ និងនិកាយភទ្រយានិកៈទាំងឡាយ ក្នុងខណៈនេះ ដែលកើតឡើងហើយយ៉ាងនេះថា "បុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល រមែងលះកិលេសទាំងឡាយបានខ្លះៗ ដោយការឃើញនូវទុក្ខ រមែងលះកិលេសបែបខ្លះៗ បាន ដោយឃើញសមុទ័យ... និរោធ... និងមគ្គ ដោយទំនងដូចគ្នានេះឯង រមែងលះកិលេសទាំងឡាយដែលនៅសល់ ព្រោះធ្វើការលះកិលេស ដោយលំដាប់ ១៦ ចំណែកយ៉ាងនេះ មានប្រការដូច្នេះ ទើបសម្រេចភាពជាព្រះអរហន្ត" ដូច្នេះ ដោយមិនពិចារណាកាន់យកព្រះសូត្រទាំងឡាយ ដែលព្រះមានព្រះភាគត្រាស់ទុកថា ៖*

***"អ្នកមានបញ្ញា គប្បីកម្ចាត់មន្ទិលរបស់ខ្លួនដែលលះបន្តិចៗ គ្រប់ៗខណៈ ដូចជាងមាសកម្ចាត់មន្ទិលមាសដូច្នោះ"*** *ដើម្បីតិះដៀលលទ្ធិនៃជនទាំងនោះ ទើបសកវាទីសួរថា* ***"ការត្រាស់ដឹងធម៌ ជាការត្រាស់ដឹងដោយលំដាប់ឬ ?"*** *ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ត្រូវសកវាទីសួរថា*

“បុគ្គលញ៉ាំងសោតាបត្តិមគ្គឲ្យកើតឡើងបានដោយលំដាប់ឬ ?” បរវាទីបដិសេធ ព្រោះខ្លាចថា “ការត្រាស់ដឹងមានចំនួនច្រើន ជារបស់មគ្គមួយ” ។ ត្រូវសកវាទីសួរលើកទីពីរ ក៏ឆ្លើយយល់ព្រម ដោយអំណាចនៃការឃើញទុក្ខជាដើម ។ ម្យ៉ាងទៀត បរវាទីរមែងឆ្លើយយល់ព្រមថា “សូម្បីញាណទាំង ៤ នោះ ជាសោតាបត្តិមគ្គមួយប៉ុណ្ណោះ, ប៉ុន្តែ រមែងប្រាថ្នាផលត្រឹមតែមួយ” ព្រោះហេតុដូច្នោះ ទើបបដិសេធ ។ សូម្បីក្នុងសកទាគាមិមគ្គជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ក្នុងបញ្ហាថា ***“ពេលឃើញមគ្គហើយ គប្បីពោលថាតាំងនៅហើយក្នុងផលឬ ?”*** អធិប្បាយថា ការឃើញទុក្ខជាដើម នៅមិនសម្រេច, ប៉ុន្តែការឃើញនោះ ឈ្មោះថា សម្រេចដោយការឃើញរបស់មគ្គហើយŸ បន្ទាប់អំពីនោះ ទើបដល់នូវការរាប់ថា អ្នកនោះតាំងនៅក្នុងផល ព្រោះហេតុណា, ព្រោះហេតុនោះ ទើបបរវាទីឆ្លើយយល់ព្រមថា ***“មែន”*** ។

ពាក្យសួររបស់បរវាទីថា ***“ពេលឃើញទុក្ខហើយ សច្ចៈទាំង ៤ ក៏ប្រាកដថាបានឃើញហើយឬ ?”*** សកវាទីឆ្លើយយល់ព្រមដោយអំណាចនៃការត្រាស់ដឹងសច្ចៈ ៤ នោះព្រមគ្នា ។ ពេលបញ្ជាក់ទៀតថា ***“ទុក្ខសច្ចជាសច្ចៈទាំង ៤ ឬ ?”*** សកវាទីនោះឯង ឆ្លើយបដិសេធ ព្រោះសច្ចៈ

*ទាំង ៤ មានសភាវៈផ្សេងគ្នា ។ ពាក្យសួរថា **“ពេលឃើញរូបក្ខន្ធ ដោយភាពជារបស់មិនទៀងហើយ ?”** ជារបស់សកវាទី, ពាក្យយល់ព្រមជារបស់បរវាទី ព្រោះលទ្ធិរបស់លោកថា “ពេលបុគ្គលចាក់ធ្លុះធម៌ឯណា ដោយភាពជារបស់មិនទៀងហើយ, ឈ្មោះថា ជាអ្នកចាក់ធ្លុះធម៌ សូម្បីទាំងអស់ ដូចបុគ្គលដឹងរសនៃទឹក ត្រឹមតែមួយតំណក់អំពីសមុទ្រ រមែងជាអ្នកឈ្មោះថា ដឹងរសដែលនៅសល់” ។*

*ពាក្យថា **“ដោយញាណ ៤”** បានដល់ ដោយញាណក្នុងទុក្ខជាដើម គឺញាណក្នុងអរិយសច្ច ៤ ។ ពាក្យថា **“ដោយញាណ ៨”** បានដល់ ដោយសច្ចញ្ញាណ ៤ ដែលទូទៅដល់សាវកទាំងឡាយ និងបដិសម្ភិទាញាណ ៤ ។ ពាក្យថា **“ដោយញាណ ១២”** បានដល់ ញាណក្នុងបដិច្ចសមុប្បាទដែលមានអង្គ ១២ ។ ពាក្យថា **“ដោយញាណ ៤៤”** បានដល់ ដោយញាណដែលលោកពោលទុកក្នុងនិទានវគ្គ យ៉ាងនេះថា “ញាណក្នុងជរា មរណៈ និងញាណក្នុងហេតុកើតឡើងនៃជរា និងមរណៈ” ។ ពាក្យថា **“ដោយញាណ ៧៧”** បានដល់ ដោយញាណដែលលោកពោលទុកក្នុងនិទានវគ្គនោះៗ យ៉ាងនេះថា “ម្នាលភិក្ខុទាំងឡាយ ជរា និងមរណៈ ជារបស់មិនទៀង ជាសង្ខតៈ កើតឡើងហើយ ព្រោះអាស្រ័យគ្នា មានការអស់ទៅ ជាធម្មតា*

មានការប្រែប្រួលទៅជាធម្មតា មានការរលត់ទៅ ជាធម្មតា” ។ ពាក្យដែលនៅសល់ក្នុងទីនេះ គប្បីជ្រាបដោយន័យតាមព្រះបាលី ព្រមជាមួយការជម្រះព្រះសូត្រនុ៎ះចុះ ៕

## ចប់អនុបុព្វាភិសមយកថា

## ១០.វោហារកថា សម្តែងអំពីវោហារ

ឥឡូវនេះ ឈ្មោះថា រឿងវោហារ គឺពាក្យសម្តីដែលហៅវត្ថុផ្សេងៗ ៖

ក្នុងរឿងនោះ លទ្ធិនៃជនទាំងឡាយណាក្នុងខណៈនេះ ដូចលទ្ធិនិកាយអន្ធកៈថា “ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងហើយ រមែងត្រាស់ដឹង ហៅដោយពាក្យដែលជាលោកុត្តរ” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅយកជនទាំងនោះ ។ ពាក្យឆ្លើយយល់ព្រម ជារបស់បរវាទី ដោយអំណាចនៃលទ្ធិ ។ ពាក្យថា ***“សោតៈដែលជាលោកុត្តរ”*** ជាដើម លោកពោលហើយ ដើម្បីសម្តែងសេចក្តីដែលបរវាទីនោះមិនគួរនឹងពោល គឺជាពាក្យដែលមិនត្រឹមត្រូវ ។ ក្នុងកន្លែងនេះ លោកអធិប្បាយទុកថា សទ្ទាយតនៈនោះៗ លោកមិនគួរពោលថា ជាលោកុត្តរ ឬថា សូម្បីសោតៈជាដើមក៏ដូចគ្នា ។

ក្នុងពាក្យថា ***“ប្រសិនបើព្រះតម្រាស់របស់ព្រះមានព្រះភាគ ប៉ះពាល់***

***សោតៈដែលជាលោកិយ"*** នេះ សេចក្តីថា បុគ្គលមិនគប្បីកាន់យកខ្លឹមសារយ៉ាងនេះថា បើព្រះតម្រាស់របស់ព្រះមានព្រះភាគនោះ ប៉ះពាល់លោកុត្តរទាំងឡាយ, ព្រះតម្រាស់ក៏គប្បីជាលោកុត្តរដែរ ។ ក្នុងសេចក្តីនេះ កាលបើព្រះតម្រាស់របស់ព្រះមានព្រះភាគប៉ះពាល់ដល់លោកិយ, ព្រះតម្រាស់នោះក៏មិនបានឈ្មោះថា ជាលោកុត្តរទេ ។ សូម្បីក្នុងពាក្យថា ***"ដោយវិញ្ញាណដែលជាលោកិយ"*** នេះ បានដល់ ដោយលោកិយប៉ុណ្ណោះ ។ សេចក្តីជាលោកិយដោយប្រការដទៃនោះ មានប្រការមិនមែនតិច ។ ពិតណាស់ លោកុត្តរមែនដឹងបាន សូម្បីដោយញាណជាលោកិយ ។ បណ្ឌិតគប្បីជ្រាបខ្លឹមសារទាំងពួង ដោយសមគួរយ៉ាងនេះចុះ ។

ក្នុងបញ្ហាទាំងឡាយ មានពាក្យថា ***"ជនទាំងអស់នោះ ឈ្មោះថាញុំាងមគ្គឱ្យកើតបានឬ ?"*** ជាដើម បរវាទីរមែងបដិសេធ ព្រោះសំដៅយកអ្នកមិនបានមគ្គ, ប៉ុន្តែ យល់ព្រមសំដៅយកអ្នកបានមគ្គ ។ ពាក្យថា ***"ប្រើឈើច្រត់មាស"*** បានដល់ ឈើច្រត់សម្រេចហើយដោយមាសសន្ទឹក, ឧទាហរណ៍នេះ ជារបស់បរវាទី ។ ពាក្យថា ***"ឈើច្រត់ដើមល្ហុង"*** បានដល់ ឈើច្រត់ដែលធ្វើអំពីដើមល្ហុង, ពាក្យនេះជាឧទាហរណ៍របស់សកវាទី ។

ឯលទ្ធិមួយរបស់និកាយអន្ធកៈពួកខ្លះថា ***"ពេលព្រះពុទ្ធជាម្ចាស់ ត្រាស់លោកិយធម៌ ក៏ជាលោកិយធម៌"*** ។ ពាក្យដែលនៅសល់ក្នុងទីនេះ មានខ្លឹម

សារផាយស្រួលទាំងអស់នុ៎ះឯង ៕

ចប់វោហារកថា

## ១១.និរោធកថា សម្តែងអំពីនិរោធ

ឥឡូវនេះ ឈ្មោះថា រឿងនិរោធ គឺសេចក្តីរលត់ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្តីយល់ឃើញថា "រួមនិរោធទាំងពីរ គឺអប្បដិសង្ខារនិរោធ បានដល់ការរលត់ ដោយមិនប្រើបញ្ញាជាគ្រឿងពិចារណា និងបដិសង្ខារនិរោធ គឺការរលត់ ដោយប្រើបញ្ញាជាគ្រឿងពិចារណាទាំងពីរនេះចូលគ្នា ទើបឈ្មោះថា និរោធសច្ច" ដូច្នេះ ដូចនិកាយមហិសាសកៈ និងនិកាយអន្ធកៈ ក្នុងខណៈនេះ, សកវាទីសំដៅយកជនទាំងនោះ ទើបសួរថា ***"និរោធមាន ២ ឬ ?"*** ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ក្នុងបញ្ហាថា ទុក្ខនិរោធមាន ២ ឬ ? បរវាទីមិនប្រាថ្នាទុក្ខសច្ចមាន ២ ដោយហេតុណា, ព្រោះហេតុនោះ ទើបឆ្លើយបដិសេធ, តែប្រាថ្នាថា ទុក្ខរមែងរលត់ទៅដោយអាការ ២ យ៉ាង ព្រោះហេតុដូច្នោះ ទើបទទួលរ៉ាប់រងក្នុងបញ្ហាថា ***"និរោធសច្ចមាន ២ ឬ ?"*** បរវាទីពេលមិនប្រាថ្នាដោយអំណាចនៃការរលត់ទុក្ខសច្ចមាន ២ យ៉ាង ទើបឆ្លើយបដិសេធ, ប៉ុន្តែ ឆ្លើយយល់ព្រម ព្រោះការរលត់ទុក្ខ រមែងមានដោយ

អាការទាំង ២ យ៉ាង ។ ក្នុងពាក្យទាំងឡាយ សូម្បីពាក្យថា ***"តាណៈ មាន ២ ឬ ?"*** ជាដើម ក៏ក្នុងន័យនេះដែរ, តាណៈ គឺធម៌ជាគ្រឿងទប់ទល់ (ការពារ) ជាដើម នេះជាវេវចនៈរបស់ព្រះនិព្វាន ។

ក្នុងពាក្យសួរទាំងឡាយ មានពាក្យថា ***"មានការខ្ពស់ និងទាបនៃនិព្វានទាំង ២ ឬ ?"*** ជាដើម បរវាទីពេលមិនឃើញព្រះនិព្វានមានការខ្ពស់និងទាបជាដើម ទើបឆ្លើយបដិសេធ ។ ពាក្យថា ***"សង្ខារដែលនៅមិនទាន់រលត់ដោយបញ្ញាជាគ្រឿងពិចារណា"*** អធិប្បាយថា សង្ខារពួកណា មិនរលត់ទៅដោយលោកុត្តរញ្ញាណដែលជាគ្រឿងពិចារណា លោកហៅ សង្ខារពួកនោះថា រលត់ទៅហើយ តាមប្រក្រតីរបស់ខ្លួនឯង ឬព្រោះមិនមានការបដិបត្តិដោយអំណាចនៃការសាកសួរខុសទ្រុសជាដើមទេ ។ ពាក្យថា ***"សង្ខារដែលរលត់ហើយ ដោយបញ្ញាជាគ្រឿងពិចារណា"*** បានដល់ សង្ខារទាំងនោះរមែងរលត់ទៅដោយលោកុត្តរញ្ញាណ គឺរមែងដល់នូវការមិនកើតឡើងទៀត ។ ពាក្យសួរថា ***"សង្ខារទាំងដែលនៅមិនរលត់ដោយបញ្ញាជាគ្រឿងពិចារណា ទាំងដែលរលត់ហើយដោយបញ្ញា ជាគ្រឿងពិចារណាផ្សេងគ្នា ក៏វិនាសទៅអស់ហើយ មិនមែនឬ ?"*** ដូច្នេះ ជារបស់បរវាទី ។ ក្នុងពាក្យវិសជ្ជនានោះ សកវាទីរមែងឆ្លើយយល់ព្រម នូវសភាវៈនៃសង្ខារទាំងឡាយនោះ

*មានការបែកធ្លាយទៅជាធម្មតា ដោយមិនត្រូវប្រើបញ្ញាជាគ្រឿងពិចារណា ព្រោះការបែកធ្លាយទៅនៃសង្ខារទាំងឡាយ ជាសភាពត្រូវបែកធ្លាយទៅដោយចំណែកមួយ, ឬថា សភាវៈនៃសង្ខារទាំងនោះ ពេលអរិយមគ្គកើតឡើងហើយ ក៏ត្រូវបែកធ្លាយទៅ ព្រោះការបែកធ្លាយនោះដូចគ្នា ។ ពាក្យដែលនៅសល់ក្នុងទីនេះ មានអត្ថន័យងាយស្រួលមែនពិត ៕*

ចប់និរោធកថា

---

## រួមកថាដែលមានក្នុងវគ្គនេះគឺ

*១.បរូបហារកថា, ២.អញ្ញាណកថា, ៣.កង្ខាកថា, ៤.បរវិតរណកថា, ៥.វចីភេទកថា, ៦.ទុក្ខាហារកថា, ៧.ចិត្តដ្ឋិតិកថា, ៨.កុក្កុឡកថា, ៩.អនុបុព្វាភិសមយកថា, ១០.វោហារកថា, ១១.និរោធកថា ។*

**ចប់វគ្គទី ២**

## វគ្គទី ៣

## ១.ពលកថា សម្តែងអំពីពលៈ គឺកម្លាំង

*ឥឡូវនេះ ឈ្មោះថា រឿងពលៈ គឺកម្លាំង ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានលទ្ធិដូចនិកាយអន្ធកៈ ក្នុងខណៈនេះថា "កម្លាំងព្រះតថាគត ទូទៅដល់ព្រះសាវកទាំងឡាយ" ព្រោះកាន់យកព្រះសូត្រ ១០ សូត្រ មានអនុរុទ្ធសំយុត្តសូត្រជាដើម ដោយមិនពិចារណាថា "ម្នាលអ្នកមានអាយុ រីឯយើងរមែងដឹងច្បាស់នូវឋានៈដោយសេចក្តីជាឋានៈ ហើយរមែងដឹងច្បាស់អឋានៈ ដោយសេចក្តីជាអឋានៈតាមសេចក្តីពិត ព្រោះថា សតិបដ្ឋានទាំង ៤ នេះ យើងចម្រើនហើយធ្វើឲ្យច្រើនហើយ" ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ។ ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ព្រោះតាំងនៅក្នុងលទ្ធិ ។ ឯឈ្មោះថា កម្លាំងនៃព្រះតថាគតនេះ ទូទៅដល់ព្រះសាវកទាំងឡាយក៏មាន, មិនទូទៅក៏មាន, ទូទៅផង មិនទូទៅផង, នៅមានក្នុងកម្លាំងទាំងនោះ; ញាណក្នុងសេចក្តីអស់ទៅនៃអាសវៈទាំងឡាយ ឈ្មោះថា* ***សាធារណៈ*** *គឺទូទៅដល់ព្រះសាវក, តែឥន្ទ្រិយបរោបរិយត្តិញ្ញាណ បានដល់ ញាណដឹងសេចក្តីចាស់ក្លានិងទន់ខ្សោយនៃឥន្ទ្រិយ, ជាអសាធារណញ្ញាណ គឺញាណមិនទូទៅ, ញាណ*

*ដែលនៅសល់ជាសាធារណៈផង ជាអសាធារណៈផង ។ ពិតណាស់ ព្រះសាវកទាំងឡាយរមែងដឹងនូវឋានាឋានញ្ញាណជាដើមបានខ្លះៗ, តែព្រះតថាគតទាំងឡាយរមែងជ្រាបឋានាឋានញ្ញាណជាដើមបាន ដោយមិនមានសេសសល់ ។ ព្រះសាវកទាំងឡាយ រមែងដឹងសាធារណញ្ញាណទាំងអស់នោះដោយខទ្ទេស គឺដោយដំពូកខ្លះ មិនដោយនិទ្ទេស គឺ (មាតិកា) ដោយនាំចេញសម្ដែងយ៉ាងពិស្ដារ ។ ក៏លទ្ធិនេះ ពោលថា* ***"សូម្បីកម្លាំងរបស់ព្រះតថាគតទាំងពួងថា ទូទៅដល់ព្រះសាវកដោយមិនប្លែកគ្នា"*** *ដូច្នេះ ដើម្បីតិះដៀលលទ្ធិនោះៗ, ព្រោះហេតុនោះ ទើបផ្ដើមសាកសួរទៀតថា "កម្លាំងរបស់ព្រះតថាគត ក៏គឺជាកម្លាំងរបស់ព្រះសាវក" ជាដើម ។*

*ក្នុងការឆ្លើយបញ្ហាទាំងនោះ បញ្ហាទី ១ បរវាទីសំដៅយកភាវៈនៃកម្លាំងទាំងនោះ ជាវិស័យ គឺជាអារម្មណ៍នៃអាការទាំងពួង ដោយនិទ្ទេស ទើបឆ្លើយបដិសេធ ។ ក្នុងបញ្ហាទី ២ ឆ្លើយយល់ព្រមដោយអំណាចនៃញាណមានឋានាឋានញ្ញាណជាដើម ដោយខទ្ទេស ។ ក្នុងបញ្ហាថា* ***"កម្លាំងរបស់ព្រះតថាគតយ៉ាងនោះ កម្លាំងរបស់ព្រះសាវក ក៏យ៉ាងនោះដែរ"*** *បរវាទីឆ្លើយបដិសេធ ព្រោះមិនមានការធ្វើដែលប្លែកផ្សេងគ្នាដោយអាការទាំងពួង ។* **បុព្វបយោគ** *គឺការប្រកបក្នុងខាងដើមក្ដី,* **បុព្វចរិយា** *គឺការ*

*ប្រព្រឹត្តខាងដើមក្តី រមែងដូចគ្នាដោយអត្ថ ។ ការពោលធម៌ផង ការសម្តែងធម៌ផង ក៏ដូចគ្នាដែរ ។*

*ក្នុងបញ្ហាថា* ***ដោយឥន្ទ្រិយបរិយត្តិញ្ញាណ*** *បរវាទីឆ្លើយយល់ព្រមក្នុងវិស័យ គឺអារម្មណ៍នៃព្រះសាវក សំដៅយកទូទៅដោយឯកទេស គឺចំណែកខ្លះ ។*

*ឥឡូវនេះ បញ្ហារបស់បរវាទី មានពាក្យថា* ***"ព្រះសាវកដឹងឋានៈ និងអឋានៈឬ ?"*** *ជាដើម ដើម្បីឲ្យតាំងទុកនូវភាវៈនៃញាណទាំងនោះជាសាវក, សាធារណញ្ញាណ ដោយភាវៈនៃលោកដឹងឋានាឋានញ្ញាណជាដើម ដោយខទ្ទេស ព្រោះហេតុដូច្នោះ ទើបប្រកាសការដឹងអត្ថរបស់ព្រះសាវកត្រឹមតែថា ការដឹងនោះប៉ុណ្ណោះ ។ ក្នុងបញ្ហានោះ បរវាទីមិនកាន់យកឥន្ទ្រិយបរោបរិយត្តិញ្ញាណ ដែលជាញាណណាមួយ នៃសាធារណញ្ញាណទាំង ៦ ឡើយ ។*

*ពាក្យថា* ***"ការអស់អាសវៈនៃព្រះតថាគត ជាមួយការអស់អាសវៈនៃព្រះសាវក"*** *អធិប្បាយថា ពាក្យណាដែលបុគ្គលគួរពោល គប្បីមាន ព្រោះអាស្រ័យការអស់អាសវៈរបស់ព្រះតថាគត ជាមួយការអស់អាសវៈរបស់ព្រះសាវកនោះ សេចក្តីប្លែកផ្សេងគ្នាមិនមានទេ ។ សូម្បីក្នុងពាក្យថា "ការរួចផុតនៃព្រះតថាគត ជាមួយការរួចផុតនៃព្រះសាវក" ក៏មានន័យ*

*ដូចគ្នានេះដែរ ។ ពាក្យដែលនៅសល់ក្នុងទីនេះ មានខ្លឹមសារងាយស្រួលទាំងអស់ ។*

*ឥឡូវនេះ បញ្ហារបស់បរវាទីថា* ***“ក្នុងការអស់ទៅនៃអាសវៈទាំងឡាយ”*** *ជាដើមនោះទៀត ដើម្បីប្រៀបធៀបញាណក្នុងការអស់ទៅនៃអាសវៈទាំងឡាយ របស់ព្រះតថាគតជាមួយនឹងព្រះសាវក ដែលសកវាទីឆ្លើយយល់ព្រមជាសាធារណញ្ញាណនោះ ហើយទើបសួរនូវសេចក្ដីជាអសាធារណញ្ញាណទាំងឡាយ សូម្បីដែលនៅសល់ ។ ញាណនោះ ដែលសកវាទីដោះស្រាយបញ្ហាយល់ព្រមហើយថា ជាសាធារណញ្ញាណ ព្រោះមិនមានអ្វីប្លែកក្នុងការអស់អាសវៈឡើយ ។ ក្នុងញាណទាំងឡាយ ក្រៅអំពីនេះ លោកឆ្លើយបដិសេធញាណ ជាសាធារណៈ ព្រោះមិនមានសេចក្ដីពិសេសក្នុងព្រះសាវក ។ ពាក្យសួររឿង* **អសាធារណញ្ញាណ** * *របស់*

---

* **អសាធារណញ្ញាណ** បានដល់ ញាណដែលមិនទូទៅដល់ព្រះសាវកទាំងឡាយមាន ៦ គឺ

**១. ឥន្ទ្រិយបរោបរិយត្តិញ្ញាណ** បានដល់ បញ្ញាស្ទង់ដឹងភាពចាស់ក្លា និងទន់ខ្សោយនៃឥន្ទ្រិយរបស់សត្វទាំងឡាយ ។

**២. អាសយានុសយញ្ញាណ** បានដល់ បញ្ញាស្ទង់ដឹងអាសយៈ គឺអធ្យាស្រ័យ និងកិលេសដែលដេកត្រាំក្នុងសន្ដានរបស់សត្វ ។

**៣. យមកប្បាដិហិរញ្ញាណ** បានដល់ បញ្ញាស្ទង់ដឹងក្នុងការធ្វើយមកប្បាដិហារ្យ

**៤. មហាករុណាសមាបត្តិញ្ញាណ**បានដល់ បញ្ញាស្ទង់ដឹងក្នុងការចូលមហាករុណាសមាបត្តិ

បរវាទី ប្រៀបធៀបអាសវក្ខយញ្ញាណនោះៗ ជាមួយនឹងបណ្តាញាណទាំងឡាយ មានឋានាឋានញ្ញាណជាដើមទៀត ។ ក្នុងការវិសជ្ជនាបញ្ហានោះ សកវាទីបដិសេធក្នុងអាសវក្ខយញ្ញាណ, ប៉ុន្តែយល់ព្រមក្នុងញាណដែលនៅសល់ ។ តអំពីនេះ ជាពាក្យសួរអសាធារណញ្ញាណរបស់បរវាទី ប្រៀបធៀបជាមួយនឹងឥន្ទ្រិយបរោបរិយត្តិញ្ញាណ ។ ញាណនោះ លោកសម្តែងទុកដោយសង្ខេប ។ សូម្បីក្នុងការវិសជ្ជនាបញ្ហា សកវាទីឆ្លើយយល់ព្រមក្នុងរឿងឥន្ទ្រិយបរោបរិយត្តិញ្ញាណ ឆ្លើយបដិសេធក្នុងញាណដែលនៅសល់ទាំងឡាយ ។ តអំពីនោះ ពាក្យសួរសាធារណញ្ញាណនៃឥន្ទ្រិយបរោ-បរិយត្តិញ្ញាណរបស់បរវាទី ដែលប្រៀបធៀបជាមួយនឹងឋានាឋានញ្ញាណទាំងឡាយ ។ សូម្បីញាណនោះ ក៏លោកសម្តែងទុក ដោយសង្ខេបដែរ ។ ក្នុងការវិសជ្ជនានូវបញ្ហានោះ សកវាទីឆ្លើយបដិសេធ ក្នុងឥន្ទ្រិយបរោបរិយត្តិញ្ញាណ ឆ្លើយយល់ព្រមក្នុងញាណទាំងឡាយ ដែលនៅសល់ ដោយប្រការដូច្នេះឯង៕

## ចប់ពលកថា

= = =

---

**៥_សព្វញ្ញុតញ្ញាណ** បានដល់ បញ្ញាស្ទង់ដឹងក្នុងធមិទាំងពួង

**៦_អនាវរណញ្ញាណ** បានដល់ បញ្ញាស្ទង់ដឹងក្នុងធមិដែលមិនមានអ្វីរាំង ។

## ២.អរិយន្តិកថា សម្តែងអំពីអរិយៈ

*ឥឡូវនេះ ឈ្មោះថា រឿងជាអរិយៈ ៖*

*ក្នុងបញ្ហានោះ លទ្ធិនៃជនទាំងឡាយណា ដូចលទ្ធិនិកាយអន្ធកៈ ក្នុងខណៈនេះថា "អាសវក្ខយញ្ញាណ ជាអរិយៈតែម្យ៉ាងប៉ុណ្ណោះ មិនបានទេតាមពិត សូម្បីញាណផ្នែកខាងដើម * ៩ យ៉ាង ដែលជាកម្លាំង ក៏ជាអរិយៈដែរ" ដូច្នេះ សកវាទីសំដៅយកជនទាំងនោះ ទើបសួរថា* ***"ការដឹង***

---

* **ទសពលញ្ញាណ** = ញាណដែលជាកម្លាំង ១០ គឺ

**១_ឋានាឋានញ្ញាណ** ប្រាជ្ញាដែលដឹងឋានៈ និងអឋានៈ

**២_វិបាកញ្ញាណ** ប្រាជ្ញាស្ទង់ដឹងផលនៃកម្ម

**៣_សព្វត្ថគាមិនីបដិបទាញាណ** ប្រាជ្ញាស្ទង់ដឹងផ្លូវទៅកាន់ភពទាំងពួង

**៤_នានាធាតុញ្ញាណ** ប្រាជ្ញាស្ទង់ដឹងធាតុផ្សេងៗ

**៥_នានាធិមុត្តិញ្ញាណ** ប្រាជ្ញាស្ទង់ដឹងអធិមុត្តិ គឺអធ្យាស្រ័យរបស់សត្វផ្សេងៗ

**៦_ឥន្ទ្រិយោបរិយត្តិញ្ញាណ** ប្រាជ្ញាស្ទង់ដឹងភាពចាស់ក្លា និងទន់ខ្សោយនៃឥន្ទ្រិយរបស់សត្វ

**៧_ឈានាទិសំកិលេសាទិញ្ញាណ** ប្រាជ្ញាស្ទង់ដឹងអាការ មានសេចក្តីសៅហ្មងជាដើមនៃធម៌មានឈានជាដើម ។

**៨_បុព្វេនិវាសានុស្សតិញ្ញាណ** ប្រាជ្ញាស្ទង់ដឹងនូវជាតិកំណើតដែលធ្លាប់អាស្រ័យក្នុងកាលមុន

***តាមពិតក្នុងឋានៈ និងអឋានៈ ជាអរិយៈឬ ?”*** *ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ មួយវិញទៀត ពាក្យសួរដោយអំណាចនៃមគ្គជាដើមថា* ***“ញាណណាក្នុងអរិយមគ្គជាដើម ញាណមួយនោះ គប្បីជាអរិយៈឬ ?”*** *ជារបស់សកវាទី, ពាក្យឆ្លើយបដិសេធជារបស់បរវាទី ។ ពាក្យសួរទៀតថា* ***ដោយសុញ្ញតារម្មណ៍*** *ជាដើម ជារបស់បរវាទី ។ ពាក្យសួរនោះ សុញ្ញតាមាន ២ យ៉ាង គឺ* **សត្តសុញ្ញតា** *ភាពសូន្យទទេចាកសត្វ ១ និង* **សង្ខារ-សុញ្ញតា** *សេចក្ដីសូន្យទទេចាកសង្ខារ ១ ។* ***បញ្ចក្ខន្ធ*** *ជាសភាពសូន្យទទេចាកសត្វ ដែលសត្វលោកសន្មតដោយទិដ្ឋិ ឈ្មោះថា* **សត្តសុញ្ញតា** *។* ***ព្រះនិព្វាន*** *ជាសភាពសូន្យទទេស្ងាត់ហើយ ជាធម្មជាតិចេញទៅហើយអំពីសង្ខារទាំងពួង ឈ្មោះថា* **សង្ខារសុញ្ញតា** *។ ក្នុងបញ្ហានោះ បរវាទីសំដៅយកសេចក្ដីសូន្យទទេដែលជាអារម្មណ៍របស់សង្ខារ ។ សូម្បីត្រូវសកវាទីសួរថា* ***“ទ្រង់ធ្វើទុកក្នុងព្រះទ័យ”*** *ដូច្នេះ ក៏បដិសេធ ព្រោះសំដៅយកព្រះនិព្វានប៉ុណ្ណោះ រមែងឆ្លើយយល់ព្រម ព្រោះសំដៅយកសង្ខារទាំងឡាយ ។ តអំពីនោះ ត្រូវសកវាទីសួរថា* ***“ជាការប្រជុំនៃផស្សៈ ២ យ៉ាង***

---

៩.ចុតូបបាតញ្ញាណ ប្រាជ្ញាស្ទង់ដឹងនូវចុតិ និងបដិសន្ធិ

១០.អាសវក្ខយញ្ញាណ ប្រាជ្ញាស្ទង់ដឹងនូវការអស់ទៅនៃអាសវៈ ។

***នៃចិត្ត ២ ដូចឬ ?”*** *ព្រោះកាន់យកន័យនេះថា* ***អ្នកមានមនសិការក្នុងឋានញ្ញាណ និងអឋានញ្ញាណជាដើម មានសង្ខារជាអារម្មណ៍ ប៉ុន្តែអ្នកមានមនសិការក្នុងភាពសូន្យទទេ មានព្រះនិព្វានជាអារម្មណ៍*** *បរវាទីនោះ ពេលមិនបានឱកាសដែលមានលេសន័យ ទើបបដិសេធ ។* ***សូម្បីអនិមិត្ត និងអប្បណិហិត*** *ក៏មានន័យដូចគ្នានេះដែរ ។ ពិតណាស់* ***ខន្ធទាំងឡាយ*** *ឈ្មោះថា* **អនិមិត្ត** *ព្រោះមិនមាននិមិត្ត គឺសត្វ,* ***ព្រះនិព្វាន*** *ឈ្មោះថា អនិមិត្ត ព្រោះមិនមាននិមិត្ត គឺសង្ខារ, ខន្ធទាំងឡាយ ឈ្មោះថា* **អប្បណិហិត** *គឺមិនមានទីតាំង ដោយការតាំងសេចក្ដីប្រាថ្នានៃសត្វដែលដល់នូវការរាប់ថា* “ **បណិធិ**” *ព្រោះអត្ថថា គប្បីតាំងទុក ពោលគឺដែលគេលើកឡើងហើយ គប្បីតាំងទុកសូម្បីក្នុងធម៌ម្យ៉ាង ។* ***ព្រះនិព្វាន*** *ឈ្មោះថា* **អប្បណិហិត** *គឺមិនមានទីតាំង ដោយការតាំងទុកនូវតណ្ហា ឬដោយការតាំងទុកនូវសង្ខារទាំងពួង ដែលជាអារម្មណ៍នៃតណ្ហា ។ ព្រោះហេតុដូច្នោះ ក្នុងការវិសជ្ជនាទាំងនេះ ទាំងការបដិសេធ ទាំងការយល់ព្រម បណ្ឌិតគប្បីជ្រាបដោយន័យមុនន៉ុះបុះ ។*

*តអំពីនេះ អនុលោម និងបដិលោម បញ្ហាថា “លោកុត្តរធម៌ទាំងឡាយ មានសតិបដ្ឋានជាដើម ជាអរិយៈផង មានសុញ្ញតៈជាដើម ជាអារម្មណ៍*

*ផង យ៉ាងណា, ញាណជាគ្រឿងស្ទង់ដឹងឋានៈ និងអឋានៈដោយលទ្ធិរបស់លោកយ៉ាងនោះឬ ?” សូម្បីក្នុងការវិសជ្ជនាបញ្ហាការឆ្លើយយល់ព្រមទាំងពួង ជារបស់បរវាទី ។ បណ្ឌិតគប្បីជ្រាបពាក្យសួរ និងពាក្យឆ្លើយសូម្បីក្នុងញាណដែលនៅសល់ ដោយឧបាយនេះចុះ ។ ប៉ុន្តែ ក្នុងព្រះបាលីលោកសង្ខេបញាណដែលនៅសល់ទុកហើយ ក៏ចែកចុតូបបាតញ្ញាណទុកក្នុងទីបំផុត ។ ខាងមុខអំពីនេះ ជាពាក្យសួរដល់ភាពជាព្រះអរិយៈ ដោយអនុលោម និងបដិលោមនៃញាណទាំងឡាយដែលនៅសល់ ប្រៀបធៀបជាមួយនឹងអាសវក្ខយញ្ញាណ ដែលសម្រេចហើយថា “ជាអរិយៈ” សូម្បីក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យសួរទាំងពួង ជារបស់បរវាទី ។ សកវាទីឆ្លើយយល់ព្រមផង បដិសេធផង ។ អត្ថន័យទាំងនោះ មានអត្ថងាយស្រួលទាំងអស់ ។ ចំណែកក្នុងបាលីលោកសង្ខេបញាណទាំង ៧ ទុកក្នុងទីនេះហើយសម្ដែងដូចន័យទី ១ នុ៎ះដែរ ៕*

**ចប់អរិយន្តិកថា**

.................

## ៣.វិមុត្តិកថា * សម្ដែងអំពីវិមុត្តិ

*ឥឡូវនេះ ឈ្មោះថា រឿងវិមុត្តិ គឺការរួចផុត ៖*

*ក្នុងបញ្ហានោះ លទ្ធិរបស់ ជនទាំងឡាយណា ដូចលទ្ធិនិកាយអន្ធកៈក្នុងខណៈនេះថា "ឈ្មោះថា ការបដិបត្តិដើម្បីរួចផុត របស់ចិត្តដែលប្រាសចាករាគៈហើយ មិនមាន, ដូចយ៉ាងថា សំពត់ដែលគេបោកគក់យកមន្ទិលចេញទៅរមែងផុតចាកមន្ទិលបាន យ៉ាងណាមិញ, ចិត្តមានរាគៈ រមែងរួចផុតចាករាគៈបាន ក៏យ៉ាងនោះដែរ" ។ សកវាទីសំដៅយកជនទាំងនោះទើបសួរបរវាទីថា " ចិត្តមានរាគៈរួចផុតឬ ?" ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី, បន្ទាប់អំពីនោះ ត្រូវសកវាទីសួរដោយន័យថា "* ***ចិត្តសហគតៈដោយរាគៈជាដើម រួចផុតបានឬ ?"*** *បរវាទីបដិសេធ ដោយសំដៅយកថា* ***ក្នុងខណៈនៃមគ្គចិត្ត ចិត្តនោះ ឈ្មោះថា រមែងរួចផុត,*** *តែក្នុងកាលនោះ ចិត្តមានសភាពដូច្នេះ រមែងមិនមានឡើយ ។ សូម្បីត្រូវសកវាទីសួរដោយន័យថា* ***"ចិត្តមានផស្សៈ"*** *ជាដើម បរវាទីពេលមិនឃើញការរួចផុតចាករាគៈ ដូចធម៌ទាំង ២ គឺផស្សៈ និងចិត្តផុតចាករាគៈ ទើប*

---

* បាលីបិដកជា វិមុច្ចតិកថា ។

*ឆ្លើយយល់ព្រម ហើយឆ្លើយបដិសេធ ។* ***សូម្បីក្នុងចិត្តមានទោសៈជាដើម*** *បណ្ឌិតគប្បីជ្រាបខ្លឹមសារដោយឧបាយនេះចុះ ៕*

**ចប់វិមុត្តិកថា**

....................

## ៤.ទិមុច្ចមានកថា សម្តែងអំពីចិត្តរួចផុត

*ឥឡូវនេះ ឈ្មោះថា រឿងចិត្តរួចផុត ៖*

*ក្នុងបញ្ហានោះ លទ្ធិនៃជនទាំងឡាយណាថា " ចិត្តរួចផុតហើយដោយវិក្ខម្ភនវិមុត្តិ ដោយឈាន ក្នុងខណៈនៃមគ្គ, ចិត្តនោះ ឈ្មោះថារួចផុតដោយសមុច្ឆេទវិមុត្តិ" ដូច្នេះ សកវាទីសំដៅយកជនទាំងនោះ ទើបសួរថា* ***" ចិត្តដែលរួចផុតហើយនៅតែរួចផុតឬ ? "*** *ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ សកវាទីសួរទៀតថា "មួយផ្នែករួចផុតហើយ" ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា* ***"មួយផ្នែក"*** *ជាពាក្យមិនប្រាកដតាមសេចក្តីពិត អធិប្បាយថា លោកសួរថា* ***" ចិត្តរួចផុតហើយមួយផ្នែក, មិនរួចផុតហើយមួយផ្នែក*** *យ៉ាងណា, ចិត្តនោះមួយផ្នែករួចផុតហើយŸ តែមួយផ្នែកទៀតមិនរួចផុតយ៉ាងនោះឬ ? " ។*

***សួរថា*** *សកវាទីសួរយ៉ាងនេះ ព្រោះហេតុអ្វី ?*

ឆ្លើយថា ព្រោះបរវាទីនោះ ពោលខុសភាវៈប្រក្រតីថា ***"ចិត្តដែលរួចផុតហើយ ថានៅរួចផុត"*** ដូច្នេះ ដូចជាដាងឈើធ្វើវត្ថុទាំងឡាយ មានឈើជាដើម គេធ្វើស្រេចហើយផ្នែកខ្លះ, ផ្នែកខ្លះនៅមិនស្រេច ព្រោះរបស់នោះ នៅមិនទាន់រៀបរយយ៉ាងណា; សូម្បីចិត្តនេះ ក៏រមែងនឹងប្រាកដតាមលទ្ធិថា "មួយផ្នែក រួចផុតហើយ, មួយផ្នែកទៀត មិនរួចផុត" យ៉ាងនោះ ។

លំដាប់នោះ បរវាទីឆ្លើយបដិសេធក្នុងបញ្ហាទី ១ ព្រោះចិត្តមិនមានផ្នែកខ្លះ ដូចដាងឈើជាដើម, ក្នុងបញ្ហាទី ២ ឆ្លើយយល់ព្រម ព្រោះសភាវៈនៃចិត្តនោះ កំពុងរួចផុត, មិនមែនរួចផុតហើយនឹងធ្វើកិច្ច នៅមិនទាន់ស្រេចទេ ។ ម្យ៉ាងទៀត លោកឆ្លើយបដិសេធ សំដៅយកលក្ខណៈនៃចិត្តដែលជាលោកិយជ្ឈាន, ប៉ុន្តែថា លក្ខណៈនៃចិត្តជាលោកិយជ្ឈាននោះ មិនមែនកំពុងរួចផុតដោយសមុច្ឆេទវិមុត្តិឡើយ ក្នុងកាលនោះ ទើបឆ្លើយយល់ព្រមសំដៅយកលក្ខណៈនៃចិត្តជាលោកុត្តរជ្ឈាន ។ លទ្ធិរបស់លោកថា " ក៏ក្នុងកាលនោះ ចិត្តនោះកំពុងរួចផុតដោយសមុច្ឆេទវិមុត្តិ ដោយមួយផ្នែកៗទៀត តាមចិត្តដែលរួចផុតហើយ" ។ លំដាប់នោះ ទើបសកវាទី ពោលថា "មួយផ្នែក ជាព្រះសោតាបន្ន" ជាដើម ដើម្បីព្រមានដោយពាក្យថា "ប្រសិនបើចិត្តដូងនោះៗ រួចផុតបានមួយផ្នែក, មួយផ្នែកទៀត មិនរួចផុតមែន កាលបើមានសេចក្ដីដូច្នេះ, បុគ្គលណាជាព្រះសោតាបន្ន ដោយ

ចិត្តមួយដួងនោះៗ សូម្បីបុគ្គលនោះ ក៏ត្រូវជាព្រះសោតាបន្នត្រឹមតែមួយផ្នែក, មិនមែនមួយផ្នែកដោយចិត្តដួងនោះទេ” ដូច្នេះ បរវាទីពេលមិនឃើញធម៌ដូវផង់ដូច្នោះ ទើបឆ្លើយបដិសេធ ។ សូម្បីវារៈដែលនៅសល់ទាំងពួង ក៏មានន័យដូចគ្នានេះដែរ ។

ក្នុងបញ្ហាថា “ដោយចិត្តរួចផុតហើយក្នុងខណៈនៃការកើតឡើង” អធិប្បាយថា បើចិត្តមួយដួងនោះឯង រួចផុតហើយផង, កំពុងរួចផុតផងសោត, ចិត្តដែលរួចផុតហើយ នឹងកំពុងរួចផុត រមែងប្រាកដក្នុងខណៈតែមួយដូចគ្នា សភាពដូច្នេះ ជាលទ្ធិរបស់លោកឬ ? ។ ក្នុងការជម្រះព្រះសូត្រ ៗ ដំបូងជារបស់បរវាទី, ក្នុងព្រះសូត្រនេះ អធិប្បាយថា ***ចិត្តរមែងរួចផុត*** ជាការបញ្ញាក់មិនជាក់លាក់ សំដៅសេចក្តីថា មិនពោលថាជាខណៈកើត ឬខណៈរលត់ទេ ព្រោះហេតុដូច្នោះ ទើបបរវាទីនាំព្រះសូត្រមកថា “ពេលបុគ្គលនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ, ចិត្តណា រមែងរួចផុតចាកអាសវៈទាំងនេះ; ចិត្តនោះ ឈ្មោះថា ***រមែងរួចផុត”*** ។ ព្រះសូត្រទី ២ ជារបស់សកវាទី, ខ្លឹមសារនោះ អធិប្បាយថា បើចិត្តរួចផុតហើយ ឈ្មោះថា កំពុងរួចផុត ព្រោះព្រះបាលីថា ***“រមែងរួចផុត”*** តាមលទ្ធិរបស់លោក នៅមានសោត, ចិត្តនោះ ក៏គប្បីរួចផុតហើយនោះឯង មិន

មែនកំពុងរួចផុតទេ, ព្រោះមិនមានពាក្យបាលីក្នុងព្រះសូត្រនេះថា ***"វមែង រួចផុត"*** ។

ឥឡូវនេះ ដើម្បីនឹងព្រមានថា " ចិត្តកំពុងរួចផុត ព្រោះការរួចផុតដែលខុសប្រក្រតីតាមលទ្ធិរបស់លោកនៅមាន យ៉ាងណា, សូម្បីចិត្តដែលកំពុងមានគម្រេកជាដើម ព្រោះរាគៈដែលខុសប្រក្រតីជាដើម យ៉ាងនោះឬ ? " ដូច្នេះ ទើបផ្ដើមពាក្យជាដើមទៀតថា ***" ចិត្តរួចផុតនៅមានឬ ? "*** ជាដើម ។ សូម្បីបរវាទីពេលមិនឃើញចិត្តដូច្នោះ ទើបបដិសេធទាំងអស់ ។ លំដាប់នោះ សកវាទីពេលនឹងញ៉ាំងបរវាទីឲ្យដឹងថា ***" ចំណែកបំផុតមាន ២ យ៉ាងប៉ុណ្ណោះ, មិនមែន ៣ យ៉ាងទេ "*** ទើបពោលពាក្យថា ***" ចិត្តមានតែត្រេកត្រអាលហើយ និងមិនត្រេកត្រអាលហើយ មិនមែនឬ ? "*** ជាដើម គប្បីជ្រាបខ្លឹមសារនៃបញ្ហានោះថា "ម្នាលភទ្រមុខ អ្នកមានភ័ក្ត្រដ៏ល្អ ចំណែកទីបំផុតមាន ២ យ៉ាងប៉ុណ្ណោះ គឺចិត្តដែលទទឹកជោកដោយរាគៈ សម្បយុត្តហើយដោយរាគៈ, និងចិត្តដែលរាគៈមិនទទឹកជោកហើយ ប្រាសចាករាគៈហើយ មិនមែនឬ ? ផ្នែកបំផុតទី ៣ គឺចិត្ត ឈ្មោះថា កំពុងសម្រើបរមែងមិនមាន " ។ ក្នុងពាក្យថា ***" ចិត្តថ្ងាំងថ្នាក់ហើយ "*** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ លំដាប់នោះ សកវាទីញ៉ាំងបរវាទីឲ្យយល់ព្រមថា ***" មែនហើយ "*** ដើម្បីសម្ដែងផ្នែកទីបំផុតទាំងពីរនោះ។ សូម្បីក្នុងផ្នែកនៃចិត្ត-

*វិមុត្តិ ទើបពោលថា **“បើចិត្តមានតែការស្រើបស្រាលហើយ”** ជាដើម ។ ខ្លឹមសារនៃបញ្ហានោះ គប្បីជ្រាបថា “បើលោកយល់ព្រមចំណែកទីបំផុតទាំង ២ នេះ គឺចិត្តដែលរួចផុតហើយ និងចិត្តដែលមិនរួចផុតហើយ ក៏លោកយល់ព្រម សូម្បីចំណែកទីបំផុតទាំងនេះ គឺចិត្តដែលសម្បយុត្តដោយកិលេស ឈ្មោះថា មិនរួចផុតហើយ, ចិត្តប្រាសចាកកិលេស ឈ្មោះថា រួចផុតហើយ កាលបើពោលដោយបរមត្ថ ចំណែកបំផុតទី ៣ ថា ចិត្តឈ្មោះថា **កំពុងរួចផុត** រមែងមិនមានតាមព្រះសូត្រឡើយ”៕*

ចប់វិមុច្ចមានកថា

## ៥.អដ្ឋមកកថា សម្តែងអំពីបុគ្គលទី ៨ *

*ឥឡូវនេះ ឈ្មោះថា រឿងបុគ្គលទី ៨ គឺព្រះអរិយបុគ្គលអ្នកតាំងនៅក្នុងសោតាបត្តិមគ្គ ៖*

* ក្នុងគម្ពីរនេះ លោករាប់លំដាប់ព្រះអរិយបុគ្គលយ៉ាងនេះ គឺបុគ្គលអ្នកតាំងនៅក្នុងអរហត្តផលជាទី ១, បុគ្គលអ្នកតាំងនៅក្នុងអរហត្តមគ្គជាទី ២, បុគ្គលអ្នកតាំងនៅក្នុងអនាគាមិផលជាទី ៣ ។ល ។ បុគ្គលអ្នកតាំងនៅក្នុងសោតាបត្តិមគ្គជាទី ៨ ។

ក្នុងរឿងនោះ លទ្ធិនៃជនទាំងឡាយណា ដូចលទ្ធិរបស់និកាយអន្ធកៈ និងសមិតិយៈក្នុងខណៈនេះថា "បុគ្គលអ្នកតាំងនៅក្នុងសោតាបត្តិមគ្គដែលជាបុគ្គលទី ៨ លះបរិយុដ្ឋានក្កិលេសទាំងពីរហើយ គឺទិដ្ឋិ និងវិចិកិច្ឆា ព្រោះមិនមានកិលេសទាំងឡាយកើតឡើងក្នុងខណៈនៃអនុលោម គោត្រភូ និងមគ្គ" ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនពួកណាមួយ ក្នុងបណ្តាជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមរបស់បរវាទី សំដៅយកការមិនកើតឡើងនៃទិដ្ឋិ ចាប់ផ្ដើមពីខណៈនៃមគ្គ ។ ធម្មតាទិដ្ឋិនេះ ព្រះសោតាបន្នជាអ្នកលះហើយ, មិនមែនបុគ្គលទី ៨ ទេ ព្រោះហេតុណា, ព្រោះហេតុនោះលំដាប់នោះ ទើបសកវាទីសួរបញ្ជាក់ថា "បុគ្គលទី ៨ ជាព្រះសោតាបន្នឬ ?" ជាដើម ។ សូម្បីក្នុងបញ្ហាពោលដោយវិចិកិច្ឆា ក៏មានន័យដូចគ្នានេះដែរ ។

ក្នុងបញ្ហាថា ***ដោយអនុស័យ*** លទ្ធិលោកថា ***"អនុស័យជាយ៉ាងដទៃក្រៅអំពីបរិយុដ្ឋាន"*** ព្រោះហេតុដូច្នោះ ទើបឆ្លើយបដិសេធថា "មិនគប្បីពោលយ៉ាងនេះទេ" ។ ក្នុងបញ្ហាថា "ដោយសីលព្វតបរាមាស" ដូច្នេះ បរវាទីមិនឃើញវោហារសីលព្វតបរាមាសជាបរិយុដ្ឋាន ទើបឆ្លើយបដិសេធ ។ លទ្ធិថា បុគ្គលទី ៨ លះបរិយុដ្ឋានក្កិលេសបានហើយប៉ុណ្ណោះ ។ ក្នុងបញ្ហាថា "បុគ្គលទី ៨ ញុំាងមគ្គឲ្យកើតឡើង" សេចក្ដីថា ក្នុងខណៈនោះ

*កំពុងចម្រើនមគ្គ, មិនមែនចម្រើនស្រេចហើយ ព្រោះហេតុដូច្នោះ ទើបលោកបដិសេធ ។ ក្នុងពាក្យសាកសួរថា* ***“លះបានហើយ ដោយធម៌ដែលមិនមែនមគ្គ”*** *ជាដើម បរវាទីឆ្លើយបដិសេធ សំដៅយកសេចក្តីដែលកិលេសទាំងនោះ លោកលះបានហើយដោយមគ្គទី ១ នោះឯង ។ លទ្ធិរបស់លោកថា “ក៏បើបុគ្គលគប្បីលះកិលេសដោយធម៌ដែលមិនមែនមគ្គបានទេ, សូម្បីគោត្រភូបុគ្គលជាដើម ក៏គប្បីលះកិលេសបានដែរ” ។*

*ពាក្យសួររបស់បរវាទីថា “គ្រឿងរួបរឹត គឺទិដ្ឋិនឹងកើតឡើងឬ ?” ពាក្យវិសជ្ជនាជារបស់សកវាទី ។ ពាក្យដែលនៅសល់ក្នុងទីទាំងពួង មានអត្ថងាយស្រួលមែនពិត ។*

ចប់អដ្ឋមកកថា

# ៦.អដ្ឋមកឥន្ទ្រិយកថា

## សម្តែងអំពីឥន្ទ្រិយរបស់បុគ្គលទី ៨

*ឥឡូវនេះ ឈ្មោះថា រឿងឥន្ទ្រិយរបស់បុគ្គលទី ៨ * ៖*

* ឥន្ទ្រិយ ៥ របស់ព្រះអរិយបុគ្គលតាំងអំពីទី ១-៨ គឺ ១-សទ្ធិន្ទ្រិយ, ២-វិរិយិន្ទ្រិយ, ៣-សតិន្ទ្រិយ, ៤-សមាធិន្ទ្រិយ, ៥-បញ្ញិន្ទ្រិយ ។

ក្នុងរឿងនោះ លទ្ធិនៃជនទាំងឡាយណា ដូចលទ្ធិរបស់និកាយអន្ធកៈ ក្នុងខណៈនេះថា "បុគ្គលទី ៨ កំពុងបានឥន្ទ្រិយទាំងឡាយក្នុងខណៈនៃមគ្គកើត, មិនមែនបានមគ្គមកពីមុនទេ" ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរបរវាទីថា ***"បុគ្គលទី ៨ មិនមានសទ្ធិន្ទ្រិយឬ ?"*** ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ត្រូវសកវាទីសួរថា ***"បុគ្គលទី ៨ មិនមានសទ្ធាឬ ?"*** បរវាទីកំណត់យកសេចក្ដីនៃសទ្ធាផ្សេងអំពីសទ្ធិន្ទ្រិយ ទើបឆ្លើយបដិសេធ ។ សូម្បីក្នុងបញ្ហាដែលនៅសល់ទាំងឡាយ ក៏មានន័យដូចគ្នានេះដែរ ។ សកវាទីផ្ដើមពាក្យជាដើមថា "បុគ្គលទី ៨ មានសទ្ធា មានសទ្ធិន្ទ្រិយឬ ?" ដូច្នេះ ដើម្បីសម្ដែងថា ដូចយ៉ាងចិត្តរបស់បុគ្គលណានៅមាន សូម្បីមនិន្ទ្រិយបានដល់ ឥន្ទ្រិយ គឺចិត្តរបស់បុគ្គលនោះ ក៏នៅមានយ៉ាងណា, ធម៌ទាំងឡាយមានសទ្ធាជាដើម របស់បុគ្គលណានៅមាន, សូម្បីឥន្ទ្រិយទាំងឡាយមានសទ្ធិន្ទ្រិយជាដើម របស់បុគ្គលនោះ ក៏នៅមានយ៉ាងនោះដែរ ។ ពាក្យទាំងអស់នោះ ព្រមទាំងការជម្រះព្រះសូត្រ មានអត្ថងាយស្រួលទាំងអស់ ៕

---

## ៧.ទិព្វចក្ខុកថា សម្ដែងអំពីទិព្វចក្ខុ

*ឥឡូវនេះ ឈ្មោះថា រឿងទិព្វចក្ខុ* [*] ៖

*ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្ដីយល់ឃើញខុស ដូចនិកាយអន្ធកៈ និងសមិតិយៈ ក្នុងខណៈនេះថា "មំសចក្ខុនោះឯង ដែលធម៌គឺចតុត្ថជ្ឈានឧបត្ថម្ភហើយ ឈ្មោះថា ទិព្វចក្ខុ" ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរបរវាទីថា* ***"មំសចក្ខុដែលធម៌ឧបត្ថម្ភហើយ ជាទិព្វចក្ខុឬ ?"*** *ពាក្យយល់ព្រមជារបស់បរវាទី, ក៏ត្រូវសកវាទី សួរទៀតថា មំសចក្ខុក៏គឺទិព្វចក្ខុ, ទិព្វចក្ខុ ក៏គឺមំសចក្ខុឬ ? បរវាទីបដិសេធថា មំសចក្ខុនោះក៏ត្រឹមតែជាមំសចក្ខុប៉ុណ្ណោះ, មិនអាចផ្សេងគ្នាទេ ។ សូម្បីក្នុងពាក្យសួរទាំងឡាយថា* ***"មំសចក្ខុ ដូចជាអ្វី ?"*** *ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះភាវៈនៃចក្ខុទាំងពីរនោះ មិនមានសភាពដូចគ្នាឡើយ ។ សូម្បីក្នុងបញ្ហាមានពាក្យថា* ***"វិស័យ"*** *ជាដើម សេចក្ដីថា រូបាយតនៈនោះឯង ជាវិស័យនៃចក្ខុទាំងពីរ ។ អធិប្បាយថា ក៏មំសចក្ខុរមែងឃើញតែរូប*

---

[*] **ចក្ខុ ៣ គឺ ១.មំសចក្ខុ** បានដល់ ចក្ខុបសាទ, **២.ទិព្វចក្ខុ** បានដល់ អភិញ្ញាចិត្តុប្បាទដែលជាទុតិយវិជ្ជាញាណ, **៣.បញ្ញាចក្ខុ** បានដល់ អាសវក្ខយញ្ញាណ (ក្នុងបករណ៍នេះ ឬក្នុងខុទ្ទកនិកាយ ឥតិវុត្តកៈ) ។ **ចក្ខុ ៥** គឺមំសចក្ខុ ១, ទិព្វចក្ខុ ១, បញ្ញាចក្ខុ ១, ពុទ្ធចក្ខុ ១ និងសមន្តចក្ខុ ១ (ក្នុងខុទ្ទកនិកាយ មហានិទ្ទេស) ។

*ដែលមកដល់គន្លងនៃចក្ខុប៉ុណ្ណោះ, ចំណែកទិព្វចក្ខុនេះ រមែងឃើញរូបដែលមិនមកដល់គន្លងនៃចក្ខុបាន សូម្បីរូបនោះ នឹងមានភ្នំបាំងទុកជាដើមក៏ដោយ ។ ឯរូបវិញ សូម្បីល្អិតក្រៃលែង ក៏ជាគោចរ គឺអារម្មណ៍របស់ទិព្វចក្ខុបានដែរ, ប៉ុន្តែ រូបដូច្នេះ ជាអារម្មណ៍របស់មំសចក្ខុមិនបានឡើយ ព្រោះហេតុដូច្នោះ អានុភាព គឺអំណាច និងគោចរ គឺអារម្មណ៍នៃចក្ខុទាំងពីរនេះ ទើបមិនដូចគ្នា ដោយប្រការដូច្នេះ ។ ត្រូវសកវាទីសួរថា* **"ជាឧបាទិន្ន** *គឺជាកម្មជរូប* ***ហើយជាអនុបាទិន្ន*** *គឺមិនមែនកម្មជរូបឬ ?" បរវាទីនោះ រមែងប្រាថ្នាមំសចក្ខុជាឧបាទិន្ន, ចំណែកទិព្វចក្ខុជាអនុបាទិន្ន ទាំងមំសចក្ខុនោះឯង ក៏មិនជាទិព្វចក្ខុទេ ព្រោះហេតុដូច្នោះ ទើបឆ្លើយបដិសេធ ។ ត្រូវសកវាទីសួរលើកទីពីរ ទិព្វចក្ខុរមែងកើតឡើង ព្រោះអាស្រ័យមំសចក្ខុជាបច្ច័យ ព្រោះអាស្រ័យព្រះបាលីថា "ការកើតឡើងនៃមំសចក្ខុជាផ្លូវនៃទិព្វចក្ខុ" ដូច្នេះ ទាំងមំសចក្ខុនោះ ក៏ជាសេចក្តីដូរផង់របស់មហាភូតរូបទាំង ៤ ដែលប្រព្រឹត្តទៅក្នុងរូបាវចរ ព្រោះហេតុដូច្នោះ ទើបបរវាទីឆ្លើយយល់ព្រម ។ សូម្បីត្រូវសកវាទីសួរថា "ជាកាមាវចរ" បរវាទីមិនប្រាថ្នានូវមំសចក្ខុនោះឯង ជាទិព្វចក្ខុ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបឆ្លើយបដិសេធ ។ ត្រូវសកវាទីសួរលើកទីពីរ ក៏ឆ្លើយយល់ព្រមថា* ***"ធម្មតា*** *រូបាវចរកើត ព្រោះភាវៈនៃមំសចក្ខុកើតឡើង*

ហើយ ដោយមានរូបាវចរជ្ឈានជាបច្ច័យ” ។ សូម្បីត្រូវសកវាទីសួរថា **“ជារូបាវចរហើយជាអរូបាវចរឬ ?”** តអំពីនេះទៅ លោកឆ្លើយបដិសេធ ព្រោះមិនមានរូបាវចរចិត្ត ក្នុងខណៈនៃអរូបាវចរ ដោយការភាវនា ។ ត្រូវសកវាទីសួរលើកទី ២ ក៏ឆ្លើយយល់ព្រម ព្រោះលទ្ធិថា “មំសចក្ខុនោះ ជាសភាពថ្លាផូរផង់នៃមហាភូតរូបទាំង ៤ ដែលជាបច្ច័យញុំាង អរូបាវចរឲ្យកើតឡើង” ។ ក៏ប៉ុន្តែបរវាទីនោះ មិនប្រាថ្នាការដែលមំស-ចក្ខុនោះជាលោកុត្តរធម៌ (អបរិយាបន្ន) ព្រោះហេតុដូច្នោះ ទើបឆ្លើយបដិសេធនោះដូចគ្នាដែរ ។ ពាក្យថា **“ទិព្វចក្ខុ ដែលធម៌ឧបត្ថម្ភហើយ”** បានដល់ ជាធម៌ដែលកាមាវចរឧបត្ថម្ភហើយ ។ ពាក្យថា **“ដែលធម៌ឧបត្ថម្ភហើយ”** បានដល់ ជាធម៌ដែលលោកុត្តរឧបត្ថម្ភហើយ ។ ត្រូវសកវាទីសួរថា **“ចក្ខុមានពីរយ៉ាងប៉ុណ្ណោះឬ ?”** បរវាទីមិនប្រាថ្នាភាវៈនៃទិព្វចក្ខុដែលធម៌ឧបត្ថម្ភហើយ ជាបញ្ញាចក្ខុ ក៏ពិតមែន, ប៉ុន្តែ ក៏ឆ្លើយបដិសេធ ព្រោះភាវៈនៃបញ្ញាចក្ខុជាសភាពនៅមាន ។ ត្រូវសកវាទីសួរទៀត ក៏ឆ្លើយយល់ព្រម ដោយអំណាចនៃលទ្ធិថា “មំសចក្ខុ ដែលធម៌ឧបត្ថម្ភហើយរមែងជាទិព្វចក្ខុ” ដូច្នេះ ពាក្យដែលនៅសល់ក្នុងទីនេះ មានអត្ថងាយស្រួលទាំងអស់មែនពិត ៕

ចប់ទិព្វចក្ខុកថា

.............

## ៨.ទិព្វសោតកថា សម្តែងអំពីទិព្វសោត *

*ឥឡូវនេះ ឈ្មោះថា រឿងទិព្វសោត ៖*

*ក្នុងរឿងនោះ បរវាទីត្រូវសកវាទីសួរថា* ***“សោតៈមានតែម្យ៉ាងប៉ុណ្ណោះឬ ?”*** *ក៏ឆ្លើយបដិសេធ ព្រោះសោតៈមានតែ ២ គឺមំសសោតនិងទិព្វសោត ។ ត្រូវសកវាទីសួរទៀត ក៏ឆ្លើយយល់ព្រម, ព្រោះថា* **មំសសោត** *នោះៗ ដែលធម៌ឧបត្ថម្ភហើយ ឈ្មោះថា* **ទិព្វសោត** *។ ពាក្យដែលនៅសល់ មានន័យដូចពោលហើយ ក្នុងខាងក្រោយនុ៎ះឯង ៕*

ចប់ទិព្វសោតកថា

## ៩.យថាកម្មូបគតញ្ញាណកថា សម្តែងអំពីយថាកម្មូបគតញ្ញាណ

*ឥឡូវនេះ ឈ្មោះថា រឿងយថាកម្មូបគតញ្ញាណ បានដល់ ញាណជាគ្រឿងដឹងនូវភាវៈនៃសត្វទាំងឡាយ ប្រព្រឹត្តទៅតាមកម្ម ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្តីយល់ឃើញថា*

---

* **សោតៈ ២ យ៉ាង គឺ ១-មំសសោត បានដល់ សោតបសាទ និង ២-ទិព្វសោត បានដល់ អភិញ្ញាញាណ ។ ក្នុងគម្ពីរយមកៈពោល សោតៈ ៣ គឺ ១-មំសសោត បានដល់ សោតបសាទ, ២-ទិព្វសោត បានដល់ អភិញ្ញាចិត្តុប្បាទ, ៣-តណ្ហាសោត បានដល់ លោភចេតសិក ។**

“យថាកម្មូបគតញ្ញាណនោះឯង ជាទិព្វចក្ខុ” ដូច្នេះ ព្រោះមិនពិចារណាកាន់យកព្រះសូត្រថា “តថាគតដឹងច្បាស់នូវភាវៈនៃសត្វទាំងឡាយ ប្រព្រឹត្តទៅតាមកម្ម ។ល។ ដោយទិព្វចក្ខុដ៏បរិសុទ្ធ មានប្រការយ៉ាងនេះ” ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ត្រូវសកវាទីសួរទៀតថា **“ធ្វើទុកក្នុងចិត្តនូវភាវៈនៃសត្វប្រព្រឹត្តទៅតាមកម្មផង”** បរវាទីឆ្លើយបដិសេធ ព្រោះអារម្មណ៍ ២ យ៉ាងរបស់ចិត្តដួងដូចគ្នា មិនមាន ។ ត្រូវសកវាទីសួរលើកទី ២ ក៏ឆ្លើយយល់ព្រមដោយអំណាចនៃចិត្តផ្សេងៗ, សកវាទីមិនឲ្យឱកាសដែលភ្លាំងភ្លាត់របស់បរវាទីនោះ ទើបសួរទៀតថា **“ជាការប្រជុំនៃផស្សៈ ២ យ៉ាងឬ ?”** បរវាទីឆ្លើយបដិសេធ ។ គប្បីជ្រាបខ្លឹមសារក្នុងការប្រកបបទយថាកម្មូ-បគតៈនេះ យ៉ាងណា, ក៏គប្បីប្រកបសូម្បីដោយបទថា **“ឥមេ វត ភោន្តោ សត្តា** = សត្វទាំងនេះហ្ន៎ លោកទាំងឡាយ” ជាដើម យ៉ាងនោះៗ ឯង ។

ពាក្យថា “ព្រះសារីបុត្តដឹងភាវៈនៃសត្វទាំងឡាយ ប្រព្រឹត្តទៅតាមកម្មឬ ?” ដូច្នេះ អធិប្បាយថា ព្រះសារីបុត្តត្ថេរ រមែងមិនប្រើអភិញ្ញាញាណទាំងឡាយ ព្រោះភាពជាអ្នកប្រាថ្នាតិច, ប៉ុន្តែ ជនពួកខ្លះ មិនដឹង ទើបសម្គាល់ថា

*“អភិញ្ញាញាណទាំងនោះ មិនមានដល់ព្រះថេរៈឡើយ” ដូច្នេះ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបសកវាទីសួរបរវាទីដែលសម្គាល់ថា “ព្រះថេរៈមិនបានទិព្វចក្ខុ” ដូច្នេះ ។ ដោយហេតុនោះឯង ទើបត្រូវសកវាទីសួរខ្លឹមសារតទៅទៀតថា* ***“ព្រះសារីបុត្តមានទិព្វចក្ខុឬ ?”*** *បរវាទីឆ្លើយបដិសេធ ។ ត្រូវសកវាទីសួរលើកទីពីរ ក៏ឆ្លើយយល់ព្រមថា “អភិញ្ញាញាណណាមួយ ដែលព្រះសាវកគប្បីសម្រេច ញាណទាំងអស់នោះ ព្រះថេរៈសម្រេចហើយដោយលំដាប់” ។ ឥឡូវនេះ សកវាទីពេលនឹងឲ្យបរវាទីប្រឫកប្រឫល ទើបពោលពាក្យថា* ***“ព្រះសារីបុត្តបានពោលពាក្យនេះទុកថា ការតាំងសេចក្តីប្រាថ្នា ដើម្បីបុព្វេនិវាសញ្ញាណ ទិព្វចក្ខុញ្ញាណ ចេតោបរិយញ្ញាណ ឥទ្ធិវិធៈ សេចក្តីបរិសុទ្ធនៃសោតធាតុ និងចុតូបបាត-ញ្ញាណរបស់យើង មិនមានទេ”*** *។ ពិតណាស់ លោកពោលថា នេះក៏ព្រោះមិនមានសេចក្តីប្រាថ្នានឹងប្រើ, លោកមិនបានពោលព្រោះមិនមានអភិញ្ញាញាណទាំងឡាយ មិនមែនឬ ?, ប៉ុន្តែបរវាទីកំណត់ខ្លឹមសារព្រះសូត្រថា* ***“សេចក្តីប្រាថ្នា ។ ល ។ របស់យើងមិនមានប៉ុណ្ណោះ”*** *ព្រោះហេតុដូច្នោះ ទើបឆ្លើយយល់ព្រមតាមលទ្ធិនោះថា “ព្រះថេរៈមានត្រឹមតែយថាកម្មូបគតញ្ញាណ, មិនមានទិព្វចក្ខុញ្ញាណទេ” ដោយហេតុ*

*នោះឯង ទើបសកវាទីសួរថា* ***“បើដូច្នោះ លោកក៏មិនគប្បីពោលថា យថា-កម្មូបគតញ្ញាណ ជាទិព្វចក្ខុឡើយ”*** ៕

ចប់យថាកម្មូបគតញ្ញាណកថា

---

## ១០.សំវរកថា សម្តែងអំពីការសង្រួម

*ឥឡូវនេះ ឈ្មោះថា រឿងសង្រួម ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្តីយល់ឃើញថា "ទេវតាទាំងឡាយជាន់លើតាំងពីជាន់តាវត្តិង្សឡើងទៅ រមែងមិនប្រព្រឹត្តកន្លងពៀរ ៥ គឺមិនកន្លងសីល ៥ ព្រោះហេតុណា, ព្រោះហេតុនោះការសង្រួមទើបមានដល់ទេវតាទាំងនោះ" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ព្រោះមិនឃើញសេចក្តីប្រាកដនៃពៀរ ៥ ។ លំដាប់នោះ ទើបសកវាទីសួរអំពីការមិនសង្រួម ព្រោះធម្មតាថា បើការសង្រួមមាន ការមិនសង្រួមដែលបុគ្គលគប្បីសង្រួម ក៏ត្រូវមានដែរ ។ ប៉ុន្តែបរវាទីឆ្លើយបដិសេធព្រោះក្នុងទេវតាទាំងឡាយ មិនមានបាណាតិបាតជាដើមទេ ។ ពាក្យថា* ***"ការសង្រួមក្នុងពពួកមនុស្ស"*** *ជាដើម សកវាទីពោលដើម្បីបញ្ជាក់ការប្រព្រឹត្តទៅនៃសេចក្តីមិនសង្រួម, ក៏កាលបើសេចក្តីសង្រួម និងការប្រព្រឹត្តទៅ នៃសេចក្តីសង្រួមមាន ការមិនសង្រួម ក៏ត្រូវមានដែរ ។ ក្នុងបញ្ហាថា* **"បាណាតិបាតា វេរមណី"** *ជាដើម គប្បីជ្រាបពាក្យឆ្លើយយល់ព្រមដោយអំណាចនៃការមិនប្រព្រឹត្តបាណាតិបាតជាដើម និងគប្បីជ្រាបពាក្យឆ្លើយបដិសេធ ព្រោះមិនមានបាណាតិបាតជាដើមទេ ។ បញ្ហាពោល*

*ដោយបដិលោម មានខ្លឹមសារងាយស្រួលទាំងអស់ ។ ក្នុងបញ្ហាថា* ***“បាណាតិបាតមិនមានក្នុងពួកទេវតាឬ ?”*** *គប្បីជ្រាបពាក្យឆ្លើយយល់ព្រមរបស់បរវាទី ដោយអំណាចនៃការមិនប្រព្រឹត្តបាណាតិបាតជាដើម និងពាក្យបដិសេធរបស់បរវាទី ព្រោះមិនមានបាណាតិបាតជាដើម ។ បញ្ហាពោលដោយបដិលោម មានខ្លឹមសារងាយស្រួលទាំងអស់ ។ ក្នុងបញ្ហាទាំងឡាយ បទទីបំផុតថា* ***“ការសង្រួមមិនមានក្នុងពួកទេវតាឬ ?”*** *ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី សំដៅយកការមិនមានសេចក្តីសង្រួមចាកការធ្វើបាណាតិបាតជាដើមទៀត ។ តអំពីនោះ ពាក្យសួររបស់បរវាទីថា* ***“បើការសង្រួមរបស់ទេវតាទាំងឡាយមិនមាន, ទេវតាទាំងពួង ក៏ត្រូវជាអ្នកសម្លាប់ជីវិតដែរ”*** *ជាដើម ដោយអំណាចនៃពាក្យដែលមានលេសន័យ ។ ពាក្យបដិសេធជារបស់បរវាទី ព្រោះមិនមានការប្រព្រឹត្តកន្លងពៀររបស់ទេវតាទាំងឡាយឡើយ ។ បរវាទីឲ្យលទ្ធិតាំងទុក ព្រោះកាន់យកត្រឹមតែពាក្យថា* ***“មិនគប្បីពោល”*** *ដូច្នេះ របស់សកវាទី ។ តែលទ្ធិដែលតាំងទុកហើយយ៉ាងនេះ រមែងតាំងទុកមិនបានឡើយ ៕*

ចប់សំវរកថា

# ១១.អសញ្ញកថា

## សម្ដែងអំពីអសញ្ញា គឺមិនមានសញ្ញា

*ឥឡូវនេះ ឈ្មោះថា រឿងអសញ្ញា* * ៖

*ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្ដីយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈ ក្នុងខណៈនេះថា "សញ្ញាមាននៅក្នុងពេលចុតិ និងបដិសន្ធិ សូម្បីរបស់អសញ្ញីសត្វទាំងឡាយថា* ***'ក៏ឈ្មោះថា បដិសន្ធិវៀរចាកវិញ្ញាណ មិនមានឡើយ'*** *ព្រោះពាក្យថា* ***'វិញ្ញាណ មានសង្ខារជាបច្ច័យ"*** *ដូច្នេះ, និងពាក្យថា* ***"ក៏ឯអសញ្ញីទេពទាំងនោះ រមែងចុតិចាកកាយនោះ ព្រោះការកើតឡើងនៃសញ្ញា"*** *ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យយល់ព្រមជារបស់បរវាទី ។ តពីនោះ សកវាទីដើម្បីនឹងព្រមានបរវាទី ដោយពាក្យជាដើមថា "ទីនោះជាភពមានសញ្ញាតាមលទ្ធិរបស់លោកឬ ?" ទើបពោលពាក្យថា* ***"ជា***

---

* រឿងនេះក្នុងគម្ពីរយមកៈអធិប្បាយថា សត្វក្នុងបញ្ចវោការភព និងចតុវោការភព ខណៈបដិសន្ធិ មានសញ្ញាកើតឡើង ក្នុងខណៈចុតិមិនមានសញ្ញាទេ ព្រោះសញ្ញាកំពុងតែរលត់; អ្នកចូលនិរោធសមាបត្តិ ក្នុងខណៈនិរោធ មិនមានសញ្ញាទេ, ចំណែកសត្វដែលជាឯកវោការភព គឺអសញ្ញីសត្វទាំងឡាយ ខណៈកើតក្ដី ខណៈតាំងនៅក្ដី ខណៈចុតិក្ដី មិនមានសញ្ញាកើតឡើងឡើយ ។

***សញ្ញាភព ជាសញ្ញាគតិ”*** ជាដើម ។ ពាក្យទាំងអស់នោះ និងពាក្យផ្សេងពីនោះទៀត គប្បីជ្រាបតាមន័យរបស់ព្រះបាលីនុ៎ះចុះ ៕

.................................

## ១២.នេវសញ្ញានាសញ្ញាយតនកថា

## សម្តែងអំពីនេវសញ្ញានាសញ្ញាយតនៈ

ឥឡូវនេះ ឈ្មោះថា រឿងនេវសញ្ញានាសញ្ញាយតនៈ គឺអាយតនៈដែលមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្តីយល់ឃើញខុសដូចលទ្ធិរបស់និកាយអន្ធកៈ ក្នុងខណៈនេះថា “ មិនគប្បីពោលថា ***‘សញ្ញាមាននៅក្នុងភពនោះ’*** ព្រោះព្រះបាលីថា ***អាយតនៈនោះ មានសញ្ញាក៏មិនមែន, មិនមានសញ្ញា ក៏មិនមែន”*** ដូច្នេះ, ពាក្យរបស់សកវាទី សំដៅដល់ជនទាំងនោះ; ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ពាក្យដែលនៅសល់ក្នុងទីនេះ គប្បីជ្រាបតាមន័យរបស់ព្រះបាលីនុ៎ះចុះ ។%

ចប់នេវសញ្ញានាសញ្ញាយតនកថា

## រួមកថាដែលមានក្នុងវគ្គនេះ គឺ

១.ពលកថា, ២.អរិយន្តិកថា, ៣.វិមុត្តិកថា, ៤.វិមុច្ចមានកថា, ៥.អដ្ឋមកកថា, ៦.អដ្ឋមកឥន្ទ្រិយកថា, ៧.ទិព្វចក្ខុកថា, ៨.ទិព្វសោត-

*កថា, ៩.យថាកម្មូបគតញ្ញាណកថា, ១០.សំវរកថា, ១១.អសញ្ញកថា, ១២.នេវសញ្ញានាសញ្ញាយតនកថា ។*

**ចប់វគ្គទី ៣**

# វគ្គទី ៤

## ១.គិហិ * អរហាតិកថា

## សម្ដែងអំពីគ្រហស្ថបានជាព្រះអរហន្ត

*ឥឡូវនេះ ឈ្មោះថា រឿងគ្រហស្ថបានជាព្រះអរហន្ត ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្ដីយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា "គ្រហស្ថ គប្បីបានជាព្រះអរហន្ត ព្រោះឃើញការកើតឡើងនៃព្រះអរហន្តរបស់ជនទាំងឡាយ មានយសកុលបុត្រជាដើម ដែលឋិតនៅក្នុងភេទជាគ្រហស្ថនៅឡើយ" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ ។ បណ្ដាពាក្យទាំងនោះ ពាក្យថា* **"គិហិស្ស"** *អធិប្បាយថា អ្នកណា ឈ្មោះថា គ្រហស្ថ ព្រោះប្រកបព្រម*

---

* ត្រង់នេះចែកបទថា **គិហិ អស្ស អរហា** = គ្រហស្ថគប្បីបានជាព្រះអរហន្ត, ម្យ៉ាងទៀតប្រែថា ព្រះអរហន្តនៅជាគ្រហស្ថដូច្នេះ ក៏បាន ។

ដោយសំយោជនៈជារបស់គ្រហស្ថ, អ្នកនោះ គប្បីបានជាព្រះអរហន្តឬ ? ចំណែកបរវាទីមិនដឹងបំណង, ពេលឃើញត្រឹមតែភេទគ្រហស្ថប៉ុណ្ណោះ ទើបឆ្លើយយល់ព្រមថា **“មែន”** ។ ឥឡូវនេះ ទើបសកវាទីផ្ដើម ពាក្យថា ***“គិហិសញ្ញោជនៈរបស់ព្រះអរហន្តមានឬ ?”*** ជាដើម ដើម្បីបញ្ជាក់ន័យនេះ ថាឈ្មោះថា ជាគ្រហស្ថ រមែងជាសំយោជនៈរបស់គ្រហស្ថ មិនមែនជាគ្រហស្ថ ដោយត្រឹមតែភេទទេ ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ៖

***“ទោះបីអ្នកណាមានធម៌ដែលប្រដាប់ (អប់រំ) ហើយ, ស្ងប់ហើយ, មានខ្លួនទូន្មានហើយ, ជាអ្នកទៀង, ជាព្រហ្មចារី, លះអាជ្ញាក្នុងសត្វទាំងឡាយហើយ, គប្បីប្រព្រឹត្តធម៌ស្មើ តថាគតពោលថា ‘អ្នកនោះ ជាព្រាហ្មណ៍ ជាសមណៈ ជាភិក្ខុ”*** ។

ពាក្យទាំងអស់នោះ មានខ្លឹមសារងាយស្រួលទាំងអស់មែនពិត ៕

ចប់គិហិអរហាតិកថា

---

## ២.ឧប្បត្តិកថា សម្ដែងអំពីការកើតឡើង

ឥឡូវនេះ ឈ្មោះថា រឿងការកើតឡើង ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្ដីយល់ឃើញខុសថា

*“ព្រះអនាគាមីឧប្បត្តិឡើងក្នុងសុទ្ធាវាស រមែងជាព្រះអរហន្តព្រមជាមួយការឧប្បត្តិ” ដូច្នេះ ព្រោះកាន់យកព្រះបាលីទាំងឡាយ ដោយមិនពិចារណាដែលមានពាក្យថា* ***“ជាឱបបាតិកៈកំណើត គឺកើតផុសឡើងក្នុងទេវលោកនោះ ហើយបរិនិព្វានក្នុងទេវលោកនោះឯង”*** *ជាដើម ឬថា ជនទាំងឡាយណា អ្នកសិក្សាព្រះពុទ្ធវចនៈ មានការយល់ឃើញថា “ព្រះអនាគាមីជាព្រះអរហន្ត ព្រមជាមួយការឧប្បត្តិឡើង” ដូច្នេះ ព្រោះផ្លាស់ប្តូរបទថា “ឧបហច្ចបរិនិព្វាយី” ទើបជាឈ្មោះរបស់ព្រះអនាគាមីមួយជំពូកក្នុង ៤៨ ជំពូក, ព្រះអនាគាមី ឈ្មោះថា ឧបហច្ចបរិនិព្វាយីនេះ លោកមានអាយុឈានកន្លងពាក់កណ្តាលនៃអាយុ ដែលកន្លងទៅហើយ ជាវេលាជិតនឹងបរិនិព្វាន លោកក៏សម្រេចជាព្រះអរហន្តហើយបរិនិព្វាន, ពួកអ្នកយល់ឃើញខុសទាំងនោះ បានប្តូរឈ្មោះចេញពីពាក្យថា* **“ឧបហច្ចបរិនិព្វាយី”** *មកជា* **“ឧបហជ្ជបរិនិព្វាយី”** *ដែលមានសេចក្តីសម្គាល់ថា “គ្រាន់តែកើតឡើងភ្លាម ក៏បរិនិព្វាន” ដូច្នេះ ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយ ក្នុងខណៈនេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ក្នុងបញ្ហានោះ ឈ្មោះថា ចិត្តដែលកើតឡើងជាលោកិយចិត្ត ទាំងបុគ្គលទាំងឡាយ ជាព្រះសោតាបន្នជាដើម ដោយ*

*លោកិយចិត្តនោះ ក៏មិនមានឡើយ, ចាំបាច់ពោលទៅថ្មីដល់ភាពជាព្រះអរហន្ត ទៅ ព្រោះហេតុដូច្នោះ ដើម្បីបញ្ជាក់ន័យនេះ ដល់បរវាទីនោះ ទើបសកវាទី ផ្តើមពាក្យជាដើមថា* ***"ជាព្រះសោតាបន្ន ព្រមជាមួយការកើតឡើង ក៏បានឬ ?"*** *។ សកវាទីពោលពាក្យថា* ***"ព្រះសារីបុត្ត"*** *ជាដើម ដើម្បីព្រមានថា "បណ្តាព្រះមហាថេរទាំងនោះ សូម្បីមួយអង្គ ឈ្មោះថាជាព្រះអរហន្តព្រមជាមួយការកើតមានឬ ?" ។ ពាក្យថា* ***" ចិត្ត ១ ដួង ស្វែងរកការកើតឡើង"*** *បានដល់ បដិសន្ធិចិត្ត; ពិតណាស់ បដិសន្ធិចិត្តនោះ រមែងស្វែងរកការកើត គឺតជាប់គ្នា ព្រោះហេតុនោះ ទើបលោកពោលបដិសន្ធិចិត្តនេះថា* ***" ចិត្ត ១ ដួង ស្វែងរកការកើតឡើង"*** *។ ពាក្យដែលនៅសល់ក្នុងទីនេះ មានខ្លឹមសារងាយស្រួលទាំងអស់មែនពិត ៕*

ចប់ឧប្បត្តិកថា

## ៣.អនាសវកថា សម្ដែងអំពីអនាសវៈ

*ឥឡូវនេះ ឈ្មោះថា រឿងអនាសវៈ គឺមិនជាអារម្មណ៍របស់អាសវៈ* * *៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយខត្តរាបថកៈ ក្នុងខណៈនេះថា "ធម៌ពួកណា របស់ព្រះអរហន្ត ដែលមិនមានអាសវៈ, ធម៌ទាំងអស់នោះ មិនជាអារម្មណ៍របស់អាសវៈឡើយ" ដូច្នេះ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា* ***"ធម៌ទាំងពួងរបស់ព្រះអរហន្ត"*** *ជាដើម ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីព្រមានថា "ធម៌ទាំងឡាយ មានមគ្គជាដើម ឈ្មោះថាជាធម៌មិនមានអាសវៈទេ, ធម៌ទាំងនោះប៉ុណ្ណោះ រមែងកើតដល់ព្រះអរហន្តឬ ?" ទើបផ្ដើមពាក្យថា* ***"ធម៌ទាំងពួងជាមគ្គ និងជាផល"*** *ជាដើម ត្រូវសកវាទីសួរថា* ***"ចក្ខុរបស់ព្រះអរហន្ត មិនជាអារម្មណ៍របស់អាសវៈឬ ?"*** *បរវាទីឆ្លើយបដិសេធ ព្រោះភាវៈនៃចក្ខុនោះ ជាអារម្មណ៍របស់អាសវៈ,*

---

* ពាក្យថា **"អាសវៈ"** គឺកិលេសជាគ្រឿងដេកត្រាំនៅក្នុងសន្ដានរបស់សត្វ មាន ៤ គឺ ១-កាមាសវៈ, ២-ភវាសវៈ, ៣-ទិដ្ឋាសវៈ, ៤-អវិជ្ជាសវៈ ។ ពាក្យថា "មិនជាអារម្មណ៍របស់អាសវៈ" បានដល់ លោកុត្តរចិត្ត ៨ ចេតសិក ៣៦ និងនិព្វាន ។

*ត្រូវសកវាទីសួរលើកទី ២ បរវាទីឆ្លើយយល់ព្រមថា ចក្ខុរបស់ព្រះអរហន្ត មិនជាអាសវៈទេ, តែជាអារម្មណ៍របស់អាសវៈ ។*

*ក្នុងបញ្ហាថា **ដោយការឱ្យចីវរ**, បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសចាកលក្ខណៈនៃបញ្ហានេះថា "ធម៌តែមួយៗងប្រព្រឹត្តទៅមិនជាអាសវៈទេ, តែជាអារម្មណ៍របស់អាសវៈ" ។ ត្រូវសកវាទីសួរលើកទីពីរ បរវាទីឆ្លើយយល់ព្រមថា ចីវររបស់ព្រះអរហន្ត មិនជាអាសវៈទេ, ប៉ុន្តែជាអារម្មណ៍របស់អាសវៈបាន; សូម្បីក្នុង ២ បញ្ហាថា **"របស់ដែលមិនជាអារម្មណ៍របស់អាសវៈដែរនោះ"** ក៏មានន័យដូចគ្នានេះដែរ ។ ប៉ុន្តែសកវាទីតែងតែព្រមាន ព្រោះការយល់ព្រមរបស់បរវាទីក្នុងពាក្យថា "របស់ដែលមិនជាអារម្មណ៍របស់អាសវៈដែរនោះ" ដោយពាក្យជាដើមថា "មគ្គមិនជាអារម្មណ៍របស់អាសវៈទេ ហើយជាអារម្មណ៍របស់អាសវៈឬ?" ។ គប្បីជ្រាបអត្ថន័យក្នុងទីទាំងពួង ដោយឧបាយនេះចុះ ៕*

ចប់អនាសវកថា

.................

## ៤.សមន្នាគតកថា * សម្តែងអំពីអ្នកប្រកប

---

* ពាក្យថា "**សមន្នាគតកថា** = រឿងអ្នកប្រកប ឬរឿងអ្នកដល់ព្រមហើយ" ។

*ផ្លូវនេះ ឈ្មោះថា រឿងអ្នកប្រកប ៖*

*ក្នុងរឿងនោះ ការប្រកប មាន ២ យ៉ាង គឺការប្រកបក្នុងភាពជាអ្នកព្រមព្រៀងគ្នាក្នុងខណៈនៃបច្ចុប្បន្ន ១, ការប្រកប គឺការបានចំពោះដោយសម្រេចភូមិណាមួយ មានរូបាវចរភូមិជាដើម ១ ។ ការប្រកប គឺការសម្រេចភូមិណាមួយនោះ នៅមិនសាបសូន្យចាកគុណវិសេស ដែលខ្លួនសម្រេចហើយត្រឹមណា ក៏ឈ្មោះថា ជាអ្នកបានគុណវិសេសត្រឹមនោះដែរ ។*

*ឯជនពួកណាមានសេចក្ដីយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយក្នុងខណៈនេះថា “វៀរលែងតែការប្រកប ២ យ៉ាងនេះហើយ ឈ្មោះថា ការប្រកបបែបផ្សេងណាមួយដោយអំណាចនៃបត្តិធម៌ គឺធម៌ដែលសម្រេច” ដូច្នេះ ដើម្បីឲ្យជនទាំងនោះ គាមចូលចិត្តថា “ឈ្មោះថា បត្តិធម៌ គឺធម៌ជាគ្រឿងសម្រេចរបស់ព្រះអរហន្តណា១ មាន បត្តិធម៌អ្វី១ មិនមាន” ទើបសួរថា* ***“ព្រះអរហន្តប្រកបដោយផល ៤ ឬ ?”*** *ពាក្យឆ្លើយយល់ព្រមសំដោយកការសម្រេចផល ជារបស់បរវាទី, លំដាប់នោះ ទើបសកវាទីផ្ដើមពាក្យជាដើមថា* ***“ព្រះអរហន្តប្រកបដោយផស្សៈ[*] ៤ ឬ ?”***

---

[*] ពាក្យថា **ផស្សៈ ៤** គឺផស្សចេតសិកដែលកើតជាមួយសោតាបត្តិផលចិត្ត, សកទាគាមិផលចិត្ត, អនាគាមិផលចិត្ត និងអរហត្តផលចិត្ត ។

ដើម្បីព្រមានថា "បើព្រះអរហន្តប្រកបដោយផលទាំង ៤ ដូចដល់ព្រមដោយនាមកន្ទ ៤ មែន, កាលបើមានសេចក្តីជាដូច្នេះ ធម៌ទាំងឡាយណាមានម្យ៉ាងៗ ៤ ក្នុងផលទាំង ៤ ជាដើម ធម៌ទាំងនោះ ក៏រមែងប្រកបព្រមដល់ព្រះអរហន្ត ព្រោះការប្រកបហើយដោយធម៌ម្យ៉ាងៗ ទាំង ៤ នោះ" ដូច្នេះ, ពាក្យទាំងនោះ បរវាទីឆ្លើយបដិសេធហើយ ព្រោះមិនមានផស្សៈជាដើមម្យ៉ាងៗ ៤ ក្នុងខណៈតែមួយទេ, សូម្បីក្នុងបញ្ហាពោលដោយព្រះអនាគាមី ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យថា ***"ព្រះអរហន្តកន្លងសោតាបត្តិផលទៅហើយមិនមែនឬ ?"*** អធិប្បាយថា ក៏សកវាទីរមែងសួរថា "ព្រះអរហន្តកន្លងផុត ព្រោះការមិនកើតឡើងទៀត មិនដូចទុតិយជ្ឈានលាភីបុគ្គលដែលឆ្លងនូវបឋមជ្ឈានហើយទេ, ពាក្យថា **"សោតាបត្តិមគ្គ"** ជាដើម ដែលសកវាទីប្រារព្ធហើយ ក៏ដើម្បីបញ្ជាក់ដល់ការមិនកើតឡើងទៀតរបស់មគ្គនោះ ព្រោះបដិបត្តិឆ្លងរួចផុតទៅហើយ ។

ក្នុងបញ្ហាថា "មិនសាបសូន្យចាកផល ៤ នោះ" សេចក្តីថា ធម៌គឺលោកិយជ្ឈានទាំងឡាយ រមែងសាបសូន្យដោយធម៌ដែលជាសឹកសត្រូវយ៉ាងណា, លោកុត្តរធម៌ជាយ៉ាងនោះ ក៏មិនមានឡើយ; ពិតណាស់ កិលេសឯណាដែលមគ្គលះហើយ កិលេសទាំងនោះ រមែងស្ងប់រម្ងាប់ទៅដោយផល, ទាំងកិលេសពួកនោះ ក៏លោកលះហើយ ជាធម្មជាតិស្ងប់រម្ងាប់

ទៅហើយ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបសកវាទីឆ្លើយយល់ព្រមថា “ ***មែន*** ” , ខ្លឹមសារនេះឯង លោកអធិប្បាយទុកហើយ ក្នុងពាក្យទាំងឡាយខាងមុខ ដែលមានពាក្យថា ***“ព្រះអរហន្តបានមគ្គ ៤ ហើយនឹងមិនសាបសូន្យចាកមគ្គ ៤ នោះ”*** ជាដើម, ពាក្យដែលនៅសល់ មានខ្លឹមសារងាយស្រួលទាំងអស់ ៕

ចប់សមន្នាគតកថា

## ៥.ឧបេក្ខាសមន្នាគតកថា សម្តែងអំពីអ្នកប្រកបដោយឧបេក្ខា

*សូម្បីក្នុងរឿងថា “ព្រះអរហន្តប្រកបដោយឧបេក្ខា ៦” បណ្ឌិតគប្បីជ្រាបខ្លឹមសារដោយន័យនេះ គឺន័យដែលពោលមកហើយ ។ ពិតណាស់ ព្រះអរហន្ត ព្រះមានព្រះភាគត្រាស់ហៅថា “អ្នកប្រកបដោយឧបេក្ខាទាំងនោះ” ព្រោះឧបេក្ខាទាំងឡាយក្នុងទ្វារទាំង ៦ សមគួរដែលនឹងកើតដល់លោក, ប៉ុន្តែឧបេក្ខាទាំង ៦ ទ្វារនោះ មិនបានកើតឡើងដល់លោកក្នុងខណៈតែមួយដូចគ្នាប៉ុណ្ណោះទេ៕*

ចប់ឧបេក្ខាសមន្នាគតកថា

........................

# ៦.ពោធិយាពុះទ្ធោគិកថា

## សម្តែងអំពីពាក្យថា ពុទ្ធៈ ព្រោះពោធិ *

*ឥឡូវនេះ ឈ្មោះថា រឿងពុទ្ធៈ ព្រោះពោធិ គឺបញ្ញាជាគ្រឿងត្រាស់ដឹង ៖*

*ក្នុងរឿងនោះ ពាក្យថា* **"ពោធិ"** *ជាឈ្មោះរបស់មគ្គញ្ញាណ ៤ ខ្វះ,*

---

* ពាក្យថា **ពោធិ** = បញ្ញាជាគ្រឿងត្រាស់ដឹង, ក្នុងទីនេះ លោកសំដៅយកមគ្គញ្ញាណខ្លះ សព្វញ្ញុតញ្ញាណខ្លះ លោកអ្នកចេះដឹងបានពោលពាក្យថា **"ពោធិ"** ទុកជា ៥ ន័យ គឺ

១-ដើមពោធិ៍ដែលព្រះពុទ្ធជាម្ចាស់ត្រាស់ដឹង ដូចជា **ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ** = ជាព្រះអភិសម្ពុទ្ធគ្រាដំបូង ត្រង់គល់ដើមពោធិ៍ ។

២-មគ្គចិត្ត ដូចជា **ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ** = ញាណក្នុងមគ្គ ៤ ព្រះសាស្តាត្រាស់ហៅថា **ពោធិ** ។

៣-សព្វញ្ញុតញ្ញាណ ដូចជា **បប្បោតិ ពោធិ អមតំ វរភូរិ មេធសោ** = ព្រះមានព្រះភាគទ្រង់សម្រេចពោធិ គឺសព្វញ្ញុតញ្ញាណដោយភូមិបញ្ញាដ៏កំពូលបំផុត ។

៤-ព្រះនិព្វាន ដូចជា **បត្វាន ពោធិ អមតំ អសង្ខតំ** = ទ្រង់សម្រេចហើយនូវពោធិ គឺព្រះនិព្វានដែលជាអមតៈ ដែលបច្ច័យអ្វីៗ តាក់តែងមិនបានឡើយ ។

៥-ជាឈ្មោះដោយចំពោះ ដូចជា **ពោធិ ភន្តេ រាជកុមារោ** = បពិត្រព្រះអង្គដ៏ចម្រើន រាជកុមារ ឈ្មោះថា **ពោធិ** ។

ជាឈ្មោះរបស់សព្វញ្ញុតញ្ញាណខ្លះ ព្រោះហេតុដូច្នោះ ជនណាមានសេចក្ដីយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយនោះឯង ក្នុងខណៈនេះថា “ឈ្មោះថា ជាព្រះពុទ្ធ ព្រោះពោធិ, ដូចពាក្យថា ‘ឈ្មោះថាមនុស្សស ព្រោះស្បែកស, ឈ្មោះថា មនុស្សខ្មៅ ព្រោះស្បែកខ្មៅ” ជាដើម, ពាក្យសួរក្ដី ពាក្យសួរបញ្ឆោកក្ដី របស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមក្ដី ពាក្យបដិសេធក្ដី ជារបស់បរវាទី ។ ក្នុងបញ្ហាថា ***“ព្រោះបញ្ញាជាគ្រឿងត្រាស់ដឹងដែលជាអតីត”*** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះខណៈនោះមិនមានទេ, ត្រូវសកវាទីសួរលើកទីពីរ លោកក៏ឆ្លើយ យល់ព្រមសំដៅយកការបានដោយចំពោះ ។ ត្រូវសកវាទីសួរដោយអំណាចនៃកិច្ចទៀត លោកក៏ឆ្លើយ ព្រោះមិនមានកិច្ចដែលគប្បីធ្វើទៀត, ត្រូវសកវាទីសួរលើកទីពីរ, លោកក៏ឆ្លើយយល់ព្រមនូវភាវៈនៃកិច្ចឯណា ដែលបញ្ញានោះធ្វើហើយ ជាអ្នកមិនវង្វេងភ្លេចក្នុងកិច្ចនោះ ។ ឯសកវាទីមិនឲ្យឱកាសដែលមានលេសន័យ ទើបសួរដោយន័យថា ***“នៅកំណត់ដឹងទុក្ខ”*** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះមិនមានកិច្ចនោះឡើយ ។ ក្នុងបញ្ហាថា ***ដោយអនាគត*** បរវាទីឆ្លើយបដិសេធ ព្រោះមិនមានមគ្គញ្ញាណក្នុងខណៈនោះ ។ ត្រូវសកវាទីសួរលើកទីពីរ, បរវាទីដែលសម្គាល់នូវភាវៈជាព្រះពុទ្ធ ព្រោះពោធិដែលជាអនាគត ដោយបាលីថា

“ព្រះពុទ្ធអង្គបានស្ដេចយាងដល់ក្រុងរាជគ្រឹះហើយ” ជាដើម ទើបឆ្លើយយល់ព្រម ។ ត្រូវសកវាទីសួរថា ***“ធ្វើកិច្ចដែលគប្បីធ្វើដោយបញ្ញាជាគ្រឿងត្រាស់ដឹង”*** បរវាទីឆ្លើយបដិសេធ ព្រោះមិនមានកិច្ចក្នុងខណៈនោះទេ, ត្រូវសកវាទីសួរលើកទីពីរ លោកឆ្លើយយល់ព្រម ដោយពាក្យថា “ឈ្មោះថា កំពុងធ្វើនោះឯង ព្រោះនរណាមួយ មិនគប្បីពោលថា ‘ព្រះពុទ្ធអង្គមិនគប្បីធ្វើករណីយកិច្ចទេ’ គួរពោលបានថា ‘ទ្រង់នឹងធ្វើណាស់’” ព្រោះហេតុដូច្នោះ ទើបឈ្មោះថា ការធ្វើនោះឯង ។ ត្រូវសកវាទីសួរហើយ ដោយមិនឲ្យឱកាសដែលមានលេសន័យទៀត ក៏ឆ្លើយបដិសេធ ។ បញ្ហាថា ដោយបច្ចុប្បន្ន ព្រមទាំងការប្រៀបធៀប មានន័យងាយស្រួលទាំងអស់ ។

ត្រូវសកវាទីសួរថា ***រួមពោធិ ៣ គឺដែលជាអតីត អនាគត និងបច្ចុប្បន្ន ឱ្យជួបគ្នា*** លោកសំដៅយកសព្វញ្ញុតញ្ញាណ ទើបឆ្លើយយល់ព្រម ព្រោះភាវៈដែលបុគ្គលគប្បីពោលថា ជាព្រះពុទ្ធដោយពោធិទាំង ៣ ។ ត្រូវសកវាទីសួររួមពោធិទាំង ៣ ទៀត, បរវាទីឆ្លើយបដិសេធ ព្រោះញាណទាំង ៣ នោះ មិនមានក្នុងខណៈតែមួយឡើយ ។ ត្រូវសកវាទីសួរលើកទីពីរទៀត, លោកក៏ឆ្លើយយល់ព្រម ដោយអំណាចនៃសព្វញ្ញុ-តញ្ញាណ ដែលមានទាំងអតីត អនាគត និងបច្ចុប្បន្ន; សកវាទីមិនឲ្យឱកាស

*ដែលមានលេសន័យដល់បរវាទីទៀត ទើបសួរថា **“ប្រកបតាំងមាំ”** ជាដើម លោកក៏ឆ្លើយបដិសេធ ។ ពាក្យសួរថា **“មិនគប្បីពោលថា ‘ឈ្មោះថា ពុទ្ធៈ ព្រោះបញ្ញាជាគ្រឿងត្រាស់ដឹងឬ ?”** ជារបស់បរវាទី; ពាក្យយល់ព្រម ជារបស់សកវាទី ព្រោះមិនសម្រេចភាវៈជាព្រះពុទ្ធ ក្នុងខណៈនៃពោធិ មិនមានទេ ។ ឯក្នុងបញ្ហាថា **“ព្រោះការបានបញ្ញាជាគ្រឿងត្រាស់ដឹង មិនមែនឬ ?”** សកវាទីនោះឯង ឆ្លើយយល់ព្រមថា **“មែន”** ព្រោះសភាពនៃសម្មតិថា “មគ្គញ្ញាណដែលបណ្ឌិតហៅថា ‘ពោធិកើតឡើងហើយក្នុងសន្តានណា, ក្នុងសន្តាននោះ ឈ្មោះថា ជាព្រះពុទ្ធ” ។ ព្រោះមិនយល់ដល់ពាក្យអធិប្បាយរបស់សកវាទីទេ, ទើបបរវាទីតាំងលទ្ធិទុកដោយពាក្យថា **“ប្រសិនបើ ឈ្មោះថា ពុទ្ធៈ ព្រោះការបានបញ្ញាជាគ្រឿងត្រាស់ដឹង ដោយហេតុនោះឯង ទើបលោកត្រូវពោលថា ‘ឈ្មោះថា ពុទ្ធៈ ព្រោះការបានបញ្ញាជាគ្រឿងត្រាស់ដឹង”** ។ ឥឡូវនេះ ជាពាក្យសួររបស់សកវាទីថា **“ឈ្មោះថា ពុទ្ធៈ ព្រោះការបានបញ្ញាជាគ្រឿងត្រាស់ដឹង ព្រោះហេតុដូច្នោះ ទើបឈ្មោះថា ពុទ្ធៈ ព្រោះបញ្ញាជាគ្រឿងត្រាស់ដឹងឬ ?”** ដើម្បីធ្វើខ្លឹមសារដែលបរវាទីនោះ មិនបានកំណត់ទុកឲ្យប្រាកដ ។ បណ្ឌិតគប្បីជ្រាបខ្លឹមសារនៃបញ្ហានោះថា “ឈ្មោះថា ជាព្រះពុទ្ធ ព្រោះការបានចំពោះនូវពោធិតាម*

លទ្ធិរបស់លោក ព្រោះហេតុណា, ព្រោះហេតុនោះ ទើបឈ្មោះថា ព្រះពុទ្ធ ព្រោះពោធិឬ ?" ។ ពេលបរវាទីមិនកំណត់កាលវិភាគនេះថា "កាលបើពោធិកើតឡើង សូម្បីរលត់ទៅហើយ ភាវៈដែលកើតឡើងហើយក្នុងសន្តាន នោះឯង ឈ្មោះថា ការបានបញ្ញាជាគ្រឿងត្រាស់ដឹង, មានក្នុងខណៈនៃមគ្គ ឈ្មោះថា **ពោធិ**" ទើបឆ្លើយយល់ព្រមទៀត; ពេលនោះ ទើបត្រូវសកវាទីសួរថា ***"ឈ្មោះថា ពោធិ ក៏ព្រោះការបានបញ្ញាជាគ្រឿងត្រាស់ដឹងឬ ?"*** ពេលមិនមានឱកាសដែលនឹងពោលអ្វីបាន, ទើបលោកឆ្លើយបដិសេធដូច្នេះឯង ៕

ចប់ពោធិយាពុទ្ធោតិកថា

បញ្ញាក់ រឿងទាំង ៣ ដូចពណ៌នាមកនេះ ជារបស់និកាយឧត្តរាបថកៈទាំងឡាយ នោះឯង ៕

---

## ៧.លក្ខណកថា សម្តែងអំពីលក្ខណៈ

ឥឡូវនេះ ឈ្មោះថា រឿងលក្ខណៈ ៖

ក្នុងបញ្ហានោះ ជនពួកណា មានសេចក្តីយល់ឃើញខុស ដូចលទ្ធិនិកាយរបស់ឧត្តរាបថកៈទាំងឡាយ ក្នុងខណៈនេះថា "មានតែព្រះពោធិសត្វប៉ុណ្ណោះ ដែលដល់ព្រមហើយដោយលក្ខណៈ ព្រោះមិនពិចារណាកាន់យក

*ព្រះសូត្រនេះថា* ***‘មានគតិតែ ២ ប៉ុណ្ណោះ*** *គឺបើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិដែលទ្រទ្រង់ធម៌ ។ ល ។ ប៉ុន្តែបើចេញបួសជាអនាគារិយៈ នឹងបានត្រាស់ដឹងជាព្រះអរហន្តសម្មាសម្ពុទ្ធ រមែងមានដល់មហាបុរសដែលប្រកបដោយលក្ខណៈ” ដូច្នេះ បញ្ហារបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ក្នុងបញ្ហាទាំងឡាយថា* ***ចក្កវត្តិសត្ត*** *សេចក្តីថា សត្វដែលជាចក្រពត្តិក្តី ជាពោធិសត្វក្តី ឬមិនមែនជាពោធិសត្វក្តី ព្រោះហេតុណា, ព្រោះហេតុនោះ បរវាទីសំដៅយកស្តេចចក្រពត្តិ ដែលមិនមែនជាពោធិសត្វ ទើបឆ្លើយបដិសេធ, រមែងឆ្លើយយល់ព្រម ព្រោះសំដៅយកស្តេចចក្រពត្តិដែលជាពោធិសត្វ ។ ព្រះសូត្រដែលបរវាទីពោលថា* ***“មហាបុរិសលក្ខណៈ ៣២ ប្រការ”*** *សំដៅយកពោធិសត្វ ។ ព្រោះថា ក្នុងភពជាទីបំផុត ពោធិសត្វនោះ រមែងជាព្រះពុទ្ធ, ក្នុងជនទាំងឡាយក្រៅអំពីនេះ ជាស្តេចចក្រពត្តិ ប៉ុន្តែមិនជាព្រះពុទ្ធទេ, ព្រោះហេតុដូច្នោះ ព្រះសូត្រដែលបរវាទីនាំមកអាងហើយ ហាក់ដូចជានឹងមិននាំមកទាល់តែសោះ ៕*

ចប់លក្ខណកថា

---

# ៨.និយាមោក្កន្តិកថា

## សម្តែងអំពីការស្ទង់ឈានចុះកាន់និយាម *

*ឥឡូវនេះ ឈ្មោះថា រឿងការស្ទង់ចុះកាន់និយាម ការស្ទង់ចុះដល់ផ្លូវដែលរឹងមាំ គឺអរិយមគ្គ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈ ក្នុងខណៈនេះថា “ព្រះពោធិសត្វមាននិយាម ដែលស្ទង់ចុះហើយ មានព្រហ្មចារ្យដែលប្រព្រឹត្តហើយ ក្នុងព្រះធម៌វិន័យរបស់ព្រះសាស្តាព្រះនាមថា* **កស្សបៈ**” *។ ព្រោះសំដៅយកការបព្វជ្ជារបស់ជោតិបាល ក្នុងឃដិការសូត្រ ។ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរដោយពាក្យថា* ***“ព្រះពោធិសត្វ”*** *ជាដើម ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ព្រោះតាំងនៅក្នុងលទ្ធិ ។ ខ្លឹមសារក្រៅពីនោះ ពាក្យថា* ***“និយាម*** *គឺផ្លូវមាំទាំក្តី, ព្រហ្មចារ្យក្តី” ជាឈ្មោះរបស់អរិយមគ្គ ។ លើកលែងតែការបំពេញបារមី របស់ព្រះពោធិសត្វចេញហើយ ឈ្មោះថាការស្ទង់ចុះដល់និយាមម្យ៉ាង រមែងមិនមាន, បើពោធិសត្វគប្បីជាព្រះ*

---

* ពាក្យថា **“និយាមោក្កន្តិ”** ញែកជា **និយាមំ** បានដល់ អរិយមគ្គ, **ឱក្កន្តិ** បានដល់ការស្ទង់ចុះ ឬការឈានចុះ ។

*សោតាបន្ន គប្បីជាអរិយសាវកមែន, ខនេះប្រព្រឹត្តទៅមិនបាន ។ ពិតណាស់ ព្រះពុទ្ធទាំងឡាយទ្រង់ព្យាករពោធិសត្វនោះថា "អ្នកនេះ នឹងជាព្រះពុទ្ធ" ព្រោះព្រះអង្គឋិតនៅក្នុងញាណដែលជាកម្លាំងរបស់ព្រះអង្គនោះឯង ព្រោះហេតុដូច្នោះ ទើបសកវាទីសាកសួរដោយពាក្យថា* ***"ពោធិសត្វ"*** *ដូច្នេះទៀត ។ ពាក្យឆ្លើយបដិសេធជារបស់បរវាទី សំដៅយកបច្ឆិមភព គឺភពចុងក្រោយបំផុត ។ ក្នុងបញ្ហាទីពីរ បរវាទីនោះឯង ឆ្លើយយល់ព្រម សំដៅយកវេលាដែលព្រះពុទ្ធអង្គកាលនៅជាជោតិបាល ។ សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា* ***"ជាសាវក"*** *ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យថា* ***"ការស្តាប់តាម"*** *សំដៅសេចក្តីថា អ្នកមានធម៌ចាក់ធ្លុះហើយ ដោយការស្តាប់តៗ គ្នាមក ។ បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកបច្ឆិមភព, រមែងឆ្លើយយល់ព្រម ព្រោះសំដៅយកការស្តាប់តៗ គ្នាមកក្នុងកាលនៅជាជោតិបាល ។ ពាក្យថា* ***"រាប់អានសាសនាផ្សេងៗ"*** *ដែលសកវាទីពោលហើយនោះ សំដៅយកអាឡារតាបស និងរាមបុត្រតាបស ។ ពាក្យថា* ***"ព្រះអានន្ទ"*** *ជាដើម ដែលសកវាទីពោលហើយ ដើម្បីបញ្ជាក់ថា "អ្នកមាននិយាមដែលស្ទង់ចុះហើយប៉ុណ្ណោះ ជាព្រះសាវក ក្រៅពីនេះមិនមែនទេ, តែអ្នកមាននិយាមដែលស្ទង់ចុះហើយដូច្នេះ មាន" ។ ត្រង់*

ពាក្យថា ***“សាវកកាលជាតិកន្លងទៅហើយ”*** សេចក្តីថា សកវាទីរមែងសួរដោយពាក្យថា “សាវកដោយជាតិណា, តែពេលរំលងជាតិហើយ មិនជាសាវកក្នុងភពផ្សេងៗ ទេឬ?” ដូច្នេះ, បរវាទីឆ្លើយបដិសេធ ព្រោះព្រះសោតាបន្នជាដើមជាសាវក ។ ពាក្យដែលនៅសល់ក្នុងទីនេះ មានខ្លឹមសារងាយស្រួលទាំងអស់ ៕

ចប់និយាមោក្កន្តិកថា

## ៩.អបរាបិសមន្នាគតកថា

## សម្តែងអំពីអ្នកប្រកបដោយរឿងផ្សេងមួយទៀត

ឥឡូវនេះ ឈ្មោះថា អ្នកប្រកបដោយរឿងផ្សេងមួយទៀត ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសថា “បុគ្គលអ្នកតាំងនៅក្នុងមគ្គទី ៤ ជាអ្នកប្រកបដោយផល ៣ ដោយអំណាចនៃការពន្ធុះ” ដូច្នេះ ដូចលទ្ធិរបស់និកាយអន្ធកៈក្នុងខណៈនេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ; ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ពាក្យដែលនៅសល់ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបខ្លឹមសារដោយន័យដែលពោលអំពីក្នុងរឿងបុគ្គលអ្នកប្រកបដោយផល ៤ ក្នុងខាងក្រោយចុះ ៕

ចប់អបរាបិសមន្នាគតកថា

# ១០.សព្វសញ្ញោជនប្បហានកថា

## សម្ដែងអំពីការលះសញ្ញោជនៈទាំងពួង

*ឥឡូវនេះ ឈ្មោះថា រឿងការលះសញ្ញោជនៈទាំងពួង ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈក្នុងខណៈនេះថា "ភាពជាព្រះអរហន្ត លះសញ្ញោជនៈទាំងពួងបានដោយអស់រលីង" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ត្រូវសកវាទីសួរដោយពាក្យថា **"សញ្ញោជនៈទាំងពួង"** ដូច្នេះទៀត បរវាទីឆ្លើយបដិសេធ សំដៅយកការលះកិលេសដោយមគ្គទាំង ៣ តាមដែលពោលហើយក្នុងគ្រាក្រោយ ។ ត្រូវសកវាទីសួរលើកទីពីរ, បរវាទីឆ្លើយយល់ព្រម ព្រោះមិនមានការលះកិលេសដោយមគ្គនោះ ។ សូម្បីក្នុងពាក្យថា "សក្កាយទិដ្ឋិ" ជាដើម ក៏បរវាទីឆ្លើយបដិសេធ សំដៅយកភាពជាអ្នកលះកិលេសបានហើយ ដោយបឋមមគ្គ ។ រមែងឆ្លើយយល់ព្រម សំដៅយកការលះកិលេសមិនឲ្យមានសល់ ដោយមគ្គទី ៤ ។ ខ្លឹមសារក្នុងទីទាំងពួងក៏មានន័យដូចគ្នានេះដែរ ៕*

ចប់សព្វសញ្ញោជនប្បហានកថា

## រួមកថាដែលមានក្នុងវគ្គនេះ គឺ

*១. គិហិអរហាតិកថា ២. ឧបបត្តិកថា*

៣. អនាសវកថា ៤. សមន្នាគតកថា
៥. ខបេក្ខាសមន្នាគតកថា ៦. ពោធិយា ពុទ្ធោតិកថា
៧. លក្ខណកថា ៨. និយាមោក្កន្តិកថា
៩. អបរាបិសមន្នាគតកថា ១០.សព្វសញ្ញោជនប្បហានកថា ៕

**ចប់វគ្គទី ៤**

## វគ្គទី ៥

### ១.វិមុត្តិកថា សម្ដែងអំពីវិមុត្តិ (ការរួចផុត)

ឥឡូវនេះ ឈ្មោះថា រឿងវិមុត្តិ គឺការរួចផុត ៖

ក្នុងរឿងនោះ ពាក្យថា **“ វិមុត្តិញ្ញាណ”** ជាឈ្មោះរបស់ញាណទាំង ៤ គឺវិបស្សនាញាណ ១, មគ្គញ្ញាណ ១, ផលញ្ញាណ ១, និងបច្ចវេក្ខណញ្ញាណ ១ ។ បណ្ដាញាណទាំងនោះ **វិបស្សនាញាណ** ឈ្មោះថា **វិមុត្តិញ្ញាណ** ព្រោះរួចផុតហើយចាកនិមិត្តារម្មណ៍ជានិច្ច ឬព្រោះភាពជាតទង្គវិមុត្តិ, **មគ្គ** ឈ្មោះថា **សមុច្ឆេទវិមុត្តិ, ផល** ឈ្មោះថា **បដិបស្សទ្ធិ-វិមុត្តិ** ក៏បច្ចវេក្ខណញ្ញាណ រមែងដឹងនូវវិមុត្តិ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា វិមុត្តិញ្ញាណ ក្នុងវិមុត្តិញ្ញាណ ៤ យ៉ាងនេះ, មានតែ ***ផលញ្ញាណ***

***ប៉ុណ្ណោះ*** *ដែលរួចផុតហើយៗ ដោយអស់ដើឝ (សព្វគ្រប់), វិមុត្តិញ្ញាណ-ទស្សនៈ ៣ ដែលនៅសល់ នរណាមួយ ក៏មិនគប្បីពោលថា "រួចផុតហើយ ឬថា មិនរួចផុតឡើយ" ដូច្នេះ ព្រោះហេតុដូច្នោះ ពួកជនណា មាន ការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា "វិមុត្តិញ្ញាណ រួចផុតហើយ ដោយមិនប្លែកគ្នាឡើយ ព្រោះមិនពោលថា 'វិមុត្តិញ្ញាណ ឈ្មោះនេះរួចផុតហើយ" ដូច្នេះទេ, ពាក្យសួររបស់សកវាទី សំដៅដល់ជន ទាំងនោះ ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ត្រូវសកវាទីសួរទៀតថា " វិមុត្តិញ្ញាណមិនថាបែបណាទាំងអស់ ឈ្មោះថា រួចផុតហើយ" បរវាទី ឆ្លើយបដិសេធ ព្រោះសំដៅយកបច្ចវេក្ខណញ្ញាណជាដើម, ត្រូវសកវាទី សួរថា "របស់បុគ្គលអ្នកបដិបត្តិ" ជាដើម ក៏ឆ្លើយយល់ព្រមសំដៅយក ការមិនមានអាសវៈរបស់មគ្គញ្ញាណ សកវាទីពោលថា* ***"ញាណរបស់ សោតាបន្ន"*** *ដូច្នេះ ជាដើមទៀត, ដើម្បីព្រមានថា ក៏ញាណនោះ មិន មែនជាញាណរបស់ព្រះសោតាបន្នដែលតាំងនៅក្នុងផលទេ, តែក៏ឈ្មោះថា វិមុត្តិញ្ញាណឬ ? ដូច្នេះ គប្បីជ្រាបខ្លឹមសារទាំងពួង ដោយឧបាយនេះចុះ ៕*

ចប់វិមុត្តិកថា

## ២.អសេក្ខញ្ញាណកថា សម្តែងអំពីញាណរបស់ព្រះអសេក្ខៈ

*ឥឡូវនេះ ឈ្មោះថា រឿងញាណរបស់ព្រះអសេក្ខៈ គឺអ្នកមិនត្រូវសិក្សា ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្តីយល់ឃើញខុសដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា "ព្រះសេក្ខៈទាំងឡាយ មានព្រះអានន្ទជាដើម រមែងដឹងនូវអសេក្ខបុគ្គលទាំងឡាយ ដោយន័យជាដើមថា 'ព្រះមានព្រះភាគជាអ្នកប្រសើរបំផុត' ដូច្នេះ ព្រោះហេតុណា, ព្រោះហេតុនោះ អសេក្ខញ្ញាណ គឺញាណរបស់ព្រះអសេក្ខៈ រមែងមានដល់សេក្ខ-បុគ្គល" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ពាក្យថា* ***"ដឹង"*** *នេះ សកវាទីពោលដោយអំណាចនៃការដឹងដោយខ្លួនឯង ហើយសម្រេច ។ ពាក្យថា* ***"គោត្រភូបុគ្គល"*** *ជាដើម សកវាទីពោលដើម្បីសម្តែងនូវការមិនមាននៃញាណ ក្នុងផ្នែកខាងលើ និងផ្នែកខាងលើរបស់ព្រះអរិយបុគ្គលអ្នកតាំងនៅក្នុងភូមិធម៌ផ្នែកខាងក្រោម ។ ត្រង់ពាក្យថា "ព្រះអានន្ទពេលនៅជាសេក្ខៈក៏ជ្រាបបានថា 'ព្រះមានព្រះភាគមានព្រះគុណខ្ពស់" អធិប្បាយថា បរវាទី*

រមែងប្រាថ្នាព្រះសេក្ខៈនោះថា ជាអ្នកមានញាណរបស់ព្រះអសេក្ខៈ ព្រោះការប្រព្រឹត្តទៅនៃញាណថា "ព្រះភគវាជាព្រះអសេក្ខៈ" , តែមិនប្រាថ្នាញាណនោះថា ជាអសេក្ខៈ ព្រោះហេតុដូច្នោះ ទោះបីលទ្ធិបរវាទីតាំងនៅហើយយ៉ាងនេះ ក៏មិនឈ្មោះថា តាំងនៅឡើយ ។

ចប់អសេក្ខញ្ញាណកថា

## ៣.វិបរិតកថា សម្តែងអំពីញាណវិបរិត

ឥឡូវនេះ ឈ្មោះថា ញាណវិបរិត ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្តីយល់ឃើញ ដូចលទ្ធិរបស់និកាយអន្ធកៈថា "អ្នកណា មានសញ្ញាក្នុងបឋវី រមែងចូលសមាបត្តិមានបឋវីជាអារម្មណ៍, ញាណនោះ របស់អ្នកនោះ ជាញាណវិបរិត" ដូច្នេះ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី, គប្បីជ្រាបពាក្យអធិប្បាយរបស់បញ្ហានោះថា និមិត្តដែលកើតឡើង ព្រោះអាស្រ័យបឋវី, តែនិមិត្តកើតឡើង មិនមែនបឋវីទេ ហើយអ្នកមានសេចក្តីសម្គាល់ក្នុងបឋវីកសិណ រមែងចូលឈាន មានបឋវីជាអារម្មណ៍ ឈាននោះ ឈ្មោះថា មានញាណដែលវិបរិត គឺខុសចាក

*សេចក្តីពិត"* ។

*លំដាប់នោះ សកវាទីដើម្បីនឹងព្រមានថា "លក្ខណៈបឋវីក្តី សសម្ភារៈបឋវីក្តី និមិត្តបឋវីក្តី បឋវីទេវតាក្តី បឋវីទាំងអស់នោះឯង, ក្នុងបណ្តាបឋវីទាំងនោះ ញាណថា 'បឋវីមិនមែនជាញាណវិបរិត' , ចំណែកការយល់ឃើញ ដែលខុសប្រក្រតីក្នុងធម៌ដែលមិនទៀងថា 'ទៀង' ជាដើម ឈ្មោះថា* ***ញាណវិបរិត****, ញាណក្នុងបឋវីទាំងនេះ ញាណណាមួយ តាមលទ្ធិរបស់លោកជាញាណវិបរិតឬ ?" ទើបពោលពាក្យថា* ***"មានការយល់ឃើញខុសក្នុងសភាវៈដែលមិនទៀងថា 'ទៀង"*** *ជាដើម បរវាទីឆ្លើយបដិសេធ សំដៅយកការមិនមានលក្ខណៈដែលឃ្លៀងឃ្លាតអំពីការពិត, រមែងឆ្លើយយល់ព្រមសំដៅយកបឋវីនិមិត្ត ។ ពាក្យថា* ***"កុសលំ"*** *លោកពោលសំដៅយកញាណរបស់សេក្ខៈ និងបុថុជ្ជនទាំងឡាយ ។ សូម្បីក្នុងបញ្ហាថា "ព្រះអរហន្តនៅមានការយល់ឃើញខុសឬ ?" បរវាទីឆ្លើយបដិសេធ ព្រោះមិនមានលក្ខណៈដែលវិបល្លាសដូច្នោះ រមែងឆ្លើយយល់ព្រម សំដៅយកបឋវីនិមិត្ត ។*

*ពាក្យថា* ***"ជាទីបរិសុទ្ធដូចគ្នាឬ ?"*** *បរវាទីសួរដោយពាក្យថា "បឋវីកសិណទាំងពួងនេះ ជាលក្ខណៈបឋវីទាំងអស់ឬ ?" សកវាទីឆ្លើយ*

*បដិសេធ ព្រោះមិនមានសេចក្តីដូច្នោះទេ ។ ពាក្យសួររបស់សកវាទីថា "ដីនៅមាន និងមនុស្សខ្លះ ដែលចូលបឋវីកសិណ ចេញពីដី ក៏មិនមែនឬ ?" ដូច្នេះ គប្បីជ្រាបខ្លឹមសារក្នុងបញ្ហានោះថា សកវាទីសួរថា "និមិត្តបឋវីមាន បុគ្គលចូលសមាបត្តិមានដីជានិមិត្តពីដីនោះ ក៏មានដែរ, មិនបានចូលពីអាបោ ឬតេជោ មិនមែនឬ ?" ។ ពាក្យថា* ***"ដីមាន"*** *ជាដើម សកវាទីពោលដើម្បីបញ្ឈាក់ដោយពាក្យថា "បើញាណរបស់អ្នកចូលបឋវីកសិណជាញាណវិបរិតដូច្នេះមែន, និព្វានក៏មាន ពេលបុគ្គលចូលសមាបត្តិ មាននិព្វានជាអារម្មណ៍ក្តី មគ្គញ្ញាណដែលទាញចេញនូវសេចក្តីវិបរិតទាំងពួងក្តី, ក៏នឹងវិបរិតតាមលទ្ធិរបស់លោក" ៕*

ចប់វិបរិតកថា

## ៤.និយាមកថា សម្តែងអំពីនិយាម

*ឥឡូវនេះ ឈ្មោះថា រឿងនិយាម គឺផ្លូវដែលរឹងមាំ (ទៀងទាត់) បានដល់ អរិយមគ្គ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា "ព្រះមានព្រះភាគ ទ្រង់ជ្រាបថា 'បុគ្គលណា នឹងឈានចុះកាន់សម្មត្តនិយាម គឺមគ្គដ៏ត្រឹមត្រូវ, បុគ្គលនោះ គួរដើម្បី*

*នឹងត្រាស់ដឹងធម៌នោះ ព្រោះហេតុណា, ព្រោះហេតុនោះ ញាណ ដើម្បីសម្រេចនិយាម គឺផ្លូវដ៏រឹងមាំរបស់អនិយតបុគ្គល ជាបុថុជ្ជននោះៗនៅមាន" ដូច្នេះ; ពាក្យសួរថា* ***"អនិយតៈ គឺបុគ្គលដែលមិនរឹងមាំ"*** *ជាដើមរបស់សកវាទី សំដៅដល់ជនទាំងនោះ ។ ពាក្យថា* ***"ដើម្បីទៅកាន់ផ្លូវដ៏រឹងមាំ"*** *ក្នុងបញ្ហានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅមគ្គថា* ***និយាម*** *អធិប្បាយថា ដើម្បីការសម្រេចមគ្គ ដើម្បីការស្ទុងចុះដល់មគ្គ ។ ក៏ពាក្យថា "ព្រះមានព្រះភាគទ្រង់ជ្រាបថា 'បុគ្គលនេះ គួរដើម្បីពន្លុះនិយាម ព្រោះឃើញញាណឯណា របស់បុគ្គលនោះ" បរវាទីសំដៅដល់ញាណនោះ ទើបឆ្លើយយល់ព្រម ។ លំដាប់នោះ សកវាទីដើម្បីបញ្ជាក់ថា វាទៈរបស់បរវាទីនោះមិនត្រឹមត្រូវ* * *ទើបសាកសួរដល់ខ្លឹមសារដែលផ្ទុយគ្នា ដោយពាក្យថា* ***"បុគ្គលអ្នករឹងមាំ"*** *ជាដើម ។*

*បណ្ដាពាក្យទាំងនោះ ក្នុងបញ្ហាដំបូង បរវាទីឆ្លើយបដិសេធ ព្រោះឈ្មោះថា ញាណដើម្បីការសម្រេចនិយាមរបស់បុគ្គលដែលរឹងមាំ មិនមាន*

---

* បាលីអដ្ឋកថាខ្លះ ប្រើពាក្យថា **"អនុយុត្តន្តិ"** សំដៅដល់ពាក្យមិនត្រឹមត្រូវ, អដ្ឋកថារបស់ភូមា ប្រើពាក្យថា **"អនុយុត្តវាទីតីតិបិ"** សំដៅដល់ មានវាទៈដែលមិនត្រឹមត្រូវ, គឺប្រើបានដូចគ្នាទាំងពីរន័យ ។

ដោយមគ្គឡើយ ។ ក្នុងបញ្ហាទី ២ រមែងឆ្លើយយល់ព្រម ព្រោះមិនមានសេចក្តី ។ បញ្ហាទី ៣ ឆ្លើយបដិសេធ ព្រោះត្រូវសកវាទីសួរដោយពាក្យថា "អ្នកមិនរឹងមាំ មិនមានញាណដើម្បីទៅដល់ផ្លូវរឹងមាំ" ដោយខុសចាកលទ្ធិ សកវាទីធ្វើបញ្ហាដំបូងនោះៗ ឲ្យជាបញ្ហាទី ៤ ទៀត ហើយធ្វើ ៣ បញ្ហារបស់និយតបុគ្គល ដោយអំណាចនៃការសម្រេចនិយាមជាដើម ។ ក្នុងបញ្ហាទាំងនោះ បញ្ហាទី ១ បរវាទីឆ្លើយបដិសេធ ព្រោះញាណដើម្បីការសម្រេចនិយាមនោះ របស់និយតបុគ្គល មិនមានដោយមគ្គជាដើមទៀតទេ ។ ក្នុងបញ្ហាទី ២ ឆ្លើយយល់ព្រម ព្រោះមិនមានសេចក្តីនោះឯង ។ ក្នុងបញ្ហាទី ៣ រមែងឆ្លើយបដិសេធ ព្រោះខុសចាកលទ្ធិ ។ សកវាទីធ្វើបញ្ហាដំបូងនោះឯង ឲ្យជាបញ្ហាទី ៨ ទៀត ហើយធ្វើ ៣ បញ្ហារបស់និយតបុគ្គល ដោយអំណាចនៃការមិនសម្រេចនិយាមជាដើម ។ បណ្ឌិតគប្បីយល់ខ្លឹមសារនៃបញ្ហាទាំងនោះ ដោយន័យដែលពោលហើយនុ៎ះចុះ ។ សកវាទីធ្វើបញ្ហាដំបូងនោះឯង ឲ្យជាបញ្ហាទី ១២ ទៀត ហើយធ្វើ ៣ បញ្ហា មានពាក្យថា ***"មានផ្លូវដ៏រឹងមាំ"*** ជាដើម អំពីមូលនោះ ។ ក្នុងបញ្ហាទាំងនោះ មគ្គញ្ញាណប៉ុណ្ណោះ ឈ្មោះថាញាណដើម្បីទៅកាន់ផ្លូវដ៏រឹងមាំ ព្រោះហេតុណា, ព្រោះហេតុនោះ សកវាទីសំដៅដល់ញាណនោះ ទើបពោលថា ***"មានផ្លូវដ៏រឹងមាំ"*** ដូច្នេះ កាលបើ

*មានពាក្យថា “មានផ្លូវដ៏រឹងមាំ” ដែលសកវាទីពោលហើយ, បរវាទីក៏ឆ្លើយ បដិសេធ ។ ពេលសកវាទីពោលថា* ***“មានញាណ”*** *ដូច្នេះ, បរវាទី ក៏ឆ្លើយយល់ព្រម ។ សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា* **“សតិបដ្ឋាន”** *ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យថា* **“បច្ចនិក”** *ក៏មានខ្លឹមសារ ងាយស្រួលទាំងអស់ដែរ ។ ពាក្យថា* ***“គោត្រភូបុគ្គល”*** *ជាដើម សកវាទី ពោលដើម្បីបញ្ជាក់ថា ញាណណាដែលបុគ្គលណា មិនសម្រេចហើយ, ញាណនោះ របស់បុគ្គលនោះ រមែងមិនមានឡើយ ។ ពាក្យថា* ***“ព្រះមាន ព្រះភាគទ្រង់ជ្រាប”*** *សេចក្តីថា ព្រះមានព្រះភាគរមែងទ្រង់ជ្រាបដោយ ញាណពលៈរបស់ព្រះអង្គឯង, មិនមែនទ្រង់ជ្រាបអំពីសភាព ការសម្រេច និយាមធម៌របស់អ្នកផ្សេងទេ ព្រោះហេតុដូច្នោះ សូម្បីបរវាទីតាំងលទ្ធិទុក ហើយ ក៏តាំងនៅមិនបាន ដោយហេតុដូច្នេះឡើយ ៕*

ចប់និយាមកថា

................

## ៥.បដិសម្ភិទាកថា សម្តែងអំពីបដិសម្ភិទា

*ឥឡូវនេះ ឈ្មោះថា រឿងបដិសម្ភិទា គឺបញ្ញាជាគ្រឿងបែកធ្លាយ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិ របស់និកាយអន្ធកៈថា “ញាណ គឺសេចក្តីដឹងទាំងពួង គឺបដិសម្ភិទា ព្រោះ*

*កាន់យកព្រះបាលីថា "ញាណ គឺសេចក្តីដឹងរបស់ព្រះអរិយៈទាំងឡាយ យ៉ាងណាមួយ ជាលោកុត្តរ" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ ក្នុងបញ្ហាពោលដោយញាណ គឺសេចក្តីដឹងសម្មតិទាំងឡាយ, បរវាទីឆ្លើយបដិសេធ សំដៅយកញាណក្នុងសមាបត្តិដែលជាបឋវីកសិណជាសម្មតិ គឺបញ្ញត្តិអារម្មណ៍ រមែងឆ្លើយយល់ព្រមសំដៅយកនិរុត្តិញាណ ។ ក្នុងបញ្ហាទាំងឡាយថា "ជនណាមួយដឹងសម្មតិ ?" បរវាទីឆ្លើយបដិសេធសំដៅយកបុថុជ្ជនទាំងឡាយ ។ ក្នុងបញ្ហាពោលដោយ* **ចេតោបរិយាយ** *ការកំណត់ដឹងក្នុងចិត្តអ្នកដទៃ, បរវាទីឆ្លើយបដិសេធ សំដៅយកញាណរបស់បុថុជ្ជន, ឆ្លើយយល់ព្រមសំដៅយកញាណរបស់ព្រះអរិយៈ ។ ក្នុងបញ្ហាទាំងឡាយថា* ***"បញ្ញាទាំងពួង ជាបដិសម្ភិទាឬ ?"*** *, បរវាទីឆ្លើយបដិសេធ សំដៅយកបញ្ញាក្នុងកសិណសមាបត្តិ, ឆ្លើយយល់ព្រមសំដៅយកលោកុត្តរ ។ ពាក្យថា* ***"សមាបត្តិដែលមានបឋវីកសិណជាអារម្មណ៍"*** *ជាដើម សកវាទីពោលដើម្បីសួរដោយពាក្យថា "បញ្ញាក្នុងទីទាំងពួង មានប្រមាណប៉ុណ្ណេះនោះ បញ្ញានោះ ជាបដិសម្ភិទាទាំងអស់ឬ ?" ។ ពាក្យថា* ***"បើដូច្នោះ សេចក្តីដឹងទាំងឡាយ ជាបដិសម្ភិទាឬ ?"*** *អធិប្បាយថា* ***លោកុត្តរបញ្ញាទាំងអស់ ជាបដិសម្ភិទា*** *ព្រោះហេតុណា, ព្រោះហេតុនោះ ពាក្យថា* ***"ទាំងពួង"*** *ទើបលោកឲ្យតាំងទុកចំពោះតែសាមញ្ញផលប៉ុណ្ណោះ ៕*

ចប់បដិសម្ភិទាកថា

## ៦.សម្មតិញាណកថា សម្ដែងអំពីសម្មតិញ្ញាណ

ឥឡូវនេះ ឈ្មោះថា រឿងសម្មតិញ្ញាណ គឺញាណក្នុងសម្មតិ ៖

ក្នុងរឿងនោះ សច្ចៈមាន ២ យ៉ាង គឺសម្មតិសច្ច និងបរមត្ថសច្ច ។ ក៏បុគ្គលទាំងឡាយណា មិនធ្វើការចែកសច្ចៈយ៉ាងនេះ រមែងពោលសូម្បីនូវសម្មតិញ្ញាណថា "មានសច្ចៈនោះ ជាអារម្មណ៍ដូចគ្នា" ដោយការពោលអាងពាក្យថា "សច្ចៈ" ដូចលទ្ធិរបស់និកាយអន្ធកៈ, ទើបសកវាទីផ្ដើមពាក្យនេះ ដើម្បីលាងជម្រះវាទៈរបស់ជនទាំងនោះថា "ពួកគេទាំងនោះ មានវាទៈមិនត្រឹមត្រូវ" ។ ក្នុងពាក្យទាំងនោះ ពាក្យសួរថា ***"មិនគប្បីពោល"*** ជារបស់បរវាទី ។ ពាក្យឆ្លើយយល់ព្រមជារបស់សកវាទី សំដៅយកបរមត្ថសច្ច ។ ពាក្យថា ***"ញាណក្នុងសម្មតិសច្ច"*** ដូច្នេះ បានដល់ ញាណក្នុងសច្ចៈដែលចូលទៅអាស្រ័យពាក្យសម្មតិ ។ម្យ៉ាងទៀត ពាក្យថា ***"ញាណក្នុងសម្មតិសច្ច"*** ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថនៃបឋមាវិភត្តិ, អធិប្បាយថា បានដល់សម្មតិសច្ច ។ ពាក្យសួររបស់សកវាទីថា ***"ញាណក្នុងសម្មតិសច្ចជាអារម្មណ៍ប៉ុណ្ណោះ, មិនមានធម៌ផ្សេងជាអារម្មណ៍ទេ"*** ពាក្យឆ្លើយយល់ព្រម ជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីនឹងព្រមានដោយពាក្យថា "បើញាណក្នុងសម្មតិនោះ មានសច្ចៈជាអារម្មណ៍ដោយមិនប្លែកគ្នាទេ, បុគ្គលក៏គប្បីធ្វើកិច្ចទាំងឡាយ មានការកំណត់ដឹងនូវទុក្ខ

*ជាដើម ដោយញាណនោះបាន" ដូច្នេះ ទើបពោលពាក្យថា* ***"កំណត់ដឹងនូវទុក្ខជាន ។ល។ ដោយញាណនោះឬ ?"*** *៕*

ចប់សម្មតិញ្ញាណកថា

## ៧.ចិត្តារម្មណកថា

## សម្តែងអំពីញាណមានចិត្តជាអារម្មណ៍

*ឥឡូវនេះ ឈ្មោះថា រឿងញាណមានចិត្តជាអារម្មណ៍ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា "ញាណនោះ មានចិត្តជាអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ព្រោះកាន់យកហេតុត្រឹមតែពាក្យថា '* ***ចេតោបរិយញ្ញាណ*** *= សេចក្តីដឹងក្នុងការកំណត់ចិត្តអ្នកដទៃ" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីដាស់តឿនដោយពាក្យថា បុគ្គលណា តែងតែដឹងចិត្តរបស់អ្នកដទៃ ដោយអំណាចនៃចិត្ត មានរាគៈជាដើម សូម្បីរាគៈជាដើម ក៏តែងតែជាអារម្មណ៍ដល់អ្នកនោះដែរ, ព្រោះហេតុដូច្នោះ លោកមិនគប្បីពោលថា "ញាណនោះ មានចិត្តជាអារម្មណ៍ត្រឹមតែម្យ៉ាង មិនមានអារម្មណ៍ផ្សេងទេ" ដូច្នេះ ទើបផ្តើមពាក្យថា* ***"មានបុគ្គលខ្លះ ពេលចិត្តមានរាគៈ ក៏ដឹងច្បាស់ថា***

***ចិត្តមានរាគៈមិនមែនឬ ?"*** ពាក្យថា ***"ក្នុងអារម្មណ៍ គឺផស្សៈ"*** បានដល់ក្នុងអារម្មណ៍ ពោលគឺផស្សៈ ។ សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា ***"ក្នុងអារម្មណ៍ គឺវេទនា"*** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ត្រូវសកវាទីសួរទៀតថា ***" មិនគប្បីពោលថា ' សេចក្ដីដឹងក្នុងអារម្មណ៍ គឺផស្សៈឬ ?"*** ដូច្នេះទៀតទេ, បរវាទីឆ្លើយយល់ព្រមដោយពាក្យថា "ពេលមនសិការ ទើបមានផុស្សនលក្ខណៈរបស់ផស្សៈជាអារម្មណ៍" ។ ត្រូវសកវាទីសួរថា ***"ជាសេចក្ដីដឹងក្នុងការកំណត់ផស្សៈឬ ?"*** បរវាទីឆ្លើយបដិសេធ ព្រោះមិនមានសេចក្ដីនៃបទព្រះសូត្រដូច្នោះឡើយ ។ សូម្បីក្នុងវេទនាជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ក្នុងពេលនេះ លទ្ធិរបស់បរវាទីនោះ អាស្រ័យពាក្យណាដែលខ្លួនពោល, កាលសម្ដែងពាក្យនោះហើយដើម្បីឲ្យលទ្ធិតាំងទុក ទើបពោលដោយពាក្យថា ***"នោះជាសេចក្ដីដឹងក្នុងការកំណត់ចិត្តអ្នកដទៃមិនមែនឬ ?"*** ប៉ុន្តែលទ្ធិនេះ ទោះបីជាលទ្ធិរបស់បរវាទីឲ្យតាំងទុក ដោយអំណាចនៃការអាស្រ័យត្រឹមតែជាពាក្យពេចន៍នោះ រមែងមិនប្រព្រឹត្តទៅតាំងទុកបានដូច្នេះឡើយ ៕

ចប់ចិត្តារម្មណកថា

# ៨.អនាគតញ្ញាណកថា

## សម្តែងអំពីញាណដឹងក្នុងអនាគត

*ឥឡូវនេះ ឈ្មោះថា រឿងញាណដឹងក្នុងអនាគត ៖*

*ក្នុងបញ្ហានោះ ខណៈដែលជាអន្តរៈក្តី, សំដៅយកខណៈចិត្តជាអន្តរៈក្តី ឈ្មោះថា* **អនាគត** *។ ក្នុងខណៈទាំងពីរនោះ ញាណរមែងដឹងអនាគតដែលជាអន្តរញ្ញាណតែម្យ៉ាងប៉ុណ្ណោះ, ឯញាណអនាគតដែលជាអន្តរៈ មាននៅដោយប្រការណា, សូម្បីញាណដែលស្ទង់ចុះក្នុងជវនមួយរបស់វិថីមួយ ក៏មានដោយប្រការនោះដែរ ។ ក្នុងបញ្ហានោះ ជនទាំងឡាយណា តែងតែប្រាថ្នាញាណសូម្បីក្នុងអនាគតទាំងអស់ ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីព្រមានដោយពាក្យថា “ញាណក្នុងអនាគតឯណា មាននៅក្នុងលទ្ធិរបស់លោក បុគ្គលរមែងដឹងអនាគតដែលកើតក្នុងចំណែកខាងក្រោយ, ប៉ុន្តែអ្នកនោះបាន ដោយអំណាចនៃមូលជាដើមឬ ? ដូច្នេះ ទើបពោលនឹងបរវាទីនោះថា* ***“អនាគតដឹងបានដោយមូល”*** *ជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យទាំងពួងថា* ***“ដោយមូលជាដើម”*** *គឺដោយមូល, ដោយហេតុ, ដោយនិទាន, ដោយសម្ភព, ដោយប្រភព, ដោយសមុដ្ឋាន, ដោយអាហារ, ដោយអារម្មណ៍,*

ដោយបច្ច័យ និងដោយសមុទ័យ; នេះជាពាក្យវេវចនៈរបស់ពាក្យថា "**ការណៈ** = គ្រឿងធ្វើ ឬហេតុ" ទាំងអស់ ។ ពិតណាស់ ការណៈ ឈ្មោះថា **មូល** ព្រោះអត្ថថា រមែងធ្វើធម៌ណា ឲ្យជាផលរបស់ខ្លួន, ធម៌ដែលជាផលនោះ ក្នុងទីនោះ ទើបអាស្រ័យតាំងនៅបាន ។ ឈ្មោះថា **ហេតុ** ព្រោះអត្ថថា ឲ្យផលនោះ ចម្រើន និងប្រព្រឹត្តទៅសព្វ ។ ឈ្មោះថា **និទាន** ព្រោះអត្ថថា ជាដែនបង្អោនឲ្យនូវផលនោះឯង ហាក់ដូចជាការបង្អោនឲ្យដោយពាក្យថា "អញ្ជើញចុះ លោកទាំងឡាយ ចូរកាន់យកវត្ថុនេះ" ។ ឈ្មោះថា **សម្ភព** ព្រោះអត្ថថា រមែងឲ្យផលនៃធម៌កើតព្រមអំពីហេតុនោះ ។ ឈ្មោះថា ***ប្រភព*** ព្រោះអត្ថថា ជាដែនកើតមុន ។ ឈ្មោះថា **សមុដ្ឋាន** ព្រោះអត្ថថា ផលធម៌នោះ រមែងតាំងឡើងព្រមក្នុងធម៌ដែលជាហេតុនោះ, ម្យ៉ាងទៀត ព្រោះអត្ថថា រមែងញ៉ាំងផលនៃធម៌នោះៗ ឲ្យតាំងឡើងព្រម ។ ឈ្មោះថា **អាហារ** ព្រោះអត្ថថា រមែងនាំមកនូវផលនៃធម៌នោះឯង ។ ក៏ហេតុនោះ ឈ្មោះថា **អារម្មណ៍** ព្រោះអត្ថថា មិនលះនូវផលនៃធម៌នោះ ។ ឈ្មោះថា **បច្ច័យ** ព្រោះអត្ថថា ផលនៃធម៌នោះ អាស្រ័យធម៌ដែលជាហេតុហើយប្រព្រឹត្តទៅ ។ សភាវៈណា រមែងញ៉ាំងផលនៃធម៌នោះ ឲ្យកើតឡើងពីហេតុ ព្រោះហេតុនោះ សភាវៈនោះ ទើបលោកហៅថា **សមុទ័យ**, ក៏ឈ្មោះថា **សមុទ័យ** ព្រោះ

*អត្ថថា ញុំាងផលឲ្យកើតឡើងអំពីហេតុ ។ ក៏នរណាមួយ មិនអាចដើម្បីដឹង អន្តរចិត្តបាន ដោយអាការទាំងនេះ គឺហេតុទាំងនេះ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបបរវាទីបដិសេធថា “ មិនគប្បីពោលយ៉ាងនេះទេ” ; ពាក្យថា* ***“ដឹងសេចក្តីជាហេតុបច្ច័យ ដែលជាអនាគតបាន”*** *សេចក្តីថា ពេលចិត្តជាអនាគតដែលនឹងកើតតជាប់គ្នាទៅ បុគ្គលរមែងដឹងនូវចិត្តនោះ ព្រោះសេចក្តីជាហេតុបច្ច័យ, អធិប្បាយថា ធម៌ទាំងឡាយណាមានហេតុបច្ច័យ ក្នុងធម៌ទាំងនោះ រមែងដឹងនូវធម៌ទាំងនោះ; សូម្បីក្នុងបទដែលនៅសល់ទាំងឡាយ ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យថា* ***“គោត្រភូបុគ្គល”*** *ជាដើម សកវាទីពោលហើយ ដើម្បីសម្តែងញាណដែលកើតឡើងក្នុងអនាគតនោះ ដោយសង្ខេប ។ ព្រះសូត្រថា* ***“ចាដលិបុត្រ”*** *ដែលបរវាទីនាំមកក៏ដើម្បីបញ្ជាក់ញាណដែលកើតឡើងក្នុងអនាគតនោះ, តែព្រះសូត្រនោះមិនសម្រេចប្រយោជន៍ដល់ញាណក្នុងអនាគតទាំងពួងទេ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះសូត្រនោះត្រឹមតែនាំមកប៉ុណ្ណោះ ដោយប្រការដូច្នេះឯង ៕*

ចប់អនាគតញ្ញាណកថា

– – – – – – –

## ៩.បច្ចុប្បន្នញ្ញាណកថា សម្ដែងអំពីញាណដឹងក្នុងបច្ចុប្បន្ន

ឥឡូវនេះ ឈ្មោះថា រឿងបច្ចុប្បន្នញ្ញាណ គឺញាណដឹងក្នុងបច្ចុប្បន្ន ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា "ញាណក្នុងបច្ចុប្បន្នទាំងពួង មានដោយមិនប្លែកគ្នាឡើយ" ព្រោះអាស្រ័យព្រះបាលីថា "ពេលឃើញសង្ខារទាំងពួង ដោយសេចក្ដីជារបស់មិនទៀង សូម្បីញាណនោះ ឈ្មោះថា ជាញាណដែលបុគ្គលនោះ ឃើញដោយភាពជារបស់មិនទៀង ក៏ដោយ" ដូច្នេះ, សកវាទីពោលសំដៅដល់ជនទាំងនោះ ទើបសួរថា ***"ញាណដឹងក្នុងបច្ចុប្បន្ន"*** ជាដើម, ពាក្យយល់ព្រមជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលសាកសួរបរវាទីនោះ ដោយពាក្យថា ***"បុគ្គលដឹងញាណនោះបានដោយញាណនោះឬ ?"*** ដើម្បីព្រមានថា "អើ ! ញាណក្នុងបច្ចុប្បន្នមានដោយមិនប្លែកគ្នាឡើយ បុគ្គលក៏ដឹងញាណនោះ សូម្បីក្នុងបច្ចុប្បន្នក្ខណៈដល់ញាណនោះបាន កាលបើដូច្នេះ ញាណទាំងពីរក៏មិនមែនជាញាណដែលដូចគ្នាទេ, បុគ្គលនឹងគប្បីដឹងញាណនោះ ដោយញាណនោះ បានយ៉ាងដូចម្ដេច ?" ក្នុងបញ្ហាទាំងនោះ បញ្ហាទី ១ បរវាទីបដិសេធថា "មិនអាចដឹងញាណនោះ ដោយញាណនោះបានទេ; ក្នុងបញ្ហាទី ២ បរវាទី

ឆ្លើយយល់ព្រម សំដៅយកការដាច់គ្នា; បញ្ហានោះ អធិប្បាយថា បើបុគ្គលឃើញនូវការបែកធ្លាយទៅនៃសង្ខារទាំងឡាយដោយលំដាប់ បុគ្គលឈ្មោះថា រមែងឃើញភង្គានុបស្សនាញាណបាន ដោយភង្គវិបស្សនាញាណនោះដែរ ។ សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា ***“បុគ្គលដឹងញាណនោះបាន ដោយញាណនោះឬ ?”*** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យទាំងឡាយដែលសកវាទីពោលថា ***“បុគ្គលពាល់ត្រូវផស្សៈនោះបាន ដោយផស្សៈនោះ”*** ជាដើម ដើម្បីហាមឱកាសដែលមានលេសន័យរបស់បរវាទីនោះ ។ ក៏ដើម្បីឲ្យលទ្ធិតាំងទុក បរវាទីពោលពាក្យណាថា “ពេលព្រះយោគាវចរឃើញសង្ខារទាំងពួង ដោយសេចក្តីជារបស់មិនទៀងដូច្នេះ, សូម្បីសេចក្តីដឹងនោះ ក៏ជាការដែលព្រះយោគាវចរនោះបាន ដោយភាពជារបស់មិនទៀងផង មិនមែនឬ ?” ពាក្យឆ្លើយយល់ព្រមជារបស់សកវាទី, ក្នុងបញ្ហានោះ អធិប្បាយថា ញាណនោះ ឈ្មោះថា ឃើញហើយដោយន័យទេ, ប៉ុន្តែមិនឃើញដោយអារម្មណ៍ទេ ព្រោះហេតុដូច្នោះ លទ្ធិដែលបរវាទីតាំងទុកហើយយ៉ាងនេះ ក៏មិនប្រាកដថាតាំងទុកបានឡើយ ៕

ចប់បច្ចុប្បន្នញ្ញាណកថា

........................

## ១០.ផលញាណកថា សម្តែងអំពីផលញ្ញាណ

*ឥឡូវនេះ ឈ្មោះថា រឿងផលញ្ញាណ គឺសេចក្តីដឹងក្នុងផល ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្តីយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា "ផលញ្ញាណដែលសត្វនោះៗ គប្បីសម្រេចសូម្បីរបស់ព្រះសាវកទាំងឡាយ ដូចព្រះពុទ្ធទាំងឡាយ ដោយសាមញ្ញថា 'ព្រះពុទ្ធទាំងឡាយក្តី ព្រះសាវកទាំងឡាយក្តី រមែងសម្តែងធម៌ដើម្បីការកើតឡើងនៃអរិយផលរបស់សត្វទាំងឡាយ" ដូច្នេះ; ព្រោះសកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា* ***"ព្រះសាវកមានញាណក្នុងផល"*** *ជាដើម ពាក្យឆ្លើយយល់ព្រមជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីព្រមានបរវាទីនោះ ដោយពាក្យថា "អើ ! បើផលញ្ញាណរបស់ព្រះសាវកមានដូចព្រះពុទ្ធមែន, ព្រះពុទ្ធទាំងឡាយ រមែងទ្រង់បញ្ញត្តការធ្វើផលក្នុងសោតា-បត្តិផល សូម្បីមានហើយថា 'ព្រះសោតាបន្នរូបនេះ ជាឯកពីជី, រូបនេះជាកោលំកោលៈ, រូបនេះ ជាសត្តក្ខត្តុំបរមៈ' បាន ដោយញាណពលៈរបស់ព្រះអង្គ យ៉ាងណា, សូម្បីព្រះសាវកតាមលទ្ធិរបស់លោក ក៏បញ្ញត្តការញ៉ាំងផលដូច្នោះដែរឬ ?" ដូច្នេះ ទើបពោលថា "ព្រះសាវកប្រកាសគុណសម្បត្តិនៃផលបានឬ ?" បរវាទីតែងតែឆ្លើយបដិសេធ ។ ពាក្យថា* ***"ការដឹងសេចក្តីពេញលេញ សេចក្តីខ្វះខាតនៃផល របស់ព្រះសាវកមានឬ ?"*** *ជាដើម, សកវាទីពោលដើម្បីសួរដល់បច្ច័យ ព្រោះភាវៈនៃផលញ្ញាណមាន*

*បច្ច័យរបស់ផល ក៏ត្រូវតែមានដែរ ។*

*ក្នុងបញ្ហានោះ អធិប្បាយថា ផលទាំងឡាយដែលបណ្ឌិតយល់ព្រម ហើយថា "ការដឹងខ្ពស់ និងទាបនៃផលទាំងឡាយ របស់ព្រះពុទ្ធទាំងឡាយ យ៉ាងនេះថា 'សភាវៈនេះជាផលយ៉ាងនេះ, សភាវៈនេះជាផលយ៉ាងនោះ, សភាវៈនេះជាផលដែលប្រាសចាកទៅហើយ" ដូច្នេះ ឈ្មោះថា* **បរោ-បរិយត្តិ** *ឬ* **ផលបរោបរិយត្តិ** *ការដឹងសេចក្តីពេញលេញ សេចក្តីខ្វះខាតនៃផល* **ឥន្ទ្រិយបរោបរិយត្តិ** *និង* **បុគ្គលបរោបរិយត្តិ** *របស់ព្រះពុទ្ធទាំងឡាយ ក៏មាន ដោយទំនងនោះ ព្រះពុទ្ធទាំងឡាយ តែងតែដឹងនូវផលនោះៗ ដោយអំណាចនៃការដឹងបុគ្គលនោះៗ ឬថា ដោយអំណាចនៃការដឹងឥន្ទ្រិយទាំងនោះ ព្រោះភាវៈនៃញាណទាំងនោះមាន, បរោបរិយត្តិញាណទាំងអស់នេះ សូម្បីរបស់ព្រះសាវកមានឬ ?; ពាក្យទាំងឡាយ សូម្បីមានពាក្យថា* ***"ការបញ្ញត្តខន្ធរបស់ព្រះសាវកមានឬ ?"*** *ជាដើម សកវាទីពោលហើយ ក៏ដើម្បីព្រមានថា "អើ ! ផលញ្ញាណរបស់ព្រះសាវកមាន ដូចរបស់ព្រះពុទ្ធជាម្ចាស់មែន, ព្រះសាវក ក៏គប្បីបញ្ញត្តធម៌ទាំងនេះបានដែរ, បញ្ញត្តិទាំងនេះរបស់ព្រះសាវករមែងមាន, ព្រះសាវករមែងអាចដើម្បីដឹង ឬដើម្បីបញ្ញត្តនូវបញ្ញត្តិទាំងនេះ ដោយកម្លាំងរបស់ខ្លួនឬ ?" ដូច្នេះ; ពាក្យថា* ***"ព្រះសាវកជាព្រះជិនស្រី"*** *ជាដើម សកវាទីពោលដើម្បីព្រមានថា "អើ ! ផលញ្ញាណរបស់ព្រះសាវកមានដូចព្រះពុទ្ធទាំងឡាយបានមែន, កាលបើមានសេចក្តី*

*ដូច្នោះ ព្រះសាវកនោះៗ ក៏ជាព្រះជិនពុទ្ធ” ; សូម្បីក្នុងបញ្ហាថា **“ព្រះសាវកជាអ្នកញ៉ាំងមគ្គដែលមិនទាន់កើត ឱ្យកើតឡើងបាន”** ជាដើម ក៏មានន័យដូចគ្នានេះដែរ; ក្នុងបញ្ហាថា **“ព្រះសាវកជាអ្នកមិនមានញាណដឹងឬ ?”** សកវាទីឆ្លើយបដិសេធ ព្រោះថា សេចក្តីមិនដឹង គឺអវិជ្ជាដែលព្រះសាវកកម្ចាត់បានហើយ, តែថា ផលញ្ញាណរបស់ព្រះសាវក មានដូចព្រះពុទ្ធក៏មិនមានទេ; ព្រោះហេតុដូច្នោះ វាទៈ គឺលទ្ធិរបស់បរវាទី ទើបជាការតាំងនៅមិនបានដូច្នេះឡើយ ៕*

ចប់ផលញ្ញាណកថា

**រួមកថាដែលមានក្នុងវគ្គនេះ គឺ**

*១. វិមុត្តិកថា ២. អសេក្ខញ្ញាណកថា*

*៣. វិបរិតកថា ៤. និយាមកថា*

*៥. បដិសម្ភិទាកថា ៦. សម្មតិញ្ញាណកថា*

*៧. ចិត្តារម្មណកថា ៨. អនាគតញ្ញាណកថា*

*៩. បច្ចុប្បន្នញ្ញាណកថា ១០. ផលញ្ញាណកថា ។*

**រួមវគ្គដែលមានក្នុងបណ្ណាសកៈនេះ គឺ**

*វគ្គទី ១, វគ្គទី ២, វគ្គទី ៣, វគ្គទី ៤ និងវគ្គទី ៥ ។%*

**ចប់មហាបណ្ណាសកៈ**

**ចប់កថាវត្ថុវគ្គទី ១**

# វគ្គទី ៦

## ១.និយាមកថា សម្ដែងអំពីនិយាម

*ឥឡូវនេះ ឈ្មោះថា រឿងនិយាមជាអសង្ខតៈ ៖*

*ក្នុងបញ្ហានោះ លោកហៅអរិយមគ្គថា **និយាម** ព្រោះព្រះបាលីថា "បុគ្គលអ្នកអាចដើម្បីចុះកាន់និយាម ដែលត្រឹមត្រូវ ក្នុងកុសលធម៌ទាំងឡាយ"*[១] *។ ក៏ជនពួកណាមានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា "កាលនិយាមនោះ កើតឡើងក្ដី និងរលត់ទៅ ហើយក្ដី បុគ្គលនោះ ឈ្មោះថា ជាអ្នកមិនទៀង ក៏មិនមែន ព្រោះហេតុណា, ព្រោះហេតុនោះ និយាមដែលកើតឡើងដល់បុគ្គលនោះ ទើបឈ្មោះ ថា ជាអសង្ខតៈ គឺមិនមានបច្ច័យតាក់តែង ព្រោះអត្ថថា ជារបស់ទៀង" ។ ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតប ជារបស់បរវាទី ។ បន្ទាប់ពីនោះ កាលសកវាទីនឹងសម្ដែងថា "ប្រសិនបើ និយាមនោះ ជាអសង្ខតៈមែន, និយាមនុ៎ះ ក៏គប្បីមានយ៉ាងនេះ" ទើបពោលពាក្យថា **"ជានិព្វាន"** ជាដើម ។ ពាក្យសួរប្រៀបធៀប មានអត្ថងាយស្រួលទាំងអស់ ។ ពាក្យថា **"បុគ្គលពួកខ្លះចុះកាន់និយាម"** ជាដើម*

---

[១] អភិ. ។

*សកវាទីពោលដើម្បីសម្ដែងភាវៈនៃសង្ខតៈជារបស់និយាម ។ ក្នុងបញ្ហាថា* ***“មគ្គជាអសង្ខតៈឬ ?”*** *ជាដើម បរវាទីរមែងបដិសេធ ព្រោះមគ្គនោះ នៅមានការកើត និងរលត់ ។ ក្នុងបញ្ហាថា* ***“និយាមជាសង្ខតៈឬ ?”*** *បរវាទីឆ្លើយបដិសេធ បំណងយកនិយាមក្នុងមគ្គ សូម្បីរលត់ទៅហើយ ក៏ជាសភាវៈនៅមាន ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា* ***“សោតាបត្តិនិយាម”*** *ជាដើម បណ្ឌិតគប្បីជ្រាបអនុលោម និងបដិលោមដោយន័យនេះឯង ។*

*ត្រូវសកវាទីសួរថា* ***“អសង្ខតៈមាន ៥ យ៉ាងឬ ?”*** *បរវាទីកាលបើមិនឃើញស្ថានទីមានមករបស់អសង្ខតៈ ៥ យ៉ាង ទើបបដិសេធ ។ ត្រូវសកវាទីសួរគ្រាទី ២ ក៏ឆ្លើយតប ព្រោះពាក្យថានិយាមនៃសម្មត្តនិយាម ៤ យ៉ាង និងព្រោះជាអសង្ខតៈរបស់ព្រះនិព្វាន ១ ។ បញ្ហាពោលអំពី* ***មិច្ឆត្ត-និយាម*** *សកវាទីពោលហើយ ដើម្បីសម្ដែងការមិនត្រឹមត្រូវនៃភាពជាអសង្ខតៈ ដោយហេតុត្រឹមតែពាក្យថានិយាមនោះឯង មានប្រការដូច្នេះ ៕*

ចប់និយាមកថា

•••••••••••

## ២.បដិច្ចសមុប្បាទកថា សម្ដែងអំពីបដិច្ចសមុប្បាទ

*ឥឡូវនេះ ឈ្មោះថា រឿងបដិច្ចសមុប្បាទ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានសេចក្ដីយល់ឃើញខុស*

ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងមហិសាសកៈថា "បដិច្ចសមុប្បាទជាអសង្ខតៈ" ព្រោះព្រះបាលីក្នុងនិទានវគ្គថា "ការឧប្បត្តិឡើងនៃព្រះតថាគតជាម្ចាស់ក្តី ការមិនឧប្បត្តិឡើងក្តី ឈ្មោះថា ***ធម្មដ្ឋិតតា*** គឺមានការតាំងនៅនៃធម៌"[២] ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ បញ្ហាថា "***អវិជ្ជាជាសង្ខតៈឬ ?***" ជាដើម សកវាទីពោលដើម្បីសម្តែងសភាវៈនៃបដិច្ចសមុប្បាទធម៌ទាំងឡាយ មានអវិជ្ជាជាដើមនោះឯង ។ ក៏អង្គមួយៗ នៃធម៌ទាំងនោះ លោកហៅថា បដិច្ចសមុប្បាទ រមែងមានដោយអត្ថណា, អត្ថនោះឯង លោកបានពោលទុករួចហើយក្នុងបដិច្ចសមុប្បាទវិភង្គ * ។

ពាក្យថា "***សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ***" ដូច្នេះ ***សភាវៈណា ជាធម្មដ្ឋិតិ*** ជាដើម សកវាទីពោលដើម្បីទម្លាយអត្ថនៃលទ្ធិដែលបរវាទីនាំមក តាំងទុកហើយដោយព្រះសូត្រនោះៗ ឯង ។

ក៏ក្នុងសេចក្តីនេះ គប្បីជ្រាបថា ធាតុណាជាសភាវៈតាំងនៅហើយ ក្នុងកាលមុន ធាតុនោះឯង លោកហៅថា ធម្មដ្ឋិតិ និងធម្មនិយាម, ធាតុនោះ វៀរចាកអវិជ្ជាជាដើម រមែងមានចំណែកមួយ ក៏មិនមែន,

---

[២] សំ. និ. ។

* អ. អ. ៥ ។

ឯពាក្យថា “ធម្មដ្ឋិតិ និងធម្មនិយាម” នេះ ជាឈ្មោះនៃបច្ច័យទាំងឡាយ មានអវិជ្ជាជាដើមនោះឯង ។ មែនពិត កាលព្រះតថាគតឧប្បត្តិហើយក្តី នៅមិនទាន់បានឧប្បត្តិក្តី សង្ខារទាំងឡាយ ក៏រមែងកើតមាន ព្រោះអវិជ្ជាជាបច្ច័យ, សូម្បីធម៌ទាំងឡាយ មានវិញ្ញាណជាដើម ក៏រមែងកើតអំពីធម៌ទាំងឡាយ មានសង្ខារជាដើមដែរ, ព្រោះហេតុដូច្នោះ ការតាំងនៅណា ព្រោះអត្ថថា ជាហេតុនៃសង្ខារធម៌ទាំងឡាយ ក្នុងបទថា “ **អវិជ្ជាបច្ចយា សង្ខារា** ” ជាដើមនេះ ព្រោះហេតុនោះ ធម៌នោះ ទើបឈ្មោះថា ***ធម្មដ្ឋិតិ*** ។ ម្យ៉ាងទៀត សេចក្តីនៃធម៌ទាំងនោះៗ ឯង ជានិយាម ព្រោះអត្ថថា ជាហេតុដូច្នោះ ធម៌នោះ ទើបឈ្មោះថា ធម្មនិយាម ព្រោះហេតុនោះ ធម្មដ្ឋិតិក្តី ធម្មនិយាមក្តី ទើបលោកហៅថា ***អវិជ្ជា,*** សកវាទីសួរថា “***សភាវៈនោះ គឺអវិជ្ជា ជាអសង្ខតៈ និព្វាន ក៏ជាអសង្ខតៈឬ ?***” បរវាទីឆ្លើយតបដោយអំណាចនៃលទ្ធិ ត្រូវសកវាទីសួរទៀតថា “***អសង្ខតៈមាន ២ យ៉ាងឬ ?***” បរវាទីពោលឆ្លើយបដិសេធ ព្រោះមិនមានក្នុងព្រះសូត្រ, តែឆ្លើយតបដោយអំណាចនៃលទ្ធិ ។ សូម្បីក្នុងបទទាំងឡាយដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ ម្យ៉ាងវិញទៀត ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដូចពាក្យដែលពោលទុកហើយ ក្នុងពេលមុន តាមន័យដែលពោលហើយនុ៎ះចុះ ៕

ចប់បដិច្ចសមុប្បាទកថា

## ៣.សច្ចកថា សម្ដែងអំពីសច្ចៈ

*ឥឡូវនេះ ឈ្មោះថា រឿងសច្ចៈ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈថា "សច្ចៈទាំង ៤ គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច និងមគ្គសច្ច ជាអសង្ខតៈ" ព្រោះអាស្រ័យព្រះសូត្រថា* ***"ម្នាលភិក្ខុទាំងឡាយ សច្ចៈ ៤ យ៉ាងនេះពិត មិនខុស មិនជាយ៉ាងដទៃ"*** [៣] *ជាដើម ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ក៏គប្បីជ្រាប ពាក្យអធិប្បាយបញ្ហានោះថា បណ្ដាទុក្ខ សមុទ័យ និងមគ្គទាំងឡាយ ឈ្មោះថា* ***វត្ថុសច្ច*** *ជាសង្ខតៈ, លក្ខណសច្ច* ***គឺនិព្វាន*** *ជាអសង្ខតៈ; ឈ្មោះថា វត្ថុសច្ចៈមែនមិនមានក្នុងនិរោធទេ, និរោធនោះ ជាអសង្ខតៈតែម្យ៉ាងប៉ុណ្ណោះ ។ ព្រោះហេតុដូច្នោះ ទើបបរវាទីឆ្លើយតបថា* ***"មែន"****; តែការឆ្លើយតបនោះ គ្រាន់តែជាលទ្ធិរបស់លោកប៉ុណ្ណោះ ។ មែនពិត បរវាទីនោះរមែងប្រាថ្នាទុក្ខថា ជាវត្ថុសច្ច, ទាំងប្រាថ្នាសមុទ័យ និងមគ្គ ក៏ដូច្នោះដែរ ។ ចំណែកធម៌ទាំងឡាយណា មានការនាំចេញចាកទុក្ខ ដែលជាគ្រឿងបៀតបៀន និងហេតុឲ្យកើតទុក្ខនៃធម៌ទាំងនោះ ជាលក្ខណៈ, ធម៌ទាំងនោះ ឈ្មោះថា* ***លក្ខណសច្ច*** *។*

---

[៣] សំ. ម. ។

ម្យ៉ាងទៀត ឈ្មោះថា ធម៌មានទុក្ខជាដើម វៀរចាកពាធនលក្ខណៈជាដើម រមែងមិនមាន ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **"តាណៈ** គឺទីជ្រកកោន" ជាដើម បណ្ឌិតគប្បីជ្រាបអធិប្បាយ តាមន័យដែលពោលហើយនុ៎ះចុះ ។

ក្នុងបញ្ហាថា **"ទុក្ខសច្ច"** បរវាទីឆ្លើយតប ព្រោះសំដៅយកលក្ខណ-សច្ច ដោយអំណាចនៃលទ្ធិ ។ ក្នុងបញ្ហាថា **"ទុក្ខ"** បរវាទីឆ្លើយបដិសេធ សំដៅយកវត្ថុសច្ច ។ ខាងមុខអំពីនេះ សុទ្ធិកបញ្ហាក្ដី បញ្ហាពោលដោយការប្រៀបធៀបក្ដី ទាំងអស់បណ្ឌិតគប្បីជ្រាបតាមទំនងនៃព្រះបាលីនុ៎ះចុះ ។ ក្នុងអវសាន ព្រះសូត្រដែលបរវាទីនាំមកដើម្បីតាំងទុកជាលទ្ធិ ព្រះសូត្រនោះ មិនមានដូចដែលនាំមកនោះទេ ព្រោះសភាវៈនៃអត្ថនោះ លោកកាន់យកខុស ដោយប្រការដូច្នេះ ៕

ចប់សច្ចកថា

.............

## ៤.អារុប្បកថា សម្ដែងអំពីភពមិនមានរូប

ឥឡូវនេះ ឈ្មោះថា រឿងអារុប្បៈ គឺភពមិនមានរូប ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសថា "សូម្បីធម៌ទាំងអស់នោះ ជាអសង្ខតៈ" ព្រោះអាស្រ័យព្រះបាលីថា "ភពមិនមានរូបទាំង ៤ មានសភាពមិនញាប់ញ័រ" ដូច្នេះ, ពាក្យសួររបស់សកវាទីថា

***"អាកាសានញ្ចាយតនៈ"*** ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលទាំងអស់ ។ សូម្បីព្រះសូត្រដែលជាសាធកៈនោះ ក៏មិនដូច (សេចក្ដី) ដែលនាំមកនោះដែរ ព្រោះមិនដឹងអត្ថហើយនាំមក ។

ចប់អារុប្បកថា

................

## ៥.និរោធសមាបត្តិកថា សម្ដែងអំពីនិរោធសមាបត្តិ

ឥឡូវនេះ ឈ្មោះថា និរោធសមាបត្តិ ៖

ក្នុងរឿងនោះ ការមិនប្រព្រឹត្តទៅនៃនាមក្ខន្ធ ៤ ឈ្មោះថា ***និរោធសមាបត្តិ*** ។ ក៏និរោធសមាបត្តិនោះ គឺបុគ្គលកាលនឹងធ្វើ ឈ្មោះថារមែងធ្វើបាន, គឺកាលនឹងចូលនិរោធសមាបត្តិ គេរមែងចូលបាន ព្រោះហេតុណា, ព្រោះហេតុនោះ ទើបលោកហៅនាមក្ខន្ធ ៤ នោះថា ជាសមាបត្តិ ដែលរលត់ទៅហើយ ។ តែនរណាមួយ មិនគប្បីពោលថា "ជាសង្ខតធម៌ និងអសង្ខតធម៌" ដូច្នេះឡើយ ព្រោះមិនមែនជាលក្ខណៈនៃសង្ខតធម៌ និងអសង្ខតធម៌ ។

ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយរបស់អន្ធកៈ និងឧត្តរាបថកៈថា "និរោធសមាបត្តិ មិនមែនជាសង្ខតៈ

*ព្រោះជាអសង្ខតៈ” ដូច្នេះ ពាក្យសួររបស់សកវាទីថា **“និរោធសមាបត្តិ”** ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា **“ញុំាងនិរោធឱ្យកើតឡើង”** ជាដើម សកវាទីពោលហើយដោយអំណាចនៃការបានចំពោះ នូវការចូលសមាបត្តិប៉ុណ្ណោះ ។ អធិប្បាយថា ដូចជាជនទាំងឡាយ រមែងញុំាងសង្ខតធម៌ទាំងឡាយ មានរូបជាដើមឲ្យកើតឡើងបានដោយវិធីណា; តែនរណាមួយ ឈ្មោះថា ញុំាងអសង្ខតធម៌ឲ្យកើតឡើងបានដោយវិធីនោះ មិនមានទេ ។ ពាក្យថា **“សេចក្ដីបរិសុទ្ធិនៃការចេញចាកនិរោធ”** បណ្ឌិតគប្បីជ្រាបថា ជាផលនៃសមាបត្តិ ។ តែសេចក្ដីបរិសុទ្ធិនៃការចេញចាកសង្ខតៈនោះ មិនប្រាកដឡើយ, ព្រោះហេតុដូច្នោះ ទើបបរវាទីឆ្លើយបដិសេធ ។*

*ពាក្យថា **“បើយ៉ាងនោះ”** សេចក្ដីថា លទ្ធិថា “ និរោធសមាបត្តិនោះមិនមែនជាសង្ខតៈ, ក៏គង់ជាអសង្ខតៈដែរ” ; តែពាក្យនេះ មិនជាហេតុក្នុងភាពជាអសង្ខតៈទេ ព្រោះហេតុដូច្នោះ សូម្បីបរវាទីពោលហើយពាក្យនោះ ក៏មិនដូចពាក្យដែលពោលមកនោះទេ ។*

ចប់និរោធសមាបត្តិកថា

## ៦.អាកាសកថា សម្តែងអំពីអាកាស

*ឥឡូវនេះ ឈ្មោះថា រឿងអាកាស ៖*

*ក្នុងរឿងនោះ អាកាសមាន ៣ យ៉ាង គឺបរិច្ឆេទាកាស គឺចន្លោះដែលជាទីកំណត់, កសិណុគ្ឃាដិមាកាស គឺចន្លោះដែលលាតឡើងរបស់កសិណ និងអជដាកាស គឺចន្លោះរបស់ផ្ទៃមេឃ; សូម្បីពាក្យថា "តិច្ឆាកាស គឺចន្លោះដែលទទេ" ក៏ជាឈ្មោះរបស់អជដាកាសនុ៎ះដែរ ។ បណ្តាអាកាសទាំងនោះ បរិច្ឆេទាកាស គឺប្រឡោះប្រហោងដែលឃាំងនៅចន្លោះរូប និងរូបជាសង្ខតៈ, ចំណែកអាកាសដ៏សេស សូម្បីទាំងពីក្រៅនេះ ត្រឹមតែជាបញ្ញត្តិ ។*

*ក៏ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈ និងមហិសាសកៈថា "សូម្បីអាកាសទាំងពីរ គឺកសិណុគ្ឃាដិមាកាស និងអជដាកាស មិនមែនសង្ខតៈ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបជាអសង្ខតៈ" ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***"អាកាស"*** *ជាដើម សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលទាំងអស់ ។*

ចប់អាកាសកថា

## ៧.អាកាសសនិទស្សនោតិកថា

## សម្តែងអំពីអាកាសជាលំហមើលឃើញបាន

*ឥឡូវនេះ ឈ្មោះថា រឿងអាកាសជាលំហមើលឃើញបានដោយចក្ខុ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា “សូម្បីអជដាកាសទាំងពួង ជាលំហមើលឃើញបាន ព្រោះអាស្រ័យការប្រព្រឹត្តទៅនៃការដឹងក្នុងទីទាំងឡាយ មានប្រហោងវន្តកទ្វារ” ជាដើម ។ ពាក្យសួររបស់សកវាទីថា* ***“អាកាសជាសនិទស្សនៈ*** *គឺឃើញបានដោយចក្ខុឬ ? ” ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលថា* ***“ជារូប”*** *ជាដើម ដើម្បីចោទបរវាទីនោះថា បើអាកាសជាលំហមើលឃើញបានមែន, អាកាសក៏គប្បីមានយ៉ាងនេះៗ ។ ក្នុងបញ្ហាទាំងឡាយថា* ***“អាស្រ័យចក្ខុ និងអាកាស”*** *ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះមិនមានព្រះសូត្របែបនោះ រមែងឆ្លើយតប ព្រោះអាស្រ័យការចូលទៅឃើញទីទាំងឡាយ មានខាងក្នុងបន្ទប់ដែលមានប្រហោងដ៏គ្រោតគ្រាត (តូច) ជាដើម ។ ក្នុងបទថា “លោកឃើញប្រឡោះប្រហោង ក្នុងចន្លោះដើមឈើទាំងពីរ” នេះ អធិប្បាយថា មនោវិញ្ញាណដែលកើតតាមមនោទ្វារ រមែងមានការដឹងថា “នេះ គឺ*

អាកាស មិនមែនចក្ខុវិញ្ញាណឃើញទេ ព្រោះមិនមានរូបារម្មណ៍ ក្នុងចន្លោះប្រហោងដែលឃើញរូបដើមឈើដោយចក្ខុឡើយ" ។ សូម្បីក្នុងពាក្យទាំងឡាយដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ ព្រោះហេតុដូច្នោះ ពាក្យដែលបរវាទីនាំមកពោលហើយនោះ ទីបមិនសម្រេចប្រយោជន៍ឡើយ ៕

**ចប់អាកាសោសនិទស្សនៅតិកថា**

## ៨.បឋវីធាតុសនិទស្សនាគយានិកថា

## សម្តែងអំពីបឋវីធាតុជាដើម ជាសនិទស្សនៈ

ឥឡូវនេះ ឈ្មោះថា រឿងបឋវីធាតុ ជាសនិទស្សនៈ គឺជាធម្មជាតិឃើញបានដោយមំសចក្ខុ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា "បឋវីធាតុជាដើម (គឺបឋវីធាតុ អាបោធាតុ តេជោធាតុ និងវាយោធាតុ) ជាធម្មជាតិឃើញបានដោយភ្នែក" ព្រោះឃើញវណ្ណាយតនៈ គឺពណ៌នៃការញ័ររបស់ផ្ទាំងថ្ម ទឹក អណ្តាតភ្លើង ដើមឈើនោះឯងផង គឺរឿងបឋវីធាតុ ។ ល ។ នៃឱកាសដែលតាំងនៅចំពោះឥន្ទ្រិយ ៥ គឺចក្ខុ សោតៈ ឃានៈ ជីវ្ហា និងកាយផង គឺរឿងចក្ខុន្ទ្រិយ ។ ល ។ ឃើញរូប មានដៃ និងជើងជាដើម ក្នុងវេលាធ្វើសកម្មភាពដោយកាយផង គឺរឿងកាយកម្ម ។ ល ។ បណ្តារឿងទាំងអស់

គឺទាំង ៣ រឿង ពាក្យសួរខាងដើមរបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីទាំងពួង បណ្ឌិតគប្បីជ្រាបតាមទំនងនៃព្រះបាលី និងគប្បីជ្រាបដោយន័យ ដូចដែលពោលហើយក្នុងពេលមុនទុះចុះ ។ រឿងចុងក្រោយថា **កាយកម្ម មិនជាសនិទស្សនៈ** គឺមិនជាធម្មជាតិឃើញបានដោយភ្នែកទេ លោកធ្វើរឿង **បឋវីធាតុ ជាសនិទស្សនៈ** ទុកជាខដំបូង ៕

ចប់បឋវីធាតុសនិទស្សនាតយាទិកថា

បរិយោសានកថា បណ្ឌិតគប្បីជ្រាបតាំងអំពីបឋវីធាតុសនិទស្សនៈរហូតដល់កាយកម្មសនិទស្សនៈចុះ ៕

## រួមកថាដែលមានក្នុងវគ្គនេះ គឺ

១.និយាមកថា, ២.បដិច្ចសមុប្បាទកថា, ៣.សច្ចកថា, ៤.អារុប្បកថា, ៥.និរោធសមាបត្តិកថា, ៦.អាកាសកថា, ៧.អាកាសោសនិទស្សនោតិកថា, ៨.បឋវីធាតុសនិទស្សនាតយាទិកថា ។

## ចប់វគ្គទី ៦

## វគ្គទី ៧

## ១.សង្គហិតកថា សម្តែងអំពីធម៌ដែលសង្គ្រោះគ្នាបាន

*ឥឡូវនេះ ឈ្មោះថា រឿងធម៌ដែលសង្គ្រោះគ្នាបាន ៖*

*ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងសិទ្ធត្ថិកៈថា "ធម៌ពួកខ្លះ ឈ្មោះថា សង្គ្រោះគ្នាបាន ជាមួយនឹងធម៌ពួកខ្លះ" , ដូចគោមួយនឹម មានគោពលិពទ្ទជាដើម ដែលគេចងទុកដោយខ្សែជាដើម រមែងមិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ ធម៌ទាំងឡាយខ្លះ ដែលសង្គ្រោះជាមួយនឹងធម៌ទាំងឡាយខ្លះទើបមិនមាន, កាលបើមានន័យតែមួយដូចគ្នា ក៏គ្មានប្រយោជន៍ឡើយ" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ដើម្បីនឹងសម្តែងភាវៈនៃធម៌ដែលសង្គ្រោះគ្នាបានដោយអត្ថតែម្យ៉ាង, ពាក្យឆ្លើយតបជារបស់បរវាទី ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ ឥឡូវនេះ ការសង្គ្រោះធម៌ដែលបណ្ឌិតរកបានដោយអត្ថឯណា ដើម្បីសម្តែងអត្ថនោះ ទើបសកវាទីផ្តើមពាក្យថា* ***"មិនមានធម៌ពួកខ្លះ ដែលលោកសង្គ្រោះចូលគ្នា ទុកដោយធម៌ពួកខ្លះឬ ?"*** *ពាក្យទាំងអស់នោះ មានអត្ថងាយស្រួលមែនពិត ដូចយ៉ាងគោពលិពទ្ទ ១ នឹម ដែលគេទឹមទុកដោយខ្សែទាម ឬខ្សែពួរ, នេះដើម្បីតាំងលទ្ធិរបស់ខ្លួន បណ្ឌិតគប្បីជ្រាបថា លទ្ធិរបស់បរវាទីនោះ ត្រូវ*

សកវាទីដែលមិនត្រេកអរពាក្យឧបមានោះ និងមិនជំទាស់ពាក្យឧបមានោះ ទម្លាយចេញហើយដោយពាក្យថា ប្រសិនបើគោពលិពទ្ទ ១ នឹម គេចងទុកដោយខ្សែទាម ឬខ្សែពួរ ដោយហេតុនោះឯង ទើបលោកត្រូវពោលថា “មានធម៌ពួកខ្លះ ដែលលោកសង្គ្រោះទុកដោយធម៌ពួកខ្លះ” ដូច្នេះ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបថា “ប្រសិនបើ ឈ្មោះថា គោពលិពទ្ទជាដើមដែលគេសង្គ្រោះចូលគ្នា គឺចងទុក ១ នឹម សម្រាប់ទឹមដោយខ្សែជាដើម តាមលទ្ធិរបស់លោក មិនមានមែន ធម៌ទាំងឡាយខ្លះ ដែលសង្គ្រោះចូលគ្នាបាន ក៏មិនមានដែរ” ៕

ចប់សង្គហិតកថា

................

## ២.សម្បយុត្តកថា សម្តែងអំពីសម្បយុត្តធម៌

ឥឡូវនេះ ឈ្មោះថា រឿងសម្បយុត្តធម៌ គឺធម៌ដែលប្រកបព្រមដោយអាការ ៤ មានឯកុប្បាទតាជាដើម ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងសិទ្ធត្ថិកៈថា “ធម៌ទាំងឡាយ មានវេទនាជាដើម មិនចូលទៅតាមហើយ គឺមិនកើតរួមក្នុងសញ្ញាជាដើម ដូចប្រេងចម្រាញ់ចេញពីល្ង ព្រោះធម៌អ្វីៗ មិនសម្បយុត្តជាមួយនឹងធម៌អ្វីៗ, កាលបើមាន

សេចក្តីយ៉ាងនេះ ពាក្យថា សម្បយុត្តហើយដោយញាណ’ ជាដើមនេះ ក៏មិនមានប្រយោជន៍ឡើយ” ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ដើម្បីសម្តែងសម្បយុត្តធម៌ដោយអត្ថតែមួយ ដែលសម្បយុត្តគ្នាបានទុំះឯង, ពាក្យឆ្លើយតបជារបស់បរវាទី ដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលទាំងអស់ ព្រោះមានន័យដូចពោលទុកហើយ ក្នុងពេលមុនទុំះឯង ។

ម្យ៉ាងទៀត បញ្ហាឧបមាឯណា ពោលអំពីប្រេងចម្រាញ់ពីល្ងជាដើម ដែលបរវាទីនាំមកហើយ, បញ្ហាឧបមានោះ មិនមានការកំណត់ផ្សេងគ្នាអំពីលក្ខណៈរបស់ល្ង និងប្រេង ដូចវេទនា និងសញ្ញាទេ; មែនពិត ពាក្យថា ល្ងនៅក្នុងគ្រាប់ល្ង ឬសូម្បីសម្បកល្ងទាំងពួង ត្រឹមតែជាវោហារប៉ុណ្ណោះ, ព្រោះហេតុនោះឯង បុគ្គលទាំងឡាយ ធ្វើល្ងឲ្យកើតហើយ ក៏កាន់យកដោយវោហារទុំះឯង ឈ្មោះថា ល្ងរមែងមិនប្រាកដដោយសណ្ឋានតាំងអំពីដើម ព្រោះហេតុណា, ព្រោះហេតុនោះ បញ្ហាឧបមានេះ ក៏ដូចគ្នាដែរ ៕

ចប់សម្បយុត្តកថា

## ៣.ចេតសិកកថា សម្តែងអំពីចេតសិកធម៌

ឥឡូវនេះ ឈ្មោះថា រឿងចេតសិក គឺសភាវធម៌ដែលប្រកបជាមួយនឹងចិត្ត ៖

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងសិទ្ធត្ថិកៈថា "ធម៌ទាំងឡាយ ឈ្មោះថា ផស្សិកៈ គឺធម៌ដែលប្រកបជាមួយនឹងផស្សចេតសិកជាដើម មិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ សូម្បីចេតសិក និងចេតសិកធម៌ ក៏មិនគប្បីមានដែរ" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា* ***"ផស្សៈកើតរួមជាមួយចិត្ត"*** *ដែលសកវាទីពោលហើយ សំដៅយកការកើតព្រមរបស់សម្បយុត្តធម៌ ។ ពាក្យសួរថា ឈ្មោះថា* ***ផស្សិកៈ*** *រមែងមានដល់សកវាទីដែលមិនឃើញនូវវោហារដូច្នោះ ។ កាលបរវាទីពោលពាក្យថា ឈ្មោះថា* ***ចេតសិក*** *ព្រោះអត្ថថា អាស្រ័យចិត្ត រមែងមានដោយវោហារ យ៉ាងណា, សូម្បីចេតសិកនោះ ឈ្មោះថា ផស្សិកៈ ព្រោះអត្ថថា អាស្រ័យផស្សៈដូច្នោះឬ ? ពាក្យឆ្លើយតបជារបស់សកវាទី ព្រោះពាក្យនោះមិនខុសទេ ។ ពាក្យដ៏សេសមានអត្ថងាយស្រួលទាំងអស់ ៕*

## ចប់ចេតសិកកថា

# ៤.ទានកថា សម្តែងអំពីទាន

*ឥឡូវនេះ ឈ្មោះថា **ទាន** ៖*

*ក្នុងរឿងនោះ ឈ្មោះថា **ទាន** មាន ៣ យ៉ាង គឺចាគចេតនា វិរតិ និងទេយ្យធម៌ ។ ទាន ឈ្មោះថា **ចាគចេតនា** ដែលមានមកក្នុងពាក្យថា "សទ្ធា ហិរិ និងទានដែលជាកុសល" ។ ទាន ឈ្មោះថា **វិរតិ** ដែលមានមកក្នុងពាក្យថា "ព្រះអរិយសាវក វៀរស្រឡះចាកបាណាតិបាតហើយ រមែងឲ្យអភ័យដល់សត្វទាំងឡាយ ប្រមាណមិនបាន"[៤] វិរតិទាន គឺ វិរតិចេតសិក ៣ ដែលជាហេតុនៃការវៀរចាកអកុសលទុច្ចរិតនោះ ។ ក្នុង **អដ្ឋកនិបាត អង្គុត្តរនិកាយ** លោកហៅទាននេះថា មហាទានទី ១ ។ ទាន ឈ្មោះថា **ទេយ្យធម៌** គឺវត្ថុដែលបុគ្គលគប្បីឲ្យ ដែលមានមកក្នុងពាក្យថា "បុគ្គលរមែងឲ្យទាន គឺបាយ និងទឹក" ជាដើម ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងទានទាំងនេះដូចតទៅ ៖*

*បុគ្គលរមែងឲ្យវត្ថុដែលគួរឲ្យ ព្រោះចាគចេតនា ដោយហេតុនោះ ចាគចេតនា ទើបឈ្មោះថា **ទាន** ។ មួយវិញទៀត ជនទាំងឡាយ រមែងឲ្យវត្ថុដែលគប្បីឲ្យ ដោយចាគចេតនានេះ ព្រោះហេតុនោះ ចាគចេតនានេះ*

---

[៤] អំ. អដ្ឋក. ។

ទើបឈ្មោះថា ***ទាន*** ។ វិរតិ ឈ្មោះថា ***ទាន*** ព្រោះអត្ថថា ការកាត់ ឬព្រោះអត្ថថា ការទម្លាយនូវអកុសលចិត្ត; មែនពិត វិរតិនោះ កាលកើតឡើង រមែងកាត់ ឬទម្លាយនូវចេតនាដែលជាហេតុទ្រុស្តសីល ដែលបណ្ឌិតកំណត់ទុកហើយថា ជាអ្នកមានការភ័យខ្លាចជាដើម ។ ទេយ្យធម៌ឯណាដែលគេឲ្យ ព្រោះហេតុនោះ ទេយ្យធម៌នោះ ទើបឈ្មោះថា ***ទាន*** បានដល់ ទេយ្យធម៌ គឺវត្ថុដែលបុគ្គលគប្បីឲ្យ សូម្បីទានទាំង ៣ យ៉ាង មានប្រការដូចពោលមកនេះ បើពោលដោយអត្ថ ក៏មានត្រឹមតែ ២ យ៉ាង គឺចេតសិកធម៌ និងទេយ្យធម៌ ។

ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងសិទ្ធត្ថិកៈថា "ចេតសិកធម៌ប៉ុណ្ណោះ ជាទាន, ទេយ្យធម៌ គឺវត្ថុដែលបុគ្គលគប្បីឲ្យ មិនមែនទានទេ" ដូច្នេះ, ពាក្យសួររបស់សកវាទីថា "ទាន គឺចេតសិក" ជាដើម សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ពាក្យសួររបស់សកវាទីថា ***"នឹងឱ្យចេតសិកធម៌ដល់មនុស្សដទៃៗ ក៏បានឬ ?"*** ដូច្នេះ ដើម្បីចោទបរវាទីនោះ ដោយអំណាចនៃទេយ្យធម៌, ពាក្យឆ្លើយបដិសេធជារបស់បរវាទី ព្រោះបុគ្គលនោះ មិនអាចឲ្យចេតសិកធម៌ ដូចជាការឲ្យបាយ និងទឹកជាដើម បានឡើយ ។ កាលបើសកវាទីសួរបញ្ហានោះ ឲ្យតឹងម្តងទៀត បរវាទីនោះ

ឯង ក៏ឆ្លើយតបដោយអំណាចនៃព្រះសូត្រថា “ព្រះអរិយសាវក វៀរស្រឡះចាកបាណាតិបាតហើយ រមែងឲ្យអភ័យដល់សត្វទាំងឡាយ ប្រមាណមិនបាន” ។ តែក្នុងបញ្ហាទាំងឡាយ មានបញ្ហាពោលអំពី ***ផស្សៈ*** ជាដើម បរវាទីកាលមិនឃើញវោហារថា ***“បុគ្គលនឹងឱ្យផស្សៈបាន”*** ជាដើម ទើបឆ្លើយបដិសេធ ។

ពាក្យថា ***“ទានមានផលមិនគួរប្រាថ្នា”*** ជាដើម លោកពោលហើយ ដើម្បីសម្តែងនូវភាវៈនៃធម៌មិនមែនជាចេតសិកទានទេ ។ មែនពិត អចេតសិកទាន គឺការឲ្យបាយ និងទឹកជាដើម រមែងមិនឲ្យវិបាកដែលគួរប្រាថ្នាតទៅ, តែពាក្យនេះ បណ្ឌិតគប្បីជ្រាបថា លោកពោលហើយ ដើម្បីនិយាមក្នុងភាពជាឥដ្ឋផល បានដល់ ***និយាម*** គឺមគ្គ ។

ក៏សូម្បីក្នុងពាក្យនេះ អធិប្បាយថា ប្រសិនបើ អចេតសិកទាន គឺការឲ្យបាយជាដើម គប្បីជាទានមែន ក៏កាលបុគ្គលឲ្យភេសជ្ជៈដែលមិនគួរប្រាថ្នា មិនជាទីពេញចិត្ត ដោយចិត្តអនុគ្រោះ ផលដែលមិនគួរប្រាថ្នានោះឯង គប្បីកើតឡើង ដូចដើមស្ដៅជាដើម ញុំាងផ្លែស្ដៅជាដើមឲ្យកើតឡើង, តែក្នុងទីនេះ ការឲ្យដោយចេតនាដែលជាហេតុបរិច្ចាគ រមែងឲ្យនូវផលដែលជាប្រយោជន៍ ព្រោះហេតុណា, ព្រោះហេតុនោះ កាលទេយ្យធម៌ គឺវត្ថុដែលបុគ្គលគប្បីឲ្យ សូម្បីមិនគួរប្រាថ្នា ក៏ឈ្មោះថា ជាទាន

*មានផលដែលគួរពេញចិត្តទាំងអស់ ។ កាលបើបរវាទីតាំងចេតសិកធម៌ជាទានយ៉ាងនេះហើយ ទើបសកវាទីពោលពាក្យជាដើមថា ព្រះមានព្រះភាគត្រាស់ថា* ***“ទានមានផលគួរប្រាថ្នា”*** *ដូច្នេះ ដើម្បីនឹងញ៉ាំងទេយ្យធម៌ដោយបរិយាយក្រៅនេះ សម្រេចភាពជាទាន ។ តែបរវាទីកាលមិនឃើញសេចក្តីត្រង់ចីវរទានជាដើម មានផលដែលគួរប្រាថ្នា ទើបបដិសេធ ។ ការជម្រះព្រះសូត្រ រមែងត្រឹមត្រូវទាំងក្នុងវាទៈរបស់បរវាទី និងសកវាទី, តែរមែងមិនត្រូវដោយសេចក្តីតែម្យ៉ាងប៉ុណ្ណោះ ។*

*ពាក្យថា* ***“ទេយ្យធម៌មានផលគួរប្រាថ្នា”*** *នេះ សកវាទីឆ្លើយបដិសេធថា សភាវៈជាឥដ្ឋផលប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ក្នុងពាក្យថា* ***“បើយ៉ាងនោះ ក៏មិនគប្បីពោលថាទាន គឺទេយ្យធម៌”*** *នេះ រមែងមិនត្រូវព្រោះភាវៈនៃទេយ្យធម៌នោះ បុគ្គលគប្បីពោលថា “ជាឥដ្ឋផលមែនពិត” ។ ម្យ៉ាងទៀត ទេយ្យធម៌ ឈ្មោះថា ទានទុំះឯង ព្រោះអត្ថថា ដែលបុគ្គលគប្បីឲ្យ ។ សម្រាប់រឿងទាននេះ លោកពោលទុកដើម្បីដោះចេញនូវភាពច្របូកច្របល់គ្នានៃទានពីរយ៉ាងប៉ុណ្ណោះ ៕*

ចប់ទានកថា

## ៥.បរិភោគមយបុញ្ញកថា

## សម្តែងអំពីបុណ្យសម្រេចពីការបរិភោគ

*ឥឡូវនេះ ឈ្មោះថា រឿងបុណ្យសម្រេចពីការបរិភោគ គឺការប្រើប្រាស់ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយរាជគិរិកៈ និងសិទ្ធត្ថិកៈថា "បុណ្យ ឈ្មោះថា សម្រេចពីការបរិភោគ រមែងមានដល់ជនទាំងឡាយ" ព្រោះកាន់យកព្រះសូត្រទាំងឡាយថា "បុណ្យរមែងចម្រើនដល់ទាយកទាំងនោះ គ្រប់កាល ទាំងថ្ងៃទាំងយប់"[៥] និងព្រះសូត្រថា "ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុបរិភោគចីវររបស់បុគ្គលណា"[៦] ជាដើម ដោយមិនពិចារណា ពាក្យសួររបស់សកវាទីថា "បុណ្យសម្រេចពីការបរិភោគ" ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីផ្តើមពោលពាក្យថា "ផស្សៈសម្រេចពីការបរិភោគ" ជាដើម ដើម្បីចោទសួរដោយពាក្យថា "កុសលធម៌ទាំងឡាយ មានផស្សៈជាដើម ឈ្មោះថាបុណ្យ, ក្រៅអំពីនេះ មិនមែនទេ, ព្រោះហេតុដូច្នោះ លោកគប្បីញ៉ាំង*

[៥] សំ. ស. ។

[៦] អំ. ចតុក្ក. ។

ផស្សៈជាដើម ឲ្យចម្រើនបានឬ ?" ។ ពាក្យទាំងអស់នោះ បរវាទី ឆ្លើយបដិសេធ ព្រោះមិនមែនចម្រើនបុណ្យឲ្យទាយកទាំងនោះ ។ ពាក្យទាំងឡាយ មានពាក្យថា "ចម្រើនបានដូចវល្លិ" ជាដើម សកវាទី ពោលដើម្បីចោទសួរដោយពាក្យថា វល្លិជាដើម សូម្បីវៀរចាកការថែទាំ ឬការធ្វើឲ្យចម្រើន រមែងចម្រើនបានដោយខ្លួនឯងពិតៗ យ៉ាងណា, តាមលទ្ធិរបស់លោក បុណ្យទាំងឡាយ រមែងចម្រើនយ៉ាងនោះឬ ?, តែពាក្យនោះ បរវាទីឆ្លើយបដិសេធថា ***មិនគប្បីពោលយ៉ាងនេះទេ*** ព្រោះបុណ្យនោះ ចម្រើនដូច្នោះមិនបានឡើយ ។

ក្នុងបញ្ហាថា ***ទាយកឱ្យទានហើយ មិនជាប់ចិត្ត (មិនពិចារណា) ក៏ជាបុណ្យបានឬ ?*** បរវាទីឆ្លើយដោយអំណាចនៃលទ្ធិថា បុរិមចេតនារបស់ទាយកនោះ រមែងចម្រើនបានដោយការបរិភោគរបស់បដិគ្គាហកៈទាំងឡាយ, បុណ្យនោះ រមែងចម្រើនយ៉ាងនេះ ។ លំដាប់នោះ ទើបត្រូវសកវាទីសាកសួរដោយពាក្យជាដើមថា "***មានដល់អ្នកមិននឹកគិត***" ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកចាកចេតនារបស់ទាយក ។ ក្នុងពាក្យទាំងនោះ ពាក្យថា "***អ្នកមិននឹកគិត***" បានដល់ ភវង្គរបស់ទាយកដែលមិននឹកគិត មិនលះដោយការពិចារណា ដែលជាបុរេចារិកក្នុងទានចេតនា ។ ពាក្យថា "***អ្នកមិនកង្វល់***" បានដល់ មិនបានរំពឹងដល់ទានចេតនា ។

ពាក្យថា **“មានដល់អ្នកមិនជាប់ចិត្ត”** បានដល់ មិនមានការជាប់ចិត្តនូវទានចេតនា; មែនពិត អាវជ្ជនចិត្តរបស់ទាយកនោះ កាលកាត់ក្រសែភវង្គដាច់ហើយ ក៏កើតក្នុងវីថិរបស់ខ្លួន ទើបឈ្មោះថា ជាប់ចិត្តនូវទានចេតនា, សកវាទីសួរថា “បុណ្យរបស់ទាយក មានដល់អ្នកមិនជាប់ចិត្ត រមែងមានដោយចិត្តនេះ ដោយកិច្ចយ៉ាងនេះ” ។ ពាក្យថា **“អ្នកមិនធ្វើទុកក្នុងចិត្ត”** បានដល់ អ្នកមិនធ្វើនូវចិត្ត; មែនពិត អាវជ្ជនចិត្តដែលកំពុងមានទានជាអារម្មណ៍កើតជាប់គ្នានោះ ឈ្មោះថា រមែងធ្វើទុកក្នុងចិត្ត, អធិប្បាយថា គេមិនធ្វើយ៉ាងនេះទេ ។ម្យ៉ាងទៀត ពាក្យថា “នូវចិត្ត” នេះ ជាទុតិយាវិភត្តិ លោកប្រើជាសត្តមីវិភត្តិ ប្រែថា ក្នុងចិត្ត ។ ពាក្យថា **“អ្នកមិនចូលចិត្ត”** បានដល់ ទាយកនោះ មិនឲ្យចេតនាក្នុងទានកើតឡើង ។ ពាក្យថា **“អ្នកមិនប្រាថ្នា”** បានដល់ ទាយកនោះ មិនធ្វើឆន្ទៈក្នុងកុសលដែលបណ្ឌិតកំណត់ហើយថា សេចក្តីត្រូវការ ។ ពាក្យថា **“អ្នកមិនតាំងចិត្ត”** អធិប្បាយថា មិនឲ្យចិត្តតាំងនៅដោយអំណាចនៃទានចេតនា ។ ពាក្យថា **“អ្នកកង្វល់”** ក្នុងខថា **“បុណ្យមានដល់អ្នកដែលបាននឹកគិតដល់មិនមែនឬ ?”** នោះ បានដល់ ព្រោះគិតដល់ទានជាអារម្មណ៍ ។ ម្យ៉ាងទៀត អធិប្បាយថា ការនឹកដល់ទាន គប្បីមានដល់ទាយក, ឬថា បុណ្យរបស់ទាយកដែលនឹកគិតដល់ទាននោះ រមែងកើតជាប់គ្នាទៅ ។ សូម្បីក្នុងបញ្ហា

ទាំងឡាយ មានពាក្យថា ***“នៃផស្សៈ ២ ឬ ?”*** ជាដើម បរវាទីរមែងឆ្លើយបដិសេធ ព្រោះមិនមានផស្សៈទាំងពីរជាដើម ក្នុងខណៈជាមួយគ្នារបស់ទាយកទេ, រមែងឆ្លើយតប សំដៅយកផស្សៈជាដើមម្យ៉ាងៗ ពីរៗ គឺផស្សៈរបស់ទាយក និងរបស់អ្នកបរិភោគ ។ ម្យ៉ាងវិញទៀត លទ្ធិរបស់បរវាទីនោះថា “ការប្រជុំព្រមគ្នានៃបញ្ចវិញ្ញាណមានដល់ទាយក” ដូច្នេះ, ទើបឆ្លើយតប សូម្បីដោយអំណាចនៃលទ្ធិ ។ លំដាប់នោះ ទើបសកវាទីសួរបញ្ហា មានពាក្យថា ***“កុសល”*** ជាដើម នឹងបរវាទីនោះ ដើម្បីបិទទ្វារនៃការបរិយាយ គឺមិនឲ្យមានការនិយាយបញ្ចិតបញ្ចៀង ហើយក៏ចោទដោយធម៌ដែលជាបដិបក្ខនឹងគ្នាដោយត្រង់ ។ សូម្បីក្នុងបញ្ហាថា ***“កុសល”*** ជាដើមនេះ បរវាទីឆ្លើយបដិសេធសំដៅយកការមិនប្រកបនូវគ្នានឹងគ្នានៃកុសល និងអកុសលក្នុងខណៈជាមួយគ្នា; តែឆ្លើយតប ព្រោះលទ្ធិថា “ចិត្តដែលសម្រេចដោយការបរិភោគ ជាចិត្តដែលមិនប្រកបចូលគ្នា” ។ ខណៈនោះ ទើបសកវាទីផ្ចញ់ផ្ចាល់បរវាទីនោះដោយព្រះសូត្រ ។ ក្នុងការនាំព្រះសូត្រមកអាងនោះ បរវាទីពោលហើយថា ***“បុណ្យរមែងចម្រើនដល់ជនទាំងនោះ គ្រប់កាល”*** សំដៅយកបុណ្យដែលកើតជាប់គ្នាទៅដោយអំណាចនៃការកសាងស្ពានទីទាំងឡាយ មានការសាងសួនជាដើម និងដោយអំណាចនៃការតាមរឭកដល់កុសលទាំងឡាយ ដែលមានការ

បដិសន្ថរណៈ (ជួសជុល) ជាដើម ។ សូម្បីពាក្យថា ***“ផារទឹក (ផល) គឺ បុណ្យរបស់បុគ្គលនោះ ប្រមាណមិនបាន”*** នេះ បរវាទីពោលកំណត់យកពាក្យនៃព្រះសូត្រថា “ភិក្ខុមានសភាពបែបនេះ ប្រើប្រាស់ចីវររបស់យើង ព្រោះវត្ថុជាបច្ច័យ គឺយើងថ្វាយដល់ភិក្ខុអ្នកមានប្រក្រតីនៅដោយសេចក្ដីមិនប្រមាទ និងដោយអំណាចនៃការសម្ដែងសេចក្ដីកោតក្រែង” ។ បរវាទីនោះ រមែងកំណត់បុណ្យនោះថា ***“សម្រេចដោយការបរិភោគ*** គឺ ប្រើប្រាស់” ។

តាមពិត ទេយ្យធម៌ដែលបដិគ្គាហកៈទទួលហើយ សូម្បីមិនបរិភោគក៏ដោយ, ប៉ុន្តែបុណ្យនោះ រមែងកើតឡើងដល់ទាយកនោះដោយពិត ព្រោះហេតុណា, ព្រោះហេតុនោះ វាទៈរបស់សកវាទី ទើបចាត់ទុកថា មានកម្លាំងជាង, ក្នុងបញ្ហានោះ បណ្ឌិតគប្បីជ្រាបអត្ថថា ទេយ្យធម៌ដែលបដិគ្គាហកៈ ទទួលហើយនៃបទថា ***“គ្រាបដិគ្គាហកៈទទួលហើយ”*** ដូច្នេះ; ពាក្យដ៏សេស មានអត្ថងាយស្រួលមែនពិត ៕

ចប់បរិភោគមយបុញ្ញកថា

## ៦.ឥតោធិន្នកថា

## សម្តែងពីទានដែលបុគ្គលឱ្យហើយអំពីលោកនេះ

*ឥឡូវនេះ ឈ្មោះថា រឿងទានដែលបុគ្គលឲ្យហើយអំពីលោកនេះ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិនិកាយរាជគិរិកៈ និងសិទ្ធត្ថិកៈថា "វត្ថុឯណា មានចីវរទានជាដើម ដែលបុគ្គលឲ្យហើយ អំពីលោកនេះ, ប្រេតទាំងឡាយរមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ដោយវត្ថុយ៉ាងនោះឯង" ដូច្នេះ ព្រោះអាស្រ័យព្រះបាលីថា* ***"ជនទាំងឡាយ ដែលលះលោកនេះទៅហើយ គឺអ្នកដែលស្លាប់ហើយ រមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងបេតលោកនោះ ដោយទានដែលបុគ្គលឱ្យហើយអំពីលោកនេះ"*** [៧] *ដូច្នេះ ពាក្យសួររបស់សកវាទីថា* ***"ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ"*** *ជាដើម ព្រោះសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ត្រូវសកវាទីសាកសួរបញ្ហាដោយការឲ្យចីវរជាដើមទៀត ទើបឆ្លើយបដិសេធ ។*

*បទថា* ***"អ្នកដទៃជាអ្នកធ្វើដល់អ្នកដទៃ"*** *នេះ លោកអធិប្បាយទុកថា អ្នកដទៃជាអ្នកធ្វើកម្មទាំងឡាយ ដើម្បីឲ្យវិបាកកើតឡើងដល់អ្នកដទៃ, មិនមែនខ្លួនឯង ធ្វើឲ្យដល់ខ្លួនឯងទេ ។ ក៏បរវាទីនោះ ត្រូវសកវាទីសួរ*

---

[៧] ខុ. បេត. ។

បញ្ញាយ៉ាងនេះហើយ ទើបឆ្លើយបដិសេធ ព្រោះខ្វាចខុសចាកព្រះសូត្រ ។ ពាក្យថា ***“ពួកប្រេតឃើញគេឱ្យទាន”*** អធិប្បាយថា ឃើញបុគ្គលដែលកំពុងឲ្យទាន ។

ក្នុងពាក្យទាំងនោះ បណ្ឌិតគប្បីជ្រាបសេចក្ដីថា ក៏ភោគៈទាំងឡាយរមែងកើតឡើងដល់ប្រេតទាំងឡាយនោះ ក្នុងទីនោះ ដោយការអនុមោទនារបស់ខ្លួន ព្រោះហេតុណា, ព្រោះហេតុនោះ លទ្ធិរបស់បរវាទីនោះ សូម្បីតាំងនៅដោយហេតុនេះ ក៏រាប់ថាមិនជាការតាំងនៅបានឡើយ; ព្រោះថាប្រេតទាំងឡាយនោះ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ដោយវត្ថុដែលបុគ្គលឲ្យហើយអំពីលោកនេះ ក៏ទេ ។ សូម្បីក្នុងការនាំព្រះសូត្រដ៏សេសមកអាង ក៏មានន័យដូចគ្នានេះដែរ ៕

ចប់ឥតោទិន្នកថា

＝ ＝ ＝ ＝

## ៧.បឋវីកម្មវិបាកោតិកថា សម្ដែងអំពីផែនដីជាកម្មវិបាក

ឥឡូវនេះ ឈ្មោះថា រឿងផែនដីជាកម្មវិបាក គឺជាផលរបស់កម្ម ៖

ក្នុងរឿងនោះ ពាក្យថា ភាវៈនៃជនទាំងឡាយ អ្នកជាធំ ឈ្មោះថា ឥស្សរិយៈ គឺភាពជាធំ, ភាវៈនៃអធិបតីជនទាំងឡាយ ឈ្មោះថា អាធិបច្ចៈ គឺភាពជាអធិបតី ឬភាពជាម្ចាស់, និងកម្មមានការជាប់ទាក់ទងជាមួយនឹង

*ភាពជាឥស្សរៈ ព្រមទាំងភាពជាអធិបតី មានលើផែនដី ដូច្នេះ លោកពោលទុកក្នុងពាក្យថា "មានកម្មដែលញ៉ាំងសត្វឲ្យប្រព្រឹត្តទៅព្រម ដើម្បីភាពជាធំ មានកម្មដែលញ៉ាំងសត្វឲ្យប្រព្រឹត្តទៅព្រមដើម្បីភាពជាម្ចាស់ " ព្រោះហេតុណា, ព្រោះហេតុនោះ ជនណា មានការយល់ឃើញខុស ដូចលទ្ធិនៃនិកាយអន្ធកៈទាំងឡាយថា "ផែនដីជាកម្មវិបាក" ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***" ផែនដី "*** *ជាដើម ព្រោះសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា* ***" ផែនដីមានសុខវេទនា "*** *ជាដើម សកវាទីពោលដោយអំណាចនៃការសម្ដែងសភាពនៃកម្មវិបាក ។ ផស្សៈដែលផ្សេងអំពីសុខវេទនាជាដើម មានក្នុងវិបាកទាំងឡាយ ដែលលោកសម្ដែងទុកដោយន័យជាដើមថា* ***" ផស្សៈជាកម្មវិបាក "*** *; ក៏ផស្សៈនោះផងធម៌ទាំងឡាយ មានសញ្ញាជាដើមផង សម្បយុត្តជាមួយនឹងធម៌ទាំងឡាយមានសុខវេទនាជាដើម, ធម៌ទាំងឡាយ មានសុខវេទនាជាដើម ក៏សម្បយុត្តជាមួយនឹងធម៌ទាំងឡាយ មានសញ្ញាជាដើម, សូម្បីធម៌ទាំងអស់នេះ ក៏ប្រព្រឹត្តទៅជាមួយគ្នាដោយអារម្មណ៍ គឺទទួលអារម្មណ៍បាន, ឯអាវជ្ជនចិត្ត ពោលគឺការទទួលអារម្មណ៍ដែលជាបុរេចារិកជាដើម នៃធម៌ទាំងនោះ និងចេតនាដែលជាកម្មប្បច្ច័យនៃធម៌ទាំងនោះ ក៏មាន, ក្នុងធម៌ទាំងនោះ ធម៌ណាមានវិបាកដែលគួរប្រាថ្នា, ការប្រាថ្នាធម៌នោះ មានតណ្ហាជាមូល ប្រព្រឹត្តទៅ*

ហើយ ដោយអំណាចនៃការតាំងចិត្ត, ព្រោះហេតុនោះ ទើបសកវាទី សួរថា "តាមលទ្ធិរបស់លោក ផែនដីមានសភាពយ៉ាងនេះឬ ?" បរវាទី ឆ្លើយបដិសេធ ។ បដិលោមបុច្ឆាជាដើម មានអត្ថងាយស្រួលមែនពិត ។

ក្នុងបញ្ហាថា ***"កម្មវិបាកមានទូទៅដល់ជនដទៃឬ ?"*** ជាដើម បរវាទី ឆ្លើយបដិសេធ សំដៅយកធម៌ទាំងឡាយ មានផស្សៈជាដើម, រមែងឆ្លើយ តបសំដៅយករូបដែលមានកម្មជាសមុដ្ឋាន និងសំដៅយកភាវៈនៃផែនដី ជាដើម ជារបស់ទូទៅ ។ ព្រះសូត្រថា ***"និធិ គឺបុណ្យមិនទូទៅដល់ជន ដទៃ។"*** ជាពាក្យដែលសកវាទីនាំព្រះសូត្រអំពីលទ្ធិរបស់បរវាទីមកសម្ដែង ។

ក្នុងបញ្ហាថា ***"សត្វទាំងឡាយបរិភោគផែនដីឬ ?"*** បរវាទីឆ្លើយ បដិសេធ សំដៅយកសត្វដែលមិនអាស្រ័យផែនដី, តែឆ្លើយតបសំដៅយក សត្វដែលអាស្រ័យផែនដី ។ ក្នុងបញ្ហាថា ***"សត្វទាំងឡាយ មិនបរិភោគ ផែនដី រមែងបរិនិព្វានឬ ?"*** បរវាទីឆ្លើយតប សំដៅយកសត្វទាំងឡាយ ដែលបរិនិព្វានក្នុងអរូបភព ។ ពាក្យថា ***"មិនញ៉ាំងកម្មវិបាកឱ្យអស់ទៅ"*** នេះ សកវាទីពោលដោយអំណាចនៃលទ្ធិរបស់បរវាទី; ព្រោះលទ្ធិរបស់ បរវាទីនោះថា "សត្វទាំងឡាយញ៉ាំងកម្មវិបាកឲ្យអស់ទៅហើយ ទើបបរិ- និព្វានបាន" , តែក្នុងលទ្ធិរបស់សកវាទី ការមិនញ៉ាំងវិបាកដែលកើតឡើង អំពីកម្មដែលធ្វើហើយ ឲ្យប្រាសចាកទៅ ឲ្យអស់ទៅ ហើយបរិនិព្វាន មិន

*មានទេ ។ មួយវិញទៀត ពោលអំពីលទ្ធិរបស់លោកទាំងនោះ បឋវីធាតុ ឈ្មោះថា ជាវិបាកដែលកើតឡើងហើយ ព្រោះជាសាធារណវិបាក ក៏ការចោទថា "ការមិនឲ្យបឋវីធាតុដែលតាំងនៅ ដោយភាពជាវិបាកនោះ ឲ្យអស់ទៅ ហើយបរិនិព្វាននោះ មិនត្រូវ" ដូច្នេះ រមែងគួរ ។ បរវាទីឆ្លើយបដិសេធដោយអំណាចនៃលទ្ធិ ។ ក្នុងបញ្ហាថា* ***"បរិភោគវិបាកនៃកម្មរបស់ស្តេចចក្រពត្តិឬ ?"*** *បរវាទីឆ្លើយបដិសេធ សំដៅយកធម៌មានផស្សៈជាដើម ដែលមិនទូទៅ, រមែងឆ្លើយតប សំដៅយកធម៌ដែលជាសាធារណៈ ។ លទ្ធិនៃលោកទាំងនោះថា "ផែនដី សមុទ្រ ព្រះចន្ទ និងព្រះអាទិត្យ" ជាដើម ជាកម្មវិបាកទូទៅដល់វត្ថុទាំងពួង ។ ក្នុងពាក្យថា* ***"កម្មដែលញ៉ាំងសត្វឱ្យប្រព្រឹត្តទៅព្រមដើម្បីភាពជាធំ"*** *នេះ សេចក្តីថា ឈ្មោះថា* ***ភាពជាឥស្សរៈ*** *ព្រោះភាពជាអ្នកមានទ្រព្យច្រើន, ឈ្មោះថា* ***អធិបតី*** *គឺភាពជាធំក្រៃលែង,* ***ភាពជាអធិបតី*** *ព្រោះញ៉ាំងជនទាំងអស់ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន អធិប្បាយថា ឈ្មោះថា* ***ភាពជាអធិបតី*** *ព្រោះអត្ថថា គួរដល់ការគោរពអំពីជនទាំងនោះ ។ ក្នុងបញ្ហានោះ កម្មឈ្មោះថា ញ៉ាំងសត្វឲ្យប្រព្រឹត្តទៅព្រមដើម្បីភាពជាឥស្សរិយៈ និងភាពជាអធិបតី ដោយអំណាចនៃការបានចំពោះនូវផែនដី, មិនមែនដោយអំណាច*

*នៃការឲ្យកើតផែនដីទេ, ព្រោះហេតុដូច្នោះ ពាក្យថា បឋវី គឺផែនដីនោះ ទើបមិនសម្រេចក្នុងភាពជាកម្មវិបាក ដោយប្រការដូច្នេះ ៗ*

ចប់បឋវីកម្មវិបាកោតិកថា

••••••••••••••••••••

## ៨.ជរាមរណវិបាកោតិកថា

## សម្តែងអំពីជរា និងមរណៈ ជាវិបាក

*ឥឡូវនេះ ឈ្មោះថា រឿងជរា និងមរណៈ ជាវិបាក គឺដល់នូវការចាស់ និងស្លាប់ ជាវិបាក ៖*

*ក្នុងបញ្ហានោះ ឈ្មោះថា **ជរា** ព្រោះភាពជាអ្នកមានសម្បុរអាក្រក់, ឈ្មោះថា **មរណៈ** ព្រោះភាពជាអ្នកមានអាយុតិច, ម្យ៉ាងទៀត កម្មដែលញុំាំងសត្វឲ្យប្រព្រឹត្តទៅព្រមដើម្បីភាពជាអ្នកមានសម្បុរអាក្រក់ និងឲ្យមានអាយុតិចនោះ រមែងមានក្នុងពាក្យថា "កម្មដែលញុំាំងសត្វឲ្យប្រព្រឹត្តទៅព្រមដើម្បីភាពជាអ្នកមានសម្បុរអាក្រក់ និងឲ្យមានអាយុតិចនោះ" ព្រោះហេតុដូច្នេះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា **"ជរា និងមរណៈជាវិបាក គឺជាផល"** ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ក្នុងបញ្ហាបដិលោម ពាក្យថា **"ជរា និងមរណៈ មិនមានអារម្មណ៍ទេ"***

អធិប្បាយថា រូបធម៌ទាំងឡាយ មិនមានអារម្មណ៍ឡើយ ចំណែកជរា និងមរណៈនៃអរូបធម៌ គឺនាមធម៌ទាំងឡាយ ឈ្មោះថា មិនមានអារម្មណ៍ ព្រោះការមិនមានលក្ខណៈនៃសម្បយោគ ។

ក្នុងបញ្ហាថា ***“ជរា និងមរណៈនៃអកុសលធម៌ ជាវិបាកនៃអកុសល-ធម៌ឬ ?”*** បរវាទីឆ្លើយតបតាមលទ្ធិថា “ក៏ឈ្មោះថា ជរា និងមរណៈ គប្បីជាវិបាកដែលមិនគួរប្រាថ្នា” ។ ព្រោះហេតុនោះឯង ទើបឆ្លើយ បដិសេធនូវភាវៈនៃជរា និងមរណៈនៃកុសលធម៌ថា ជាវិបាករបស់កុសលធម៌ និងរមែងឆ្លើយតបជរា ព្រមទាំងមរណៈនៃកុសលធម៌ថា ជាវិបាកនៃកុសលធម៌ខាងមុខនុ៎ះឯង ។ម្យ៉ាងទៀត សកវាទីលោករួមបញ្ហាឲ្យមានតែមួយ ដូចគ្នា ដោយអំណាចនៃពាក្យសួរថា ***“ជរា និងមរណៈនៃកុសល និងអកុសលធម៌”***, តែជរា និងមរណៈនៃកុសល និងអកុសលនោះ មិនមាន ក្នុងខណៈតែម្យ៉ាងជាមួយគ្នាឡើយ ។ ឈ្មោះថា ***ពាក្យបរិយាយ*** គឺនិយាយ បញ្ចិតបញ្ចៀង ព្រោះពាក្យដែលបុគ្គលគប្បីពោលថា “ជរា និងមរណៈ ជាវិបាក ***របស់អព្យាក្រឹត*** ដែលមិនមែនជាវិបាកទាំងឡាយ” ដូច្នេះ មិនមាន ទេ, ព្រោះហេតុដូច្នេះ ទើបខ្ញុំ ***មិនសួរបញ្ហា*** ពោលអំពីអព្យាក្រឹតឡើយ ។

ក្នុងបទថា ***“កម្មដែលញុំាងសត្វឱ្យប្រព្រឹត្តទៅព្រមដើម្បីភាពជាអ្នកមានសម្បុរអាក្រក់”*** នេះ អធិប្បាយថា ឈ្មោះថា ភាពជាអ្នកមានសម្បុរ

មិនល្អ ព្រោះមានសម្បុរមិនបរិសុទ្ធ ។ ឈ្មោះថា ភាពជាអ្នកមានអាយុតិច ព្រោះមិនអាចឲ្យអាយុប្រព្រឹត្តទៅបានយូរ ។ ក្នុងបញ្ហានោះ អកុសលកម្ម ជាកម្មប្បច្ច័យដល់រូប ដែលមានសម្បុរមិនល្អ ព្រោះមានកម្មជាសមុដ្ឋាន ។ តែវិបាកនៃអកុសលកម្មនោះ ឈ្មោះថា រមែងមិនមានដល់រូបនោះ ព្រោះ ជាសភាវធម៌មិនដូចគ្នា ។ ម្យ៉ាងទៀត វិបាកនៃអកុសលកម្មនោះ រមែង ជាបច្ច័យដល់សមុដ្ឋានទាំងឡាយ មានឧតុសមុដ្ឋានជាដើម ដោយអំណាចនៃ ការឲ្យបានរូបដែលមានសម្បុរអាក្រក់នោះ និងដោយអំណាចនៃការចូលទៅ កាត់នូវអាយុ ។ អកុសលកម្មនោះ ឈ្មោះថា ទាក់ទងគ្នាដោយភាពជាអ្នក មានសម្បុរមិនល្អ និងជាអ្នកមានអាយុតិច ដោយប្រការដូច្នេះ ។ ធម៌ នោះ ឈ្មោះថា មិនឲ្យប្រព្រឹត្តទៅដោយអំណាចនៃការកើតឡើងនៃជរា និង មរណៈដោយត្រង់ ដូចផស្សៈដែលជាវិបាកជាដើម, ព្រោះហេតុដូច្នោះ ជរា និងមរណៈនោះ ទើបមិនសម្រេចក្នុងភាពជាវិបាកឡើយ ។ ពាក្យដ៏សេស ក្នុងទីនេះ ដូចពាក្យដែលខ្ញុំពោលហើយ ក្នុងពេលមុននុ៎ះឯង ៕

ចប់ជរាមរណវិបាកោតិកថា

## ៩.អរិយធម្មវិបាកកថា សម្តែងអំពីវិបាកនៃអរិយធម៌

ឥឡូវនេះ ឈ្មោះថា រឿងវិបាកនៃអរិយធម៌ ៖

*ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា "សាមញ្ញផល គឺផលនៃភាពជាសមណៈ ត្រឹមតែការលះកិលេសប៉ុណ្ណោះ, មិនមែនចិត្ត និងចេតសិកធម៌ទេ" ដូច្នេះ ពាក្យសួររបស់សកវាទីថា* ***"វិបាកនៃអរិយធម៌មិនមានឬ ?"*** *ដោយសំដៅដល់ជនទាំងនោះ ។ បណ្ដាពាក្យទាំងនោះ ពាក្យថា* ***"វិបាកនៃអរិយធម៌"*** *បានដល់ផលរបស់អរិយមគ្គ ពាក្យឆ្លើយតបរបស់បរវាទី ដោយលទ្ធិថា អរិយផលត្រឹមតែជាការអស់ទៅនៃកិលេស ។ ពាក្យថា* ***"សាមញ្ញ"*** *បានដល់ ភាពជាសមណៈ, ពាក្យនេះ ជាឈ្មោះរបស់អរិយមគ្គ សមពិតដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា* ***"ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសម្ដែងភាពជាសមណៈ និងផលនៃសមណៈដល់អ្នកទាំងឡាយ"***[៨] *។*

*សូម្បីក្នុងភាពជាព្រហ្ម គឺព្រហ្មញ្ញ ក៏មានន័យដូចគ្នានេះដែរ ។*

*ក្នុងបញ្ហាទាំងឡាយ មានពាក្យថា* ***"សោតាបត្តិផលមិនជាវិបាកឬ ?"*** *ជាដើម បរវាទីឆ្លើយតបនូវភាវៈនៃអរិយផលទាំងឡាយ មិនជាវិបាក ព្រោះសំដៅយកភាវៈនៃសោតាបត្តិមគ្គជាដើម មិនមានការសន្សំវដ្តៈ, រមែងឆ្លើយបដិសេធផលនៃទានជាដើម គឺសំដៅយកវិបាកវដ្តៈ ។ មែនពិត*

---

[៨] សំ. ម.។

លោកហាមអត្ថនៃអាចយគាមីតិកៈ [៥] ដោយពាក្យយ៉ាងនេះថា ៖ ធម៌ទាំងឡាយណា រមែងទៅកាន់ទីមានការសន្សំ ដែលបណ្ឌិតរាប់ព្រមហើយថាជាវិបាក, ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា ***អាចយគាមី***, ម្យ៉ាងទៀត ធម៌ទាំងឡាយណាកាលសន្សំ រមែងទៅកាន់ទីមានការសន្សំ ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា ***អាចយគាមី***, ធម៌ទាំងឡាយណា កាលបើមិនមានការសន្សំវិបាកប្រព្រឹត្តទៅ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា ***អាបចយគាមី***; ព្រោះហេតុដូច្នោះ ទើបបរវាទីឆ្លើយស្របផង បដិសេធផង យ៉ាងនេះ ។

ពាក្យសួរថា ***"កាមាវចរកុសល មានវិបាកជាអាចយគាមី គឺជាធម៌សន្សំវិបាកវដ្តៈ"*** ដូច្នេះ ជារបស់បរវាទី, ពាក្យឆ្លើយស្រប និងបដិសេធជារបស់សកវាទី ។ មែនពិត លោកិយកុសលវិបាក ឈ្មោះថា ***អាចយ-គាមី*** ព្រោះអត្ថថា មានប្រក្រតីសន្សំចុតិ បដិសន្ធិ និងវដ្តៈ ឲ្យប្រព្រឹត្តទៅ, លោកុត្តរកុសលនេះ រមែងជាធម៌មានវិបាកទាំងអស់ មិនមែនមិនមានវិបាក ដោយហេតុត្រឹមតែពាក្យថា ជាអបចយគាមី គឺជាធម៌មិនសន្សំចុតិ បដិសន្ធិ និងវដ្តៈទេ ។ គប្បីជ្រាបពាក្យឆ្លើយតប និងបដិសេធរបស់

---

[៥] ពាក្យថា **អាចយគាមីតិកៈ** បានដល់ ពួក ៣ នៃអាចយគាមីក្នុងតិកមាតិកា ។

*សកវាទី ក្នុងទីនេះ ព្រោះសំដៅយកអត្ថនេះ ដោយប្រការដូច្នេះឯង ៕*

ចប់អរិយធម្មវិបាកកថា

---

## ១០.ទិបាកោទិបាកធម្មធម្មោតិកថា

## សម្តែងអំពីវិបាកជាវិបាកធម្មធម៌

*ឥឡូវនេះ ឈ្មោះថា រឿងវិបាកជាវិបាកធម្មធម៌ គឺវិបាកធម៌ដែលជាហេតុឲ្យវិបាកកើតឡើង ៖*

*ក្នុងបញ្ហានោះ វិបាកជាបច្ច័យដល់វិបាក ដោយអំណាចនៃអញ្ញមញ្ញបច្ច័យជាដើម, ជនណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា "សូម្បីវិបាក ក៏ជាវិបាកធម្មធម៌ គឺធម៌ដែលជាហេតុឲ្យវិបាកកើតឡើង" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតប ជារបស់បរវាទី ។ ពាក្យថា* ***"វិបាករបស់វិបាកនោះ ក៏ជាធម៌ដែលជាហេតុនៃវិបាកដែរ"*** *សេចក្តីថា សកវាទីរមែងសួរថា "វិបាកណា រមែងមាន, សូម្បីវិបាកនោះ ជាវិបាកធម្មធម៌ ដល់វិបាកដែលជាវិបាកធម្មធម៌នោះឬ ?" បរវាទីឆ្លើយបដិសេធ សំដៅយកភាវៈនៃការឲ្យផលតទៅ ។ ត្រូវសកវាទីសួរគ្រាទី ២ ឆ្លើយបដិសេធ*

ដោយខុសចាកលទ្ធិ, តែលោកក៏ឆ្លើយតបសំដៅយកការកើតឡើងនៃវិបាក ដទៃ ព្រោះជាបច្ច័យសូម្បីដល់វិបាកនោះ ។ ក៏កាលបើមានសេចក្ដី យ៉ាងនោះ ការមិនកាត់វដ្តៈ រមែងប្រាកដថា “សូម្បីវិបាកនៃវិបាកនោះ ក៏ជាវិបាកនៃវិបាកនោះតទៅ ដូចកុសល និងអកុសលឬ ?” បរវាទីត្រូវ សកវាទីសួរបញ្ហានេះ ក៏ឆ្លើយបដិសេធ ព្រោះខ្លាចខុសចាកលទ្ធិ ។ ក៏ក្នុង ការពិសោធពាក្យពេចន៍ថា ***“ពាក្យថា វិបាក ឬធម៌ដែលជាហេតុនៃវិបាកក្ដី”*** ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះថា ប្រសិនបើភាវៈនៃវិបាក ជាអត្ថ តែមួយដល់ធម៌ដែលជាហេតុនៃវិបាកមែន ពាក្យថា ***កុសល អកុសល និង អព្យាក្រឹត*** ក៏នឹងគប្បីមានអត្ថតែមួយ ដូចគ្នាដែរ ។

ក្នុងពាក្យថា ***“វិបាក និងធម៌ដែលជាហេតុនៃវិបាក”*** នេះ មានពាក្យ អធិប្បាយថា កាលបើបរវាទីកំណត់នូវវិបាកក្នុងនាមក្ខន្ធទាំង ៤ ខន្ធមួយៗ ឈ្មោះថា ជាវិបាកធម្មធម៌ គឺធម៌ដែលជាហេតុឲ្យវិបាកកើតឡើង ព្រោះ អត្ថថា ជាបច្ច័យក្នុងបច្ច័យទាំងឡាយ មានអញ្ញមញ្ញបច្ច័យជាដើម និង ព្រោះអត្ថថា ជាបច្ចយុប្បន្នដូច្នោះ កាលត្រូវសកវាទីសួរថា ***“វិបាកជា ធម៌ដែលជាហេតុនៃវិបាកឬ ?”*** ទើបឆ្លើយតបថា “មែន” ។ លំដាប់នោះ សកវាទីដើម្បីចោទបរវាទីនោះ ទើបពោលពាក្យយ៉ាងនេះថា “វិបាកក្នុង នាមក្ខន្ធ ៤ ក្ដី ជាធម៌ដែលលោកយល់ព្រមហើយ ព្រោះហេតុណា,

*ព្រោះហេតុនោះ ភាវៈនៃវិបាក និងធម៌ដែលជាហេតុនៃវិបាកទាំងនោះ រមែងប្រាកដថា ជាធម៌សហគតៈគ្នាឬ ?” បរវាទីឆ្លើយបដិសេធ សំដៅយកធម៌ដែលជាហេតុនៃវិបាក គឺកុសល ។ ពាក្យថា* ***“អកុសលយ៉ាងនោះ”*** *សេចក្ដីថា បើវិបាកដែលជាហេតុនៃវិបាក តាមលទ្ធិរបស់លោកមែន, វិបាកណា ជាអកុសលវិបាក, វិបាកនោះ ក៏ដល់ភាពជាអកុសល ។* ***សួរថា*** *ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះលោកពោលថា “អកុសលវិបាក ជាសភាវៈតែមួយដូចគ្នានឹងធម៌ដែលជាហេតុនៃវិបាក” ។ សូម្បីក្នុងពាក្យថា* ***“កុសលយ៉ាងនោះ”*** *ជាដើម ក៏មានន័យដូចគ្នានេះដែរ ។*

*ពាក្យថា* ***“អញ្ញមញ្ញប្បច្ច័យ”*** *នេះ បរវាទីពោលហើយ ដោយត្រឹមតែជាបច្ច័យនៃសហជាតធម៌ទាំងឡាយ ព្រោះហេតុដូច្នោះ ពាក្យថា* ***“អញ្ញមញ្ញប្បច្ច័យ”*** *នេះ ទើបមិនសម្រេចប្រយោជន៍ឡើយ ។ សូម្បីការពោលដល់ភាវៈនៃមហាភូតរូបទាំងឡាយ ជាបច្ច័យដល់គ្នានឹងគ្នានោះ ក៏មិនមែនជាវិបាកទេ ទាំងមិនជាធម៌ដែលជាហេតុនៃវិបាកផងដែរ ដោយប្រការដូច្នេះ ។*

ចប់វិបាកោវិបាកធម្មធម្មោតិកថា

---

## រួបកថាដែលមានក្នុងវគ្គនេះ គឺ

*១.សន្ទហិតកថា, ២.សម្បយុត្តកថា, ៣.ចេតសិកកថា, ៤.ទានកថា, ៥.បរិភោគមយបុញ្ញកថា, ៦.ឥតោទិន្នកថា, ៧.បថវីកម្មវិបាកោតិកថា, ៨.ជរាមរណវិបាកោតិកថា, ៩.អរិយធម្មវិបាកកថា, ១០.វិបាកោ វិបាកធម្មធម្មោតិកថា ។*

## ចប់វគ្គទី ៧

## វគ្គទី ៨

## ១.ឆគតិកថា សម្តែងអំពីគតិ ៦

*ឥឡូវនេះ ពោលអំពីរឿងគតិ ៦ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈ និងឧត្តរាបថកៈថា “គតិមាន ៦ រួមទាំងអសុរកាយផង” ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទដោយអំណាចនៃគតិទាំងឡាយ ដែលព្រះមានព្រះភាគទ្រង់កំណត់ទុក ក្នុងរឿងលោមហង្សនសូត្រថា* ***“ម្នាលសារីបុត្ត គតិទាំង ៥ នេះឯង រមែងមាន”***[១០] *ដូច្នេះ ទើបពោលថា* ***“ព្រះមានព្រះភាគត្រាស់គតិទុក ៥ មិនមែនឬ ?”*** *ជាដើម*

---

[១០] ម. មូ. ។

បរវាទីឆ្លើយតប ព្រោះខ្វាចខុសអំពីព្រះសូត្រ ។ **សួរថា** ក៏ព្រោះហេតុអ្វី ? ទើបសកវាទីមិនព្រមទទួលគតិ ៦ សូម្បីអសុរកាយ លោកក៏សង្គ្រោះចូលក្នុងអបាយភូមិ ដូចពាក្យថា "ព្រះអរិយៈផុតហើយអំពីអបាយទាំង ៤" ដូច្នេះ មិនមែនឬ ? នេះ ឆ្លើយថា លោកសង្គ្រោះអសុរកាយទុកក្នុងខនោះ ក៏ពិតមែនហើយ, ប៉ុន្តែ ក៏មិនចាត់ជាគតិទេ ។ **សួរថា** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមិនមានគតិចំណែកមួយផ្សេងទៀត ។ មែនពិត ពួកអសុរ ឈ្មោះថា កាលកញ្ជិកា ក្នុងជំពូកពួកអសុរកាយ លោកសង្គ្រោះចូលក្នុងគតិនៃប្រេត ។ បរិស័ទនៃស្តេចវេបចិត្រ លោកសង្គ្រោះចូលក្នុងគតិនៃពួកទេវតា ។ ពាក្យថា "**អសុរកាយ**" នេះ ឈ្មោះថា ជាចំណែកមួយផ្សេងទៀត មិនមានឡើយ ។

ឥឡូវនេះ ទើបសកវាទីផ្តើមពាក្យថា "ពួកអសុរកាលកញ្ជិកា" ជាដើម ដើម្បីសម្តែងអត្ថតែមួយដូចគ្នានោះឯង ។ ក្នុងពាក្យទាំងនោះ ពាក្យថា **"សមានវណ្ណា"** បានដល់ មានរូបរាងសណ្ឋានតែមួយដូចគ្នា ។ ពាក្យថា **"មានរូបរាងគួរស្អប់"** បានដល់ មានរូបពិការ មានលក្ខណៈអាក្រក់ ។ ពាក្យថា **"មានការសោយអារម្មណ៍តែមួយដូចគ្នា"** បានដល់ មានការប្រព្រឹត្តក្នុងមេថុនធម្មតែមួយដូចគ្នា ។ ពាក្យថា **"មានអាហារតែមួយដូចគ្នា"** បានដល់ មានអាហារ មានទឹកមាត់ ទឹកសំបោរ ទឹកមូត្រ និងឈាម

ជាដើម តែមួយដូចគ្នា ។ ពាក្យថា ***“មានអាយុប៉ុនគ្នា”*** បានដល់ មានការកំណត់អាយុដូចគ្នា ។ ពាក្យថា ***“អាវាហៈ និងវិវាហៈ”*** បានដល់ការទទួលកូនក្រមុំ និងការឲ្យកូនក្រមុំ ។

ក្នុងពួកទេពសុក្កបក្ខេ អ្នកមានសេចក្ដីល្អ និងសេចក្ដីស្អាត ពាក្យថា ***“មានរូបរាងដូចគ្នា”*** បានដល់ ជាអ្នកមានរូបរាងល្អស្អាតតែមួយដូចគ្នា ដល់ព្រមដោយពន្លឺ ដែលនាំមកនូវសេចក្ដីជ្រះថ្លាគួរទស្សនា គឺគួរស្រឡាញ់ គួរមើល ។ ពាក្យថា ***“មានការសោយអារម្មណ៍តែមួយដូចគ្នា”*** បានដល់ មានការបរិភោគកាមគុណ ៥ ដូចគ្នា ។ ពាក្យថា ***“មានអាហារតែមួយដូចគ្នា”*** បានដល់ អាហារមានសុធាភោជនជាដើមដូចគ្នា ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយមែនពិត ។ ពាក្យថា ***“មានអសុរកាយ មិនមែនឬ ?”*** ជាការសម្រេចប្រយោជន៍ត្រឹមតែថា មានតែអសុរកាយប៉ុណ្ណោះ; តែមិនសម្រេចថា ជាគតិរបស់អសុរកាយនោះទេ ព្រោះមិនមានការកំណត់គតិរបស់អសុរកាយទុកដោយចំណែកមួយដូច្នោះឯង ៕

ចប់ឆគតិកថា

## ២.អន្តរាភវកថា សម្ដែងអំពីអន្តរាភព

ឥឡូវនេះ ឈ្មោះថា រឿងអន្តរាភព គឺភពដែលខណ្ឌក្នុងចន្លោះ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងសមិតិយៈថា "សត្វ សំដៅដល់អ្នកនឹងបដិសន្ធិអ្នកមិនមានទិព្វចក្ខុ ប្រៀបដូចជាមានទិព្វចក្ខុ, អ្នកមិនមានឫទ្ធិ ប្រៀបដូចជាអ្នកមានឫទ្ធិ ពិចារណាមើលនូវការរស់នៅរួមគ្នា របស់មាតាបិតា និងការមានរដូវ គេតាំងនៅប្រមាណ ៧ ថ្ងៃ ឬ លើសជាង ៧ ថ្ងៃនោះក្នុងទីណា, ក្នុងទីនោះ ឈ្មោះថា អន្តរាភព" ព្រោះកាន់យកបទព្រះសូត្រថា "បុគ្គល ឈ្មោះថា អន្តរាបរិនិព្វាយី គឺអ្នកបរិនិព្វានក្នុងចន្លោះអាយុនៅមិនទាន់ដល់ពាក់កណ្តាលនៃអាយុក្ស័យ" ដោយមិនពិចារណាដូច្នេះ ពាក្យសួររបស់សកវាទីថា "**អន្តរាភពរមែងមានឬ ?**" ព្រោះសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ព្រោះតាំងនៅក្នុងលទ្ធិ ។ លំដាប់នោះ សកវាទីដើម្បីនឹងចោទបរវាទីនោះ ដោយអំណាចនៃភពទាំង ៣ ណា ដែលព្រះមានព្រះភាគត្រាស់ហើយនោះ ទើបពោលពាក្យថា "**ជាកាមភព**" ជាដើម ។

ក្នុងបញ្ហានោះ អធិប្បាយថា ប្រសិនបើភពអ្វីៗ ឈ្មោះថា អន្តរាភពរមែងមានតាមលទ្ធិរបស់លោកមែន ភពនោះ ក៏គប្បីមានដូចបញ្ចវោការភពភពណាទីមួយ មានកាមភពទាំងឡាយជាដើមនោះឯង, ព្រោះហេតុនោះទើបខ្ញុំសួរលោកថា "ជាកាមភព ឬរូបភព ឈ្មោះថា អន្តរាភព តាមលទ្ធិរបស់លោក" ។ បរវាទីកាលមិនប្រាថ្នាដូច្នោះ ទើបបដិសេធទាំងអស់ ។

ពាក្យថា **“រមែងមានក្នុងចន្លោះកាមភព”** ជាដើម សកវាទីពោលដើម្បីចោទថា បើអន្តរាភពមានមែន អន្តរាភពនោះ ក៏នឹងគប្បីមាន ដូចគ្នានឹងខេត្តដែននៃខេត្តដែនទាំង ២; បរវាទីកាលមិនប្រាថ្នាដូច្នោះ ទើបបដិសេធបញ្ហាទាំងពួង រមែងបដិសេធចេញទៅ ព្រោះលទ្ធិតែម្យ៉ាង, តែមិនបដិសេធតាមសេចក្ដីពិតទេ ។ ដោយពាក្យនោះឯង ទើបសកវាទីពោលបដិសេធនឹងបរវាទីថា **“លោក ក៏មិនត្រូវពោលថា អន្តរាភពមាន”** ទេ, សូម្បីពាក្យថា **“អន្តរាភពជាកំណើតទី ៥”** ជាដើម សកវាទីសួរដើម្បីចោទថា អន្តរាភពនោះ មិនរួមនៅក្នុងកំណើតជាដើម តាមដែលព្រះមានព្រះភាគទ្រង់កំណត់ទុកហើយ, កាលបើដូច្នេះ អន្តរាភពនោះ ក៏នឹងគប្បីជាភពដែលលើសអំពីកំណើត អំពីគតិជាដើមនោះៗ ។ ពាក្យថា **“កម្មដែលញ៉ាំងសត្វឱ្យចូលដល់អន្តរាភពមានឬ ?”** សកវាទីសួរដើម្បីចោទថា សូម្បីអន្តរាភពនោះ គប្បីជាភព ១ ដទៃ ផ្សេងទៀតមែន កម្មដែលញ៉ាំងសត្វឱ្យចូលដល់កាមភពជាដើម ដូចព្រះតម្រាស់ដែលព្រះសាស្ដាទ្រង់ចែកទុកហើយ និងសម្ដែងទុកហើយថាជា **“កម្មមានពិតយ៉ាងនេះ”** ដូច្នេះ ។ ម្យ៉ាងទៀតលទ្ធិទាំងនោះ ក្នុងលទ្ធិរបស់បរវាទីថា កម្មដោយចំពោះ ដែលឈ្មោះថាការញ៉ាំងសត្វឱ្យចូលដល់អន្តរាភព មិនមាន សត្វណានឹងចូលដល់ភពណាៗ រមែងកើតក្នុងអន្តរាភពបាន ដោយកម្មដែលញ៉ាំងសត្វឱ្យចូលដល់ភពនោះៗ

ព្រោះហេតុណា, ព្រោះហេតុនោះ ទើបបរវាទីឆ្លើយថា "មិនគប្បីពោលយ៉ាងនេះទេ" ។ សូម្បីត្រូវសកវាទីសួរថា **"សត្វដែលចូលដល់អន្តរាភពមានឬ ?"** បរវាទីឆ្លើយបដិសេធតាមលទ្ធិថា សត្វទាំងនោះ ឈ្មោះថាអ្នកកើតក្នុងកាមភពនោះឯង ។ សូម្បីត្រូវសកវាទីសួរថា **"សត្វទាំងឡាយរមែងកើត... ក្នុងអន្តរាភពឬ ?"** បរវាទីកាលមិនប្រាថ្នានូវការកើត ចាស់ ស្លាប់ ចុតិ និងឧប្បត្តិ ក្នុងអន្តរាភពនោះ ទើបឆ្លើយបដិសេធ ។ សូម្បីត្រូវសកវាទីសួរដោយអំណាចនៃរូបជាដើម ក៏ឆ្លើយបដិសេធ ព្រោះលទ្ធិនៃជនទាំងនោះថា "រូបរបស់សត្វក្នុងអន្តរាភព ឃើញមិនបានទេ, សូម្បីធម៌ទាំងឡាយ មានវេទនាជាដើម ក៏មិនគ្រោតគ្រាតដូចពួកសត្វដទៃឡើយ" ។ ដោយហេតុនោះឯង គប្បីជ្រាបការបដិសេធ សូម្បីក្នុងបញ្ចវោការភព ។

ឥឡូវនេះ ពាក្យថា **"កាមភព ជាភព ជាគតិ"** ជាដើម ឈ្មោះថាជាការប្រៀបធៀបភព ។ ក្នុងសេចក្តីនេះ អធិប្បាយថា បើភពអ៊ីៗ ឈ្មោះថា អន្តរាភព គប្បីមានតាមលទ្ធិរបស់លោកមែន ក៏បណ្តាភពទាំងឡាយ មានកាមភពជាដើម រមែងមានការប្លែកផ្សេងគ្នានៃភព និងគតិជាដើម គប្បីអាចឃើញបាន យ៉ាងណា, សូម្បីក្នុងអន្តរាភពនោះ ក៏នឹងគប្បីឃើញបានយ៉ាងនោះ ក្នុងអន្តរាភពមិនអាចឃើញបាន យ៉ាងណា, សូម្បីក្នុងកាមភពជាដើមទាំងនេះ ក៏មិនអាចឃើញបាន យ៉ាងនោះដែរ,

*ព្រោះថា ការចែកដោយល្អនៃភព និងគតិនោះឯង រមែងមានក្នុងភាពជាភពដែលមាន, មិនមែនក្នុងភពក្រៅពីនេះទេ ក៏អ្វីទៅ ជាហេតុប្លែកគ្នារវាងកាមភពជាដើមទាំងនោះ និងអន្តរាភពក្នុងទីនេះ ។ បរវាទីរមែងឆ្លើយតប និងឆ្លើយបដិសេធនូវបញ្ហានោះៗ ដោយអំណាចត្រឹមតែលទ្ធិ ។*

*ត្រូវសកវាទីសួរថា* ***"អន្តរាភពមានសម្រាប់សត្វទាំងពួង តែម្យ៉ាងឬ ?"*** *ដូច្នេះ បរវាទីនោះ មិនត្រូវការអន្តរាភព មានដល់សត្វដែលកើតក្នុងនរក អសញ្ញីសត្វ និងអរូបព្រហ្ម ព្រោះហេតុដូច្នោះ ទើបបដិសេធ ។ រមែងឆ្លើយតបដោយបដិលោម ព្រោះហេតុនោះឯង ពាក្យថា* ***"អន្តរាភពមានដល់បុគ្គលដែលធ្វើអនន្តរិយកម្ម"*** *ជាដើម ទើបសកវាទីពោលដើម្បីចែកសម្ដែងភពទាំងឡាយ ដោយន័យដែលបរវាទីនោះ មិនប្រាថ្នាអន្តរាភពរបស់ពួកសត្វនោះឯង ។ ពាក្យទាំងអស់នោះ បណ្ឌិតគប្បីជ្រាបតាមទំនងនៃព្រះបាលី ព្រមទាំងការអាងព្រះសូត្រផងចុះ ៕*

**ចប់អន្តរាភវកថា**

## ៣.កាមគុណកថា សម្ដែងអំពីកាមគុណ

*ឥឡូវនេះ ឈ្មោះថា រឿងកាមគុណ ៖*

រឿងនេះ ក្នុងលទ្ធិរបស់សកវាទីមុន វត្ថុកាមក្តី កិលេសកាមក្តី កាមភពក្តី លោកហៅថា **"កាមធាតុ"** ។ មែនពិត បណ្តាកាមទាំងនោះ វត្ថុកាម ឈ្មោះថា **កាម** ព្រោះអត្ថថា ជាវត្ថុដែលគួរប្រាថ្នា, ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ជាសភាវៈ ជានិស្សត្តៈ និងជាសុញ្ញតៈ ព្រោះហេតុដូច្នោះ ទើបឈ្មោះថាជា **កាមធាតុ** កិលេសកាម ឈ្មោះថា **កាម** ព្រោះអត្ថថា ជាវត្ថុដែលគួរប្រាថ្នាផង និងព្រោះអត្ថថា ជាការពេញចិត្តផង, ឈ្មោះថា **ធាតុ** ព្រោះមានអត្ថដូចដែលពោលហើយនោះឯង ព្រោះហេតុដូច្នោះ ទើបឈ្មោះថា ជាកាមធាតុ កាមភព ឈ្មោះថា **កាម** ព្រោះហេតុ ៣ គឺព្រោះអត្ថថា ជាវត្ថុដែលគួរប្រាថ្នា ១, ព្រោះអត្ថថា ជាគ្រឿងឈានទៅ ១ និងព្រោះអត្ថថា ជាស្ថានទីប្រព្រឹត្តទៅនៃវត្ថុកាម ១, ឈ្មោះថា ជាធាតុ ព្រោះមានអត្ថដូចដែលពោលហើយនោះឯង ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **កាមធាតុ** ។ ក៏ក្នុងលទ្ធិរបស់អ្នកដទៃកាន់យកកាមគុណ ៥ ប៉ុណ្ណោះ ជាកាមធាតុ ព្រោះអាស្រ័យត្រឹមតែបាលីថា **"ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ យ៉ាង"** ។ ព្រោះហេតុដូច្នោះ ជនពួកណា មានសេចក្តីយល់ឃើញខុស ដូចលទ្ធិរបស់និកាយ បុព្វសេលិយៈទាំងឡាយ សកវាទីសំដៅដល់ជនទាំងនោះ ទើបសួរថា **"កាមគុណ ៥ ប៉ុណ្ណោះ"** ជាដើម ដើម្បីចោទនូវភាវៈនៃកាមគុណនោះ មានសភាព

ផ្សេងអំពីកាមធាតុ, ពាក្យឆ្លើយតបជារបស់បរវាទី ដោយអំណាច នៃលទ្ធិ (របស់ខ្លួន) ។ ពាក្យថា ***"រមែងមានមិនមែនឬ ?"*** ជាដើម សកវាទីពោលហើយ ដើម្បីសម្ដែងដល់កិលេសកាម ។

ក្នុងពាក្យទាំងនោះ ពាក្យថា ***"សេចក្ដីពេញចិត្តជាប់ជាមួយកាមគុណនោះ"*** បានដល់ ប្រកបព្រមចំពោះហើយដោយកាមគុណ គឺមានកាមគុណជាអារម្មណ៍ ។ ក្នុងពាក្យទាំងឡាយថា ***"ក៏មិនត្រូវពោលថាកាមគុណ ៥ ប៉ុណ្ណោះទេ"*** នេះ សេចក្ដីថា បណ្ដាធម៌ទាំងឡាយ មានសេចក្ដីពេញចិត្តជាប់ជាមួយកាមគុណជាដើមនោះ លោកក៏មិនគួរពោលថា កាមគុណ ៥ ប៉ុណ្ណោះ ជាកាមធាតុ ។ អធិប្បាយថា ក៏ធម៌ទាំងឡាយ មានការពេញចិត្តជាដើម សូម្បីទាំងនេះ ឈ្មោះថា កាមផង ឈ្មោះថា ធាតុផង ព្រោះអត្ថថា ជាវត្ថុដែលគួរប្រាថ្នា ព្រោះហេតុនោះឯង ទើបឈ្មោះថា កាមធាតុ, ឆន្ទៈជាដើម ឈ្មោះថា ធាតុដែលបណ្ឌិតរាប់យកហើយថា ***កាម*** ព្រោះអត្ថថា ជាការពេញចិត្ត ព្រោះហេតុនេះឯង ក៏ឈ្មោះថា កាមធាតុ ។ ពាក្យថា ***"ចក្ខុរបស់មនុស្សទាំងឡាយ"*** ជាដើម សកវាទីពោលដើម្បីសម្ដែងដល់វត្ថុកាម ។

ក្នុងបញ្ហាទាំងនោះ ត្រូវបរវាទីសួរថា ***"មនោរបស់មនុស្សទាំងឡាយមិនមែនជាកាមធាតុឬ ?"***ម្ដងទៀត ព្រោះបដិសេធនូវភាវៈនៃអាយតនៈ

*សូម្បីទាំង ៦ ថា "មិនមែនជាកាមធាតុ, តែជាវត្ថុកាម" ទាំងមិនឆ្លើយតប នូវភាវៈនៃចិត្តនោះថាជា* ***"កាមធាតុ"*** *ព្រោះសំដៅយកមហគ្គតៈ និង លោកុត្តរចិត្ត ។ សេចក្ដីពិត សូម្បីមនោដែលប្រព្រឹត្តទៅក្នុងភូមិ ២ ទាំងអស់ ឈ្មោះថា កាមធាតុមែនពិត ព្រោះហេតុណា, ព្រោះហេតុនោះ ទើបសកវាទី តិះដៀល (ដុញដាល់) បរវាទីនោះ ដោយការអាងព្រះសូត្រ ។ ពាក្យថា* ***"កាមគុណជាភព"*** *ជាដើម សកវាទីពោលដើម្បីសម្ដែងភាវៈនៃភពជា កាមធាតុ ។ តែវោហារថា* ***"ភព"*** *ក្នុងពាក្យត្រឹមតែកាមគុណរមែងមិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ ទើបបរវាទីបដិសេធថា "មិនគប្បី ពោលយ៉ាងនោះទេ" ។ ពាក្យទាំងពួងថា* ***"កម្មដែលញុំាងសត្វឱ្យចូលដល់ កាមគុណ"*** *ជាដើម សកវាទីពោលហើយ ដើម្បីសម្ដែងភាវៈនៃវោហារ ត្រឹមតែកាមគុណ ជាកាមធាតុ ក៏ទេ ។ តាមពិត កម្មដែលញុំាងសត្វឱ្យ ចូលដល់កាមភព គឺបណ្ឌិតរាប់ព្រមហើយថា ជាកាមធាតុ, ឯសត្វទាំងឡាយ ដែលកើតក្នុងកាមភពនោះឯង ក៏មានដែរ ។ ព្រោះហេតុដូច្នោះ បណ្ឌិត គប្បីជ្រាបសេចក្ដីក្នុងទីទាំងពួង ដោយឧបាយនេះថា "សត្វទាំងឡាយ រមែងកើត ចាស់ ស្លាប់ ចុតិ និងរមែងឧប្បត្តិក្នុងកាមភពនោះ, មិនមែន ក្នុងកាមគុណទាំងឡាយទេ"* ៕

ចប់កាមគុណកថា

## ៤.កាមកថា សម្តែងអំពីកាម

*ឥឡូវនេះ ឈ្មោះថា រឿងកាម ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈថា អាយតនៈទាំង ៥ មានរូបាយតនៈជាដើមប៉ុណ្ណោះ ជាកាម ។ ព្រោះអាស្រ័យត្រឹមតែបាលីថា* **“បញ្ចិមេ ភិក្ខវេ កាមគុណា** *= ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ យ៉ាង” ដូច្នេះ ពាក្យសួររបស់សកវាទីថា* ***“អាយតនៈ ៥ ប៉ុណ្ណោះ*** *ដើម្បីសម្តែងភាវៈនៃកិលេសកាមនុ៎ះឯង ជាកាមដោយពិត” ដូច្នេះ ដោយសំដៅយកជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលទាំងអស់ ៕*

ចប់កាមកថា

## ៥.រូបធាតុកថា សម្តែងអំពីរូបធាតុ

*ឥឡូវនេះ ឈ្មោះថា រឿងរូបធាតុ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា “រូបធម៌ប៉ុណ្ណោះ ឈ្មោះថា* ***រូបធាតុ”*** *ដូច្នេះ ពាក្យសួររបស់សកវាទីថា* ***“រូប”*** *ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតប*

ជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីប្រកែកដោយអត្ថថា រូបភព ក៏ឈ្មោះថា ***រូបធាតុ***, មិនមែនត្រឹមតែរូបមប៉ុណ្ណោះទេ ដោយអត្ថនោះ ទើបពោលថា ***"រូបធាតុ"*** ជាដើម ។ ពាក្យទាំងអស់នោះ បណ្ឌិតគប្បី ជ្រាបសេចក្តី តាមន័យដែលខ្ញុំពោលហើយ ក្នុងរឿងកាមគុណនុ៎ះចុះ ។

ត្រូវសកវាទីសួរថា ***"កាមធាតុបែបនោះ រូបធាតុ ក៏បែបនោះដែរ ឬ ?"*** បរវាទីកាលបើឃើញខុសពីការកំណត់ភូមិ ទើបឆ្លើយបដិសេធ ។ ត្រូវសកវាទីសួរម្តងទៀត ក៏ឆ្លើយតបដោយអំណាចនៃលទ្ធិរបស់ខ្លួន; កាលបើ មានសេចក្តីដូច្នេះ រូបនោះ ក៏រមែងប្រាកដ, ព្រោះការប្រជុំគ្នាដោយភព ទាំង ២ គឺកាមភព និងរូបភព, ព្រោះហេតុនោះ ទើបសកវាទីពោល នឹងបរវាទីនោះថា ***"បុគ្គលប្រកបដោយកាមភព"*** ជាដើម បរវាទីឆ្លើយ បដិសេធ ព្រោះមិនមានត្រឹមតែរូប ១ ក្នុងភពទាំង ២ ៕

<u>ចប់រូបធាតុកថា</u>

## ៦.អរូបធាតុកថា សម្តែងអំពីអរូបធាតុ

សូម្បីក្នុងរឿងអរូបធាតុ ក្នុងឱកាសនេះ បណ្ឌិតគប្បីជ្រាបអត្ថ ដោយឧបាយនេះឯង គឺតាមន័យដែលពោលហើយនុ៎ះចុះ ។ តែក្នុង អរូបធម៌ទាំងឡាយ គឺនាមក្ខន្ធ ៤ លោកធ្វើការសម្តែងទុកក្នុងទីនេះ

ព្រោះថា ***វេទនាជាភព*** ជាដើម ព្រោះកាន់យកវេទនាខន្ធនុ៎ះឯង ។ ក្នុងបញ្ហានោះ បណ្ឌិតគប្បីជ្រាបអត្ថយ៉ាងនេះថា សកវាទីសួរថា “វេទនាដែលដល់នូវការរាប់ថា ជាអរូបធម៌ទាំងឡាយយ៉ាងណាមួយ មានភពជាដើម តាមលទ្ធិរបស់លោកឬ ?” ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងពេលមុននុ៎ះចុះ ៕

ចប់អរូបធាតុកថា

## ៧.រូបធាតុយា អាយតនកថា

## សម្តែងអំពីអាយតនៈក្នុងរូបធាតុ

ឥឡូវនេះ ឈ្មោះថា រឿងអាយតនៈក្នុងរូបធាតុ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈ និងសមិតិយៈថា អត្តភាពរបស់ព្រហ្មទាំងនោះ មានអាយតនៈគ្រប់ទាំង ៦ ព្រោះអាស្រ័យព្រះសូត្រថា “ពួកព្រហ្មដែលមានរូប មានការសម្រេចដោយចិត្ត មានអវយវៈតូច-ធំទាំងអស់ មានឥន្ទ្រិយដែលមិនខ្វះខាត គឺមានអត្តភាពសម្បូរ”[១១] ដូច្នេះ ទើបសម្គាល់ថា “សូម្បីឃាននិមិត្ត គឺរូបរាងនៃច្រមុះរបស់ព្រហ្មទាំងនោះ ជាអាយតនៈពិត គឺសំដៅ

[១១] ទី. សី. ។

សេចក្តីថា ជាឃានាយតនៈនោះឯង” ដូច្នេះ ពាក្យសួររបស់សកវាទីថា **“អត្តភាពរបស់ពួកព្រហ្ម មានអាយតនៈទាំង ៦”** ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទីដោយអំណាចនៃលទ្ធិ ។ លំដាប់នោះ សកវាទីដើម្បីចោទដោយអំណាចនៃអាយតនៈ ដែលមិនមានក្នុងពួកព្រហ្មនោះ ទើបផ្តើមពោលនឹងបរវាទីថា **“ក្នុងរូបធាតុនោះ មានឃានាយតនៈឬ ?”** ជាដើម; លំដាប់នោះ បរវាទី ក៏ឆ្លើយតបដោយលទ្ធិថា “សណ្ឋាននិមិត្តរបស់អាយតនៈទាំង ៣ គឺឃានាយតនៈ ជិវ្ហាយតនៈ និងកាយាយតនៈ ដែលជាខាងក្នុងមានឃានាយតនៈជាដើមណាមួយ ក្នុងរូបធាតុនោះ សណ្ឋាននិមិត្តនុ៎ះឯង ជាអាយតនៈ” ។ ត្រូវសកវាទីសួរដោយអំណាចនៃគន្ធាយតនៈជាដើម ដែលជារបស់ខាងក្រៅ បរវាទីកាលសេពនូវអារម្មណ៍នៃឃានាយតនៈជាដើមនោះ ទើបមិនប្រាថ្នាឃានបសាទជាដើម ក្នុងរូបធាតុនោះ ព្រោះហេតុដូច្នោះ ទើបឆ្លើយបដិសេធ ។ ក្នុងបញ្ហាបដិលោម និងបញ្ហាពោលអំពីការប្រៀបធៀបទាំងឡាយ បណ្ឌិតគប្បីជ្រាបសេចក្តីដោយឧបាយនេះចុះ ។

ពាក្យថា **“ក្នុងរូបធាតុនោះ មានឃានាយតនៈ គន្ធាយតនៈ និងធុំក្លិននោះ ដោយឃានៈនោះឬ ?”** ដូច្នេះ សកវាទីពោលសំដៅដល់អាចារ្យពួកខ្លះ ក្នុងលទ្ធិដទៃប៉ុណ្ណោះ ។ បានឮថា អាចារ្យទាំងនោះ ពួកខ្លះ

មានការសម្គាល់ថា ក្នុងរូបធាតុនោះ មានអាយតនៈខាងក្នុងគ្រប់ទាំង ៦ បរិបូណ៌, តែឈ្មោះថា អាយតនៈ ក៏គប្បីធ្វើកិច្ចរបស់ខ្លួន គឺទទួលអារម្មណ៍បានតាមនាទី, ព្រោះហេតុដូច្នោះ អាយតនៈទាំងនោះ ទើបហិតក្លិន ភ្លក្សរស ប៉ះនូវក្លិនជាដើមទាំងនោះ ដោយឃានៈជាដើមនោះដូច្នេះ ។ បរវាទីអាស្រ័យលទ្ធិនោះ ទើបឆ្លើយតបថា **“អាមន្តា = មែន”** ។ ក៏ត្រូវសកវាទីសួរពាក្យថា “ក្នុងរូបធាតុនោះ មានក្លិនកើតអំពីឫសឈើ” ជាដើម បរវាទីកាលមិនអាចញុំាំងអាយតនៈខាងក្រៅឲ្យប្រាកដបាន ទើបឆ្លើយបដិសេធ ។ ពាក្យថា “ក្នុងរូបធាតុនោះ មានឃានទិមិត្ត មិនមែនឬ ?” ជាដើម ពាក្យនោះ សម្រេចត្រឹមតែជារូបរាងសណ្ឋានប៉ុណ្ណោះ, មិនបានសម្រេចជាអាយតនៈទេ, ព្រោះហេតុដូច្នោះ ពាក្យនោះ សូម្បីបរវាទីនាំមកតាំងលទ្ធិទុកហើយ ក៏ដូចជាមិនបាននាំមកឡើយ ៕

ចប់រូបធាតុយា អាយតនកថា

## ៨.អរូបេរូបកថា សម្តែងអំពីរូបក្នុងអរូបសត្វ

ឥឡូវនេះ ឈ្មោះថា រឿងរូបក្នុងអរូបសត្វ គឺសត្វដែលមិនមានរូបបានដល់ អរូបព្រហ្ម ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិ

*របស់និកាយអន្ធកៈថា សុខុមរូបអាស្រ័យឱឡារិករូប រមែងមានសូម្បីក្នុងអរូបភព ព្រោះព្រះបាលីថា* “ **វិញ្ញាណប្បច្ចយា នាមរូបំ** = *នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ*” *ដូច្នេះ, ពាក្យសួររបស់សកវាទីថា* “***រូបរមែងមានក្នុងអរូបសត្វទាំងឡាយឬ ?***” *ដូច្នេះ សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕*

ចប់អរូបេរូបកថា

## ៩.រូបំ កម្មន្តិកថា សម្តែងអំពីពាក្យថា រូបជាកម្ម

*ឥឡូវនេះ ឈ្មោះថា រឿងរូបជាកម្ម (គឺការធ្វើ) ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហិសាសកៈ និងសមិតិយៈថា* “*កាយវិញ្ញត្តិរូប និងវចីវិញ្ញត្តិរូបនោះឯង ឈ្មោះថា កាយកម្មនិងវចីកម្ម*” *ក៏រូបនោះ មានកុសលជាសមុដ្ឋាន ទើបជាកុសល, រូបនោះ មានអកុសលជាសមុដ្ឋាន ទើបជាអកុសល ព្រោះហេតុដូច្នោះ ពាក្យសួររបស់សកវាទីថា* “***កាយកម្មដែលតាំងឡើងដោយកុសលចិត្ត ជារូប ជាកុសលឬ ?***” *ដូច្នេះ សំដៅដល់ជនទាំងនោះ, ពាក្យ*

ឆ្លើយតបដារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទបរវាទីនោះ ដោយពាក្យថា "បើរូបនោះ ជាកុសលមែន រូបនោះ ក៏គប្បីមានអារម្មណ៍បាន" ដូច្នេះ ទើបផ្ដើមពាក្យថា ***"រូបជាធម៌មានអារម្មណ៍ឬ ?"*** ជាដើម ។

ក្នុងបញ្ហានោះ ពាក្យថា "**បត្ថនា** គឺការប្រាថ្នា, **បណិធិ** គឺការតាំងចិត្ត" នេះជាវេវចនៈ គឺជាពាក្យជំនួសឈ្មោះគ្នា របស់ការចូលចិត្ត គឺចេតនានោះឯង ។ មែនពិត កាលបើនឹកដល់កុសលចេតនានុ៎ះឯង លោកហៅថា "ការប្រាថ្នា" និងហៅថា "ការតាំងចិត្ត" ព្រោះតាំងទុកដោយអំណាចនៃការនឹកដល់ ។ ម្យ៉ាងទៀត ក្នុងបទថា ***"វេទនា សញ្ញា ចេតនា និងសទ្ធា"*** ជាដើម ***ដែលតាំងឡើងដោយកុសលចិត្ត*** ខាងមុខពាក្យថា ចេតនា គឺការចូលចិត្ត ការប្រាថ្នា ការតាំងចិត្ត រមែងមានដល់វេទនាជាដើម រមែងមិនមានដល់ចេតនាឡើយ ។ ***សួរថា*** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមិនមានចេតនា ២ ដួង រួមគ្នាជា ១ ដួងឡើយ ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបលំនាំយ៉ាងនេះ ព្រោះភាវៈនៃចេតនានុ៎ះ ជាធម្មជាតិធ្លាក់ទៅកាន់ក្រសែ ។

ពាក្យថា ***"រូបាយតនៈ"*** ជាដើម សកវាទីពោលដើម្បីសម្ដែងប្រភេទនៃធម៌ដែលបំប្រួញទុកជាវារៈដំបូងថា "រូបដែលតាំងឡើងដោយកុសលចិត្តមិនថាយ៉ាងណាទាំងអស់ ជាកុសលចិត្តឬ ?" ជាន័យប្រៀបធៀបនឹង

ពាក្យដ៏សេស, ជាសម្ដីពោលដោយវចីកម្ម, ឯពាក្យថា **“តាំងឡើងដោយអកុសលចិត្ត”** បណ្ឌិតគប្បីជ្រាបពាក្យទាំងពួង តាមវិធីការខាងដើម ដោយទំនងនៃបាលីនុ៎ះចុះ ។ ក៏ក្នុងពាក្យថា **“អសុចិ”** លោកបំណងយកទឹកសុក្កៈ ។ ការជម្រះព្រះសូត្រ មានអត្ថងាយស្រួលទាំងអស់ ៕

ចប់រូបកម្មន្តិកថា

= = = =

## ១០.ជីវិតិន្ទ្រិយកថា សម្ដែងអំពីជីវិតិន្ទ្រិយ

ឥឡូវនេះ ឈ្មោះថា រឿងជីវិតិន្ទ្រិយ ៖

ក្នុងរឿងនោះ ជនពួកណា មានការយល់ឃើញខុសថា “ឈ្មោះថាជីវិតិន្ទ្រិយជាធម៌មិនមានរូប មិនប្រកបជាមួយចិត្ត, ព្រោះហេតុដូច្នោះទើបមិនមានរូបជីវិតិន្ទ្រិយទេ” ដូច្នេះ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងសមិតិយៈ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។

ក្នុងបញ្ហាថា **“អាយុ... មិនមានដល់រូបធម៌ទាំងឡាយ”** អធិប្បាយថា បរវាទីនោះ រមែងប្រាថ្នាថា អាយុ ការតាំងនៅ ការរស់នៅ កិរិយាដែលប្រព្រឹត្តទៅ អាការដែលជាប់តគ្នា ដោយអំណាចជាគំណនៃឧបាទិន្នរូប

ខ្លះ នៃអនុបាទិន្នរូប មានដើមស្មៅ និងអុសជាដើមខ្លះ, ព្រោះហេតុដូច្នោះ ទើបឆ្លើយបដិសេធ ។ សូម្បីក្នុងបញ្ហាថា ***រមែងមាន*** ក៏យល់ព្រម ដោយហេតុនោះ ។ ក្នុងបញ្ហាថា ***"អរូបជីវិតិន្ទ្រិយមានឬ ?"*** បរវាទី ប្រាថ្នាថា ឈ្មោះថា ការដាច់តគ្នារបស់ជីវិតិន្ទ្រិយដែលមិនប្រកបដោយ ចិត្តនៃអរូបធម៌ទាំងឡាយ, ព្រោះហេតុដូច្នោះ ទើបឆ្លើយតប ។ ក្នុងបញ្ហាថា ***"អាយុរបស់រូបធម៌ទាំងឡាយ ជាអរូបជីវិតិន្ទ្រិយឬ ?"*** អធិប្បាយថា ក៏ជីវិតិន្ទ្រិយដែលជារូបធម៌ តែងមាននៅក្នុងសន្តាននៃសត្វ, តែបរវាទី ប្រាថ្នានូវអរូបជីវិតិន្ទ្រិយ ដែលជាចិត្តវិប្បយុត្តនៃសត្វទាំងពួងនោះឯង, ព្រោះហេតុដូច្នោះ ទើបឆ្លើយតប ។ សូម្បីក្នុងបញ្ហាពោលអំពី ***អ្នកចូលនិរោធសមាបត្តិ*** បរវាទីសំដៅយកអរូបជីវិតិន្ទ្រិយដែលជាចិត្តវិប្បយុត្ត នោះឯង ទើបឆ្លើយបដិសេធខ្លះ ឆ្លើយស្រួបខ្លះ ។ ចំណែកសកវាទី កាល មិនយល់ព្រមពាក្យនោះ ទើបពោលថា ***"ប្រសិនបើ"*** ជាដើម ដើម្បីចោទ ដោយពាក្យថា "បើអរូបមិនប្រព្រឹត្តទៅ រូបក៏គប្បីមាន (ប្រព្រឹត្តទៅ) បានដែរ" ។

ក្នុងបញ្ហាពោលអំពីសង្ខារក្ខន្ធ បរវាទីសំដៅយកសង្ខារក្ខន្ធមាន ***ផស្សៈ*** ជាដើម ទើបឆ្លើយបដិសេធ, តែឆ្លើយតបសំដៅយកសង្ខារក្ខន្ធ មានកាយ-កម្មជាដើម ។ លទ្ធិរបស់បរវាទីថា ធម៌ទាំងឡាយ មានកាយវិញ្ញត្តិ វចី-

វិញ្ញត្តិ សម្មាវាចា សម្មាកម្មន្តៈ និងជីវិតិន្ទ្រិយជាដើមថា "ជាធម៌ជាប់ (ទាក់ទង) ដោយសង្ខារក្ខន្ធ" ។ តែសកវាទីកាលមិនឆ្លើយតបពាក្យនោះ ទើបពោលថា ***"អ្នកចូលនិរោធមានវេទនាខន្ធ"*** ជាដើម ដើម្បីចោទថា "បើការប្រព្រឹត្តទៅនៃអរូប សូម្បីរលត់ទៅហើយសង្ខារក្ខន្ធនៅមានមែន, នាមក្ខន្ធ ៤ ក៏ត្រូវមានដែរ" ។ បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកខាងក្នុងសមាបត្តិ រមែងឆ្លើយយល់ព្រមសំដៅយកខាងដើម និងខាងចុង របស់អ្នកចូលសមាបត្តិ និងអ្នកចេញចាកសមាបត្តិ ។ សូម្បីក្នុងវារៈពោលអំពីអសញ្ញសត្ត ក៏មានន័យដូចគ្នានេះដែរ ។ មែនពិត ព្រោះលទ្ធិនោះថា "ក្នុងកាលបដិសន្ធិនៃអសញ្ញសត្តទាំងឡាយ ចិត្តកើតឡើងហើយក៏រលត់ទៅ, អរូបជីវិតិន្ទ្រិយដែលជាចិត្តវិប្បយុត្តនោះ កើតឡើងហើយក៏ប្រព្រឹត្តទៅរហូតដល់អស់អាយុ; ព្រោះហេតុដូច្នោះ កាលត្រូវសកវាទីសួរថា ***"អសញ្ញសត្តទាំងឡាយ មិនមានជីវិតិន្ទ្រិយឬ ?"*** ទើបឆ្លើយបដិសេធ ។ ត្រូវសកវាទីសួរថា "មានជីវិតិន្ទ្រិយឬ ?" ក៏ឆ្លើយតប ។ រមែងបដិសេធសូម្បីនូវវេទនាខន្ធជាដើម ដោយអំណាចនៃបវត្តិកាលរបស់អសញ្ញសត្តមែនពិត, រមែងឆ្លើយដោយអំណាចនៃបដិសន្ធិកាលរបស់អសញ្ញសត្តទាំងនោះ ។ ក៏សកវាទីកាលមិនត្រូវការពាក្យនោះ ទើប

ពោលថាជា ***"បញ្ចវោការភព"*** ជាដើម ដើម្បីចោទថា "បើក្នុងអសញ្ញសត្តទាំងនោះ មានវេទនាជាដើម សូម្បីត្រឹមតែមួយខណៈមែន, អសញ្ញសត្តនោះ ក៏រាប់ថាជាបញ្ចវោការភពដែរ" ; បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសចាកព្រះសូត្រ ។

ក្នុងបញ្ហានោះថា ***"ចិត្តមួយដួង ស្វែងរកឧប្បត្តិរលត់ទៅមួយចំណែក"*** អធិប្បាយលទ្ធិរបស់បរវាទីនោះថា ធម៌ដែលសម្បយុត្តគ្នា រមែងបែករលត់ទៅ, តែធម៌ដែលវិប្បយុត្តគ្នារមែងតាំងនៅ, ព្រោះហេតុដូច្នោះ ទើបឆ្លើយតប ។ ពាក្យសួររបស់បរវាទីថា ***"ជីវិតិន្ទ្រិយមាន ២ ឬ ?"*** ពាក្យឆ្លើយតបជារបស់សកវាទី ។ មែនពិត រូបជីវិតិន្ទ្រិយ និងអរូបជីវិតិន្ទ្រិយមាន, ទើបលោកពោលថា "សត្វរមែងរស់នៅ ដោយជីវិតិន្ទ្រិយទាំង ២ នុ៎ះឯង, រមែងស្លាប់ ព្រោះការរលត់ទៅនៃជីវិតិន្ទ្រិយទាំង ២ នោះដែរ" ។ ក៏ក្នុងខណៈចុតិ សូម្បីជីវិតិន្ទ្រិយទាំង ២ រមែងរលត់ព្រមគ្នាមែនពិត ៕

## ចប់ជីវិតិន្ទ្រិយកថា

## ១១.កម្មហេតុកថា សម្ដែងអំពីហេតុនៃកម្ម

ឥឡូវនេះ ឈ្មោះថា រឿងហេតុនៃកម្ម ឬកម្មជាហេតុ ៖

ក្នុងរឿងនោះ លទ្ធិនៃជនពួកណាថា "ព្រះអរហន្តអង្គណា ធ្លាប់ពោលមួលបង្កាច់ព្រះអរហន្តក្នុងភពមុន ដោយកម្មណា, ព្រះអរហន្តអង្គនោះ រមែងវិនាសចាកភាពជាព្រះអរហន្ត ព្រោះកម្មនោះជាហេតុ" ដូច្នេះ ដូចលទ្ធិរបស់និកាយបុព្វសេលិយៈ និងសមិតិយៈទាំងឡាយ ពាក្យសួររបស់សកវាទីថា ***"ព្រោះហេតុនៃកម្ម"*** ដូច្នេះ សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេស មានន័យដូចដែលពោលទុកក្នុងបរិហានិកថានុ៎ះឯង ។

បទថា ***"ព្រោះពោលមួលបង្កាច់ព្រះអរហន្តទាំងឡាយ"*** សេចក្ដីថា ភាពជាព្រះអរហន្តនេះ រមែងវិនាស ព្រោះហេតុនៃកម្មណា, បរវាទីពោលដើម្បីឲ្យយល់ព្រមនូវកម្មនោះ ។ លំដាប់នោះ សកវាទីញ៉ាំងបរវាទីឲ្យយល់ព្រមនូវក្រុមនោះ ហើយទើបពោលថា ***"មិនថានរណាដែលពោលមួលបង្កាច់ព្រះអរហន្តទេ"*** ជាដើម ដើម្បីចោទដោយពាក្យថា ***"បើជនពួកណាគប្បីជាអ្នកពោលមួលបង្កាច់ព្រះអរហន្តដោយកម្មពួកណា យ៉ាងនេះមែន, ជនទាំងអស់នោះ គប្បីសម្រេចជាព្រះអរហន្តបានឬ ?"*** ដូច្នេះ

បរវាទីកាលមិនឃើញនិយាម ក្នុងការសម្រេចភាពជាព្រះអរហន្ត ដោយកម្មនោះ ទើបឆ្លើយបដិសេធ ៕

ចប់អដ្ឋកថាកម្មហេតុកថា

**រួមកថាដែលមានក្នុងវគ្គនេះ គឺ**

១.ឆគតិកថា, ២.អន្តរាភវកថា, ៣.កាមគុណកថា, ៤.កាមកថា, ៥.រូបធាតុកថា, ៦.អរូបធាតុកថា, ៧.រូបធាតុយា អាយតនកថា, ៨.អរូបេ្ប-រូបកថា, ៩.រូបំកម្មន្តិកថា ១០.ជីវិតិន្ទ្រិយកថា, ១១.កម្មហេតុកថា ។

**ចប់វគ្គទី ៨**

## វគ្គទី ៩

## ១.អានិសង្សកថា សម្តែងអំពីអានិសង្ស

ឥឡូវនេះ ឈ្មោះថា រឿងអានិសង្ស ៖

ក្នុងរឿងនោះ ការឆ្លើយបញ្ហា គឺការគូសបញ្ជាក់ក្នុងលទ្ធិរបស់សកវាទីថា "ការលះសំយោជនៈ រមែងមានដល់អ្នកឃើញសង្ខារទាំងឡាយ ដោយភាពជាទោស និងឃើញព្រះនិព្វានដោយភាពជាអានិសង្ស" ដូច្នេះ ក៏ជនពួកណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា

ការលះសំយោជនៈ រមែងមានដល់អ្នកឃើញព្រះនិព្វាន ដោយសេចក្ដីជាអានិសង្សប៉ុណ្ណោះ ព្រោះកាន់យកវាទៈរបស់សកវាទីត្រឹមតែ ១ ខ ក្នុងវាទៈ ២ ខនោះ ពាក្យសួររបស់សកវាទី សំដៅយកជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា ***“បុគ្គលមនសិការនូវសង្ខារទាំងឡាយ”*** ជាដើម ដល់បរវាទីនោះ ដើម្បីសម្ដែងវិភាគវាទៈរបស់សកវាទីនោះ លោកកាន់យកហើយសូម្បីនូវភាពជាទោសក្នុង ***សង្ខារទាំងឡាយ*** ក៏លោកគប្បីឃើញដោយពិត ។

ក្នុងបញ្ហាថា ***“បុគ្គលមនសិការនូវសង្ខារទាំងឡាយដោយភាពជារបស់មិនទៀងផង, ជាអ្នកឃើញអានិសង្សក្នុងព្រះនិព្វានផង”*** គប្បីជ្រាបអធិប្បាយដូចតទៅនេះថា ៖

លទ្ធិរបស់បរវាទីទាំងនោះថា ការលះសំយោជនៈ រមែងមានដល់អ្នកឃើញអានិសង្សក្នុងព្រះនិព្វានដូច្នេះ; ទើបត្រូវសកវាទីសួរថា ***“បុគ្គលមនសិការនូវសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀង លះសំយោជនៈបានមិនមែនឬ ?”*** បរវាទីឆ្លើយតបថា ***“មែន”***; ដោយពាក្យនោះ ទើបសកវាទីពោលថា ***“បុគ្គលមនសិការនូវសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀងផង, ជាអ្នកឃើញអានិសង្សក្នុងព្រះនិព្វានផង”*** ដូច្នេះ ពាក្យនេះលោកឆ្លើយតបឬ ? លំដាប់នោះ ទើបបរវាទីឆ្លើយបដិសេធ ព្រោះ

សំដៅយកខណៈចិត្តតែមួយ, ត្រូវសកវាទីសួរគ្រាទី ២ ក៏លោកឆ្លើយតប ដោយអំណាចនៃចិត្តផ្សេងៗ ។ ក៏សកវាទីញាំញីបំណងរបស់បរវាទីនោះហើយ ទើបសួរថា ***“ជាការប្រជុំនៃផស្សៈ ២ យ៉ាង នៃចិត្ត ២ យ៉ាងឬ ?”*** ព្រោះភាវៈនៃបុគ្គលដែលមនសិការសង្ខារ ដោយភាពជារបស់មិនទៀងជាអ្នកមានប្រក្រតីឃើញអានិសង្សក្នុងព្រះនិព្វាន ព្រោះបរវាទីឆ្លើយតបដោយការរួមតែម្យ៉ាងជាមួយគ្នាដូច្នេះ; បរវាទីកាលមិនឃើញការប្រជុំនៃផស្សៈ ២ យ៉ាងជាដើម ទើបឆ្លើយបដិសេធ ។ សូម្បីក្នុងបញ្ហាមានពាក្យថា ***“ដោយភាពជាទុក្ខ”*** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ក៏ក្នុងសេចក្ដីនេះ មានការសន្និដ្ឋានយ៉ាងណា ? គឺរមែងលះសំយោជនៈទាំងឡាយ ព្រោះមនសិការសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀងជាដើម, ឬរមែងលះសំយោជនៈរបស់អ្នកឃើញព្រះនិព្វាន, ឬក៏រមែងលះសំយោជនៈរបស់អ្នកធ្វើសូម្បីទាំងពីររួមគ្នា ។ បើថា ការលះសំយោជនៈ ព្រោះមនសិការសង្ខារដោយភាពជារបស់មិនទៀងជាដើមមុនមែន, ការលះនេះ ក៏គប្បីមានដោយវិបស្សនាចិត្តប៉ុណ្ណោះ, បើការលះសំយោជនៈដោយអំណាចនៃការតាមរឭក របស់អ្នកមានប្រក្រតីឃើញអានិសង្សមែន, ការលះនោះ ក៏គប្បីមានដោយវិបស្សនាចិត្តរបស់អ្នកឃើញនូវអានិសង្សក្នុងព្រះនិព្វានទុំះឯង, បើថា ការលះសំយោជនៈ គប្បី

មានដល់អ្នកធ្វើសូម្បីទាំងពីររួមគ្នាមែន, ការប្រជុំនៃជស្សៈ ៧ ដួងជាដើម ក៏គប្បីមាន សូម្បីយ៉ាងណាក្តី, កិច្ចរបស់អ្នកមនសិការសង្ខារដោយភាពជារបស់មិនទៀងជាដើម រមែងដល់ការសម្រេចក្នុងខណៈនៃមគ្គ ព្រោះសកវាទីរមែងត្រូវការឃើញអានិសង្សក្នុងព្រះនិព្វាន ដោយសភាពនៃធម៌ដែលកើតឡើងរបស់អ្នកប្រកាន់សង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀងជាដើម ដោយប្រចក្សនោះឯងទៀត ព្រោះហេតុណា, ព្រោះហេតុនោះបណ្ឌិតគប្បីជ្រាបថា "ការលះសំយោជនៈទាំងឡាយ របស់អ្នកឃើញអានិសង្សក្នុងព្រះនិព្វាន ដោយអំណាចនៃការឲ្យសម្រេចកិច្ចក្នុងអរិយមគ្គផង ដោយអំណាចនៃការប្រព្រឹត្តទៅ ព្រោះធ្វើឲ្យជាអារម្មណ៍ ដោយមនសិការសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀងជាដើមផង" ។ ព្រះសូត្រថា "ជាអ្នកពិចារណាឃើញថាជាសុខ... ក្នុងព្រះនិព្វាន" ជាដើម រមែងឲ្យសម្រេចក្នុងសភាពនៃធម៌ មានការតាមឃើញនូវសេចក្តីសុខក្នុងព្រះនិព្វាន មិនមែនឲ្យសម្រេចកិច្ចក្នុងការលះសំយោជនៈទាំងឡាយ ដោយត្រឹមតែការឃើញអានិសង្សក្នុងព្រះនិព្វានប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ ព្រះសូត្រនេះសូម្បីបរវាទីនាំមកអាងហើយ ក៏មិនជាយ៉ាងនោះឡើយ ៕

## ចប់អានិសង្សកថា

## ២.អមតារម្មណកថា

## សម្ដែងអំពីសំយោជនៈមានអមតៈជាអារម្មណ៍

*ឥឡូវនេះ ឈ្មោះថា រឿងសំយោជនៈមានអមតៈជាអារម្មណ៍ បានដល់អមតៈ គឺព្រះនិព្វាន ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈថា សំយោជនៈមានអមតៈជាអារម្មណ៍ ព្រោះកាន់យកអត្ថ ដោយមិនប្រាជ្ញានូវការពិចារណានៃបទទាំងឡាយថា* ***“បុថុជ្ជនដឹងព្រះនិព្វាន”*** *ជាដើម, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលនឹងបរវាទីថា* ***“អមតៈជាអារម្មណ៍របស់សំយោជនៈ”*** *ជាដើម ដើម្បីចោទថា បើសំយោជនៈមានអមតៈជាអារម្មណ៍បានមែន, អមតៈ ក៏ត្រូវប្រាកដថា ជាអារម្មណ៍របស់សំយោជនៈបាន, បរវាទីបដិសេធពាក្យទាំងពួង ព្រោះខ្លាចខុសអំពីព្រះសូត្រ; បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងវារៈទាំងពួង ដោយឧបាយនេះចុះ ។ ក៏ព្រះសូត្រដែលបរវាទីលើកមកថា* ***“បុថុជ្ជន... សម្គាល់ដឹងព្រះនិព្វាន ដោយភាពជាព្រះនិព្វាន”*** *នេះ លោកពោល*

សំដៅយកនិព្វានក្នុងទិដ្ឋធម៌ គឺក្នុងភព (បច្ចុប្បន្ន) នេះ, ព្រោះហេតុដូច្នោះ សេចក្តីនេះ ទើបមិនសម្រេចប្រយោជន៍ឡើយ ៕

ចប់អមតារម្មណកថា

# ៣.រូបំ សារម្មណន្តិកថា

## សម្តែងអំពីរូបជាធម៌មានអារម្មណ៍

ឥឡូវនេះ ឈ្មោះថា រឿងរូបជាធម៌មានអារម្មណ៍ ៖

ក្នុងរឿងនោះ ពោលដោយអំណាចនៃអារម្មណប្បច្ច័យថា រូបឈ្មោះថា មានអារម្មណ៍ ព្រោះអត្ថថា មានបច្ច័យ, តែរូបនោះ ធ្វើធម៌ដទៃឲ្យជាអារម្មណ៍មិនបាន គឺសំដៅសេចក្តីថា ដឹងអារម្មណ៍មិនបាន ។ ក៏លទ្ធិនៃជនទាំងឡាយណា ដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា "រូបមានអារម្មណ៍បានដោយមិនប្លែកគ្នា" ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ដើម្បីសម្តែងការវិភាគអារម្មណ៍ ២ យ៉ាង ***គឺឱលុព្ភារម្មណ៍*** បានដល់អារម្មណ៍ដែលជាគ្រឿងតោង និង ***បច្ចយារម្មណ៍*** បានដល់អារម្មណ៍គឺជាបច្ច័យ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយទំនងនៃព្រះបាលីនុ៎ះចុះ ។

*ក្នុងបញ្ហាថា* ***“មិនគប្បីពោលទេ”*** *ជាដើម ពាក្យឆ្លើយតបជារបស់សកវាទីសំដៅយកឱលុព្ភារម្មណ៍ គឺអារម្មណ៍ដែលជាគ្រឿងគោង ។ សូម្បីក្នុងបញ្ហាទី ២ សកវាទីនោះឯង ឆ្លើយតបសំដៅយកអារម្មណ៍ គឺជាបច្ច័យ; ព្រោះហេតុដូច្នោះ ក្នុងទីនេះ ភាវៈនៃរូបនោះ ជាធម្មជាតិមានអារម្មណ៍សម្រេចហើយ ព្រោះអត្ថថា មានបច្ច័យប៉ុណ្ណោះ មិនមែនមានអារម្មណ៍ដែលជាគ្រឿងគោង ដោយប្រការដូច្នេះឡើយ ៕*

ចប់រូបំសារម្មណន្តិកថា

........................

## ៩.អនុសយា អនារម្មណាតិកថា

## សម្តែងអំពីអនុស័យជាធម៌មិនមានអារម្មណ៍

*ឥឡូវនេះ ឈ្មោះថា រឿងអនុស័យជាធម៌មិនមានអារម្មណ៍ ៖*

*ក្នុងរឿងនោះ ជនឯណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈ និកាយឯកច្ចៈ និងនិកាយឧត្តរាបថកៈថា “ឈ្មោះថាអនុស័យទាំងឡាយ គឺកិលេសដែលដេកត្រាំនៅក្នុងសន្តាន មិនប្រកបជាមួយចិត្តជាអហេតុកៈ ជាអព្យាក្រឹត ដោយហេតុនោះឯង គឺដោយហេតុដែលមិនប្រកបជាមួយចិត្តជាដើម ទើបជាអនារម្មណ៍” ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***“អនុស័យ”*** *ជាដើម ព្រោះសំដៅដល់ជនទាំងនោះ, ពាក្យ*

ឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលនឹងបរវាទីថា **"អនុស័យជារូប"** ជាដើម ដើម្បីចោទថា "ធម្មតាអនុស័យមិនមានអារម្មណ៍ទេ អនុស័យនោះ ក៏នឹងគប្បីជាយ៉ាងនេះ គឺគប្បីដូចរូប" ជាដើម ។ ពាក្យថា **"កាមរាគៈ"** ជាដើម លោកសម្តែងដោយភាពជាកាមរាគានុស័យ មិនមែនដោយសេចក្តីដទៃឡើយ ។ ក្នុងបញ្ហាថា **"សង្ខារក្ខន្ធជាធម៌មិនមានអារម្មណ៍ឬ ?"** បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកសង្ខារក្ខន្ធដែលសម្បយុត្តជាមួយចិត្ត; រមែងឆ្លើយតប ព្រោះសំដៅយកអនុស័យ ជីវិតិន្ទ្រិយ និងរូប មានកាយកម្មជាដើមថា ជាធម៌ដែលរាប់បញ្ចូលដោយសង្ខារក្ខន្ធ ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងវារៈទាំងពួង ដោយឧបាយនេះឯង ។

ម្យ៉ាងទៀត ក្នុងបញ្ហាថាជា **"អ្នកមានអនុស័យឬ ?"** អធិប្បាយថា បុថុជ្ជន ឈ្មោះថា ជាអ្នកនៅមានអនុស័យ ព្រោះភាវៈដែលគេនៅមិនទាន់បានលះ, តែសភាពនៃការប្រព្រឹត្តទៅរបស់អនុស័យទាំងឡាយ គឺការកើតរលត់ ព្រះមានព្រះភាគទ្រង់មិនបានបញ្ញត្តទុកឡើយ; **មែនពិត អនុស័យណា ដែលបុគ្គលណាលះមិនទាន់បាន, អនុស័យនោះ មិនរាប់ថា ជាអតីត អនាគត និងបច្ចុប្បន្នទេ; ក៏ប៉ុន្តែ អនុស័យនោះ ឈ្មោះថា ជាកិលេសដែលគប្បីលះដោយមគ្គ ព្រោះភាវៈជាអ្នកនៅលះមិនទាន់បានទុំះឯង ទើបលោកពោលថា "ជារបស់មាន"** ។ មួយវិញទៀត នរណាមួយ មិន

គប្បីពោលថា ធម៌ឈ្មោះនេះ ជាអារម្មណ៍របស់អនុស័យយ៉ាងនេះ គឺលោកសំដៅយកចំពោះខណៈចិត្តដែលជាកុសល ឬអព្យាក្រឹត ដែលអនុស័យមិនបានកើតសម្បយុត្តជាមួយ, ព្រោះហេតុដូច្នោះ អារម្មណ៍របស់អនុស័យនោះ ទើបលោកបដិសេធហើយ ។ សេចក្ដីពិត អារម្មណ៍នោះៗ រមែងមិនមានដល់អនុស័យតែម្យ៉ាងប៉ុណ្ណោះទេ, អារម្មណ៍នោះៗ រមែងមិនមានដល់កិលេសទាំងឡាយ សូម្បីមានរាគៈជាដើម ក៏ដូចគ្នា, ត្រង់នេះ លោកសំដៅយកខណៈដែលកិលេសទាំងនោះ មិនទាន់កើតសម្បយុត្តជាមួយនឹងចិត្ត, ព្រោះហេតុដូច្នោះ សេចក្ដីនេះ ទើបមិនសម្រេចនូវភាវៈនៃអនុស័យទាំងឡាយ ជាធម៌មានអារម្មណ៍ ៕

## ចប់អនុសយា អនារម្មណាតិកថា

### កំណត់ហេតុ ៖

ការវិនិច្ឆ័យអនុសយកថា ក្នុងគម្ពីរកថាវត្ថុនេះ លោកសំដៅយកកិលេស ៧ យ៉ាង មានកាមរាគានុស័យជាដើម ដែលមិនទាន់បានលះដោយអរិយមគ្គ អនុសយក្កិលេសនេះឯង ខណៈដែលចិត្តជាកុសលក្ដី ជាអព្យាក្រឹតក្ដី លោកហៅថា ជាចិត្តវិប្បយុត្ត ព្រោះមិនប្រកបនឹងចិត្តក្នុងខណៈនោះ ហៅថា អហេតុកៈ ព្រោះមិនមានហេតុប្រកបក្នុងខណៈនោះ

ហៅថា ជាអព្យាក្រឹត ព្រោះព្រះមានព្រះភាគទ្រង់មិនព្យាករថា "ជាបុណ្យ ឬជាបាបក្នុងខណៈនោះ ដោយហេតុទាំង ៣ នេះឯង ទើបលោក ហៅថា ជាអនារម្មណ៍ គឺជាធម៌មិនមានអារម្មណ៍" ។

ចំណែកន័យរបស់អដ្ឋកថា អនុសយយមកៈខាងមុខ... លោកសម្តែងទុកដូច្នេះ ៖

**អនុសយាតិ កេនដ្ឋេន អនុសយា ។ អនុសយនដ្ឋេន ។ល។**

***សួរថា*** អនុស័យទាំងឡាយ ឈ្មោះថា ***អនុស័យ*** ព្រោះអត្ថថាដូចម្តេច ?

ឆ្លើយថា ព្រោះអត្ថថា ដេកត្រាំ ។

***សួរថា*** ឈ្មោះអត្ថថា ដេកត្រាំនេះ តើដូចម្តេចដែរ ?

ឆ្លើយថា ឈ្មោះអត្ថថា ដេកត្រាំនេះ មានការលះមិនបាន ជាអត្ថ អធិប្បាយថា អនុស័យទាំងនោះ ឈ្មោះថា រមែងដេកត្រាំនៅក្នុងសន្តាននៃសត្វ ព្រោះអត្ថថា នៅលះមិនទាន់បាន ព្រោះហេតុដូច្នោះ ទើបលោកហៅថា ***អនុស័យ*** ។

ពាក្យថា ***"រមែងដេកត្រាំ"*** អធិប្បាយថា អនុស័យទាំងនោះ មានហេតុដ៏សមគួរហើយ ទើបកើតឡើង ។ មា្យ៉ងទៀត អធិប្បាយថា បើអាការ គឺការលះមិនទាន់បាននៅមាន ព្រោះអនុស័យទាំងឡាយនៅមាន ។

ក្នុងទីនេះ លោកឆ្លើយតបថា "អនុស័យ គឺអាការដែលលះមិនទាន់បាន" ។ ម្យ៉ាងទៀត ពាក្យថា "**អនុស័យ**" លោកហៅកិលេសដែលមានកម្លាំង ព្រោះអត្ថថា លះមិនបាន ។ អធិប្បាយថា អនុស័យនោះ ជាចិត្តសម្បយុត្ត ជាសារម្មណៈ ជាសហេតុកៈ ព្រោះអត្ថថា មានបច្ច័យជាអកុសលតែម្យ៉ាង ទាំងជាអតីតខ្លះ ជាអនាគតខ្លះ ជាបច្ចុប្បន្នខ្លះ ព្រោះហេតុដូច្នោះ កាលពោលថា "អនុស័យរមែងកើតឡើង" ដូច្នេះ រមែងគួរ ។ ក្នុងទីនេះ លោកកាន់យកពាក្យដែលពោលមកនេះ ជាប្រមាណ ។ ក្នុងគម្ពីរយមកៈនេះ មានការធានាសេចក្ដីដល់គម្ពីរកថាវត្ថុ និងគម្ពីរដទៃៗទៀតដែរ ដូចពោលថា ៖

ក្នុងគម្ពីរអភិធម្មកថាវត្ថុ លោកបដិសេធវាទៈទាំងពួងថា អនុស័យទាំងឡាយជាអព្យាក្រឹត ជាអហេតុកៈ និងជាចិត្តវិប្បយុត្ត សំដៅដល់ខណៈនោះ ចិត្តកំពុងនៅជាកុសល ឬអព្យាក្រឹត ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គ លោកធ្វើពាក្យសួរថា "បុគ្គលរមែងលះកិលេសទាំងឡាយ សូម្បីជាបច្ចុប្បន្នឬ ?" ដូច្នេះ ហើយឆ្លើយថា "បុគ្គលឈ្មោះថា រមែងលះអនុស័យដែលមានកម្លាំង ព្រោះភាវៈនៃអនុស័យទាំងឡាយ ជាសភាវៈមានរហូតដល់បច្ចុប្បន្ន" ។

ក្នុងធម្មសង្គហៈ ត្រង់ការចែកបទមោហៈ លោកពោលការកើតឡើងនៃអវិជ្ជានុស័យ និងអកុសលចិត្តថា "***អវិជ្ជានុស័យ បានដល់ អនុស័យ***

*គឺអវិជ្ជា, អវិជ្ជាបរិយុដ្ឋាន ធានដល់ បរិយុដ្ឋាន គឺអវិជ្ជា, អវិជ្ជាលង្គី ធានដល់ គន្លឹះ គឺអវិជ្ជា, អកុសលមូល គឺមោហៈនេះ មានក្នុងសម័យណា សម័យនោះ ក៏មានមោហៈ”* ។

ក្នុង **អនុសយយមកៈ** ទុំះឯង ត្រង់ឧប្បជ្ជវារៈ គឺវារៈពោលដោយការកើតឡើង វារៈឯណាមួយនៃមហាវារៈ ៧ លោកពោលពាក្យជាដើមទុកថា “កាមរាគានុស័យ រមែងកើតដល់បុគ្គលណា បដិឃានុស័យ ក៏រមែងកើតដល់បុគ្គលនោះមែនទេ ?” ដូច្នេះ ព្រោះហេតុដូច្នោះ ពាក្យណា ដែលលោកពោលហើយថា “រមែងដេកត្រាំ ពាក្យនោះ អធិប្បាយថា អនុស័យទាំងឡាយនោះ មានហេតុដ៏សមគួរហើយ រមែងកើតឡើង” ដូច្នេះ បណ្ឌិតគប្បីជ្រាបថា ពាក្យនោះ លោកពោលល្អហើយ ដោយបែបផែននេះជាប្រមាណ ។ សូម្បីពាក្យណាដែលលោកពោលទុកជាដើមថា “អនុស័យជាចិត្តសម្បយុត្ត ជាសារម្មណ៍” ដូច្នេះ សូម្បីពាក្យនោះ ក៏ឈ្មោះថាលោកពោលទុកល្អហើយដែរ ។ ពាក្យថា ក៏ឈ្មោះថា “អនុស័យជារបស់សម្រេចហើយ ជាចិត្តសម្បយុត្ត ជាអកុសលធម៌” ដូច្នេះ គប្បីដល់សេចក្ដីចុងក្រោយក្នុងទីនេះឯង ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យទាំងឡាយ មានកាមរាគា-

នុស័យជាដើមថា ៖

កាមរាគៈនុ៎ះឯង ឈ្មោះថា ***អនុស័យ*** ព្រោះអត្ថថា នៅលះមិនទាន់បាន ព្រោះហេតុដូច្នោះ ទើបឈ្មោះថា កាមរាគានុស័យ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ តទៅលោកបានបញ្ជាក់បន្ថែមទៅទៀតថា "អនុស័យកើតទីណាខ្លះ ?" ដូចពាក្យថា ៖

ឥឡូវនេះ ដើម្បីប្រកាសនូវទីជាកន្លែងកើតឡើងនៃអនុស័យទាំងឡាយនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **"តត្ថ កាមរាគានុសយោ អនុសេតិ** = កាមរាគានុស័យ រមែងដេកត្រាំក្នុងកាមធាតុនោះ" ជាដើម, សូមលោកអ្នកឆ្លៀវឆ្លាសស្រាវជ្រាវក្នុងអនុសយយមកៈនុ៎ះចុះ ។

សរុបសេចក្ដីមក ពាក្យថា អនុស័យដែលពោលទុកក្នុងគម្ពីរកថាវត្ថុនោះ មានបំណងយកតែម្យ៉ាង, ដែលពោលទុកក្នុងគម្ពីរអនុសយយមកៈនោះ បំណងយកតែម្យ៉ាង, ន័យទាំងពីរនេះ កាលពិចារណាហើយ ក៏ត្រឹមត្រូវដូចគ្នាដែរ ៕

---

# ៥.ញាណំ អនារម្មណន្តិកថា

## សម្តែងអំពីញាណមិនមានអារម្មណ៍

*ឥឡូវនេះ ឈ្មោះថា រឿងញាណមិនមានអារម្មណ៍ ៖*

*ក្នុងរឿងនោះ ព្រះអរហន្តដែលបរិបូណ៌ដោយចក្ខុវិញ្ញាណ គឺចក្ខុ-វិញ្ញាណចិត្តរបស់លោកកំពុងកើត គេហៅថា មានញាណ គឺមានបញ្ញា, តែអារម្មណ៍របស់ញាណក្នុងខណៈដែលចក្ខុវិញ្ញាណចិត្តកំពុងកើតនោះ មិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ លទ្ធិនៃជនទាំងឡាយណា ដូចលទ្ធិរបស់និកាយអន្ធកៈថា "ញាណរបស់ព្រះអរហន្ត ជាធម៌មិនមានអារម្មណ៍" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងរឿងអនុស័យនុ៎ះចុះ ៕*

ចប់ញាណំអនារម្មណន្តិកថា

\- - - - - - - - - - - -

# ៦.អតីតានាគតារម្មណកថា

## សម្តែងអំពីចិត្តដែលមានអតីត និងអនាគតជាអារម្មណ៍

*ឥឡូវនេះ ឈ្មោះថា រឿងចិត្តដែលមានអតីត និងអនាគតជាអារម្មណ៍ ៖*

*ក្នុងរឿងនោះ អតីត និងអនាគត ឈ្មោះថា មិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា "តទារម្មណចិត្តនោះ មិនគប្បីមានអារម្មណ៍ ព្រោះភាវៈនៃអារម្មណ៍មិនមាន ព្រោះហេតុនោះ ទើបពោលចិត្តដែលមានអតីត និងអនាគត ជាអារម្មណ៍នោះថា ជាចិត្តដែលមិនមានអារម្មណ៍" ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***"ចិត្តដែលមានអតីត និងអនាគត ជាអារម្មណ៍"*** *ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីកាន់យកតាមព្រះបាលីនុ៎ះចុះ ៕*

ចប់អតីតានាគតារម្មណកថា

..............................

## ៧.ទិតក្កានុបត្តិកថា

### សម្តែងអំពីចិត្តប្រកបជាមួយនឹងវិតក្កៈ

ឥឡូវនេះ ឈ្មោះថា រឿងចិត្តប្រកបជាមួយនឹងវិតក្កៈ គឺសំដៅសេចក្តីថា ចិត្តធ្លាក់ទៅតាមវិតក្កៈ ឬហៅថា ចិត្តកើតឡើងតាមវិតក្កៈ ៖

ក្នុងរឿងនោះ ឈ្មោះថា ចិត្តដែលប្រកបជាមួយនឹងវិតក្កៈ មាន ២ យ៉ាង គឺដោយអារម្មណ៍ម្យ៉ាង និងដោយសម្បយោគម្យ៉ាង; ក្នុងពីរយ៉ាងនោះ ចិត្តទាំងអស់ ឈ្មោះថា ជាធម៌ប្រកបជាមួយវិតក្កៈ ព្រោះមិនមានការកំណត់ពិតប្រាកដថា “ឈ្មោះថា ចិត្តដូចឯណោះ មានអារម្មណ៍ប្រព្រឹត្តទៅជាមួយវិតក្កៈ” ដូច្នេះ, តែចិត្តទាំងអស់នោះ ឈ្មោះថា មិនប្រកបជាមួយនឹងវិតក្កៈ ព្រោះសភាពនៃចិត្តដែលវិប្បយុត្តជាមួយវិតក្កៈ រមែងមាន, ជនណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈទាំងឡាយថា “ចិត្តទាំងពួង ប្រកបជាមួយវិតក្កៈ ដោយមិនបែកគ្នាឡើយ ព្រោះមិនធ្វើការវិភាគអត្ថនេះ ដោយប្រការយ៉ាងនេះ” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីកាន់យកតាមព្រះបាលីនុ៎ះចុះ ៕

ចប់វិតក្កានុបត្តិកថា

# ៨.ទិតក្កវិប្ផារសទ្ទកថា

## សម្ដែងអំពីការផ្សាយទៅនៃវិតក្កៈជាសំឡេង

*ឥឡូវនេះ ឈ្មោះថា រឿងការផ្សាយទៅនៃវិតក្កៈជាសំឡេង ៖*

*ក្នុងរឿងនោះ ជនពួកណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយថា "ការផ្សាយចេញទៅនៃវិតក្កៈនោះឯងជាសំឡេង ព្រោះព្រះមានព្រះភាគត្រាស់ទុកថា '* ***វិតក្ក និងវិចារៈ ជាវចី-សង្ខារ"*** *ដូច្នេះ ព្រោះហេតុណា, ព្រោះហេតុនោះ រាល់ពេលដែលបុគ្គលត្រិះរិះ ពិចារណា ដោយហោចទៅ សូម្បីក្នុងវេលាប្រព្រឹត្តទៅនៃមនោធាតុដូច្នោះ ពាក្យសួររបស់សកវាទីថា "* ***រាល់ពេលដែលត្រិះរិះ"*** *ជាដើម សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលនឹងបរវាទីនោះថា "* ***រាល់ពេលដែលពាល់ត្រូវ"*** *ជាដើម ដើម្បីចោទថា "ប្រសិនបើ ហេតុត្រឹមតែការផ្សាយចេញទៅនៃវិតក្កៈជាសំឡេងមែន, សូម្បីការផ្សាយចេញទៅនៃផស្សៈជាដើម ក៏គប្បីជាសំឡេងដែរ" ដូច្នេះ; បរវាទី កាលមិនឃើញសេចក្ដីប្លែកគ្នារបស់ព្រះសូត្រដូច្នោះ ទើបឆ្លើយបដិសេធ ។ ពាក្យថា "* ***ការផ្សាយចេញទៅនៃវិតក្កៈ ជាសំឡេងដែលគប្បីដឹងបានដោយសោតវិញ្ញាណ"*** *សេចក្ដីថា សកវាទីធ្វើបញ្ហាសួរថា "ហេតុត្រឹមតែការផ្សាយចេញទៅនៃវិតក្កៈនុ៎ះឯងជាសំឡេង មិនធ្វើបញ្ហាសួរដល់សំឡេងដែលកើតឡើង ព្រោះការផ្សាយ*

ចេញទៅនៃវិតក្កៈរបស់អ្នកវង្វេង ឬភ្លេចសតិ” ដូច្នេះ, ទើបបរវាទីឆ្លើយបដិសេធ ។ ព្រោះលទ្ធិនោះឯង ទើបសកវាទីសម្តែង ពាក្យពេចន៍នេះថា “ការផ្សាយទៅនៃវិតក្កៈ មិនមែនជាសំឡេងដែលគប្បីដឹង បានដោយសោត-វិញ្ញាណ... មិនមែនឬ ?” ដូច្នេះ មែនពិត គេពោលនូវហេតុត្រឹមតែការផ្សាយចេញទៅនៃវិតក្កៈប៉ុណ្ណោះថា ជាសំឡេង, តែសំឡេងនោះ បុគ្គលមិនគប្បីដឹងបានដោយសោតវិញ្ញាណឡើយ; តែបរវាទីពោលថា សំឡេងនោះគប្បីដឹងបានដោយសោតវិញ្ញាណនោះឯង ព្រោះព្រះបាលីថា “បុគ្គលស្តាប់សំឡេងដែលផ្សាយចេញទៅនៃវិតក្កៈហើយ គេរមែងសន្និដ្ឋាន គឺរមែងដឹងដល់ចិត្តរបស់អ្នកដទៃបាន” [១២] ៕

ចប់វិតក្កវិប្ផារសទ្ទកថា

═══ ═══ ═══

## ៩.នយថាចិត្តស្សវាចាតិកថា

## សម្តែងអំពីអ្នកមិនមានការគិតយ៉ាងណា ក៏មានវាចាបាន [១៣]

ឥឡូវនេះ ឈ្មោះថា រឿងអ្នកមិនមានការគិតយ៉ាងណា ក៏មានវាចាបាន គឺសំដៅសេចក្តីថា វាចាមិនប្រព្រឹត្តទៅតាមចិត្ត ៖

ក្នុងរឿងនោះ ជនណាមានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយ

---

[១២] ទី. បា. ។

[១៣] មួយ៉ាងទៀត ប្រែថា រឿងវាចាមិនប្រព្រឹត្តទៅតាមចិត្ត ។

បុព្វសេលិយៈទាំងឡាយថា “បុគ្គលខ្លះគិតថា ‘យើងនឹងពោលម្យ៉ាង’ តែរមែងពោលម្យ៉ាងវិញ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបវាចាឈ្មោះថា មិនប្រព្រឹត្តទៅតាមចិត្ត មិនបណ្តោយទៅតាមចិត្ត, សូម្បីវៀរចិត្តចេញហើយ វាចាក៏រមែងប្រព្រឹត្តទៅបាន” ដូច្នេះ ពាក្យសួររបស់សកវាទីសំដៅ ដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា “បុគ្គលអ្នកមិនមានផស្សៈ” ជាដើម ដើម្បីចោទបរវាទីនោះថា “បើចិត្តដែលជាហេតុឲ្យវាចាកើតឡើងមិនមានទេ, សូម្បីធម៌ទាំងឡាយ មានផស្សៈជាដើម ក៏មិនគប្បីមានក្នុងខណៈនោះដែរ” ។

ក្នុងពាក្យទាំងឡាយ មានពាក្យថា ***“បុគ្គលមិនប្រាថ្នានឹងពោល”*** ជាដើម អធិប្បាយថា បុគ្គលគិតថា “យើងនឹងពោលពាក្យម្យ៉ាង” សូម្បីពោលនូវពាក្យម្យ៉ាងទៀត គេរមែងឈ្មោះថា ជាអ្នកប្រាថ្នានឹងពោលនោះឯង ព្រោះហេតុណា, ព្រោះហេតុនោះ ទើបបរវាទីឆ្លើយបដិសេធថា មិនគប្បីពោលយ៉ាងនេះទេ ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា ***“បុគ្គលខ្លះដែលគិតថា ‘នឹងពោលម្យ៉ាង’ ក៏ពោលចេញម្យ៉ាងទៀត... រមែងមានមិនមែនឬ ?”*** ជាដើម អធិប្បាយថា បុគ្គលណា ប្រាថ្នានឹងពោលពាក្យណាមួយ ក្នុងកាលមុន គេក៏គប្បីពោលពាក្យនោះ គឺពាក្យដែលគិតទុកអំពីដើមនោះ ក្នុងទីនេះ លោកសំដៅយកចិត្តរបស់អ្នកប្រាថ្នាដើម្បីនឹង

ពោលមានម្យ៉ាង, ចិត្តដែលជាហេតុឲ្យពោល ក៏មានម្យ៉ាង, ព្រោះហេតុដូច្នោះ ទើបឈ្មោះថា វាចាមិនប្រព្រឹត្តទៅតាមចិត្ត ព្រោះមិនដូចចិត្តដែលជាចំណែកខាងដើម ដោយហេតុនោះ ទើបឈ្មោះថា មិនត្រឹមត្រូវដោយអស់សេចក្តី, តែចិត្តណាដែលមានក្នុងកាលមុន ចិត្តនោះ មិនជាហេតុឲ្យពាក្យនិយាយកើតឡើង ក៏ទេ, លោកបដិសេធសំដៅយកសេចក្តីថា វាចានោះ មិនប្រព្រឹត្តទៅតាមចិត្តត្រឹមតែប៉ុណ្ណោះឡើយ ។ ដោយឧទាហរណ៍នេះ សូម្បីលទ្ធិបរវាទីដែលតាំងទុកហើយថា "អ្នកមិនមានសេចក្តីគិតយ៉ាងណា ក៏មានវាចាបាន គឺសំដៅសេចក្តីថា វាចាមិនប្រព្រឹត្តទៅតាមចិត្ត" ដូច្នេះ រមែងជាលទ្ធិតាំងនៅមិនបានឡើយ ៕

ចប់នយថាចិត្តស្សវាចាតិកថា

## ១០.នយថាចិត្តស្សកាយកម្មន្តិកថា

## សម្តែងអំពីអ្នកមិនមានការគិតយ៉ាងណា ក៏មានកាយកម្មបាន

ឥឡូវនេះ ឈ្មោះថា រឿងអ្នកមិនមានការគិតយ៉ាងណា ក៏មានកាយកម្មបាន គឺសំដៅសេចក្តីថា កាយកម្មមិនប្រព្រឹត្តទៅតាមចិត្ត ៖

ក្នុងរឿងនោះ ជនពួកណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈទាំងឡាយថា "បុគ្គលខ្លះ ដែលគិតថា 'នឹងទៅក្នុងទីកន្លែងមួយ' , តែក៏ទៅក្នុងទីកន្លែងមួយទៀត ព្រោះហេតុណា, ព្រោះ

ហេតុនោះ ទើបកាយកម្មមិនប្រព្រឹត្តទៅតាមចិត្ត មិនអនុរូបដល់ចិត្ត មិនស្រប តាមចិត្ត, សូម្បីវៀរចិត្តចេញ ក៏ប្រព្រឹត្តទៅបាន” ដូច្នេះ, ពាក្យសួររបស់ សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតប ជារបស់បរវាទី ។ ពាក្យ ដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងពេលមុនចុះ ៕

**ចប់នយថាចិត្តស្សកាយកម្មន្តិកថា**

## ១១.អតីតានាគតេហិ សមន្នាគតកថា [១៤]

## សម្ដែងអំពីបុគ្គលអ្នកប្រកបដោយអតីត និងអនាគត

ឥឡូវនេះ ឈ្មោះថា រឿងបុគ្គលអ្នកប្រកបដោយអតីត និង អនាគត ៖

ក្នុងរឿងនោះ បណ្ឌិតគប្បីជ្រាបបញ្ញត្តិ ២ យ៉ាង គឺសមន្នាគត-ប្បញ្ញត្តិ បានដល់ បញ្ញត្តិពាក្យថា អ្នកប្រកប និងបដិលាភប្បញ្ញត្តិ បានដល់ បញ្ញត្តិពាក្យថា ការបានចំពោះ; ក្នុងបញ្ញត្តិ ២ យ៉ាងនោះ អ្នកដល់ព្រម ដោយបច្ចុប្បន្នធម៌ លោកហៅថា សមន្នាគតៈ; ចំណែកសមាបត្តិទាំងឡាយ របស់អ្នកបានឈាន ៨ មិនប្រព្រឹត្តទៅក្នុងខណៈជាមួយគ្នា គឺចំណែកមួយ ជាអតីត, ចំណែកមួយជាអនាគត និងចំណែកមួយទៀត ជាបច្ចុប្បន្ន ក៏ពិតមែនហើយ; ប៉ុន្តែលោកក៏ហាមថា ***លាភី*** អ្នកមានប្រក្រតីបាន ព្រោះ

[១៤] ក្នុងអភិធម្មបិដក ជាអតីតានាគតបច្ចុប្បន្នកថា ។

ភាពជាអ្នកចាក់ធ្លុះហើយ ជាសភាពមិនវិនាសទៅ ។

ក្នុងបញ្ហានោះ ជនណា មិនកាន់យកការវិភាគយ៉ាងនេះ មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈទាំងឡាយថា "ឈានទាំងឡាយសូម្បីជាអតីត និងអនាគតរមែងមានដល់អ្នកបានឈាន ព្រោះហេតុណា, ព្រោះហេតុនោះ ឈានលាភីបុគ្គលនោះ រមែងជាអ្នកប្រកបដោយអតីតខ្លះ ដោយអនាគតខ្លះ" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់មែនពិត ។ម្យ៉ាងទៀត ពាក្យថា ***បុគ្គលអ្នកមានប្រក្រតីសម្លឹងវិមោក្ខ ៨ ជាដើម ជាខពិសោធន៍នៃភាពជាអ្នកបាន (លាភីបុគ្គល) គឺអ្នកបានសមាបត្តិ ៨,*** មិនមែនសាកល្បងភាពជាអ្នកប្រកបដោយអតីត និងអនាគតទេ ៕

ចប់អតីតានាគតេហិ សមន្នាគតកថា

## រួចកថាដែលមានក្នុងវគ្គនេះ គឺ

១.អានិសង្សកថា, ២.អមតារម្មណកថា, ៣.រូបំសារម្មណន្តិកថា, ៤.អនុសយា អនារម្មណាតិកថា, ៥.ញាណំអនារម្មណន្តិកថា, ៦.អតីតា-នាគតារម្មណកថា, ៧.វិតក្កានុបតិ្តកថា, ៨.វិតក្កវិប្ផារសទ្ទកថា, ៩.នយថា-ចិត្តស្សវាចាតិកថា, ១០.នយថាចិត្តស្សកាយកម្មន្តិកថា, ១១.អតីតា-នាគតេហិ សមន្នាគតកថា ។

**ចប់វគ្គទី ៩**

# វគ្គទី ១០

## ១.និរោធកថា សម្តែងអំពីការរលត់

*ឥឡូវនេះ ឈ្មោះថា រឿងការរំលត់ ៖*

*ក្នុងរឿងនោះ លទ្ធិនៃជនពួកណា ដូចលទ្ធិរបស់និកាយអន្ធកៈទាំង-ឡាយថា "ខន្ធ ៥ គឺនាមក្ខន្ធ ៤ ដែលដល់នូវការរាប់ថា ជាកិរិយា, ឬជាកុសល, ឬក៏ជាអកុសល និងរូបដែលមានចិត្តជាសមុដ្ឋាន រមែងកើតឡើង ព្រមជាមួយនឹងភង្គខណៈ គឺខណៈនៃការរលត់របស់ភវង្គចិត្តដែលដល់នូវការរាប់ថា ខន្ធដែលស្វែងរកការកើត; ព្រោះថា កាលខន្ធទាំងនោះមិនទាន់កើត ភវង្គចិត្តរលត់ទៅហើយ ការដាច់តំណរបស់សន្តតិ គប្បីមាន" ដូច្នេះ, ពាក្យសួររបស់សកវាទីថា "កាលខន្ធ ៥ ត្រូវស្វែងរកឧប្បត្តិ" ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ សូម្បីក្នុងបទទាំង ៤ ថា* **ឧប្បត្តេសិយេ** *= កាលបើខន្ធ ៥ ត្រូវស្វែងរកឧប្បត្តិនោះ ជាសត្តមី ឯកវចនៈ ចុះក្នុងអត្ថនៃសត្តមី ពហុវចនៈ, ក៏ក្នុងពាក្យនេះ លោកអធិប្បាយថា កាលខន្ធ ៥ ត្រូវស្វែងរកនូវការកើត មិនទាន់រលត់ ។ ពាក្យថា* ***"ខន្ធ ១០"*** *សកវាទីពោលដោយអំណាចនៃខន្ធ ៥ ដែលស្វែងរកការកើត និងខន្ធ ៥ ដែលជាកិរិយា សំដៅដល់ខន្ធរបស់ព្រះអរហន្តដែលមិនត្រូវស្វែងរកការកើត ។*

*ក្នុងបញ្ហាដំបូងនោះ បរវាទីឆ្លើយបដិសេធដោយសំដៅយកខន្ធទាំង*

*នោះ ឈ្មោះថា មាន ៥ ប៉ុណ្ណោះ ដោយអំណាចនៃលក្ខណៈរបស់ខន្ធ និង ដោយអំណាចនៃកិរិយា ។ ក្នុងបញ្ហាទី ២ បរវាទីឆ្លើយតបសំដៅយក សេចក្តីផ្សេងគ្នានៃខន្ធ ៥ ដោយអំណាចនៃខន្ធដែលកើតមុន និងកើតក្រោយ ព្រមទាំងដោយអំណាចនៃខន្ធដែលស្វែងរកការកើត និងខន្ធដែលជាកិរិយា គឺខន្ធ ដែលមិនស្វែងរកការកើត ។ ត្រូវសកវាទីសួរថាជា* ***"ការប្រជុំនៃផស្សៈ ២ ។ល។ នៃចិត្ត ២ ឬ ?"*** *ក៏ឆ្លើយបដិសេធ ព្រោះមិនមានខអាងក្នុងព្រះសូត្រ ។ ពាក្យថា* ***"ខន្ធ ៤ ដែលជាកិរិយា"*** *សេចក្តីថា សកវាទីកាន់យកនាមក្ខន្ធ ៤ ដែលជាកុសល ឬអកុសល ដោយវៀរចាករូប ។ ពាក្យថា* ***"ញាណដែលជាកិរិយា"*** *បានដល់ ញាណដែលមិនមានអារម្មណ៍របស់ព្រះអរហន្ត ក្នុងខណៈដែលលោកដល់ព្រមដោយចក្ខុវិញ្ញាណ-ចិត្ត ដែលបរវាទីយល់ព្រមហើយ ។ ពាក្យថា* ***"កាលខន្ធ ៥ ដែលស្វែងរកឧប្បត្តិរលត់ទៅហើយ មគ្គក៏កើតឡើងបានឬ ?"*** *ជារបស់បរវាទី, ពាក្យឆ្លើយតប ជារបស់សកវាទី, ព្រោះកាលបើខន្ធ ៥ ដែលស្វែងរកការកើតមិនទាន់រលត់ហើយ មគ្គក៏មិនទាន់កើតឡើង ។ ពាក្យសួរដោយលេសន័យរបស់បរវាទីថា* ***"អ្នកស្លាប់ហើយ ញុំាងមគ្គឱ្យកើតបាន... ឬ ?"*** *សកវាទីឆ្លើយបដិសេធថា* ***"មិនគប្បីពោលយ៉ាងនេះទេ"*** *ក៏ព្រោះថា ចាប់តាំងអំពីបដិសន្ធិ រហូតដល់ចុតិចិត្ត សត្វឈ្មោះថា មានជីវិតរស់នៅនោះឯង ៕*

ចប់និរោធកថា

...............

## ២.រូបំមគ្គោតិកថា សម្តែងអំពីរូបជាមគ្គ

*ឥឡូវនេះ ឈ្មោះថា រឿងរូបជាមគ្គ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហិសាសកៈ សមិតិយៈ និងមហាសង្ឃិកៈថា "សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ជារូប" ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***រូបរបស់បុគ្គលអ្នកមានការព្រមព្រៀងដោយមគ្គ*** *ព្រោះសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***"រូបនោះ ជាធម៌មានអារម្មណ៍"*** *ជាដើម ដើម្បីនឹងចោទបរវាទីនោះដោយពាក្យថា "បើសម្មាវាចាជាដើម ជារូប, មិនមែនជាវិរតិតាមលទ្ធិរបស់លោកទេ, មគ្គ មានសម្មាទិដ្ឋិជាដើម ជាសភាវៈដែលមានអារម្មណ៍ជាដើម យ៉ាងណា, សូម្បីរូបនោះ ក៏គប្បីមានយ៉ាងនោះ" ដូច្នេះ ។ ក្នុងបញ្ហានោះ គប្បីជ្រាបពាក្យបដិសេធ និងពាក្យយល់ព្រមតាមសមគួរដោយអំណាចនៃលទ្ធិរបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕*

ចប់រូបំមគ្គោតិកថា

## ៣.បញ្ចវិញ្ញាណសមង្គិមគ្គភាវនាកថា

## សម្តែងអំពីអ្នកព្រមព្រៀងដោយបញ្ចវិញ្ញាណចម្រើនមគ្គ

ឥឡូវនេះ ឈ្មោះថា រឿងអ្នកព្រមព្រៀងដោយបញ្ចវិញ្ញាណ ចម្រើនមគ្គ ៖

ក្នុងរឿងនោះ ជនពួកណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈទាំងឡាយថា "ការចម្រើនមគ្គមានដល់អ្នកព្រមព្រៀងដោយបញ្ចវិញ្ញាណ" ព្រោះអាស្រ័យព្រះសូត្រថា "ភិក្ខុឃើញរូបដោយចក្ខុហើយ រមែងមិនកាន់យកដោយនិមិត្តទេ" ជាដើម, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ខណៈនោះទើបសកវាទីពោលថា ***"វិញ្ញាណ ៥ មានធម៌ដែលកើតឡើងហើយ មិនមែនឬ ?"*** ជាដើម ដើម្បីចោទដោយពាក្យថា "បើការចម្រើនមគ្គ មានដល់អ្នកព្រមព្រៀងដោយវិញ្ញាណ ៥ នោះមែន, មគ្គក៏គប្បីមានគតិដូចវិញ្ញាណ ៥ ឬវិញ្ញាណ ៥ ក៏គប្បីមានគតិដូចមគ្គដែរ, តែបញ្ចវិញ្ញាណទាំងនោះ មិនមានគតិដូចមគ្គទេ ព្រោះមិនមានព្រះនិព្វានជាអារម្មណ៍ទាំងមិនមែនជាលោកុត្តរ, សូម្បីមគ្គក៏មិនមានគតិដូចបញ្ចវិញ្ញាណដែរ ព្រោះសង្គ្រោះគ្នាដោយលក្ខណៈនៃបញ្ចវិញ្ញាណទាំងនោះមិនបាន" ។

ក្នុងសេចក្តីនោះ គប្បីជ្រាបអធិប្បាយថា បើមគ្គភាវនាគប្បីមានដល់អ្នកព្រមព្រៀង ដោយបញ្ចវិញ្ញាណមែន, មគ្គដែលសម្បយុត្តដោយមនោវិញ្ញាណណា, សូម្បីមនោវិញ្ញាណនោះ ក៏គប្បីមានដល់អ្នកព្រមព្រៀងដោយបញ្ចវិញ្ញាណបាន; កាលបើមានសេចក្តីដូច្នេះ ពាក្យដែលជាលក្ខណៈ

នេះឯង លោកពោលថា ***“បញ្ចវិញ្ញាណមានធម៌ដែលកើតឡើងហើយជាវត្ថុ”*** ជាដើម, លោកមិនគប្បីពោលពាក្យនោះយ៉ាងនេះទេ, គួរតែពោលថា “វិញ្ញាណ ៦” ; តែលោកមិនពោលយ៉ាងនេះឡើយ គួរពោលតែត្រឹមពាក្យថា “បញ្ចវិញ្ញាណ” ដូច្នេះ, ព្រោះហេតុដូច្នោះ នរណាមួយមិនគប្បីពោលថា “មគ្គភាវនាមានដល់អ្នកព្រមព្រៀងដោយបញ្ចវិញ្ញាណ” ដូច្នេះទេ ។ ក្នុងសេចក្ដីនេះ មានអធិប្បាយត្រឹមតែប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ ទើបសកវាទីឲ្យបរវាទីយល់ព្រមលក្ខណៈនោះ ហើយពោលថា ***“ព្រោះហេតុនោះឯង លោកមិនគប្បីពោលថា បុគ្គលដែលមានការព្រមព្រៀងដោយវិញ្ញាណ ៥ ញ៉ាំងមគ្គឱ្យកើតបានឡើយ”*** ។

ន័យមួយទៀត វិញ្ញាណ ៥ មានធម៌ដែលកើតឡើងហើយ ជាវត្ថុ, ចំណែកមគ្គសូម្បីមិនមានវត្ថុ ក៏កើតឡើងបាន, វិញ្ញាណទាំង ៥ នោះ មានធម៌ដែលកើតឡើងហើយជាអារម្មណ៍, មគ្គមានអារម្មណ៍ដែលនរណាមួយមិនគប្បីពោលបានឡើយ, មានព្រះនិព្វានជាអារម្មណ៍ដែលនរណាមួយ មិនគប្បីពោលថា ព្រះនិព្វានកើត ថាកើតឡើង វិញ្ញាណ ៥ មានវត្ថុដែលកើតមុន, មគ្គ សូម្បីមិនមានវត្ថុ ក៏កើតបាន; វិញ្ញាណទាំង ៥ នោះ មានអារម្មណ៍កើតមុន, មគ្គមិនមានអារម្មណ៍កើតមុនទេ, វិញ្ញាណទាំង ៥ នោះ មានធម៌ខាងក្នុងជាវត្ថុ, មគ្គ សូម្បីមិនមានវត្ថុ ក៏កើតបាន; វិញ្ញាណទាំង ៥ នោះ មានធម៌ខាងក្រៅជាអារម្មណ៍ ដោយអំណាចនៃរូបជាដើម,

មគ្គ មានព្រះនិព្វានជាអារម្មណ៍; វិញ្ញាណ ៥ មានវត្ថុធម៌ដែលនៅមិនទាន់បែកធ្លាយជាវត្ថុ ព្រោះធ្វើវត្ថុដែលនៅមិនទាន់បែកធ្លាយឲ្យជាទីអាស្រ័យហើយប្រព្រឹត្តទៅ, សូម្បីមគ្គមិនមានវត្ថុ ក៏ប្រព្រឹត្តទៅបាន; វិញ្ញាណទាំង ៥ នោះ មានធម៌ដែលនៅមិនទាន់បែកធ្លាយទៅជាអារម្មណ៍ ព្រោះប្រារព្ធរូបជាដើម ដែលនៅមិនទាន់បែកធ្លាយនោះឯងហើយប្រព្រឹត្តទៅ, មគ្គមានព្រះនិព្វានជាអារម្មណ៍; វិញ្ញាណទាំង ៥ នោះ មានវត្ថុផ្សេងៗ, មគ្គមិនមានវត្ថុ ឬមានវត្ថុមួយ; វិញ្ញាណទាំង ៥ នោះ មិនសោយអារម្មណ៍របស់គ្នានឹងគ្នាទេ ព្រោះប្រព្រឹត្តទៅក្នុងអារម្មណ៍របស់ខ្លួនៗ មានរូបារម្មណ៍ជាដើម, មានវត្ថុផ្សេងៗ, មគ្គរមែងមិនធ្វើរូបារម្មណ៍ជាដើម សូម្បីត្រឹមតែមួយ ឲ្យជាអារម្មណ៍; វិញ្ញាណទាំង ៥ នោះ មិនរួមគ្នា ព្រោះធ្វើកិរិយាមនោធាតុ ឲ្យជាបុរេចារិកហើយ ទើបកើត បើមិនមានមនសិការទេ ក៏មិនកើតឡើង, មគ្គក៏មិនមានអាវជ្ជនៈឡើយ; វិញ្ញាណទាំង ៥ នោះ បរិបូណ៌ដោយការទទួលអារម្មណ៍ជាដើម ទើបកើតឡើង, មគ្គមិនលាមក គឺមិនមានភាពចុះឱនថយឡើយ; វិញ្ញាណ ទាំង ៥ នោះ រមែងកើតឡើងដោយការប្របល់គ្នានឹងគ្នា គឺសំដៅសេចក្តីថា កើតមុនខ្លះ កើតក្រោយខ្លះ មិនមានរបៀបថា តើណាកើតមុន ឬកើតក្រោយ ការកើតមុន កើតក្រោយរបស់មគ្គរួមគ្នានឹងវិញ្ញាណទាំង ៥ នោះ មិនមាន ព្រោះមគ្គកើតក្នុងខណៈនៃវិញ្ញាណទាំង ៥ នោះ មិនបាន; ក្នុងសម័យដែលវិបស្សនាញាណ

ចាស់ក្លា ក្នុងអរូបភពដែលជាទីអាស្រ័យ វិញ្ញាណ ៥ មិនកើតក្តី មគ្គក៏កើតបាន, វិញ្ញាណទាំង ៥ នោះ មិនកើតជាប់គ្នានឹងគ្នា ព្រោះមានសម្បដិច្ឆន្នចិត្តជាដើម ខណ្ឌក្នុងចន្លោះ, ការខណ្ឌក្នុងចន្លោះដោយសម្បដិច្ឆន្ន-ចិត្តជាដើមរបស់មគ្គមិនមានឡើយ ។ សូម្បីកិច្ចត្រឹមតែការសោយអារម្មណ៍ ព្រោះការធ្លាក់ទៅនៃវិញ្ញាណ ៥ ក្នុងអារម្មណ៍ណាមួយមិនមាន, កិច្ចរបស់មគ្គមានការដកចេញនូវកិលេស; ក្នុងសេចក្តីនេះ មានអធិប្បាយត្រឹមតែប៉ុណ្ណេះ, ព្រោះហេតុដូច្នោះ ទើបសកវាទីឲ្យបរវាទីយល់ព្រមនូវសេចក្តីនៃមគ្គមិនមានគតិដូចវិញ្ញាណទាំង ៥ នោះ ដោយអាការទាំងនេះ ហើយទើបពោលថា "ក៏មិនគប្បីនិយាយថា 'បុគ្គលដែលព្រមព្រៀងដោយវិញ្ញាណ ៥ ញុំាងមគ្គឲ្យកើតបាន" ដូច្នេះទេ ។

ពាក្យថា ***"ប្រារព្ធសេចក្តីសូន្យ"*** សេចក្តីថា សកវាទីសួរថា "លោកុត្តរ-មគ្គរមែងកើត ព្រោះប្រារព្ធសុញ្ញតនិព្វាន, លោកិយមគ្គរមែងកើត ព្រោះប្រារព្ធគំនរបុណ្យដែលជាសុទ្ធសង្ខារឲ្យកើតឡើង យ៉ាងណា, ចក្ខុវិញ្ញាណកើតឡើង ព្រោះប្រារព្ធដូច្នោះឬ ?"; បរវាទីឆ្លើយបដិសេធ ព្រោះព្រះបាលីថា ***"ចក្ខុវិញ្ញាណកើត ព្រោះអាស្រ័យចក្ខុផង រូបផង"*** ។ ត្រូវសកវាទីសួរគ្រាទី ២ ក៏ឆ្លើយតបដោយសំដៅយកពាក្យថា វត្ថុណា មិនមាននិមិត្តក្នុងទីនោះ វត្ថុនោះ ឈ្មោះថា សូន្យទទេ ព្រោះព្រះបាលីថា ***"មិនកាន់យកដោយនិមិត្ត"*** ក្នុងបញ្ហា ២ ខទៀតថា ***អាស្រ័យចក្ខុ*** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ក្នុងបទថា **“ចក្ខុវិញ្ញាណប្រារព្ធអតីត និងអនាគត”** នោះ អធិប្បាយថា ការបម្រើនមគ្គ មានដល់អ្នកព្រមព្រៀងដោយមនោវិញ្ញាណ, ឯមនោ-វិញ្ញាណរមែងកើតឡើង ព្រោះប្រារព្ធធម៌ដែលជាអតីត និងអនាគតយ៉ាងណា, សូម្បីចក្ខុវិញ្ញាណ ក៏ដូច្នោះឬ ? ក្នុងពាក្យទាំងឡាយថា **“មនោ-វិញ្ញាណប្រារព្ធផស្សៈ”** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ក្នុងបទថា **“ឃើញរូបដោយចក្ខុហើយ ជាអ្នកមិនកាន់យកនិមិត្ត”** នេះ អធិប្បាយថា លោកពោលថា មិនកាន់យកនិមិត្តក្នុងខណៈនៃជវន, មិនមែនមិនកាន់យកនិមិត្តក្នុងខណៈនៃចក្ខុវិញ្ញាណទេ; ព្រោះហេតុដូច្នោះ ពាក្យថា ចក្ខុវិញ្ញាណនេះ សំដៅយកត្រឹមតែជាលោកិយដែលមិនមែនជាការសាកល្បង (ពិសោធន៍ ឬសាធកៈ) ថា ការបម្រើនមគ្គមានដល់អ្នកព្រមព្រៀងដោយវិញ្ញាណ ៥ ឡើយ ៕

ចប់បញ្ចវិញ្ញាណសមង្គិមគ្គភាវនាកថា

# ៤.បញ្ចវិញ្ញាណាកុសលាបីតិកថា

## សម្តែងអំពីបញ្ចវិញ្ញាណជាកុសលក៏មាន ជាអកុសលក៏មាន

ឥឡូវនេះ ឈ្មោះថា បញ្ចវិញ្ញាណជាកុសលក៏មាន និងជាអកុសលក៏មាន ៖

*រឿងនេះ បណ្ឌិតគប្បីជ្រាបដោយន័យដែលខ្ញុំពោលទុកហើយ ក្នុងពេលមុនន៉ុះចុះ ។*

ចប់បញ្ចវិញ្ញាណាកុសលាបីតិកថា

..................................

## ៥.បញ្ចវិញ្ញាណាសាភោគាតិកថា

## សម្តែងអំពីបញ្ចវិញ្ញាណមានការសង្ស៊ឹម

*ឥឡូវនេះ ឈ្មោះថា រឿងបញ្ចវិញ្ញាណមានការសង្ស៊ឹម ៖*

*ក្នុងរឿងនោះ ឈ្មោះថា ការគិតរំពឹង រមែងមានបាន ដោយអំណាចនៃកុសល និងអកុសល ។ ក៏សេចក្តីនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា* ***“ភិក្ខុឃើញរូបដោយចក្ខុ ហើយកាន់យកនិមិត្ត... មិនកាន់យកនិមិត្ត”*** *ជាដើម ។ ជនទាំងឡាយណា កាន់យកព្ទវចនៈនោះ ដោយមិនពិចារណា ទើបមានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា “វិញ្ញាណ ៥ មានការនឹកគិតរំពឹងបាន” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ ដូចគ្នានឹងរឿងមុនន៉ុះដែរ ។*

ចប់បញ្ចវិញ្ញាណាសាភោគាតិកថា

..................................................

# ៦.ទ្វិសីលសមន្នាគតោតិកថា

## សម្តែងអំពីអ្នកប្រកបដោយសីល ២ យ៉ាង

ឥឡូវនេះ ឈ្មោះថា រឿងបុគ្គលអ្នកប្រកបដោយសីល ២ យ៉ាង ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈនោះឯងថា "បុគ្គលអ្នកមានសីលរមែងឲ្យលោកុត្តរមគ្គកើតដោយលោកិយសីលបាន" ព្រោះព្រះបាលីថា ***"នរជនអ្នកមានសីល តាំងនៅចំពោះហើយក្នុងសីល"***[១៥] ជាដើម ព្រោះហេតុណា, ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា "អ្នកប្រកបដោយសីល ២ យ៉ាង គឺដោយលោកិយសីលដែលកើតមុន និងលោកុត្តរសីលដែលកើតក្នុងខណៈនៃមគ្គ" ដូច្នេះ, ពាក្យសួររបស់សកវាទីថា ***"បុគ្គលដែលមានការព្រមព្រៀងដោយមគ្គ"*** សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលថា "ជាអ្នកប្រកបដោយផស្សៈ ២ យ៉ាង" ជាដើម ដើម្បីចោទដោយពាក្យថា "បើបុគ្គលនោះប្រកបដោយសីល ២ យ៉ាង គឺលោកិយសីល និងលោកុត្តរសីល ក្នុងខណៈតែមួយបានមែន, ក៏គប្បីជាអ្នកប្រកបដោយធម៌ម្យ៉ាងៗ ២ មានផស្សៈ ២ ជាដើមបាន" ដូច្នេះ, បរវាទីកាលមិនឃើញន័យដែលមាន

---

[១៥] សំ. ស. ។

*សភាពយ៉ាងនោះ ទើបឆ្លើយបដិសេធ ។ ក្នុងបញ្ហាថា* ***“ជាអ្នកប្រកប ដោយសីលដែលជាលោកិយ និងលោកុត្តរ”*** *ទើបបរវាទីឆ្លើយតប សំដៅយកលោកិយសីល បានសមាទានហើយក្នុងកាលមុន និងលោកុត្តរសីលដែលមានសម្មាវាចាជាដើម ដែលកើតឡើងក្នុងខណៈនៃមគ្គ ។ ពាក្យសួរថា* ***“កាលបើសីលជាលោកិយរលត់ទៅហើយ”*** *ដូច្នេះ ជារបស់បរវាទី, ពាក្យឆ្លើយតបរបស់សកវាទី សំដៅយកការរលត់ គឺការរលត់ក្នុងខណៈ បានដល់ភង្គខណៈ; បរវាទីនោះ កាលកំណត់ពាក្យថា សីលរលត់នោះ ដូចជាការកន្លងសីលទៀត ទើបសួរថា* ***“បុគ្គលអ្នកទ្រុស្តសីល”*** *ជាដើម; មួយវ៉ាងទៀត ការតាំងលទ្ធិរបស់បរវាទីនោះ រមែងសម្តែងនូវភាវៈនៃបុគ្គលមានសីលមិនដាច់មកពីមុនប៉ុណ្ណោះ, មិនបានសម្តែងនូវភាវៈនៃបុគ្គលជាអ្នកប្រកបដោយសីល ២ យ៉ាង; ព្រោះហេតុដូច្នោះ ទើបតាំងនៅមិនបាន ៕*

ចប់ទ្ធិសីលេសមន្នាគតោតិកថា

# ៧.សីលំ អចេតសិកន្តិកថា

## សម្តែងអំពីសីលមិនមែនជាចេតសិក

*ឥឡូវនេះ ឈ្មោះថា រឿងសីលមិនមែនជាចេតសិក ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា “កាលបើសីលកើតឡើង សូម្បីរលត់ទៅ*

ហើយ បុគ្គលនោះ ឈ្មោះថា មានការសន្សំ (រក្សា) សីលដែលមានការសមាទានជាហេតុ, គេឈ្មោះថា ជាអ្នកមានសីល ព្រោះហេតុណា, ព្រោះហេតុនោះឯង ទើបសីលមិនមែនជាចេតសិក" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងរឿងរបស់ពាក្យថាទានមិនមែនជាចេតសិកនោះឯង; សូម្បីបរវាទីឲ្យលទ្ធិតាំងទុកហើយ ក៏មិនអាចតាំងទុកបានឡើយ ព្រោះកាន់យកព្រះសូត្រដោយមិនបានពិចារណា ៕

ចប់សីលំអចេតសិកន្តិកថា

## ៨.សីលំ ន ចិត្តានុបរិវត្តីតិកថា

## សម្តែងអំពីសីលមិនប្រព្រឹត្តទៅតាមចិត្ត

ឥឡូវនេះ ឈ្មោះថា រឿងសីលមិនប្រព្រឹត្តទៅតាមចិត្ត ៖

ក្នុងរឿងនោះ ពាក្យថា "**សីលមិនកើតស្របតាមចិត្ត**" នេះ ជាពាក្យផ្សេងគ្នាវាងភាសាប៉ុណ្ណោះ ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងមុនន៎ះដែរ ៕

ចប់សីលំ ន ចិត្តានុបរិវត្តីតិកថា

---

## ៩.សមាទានហេតុកកថា

## សម្តែងអំពីសីលមានការសមាទានជាហេតុ

*ឥឡូវនេះ ឈ្មោះថា រឿងសីលមានការសមាទានជាហេតុ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈដែលថា “សីលមានការសមាទានជាហេតុ រមែងចម្រើន” ដោយអាស្រ័យព្រះបាលីថា* ***“បុណ្យរមែងចម្រើនគ្រប់កាល”*** *ព្រោះកាន់យកអត្ថដោយមិនពិចារណា ក្នុងរឿងកសាងអារាមជាដើម, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់សកវាទី សំដៅយកការសន្សំ (រក្សា) សីលដែលមិនប្រកបដោយចិត្ត ។ ពាក្យដ៏សេស ដូចនឹងរឿងមុនដែរ ៕*

ចប់សមាទានហេតុកកថា

## ១០.វិញ្ញត្តិ សីលន្តិកថា សម្ដែងអំពីវិញ្ញត្តិជាសីល

*ឥឡូវនេះ ឈ្មោះថា រឿងវិញ្ញត្តិជាសីល ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈ និងសមិតិយៈថា “ វិញ្ញត្តិ គឺការកម្រើក កាយនិងវាចាថា ជាសីល ព្រោះកាន់យកសេចក្ដីនៃព្រះសូត្រថា* ***‘ កាយវិញ្ញត្តិជាកាយកម្ម, វចីវិញ្ញត្តិ ជាវចីកម្ម”*** *ដូច្នេះ; ពាក្យសួររបស់សកវាទីថា* ***“វិញ្ញត្តិ”*** *ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់*

*បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទបរវាទី ដោយអត្ថថា “ចេតនាជាគ្រឿងវៀរ ឈ្មោះថា សីល, រូបធម៌ មិនមែនសីល ព្រោះហេតុណា, ព្រោះហេតុនោះ ទើបពោលពាក្យថា* **“បាណាតិបាតា វេរមណី”** *ជាដើម ។ ពាក្យថា* ***“ការថ្វាយបង្គំ ជាសីល”*** *ជាដើម លោកពោលដើម្បីសម្ដែងពាក្យប្រៀបធៀបថា វិញ្ញត្តិជារូប យ៉ាងណា, ពាក្យថា សីលជាបញ្ញត្តិក៏ដូច្នោះដែរ រមែងមិនមាន ។ ក៏ឯវិញ្ញត្តិនោះ មិនមែនចេតនាជាគ្រឿងវៀរ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបសកវាទីពោលពាក្យជាដើមថា* **“បាណាតិបាតា វេរមណី”** *ដូច្នេះទៀត ។ ក៏លទ្ធិរបស់បរវាទីនោះ ឈ្មោះថា តាំងនៅមិនបាន ព្រោះតាំងនៅចំពោះហើយដោយលេសន័យមានប្រការដូច្នេះ ៕*

ចប់វិញ្ញត្តិសីលន្តិកថា

## ១១.អវិញ្ញត្តិ ទុស្សីល្យន្តិកថា

## សម្ដែងអំពីអវិញ្ញត្តិ ជាការទ្រុស្តសីល

*ឥឡូវនេះ ឈ្មោះថា រឿងអវិញ្ញត្តិ គឺការមិនសម្ដែងកាយវាចាឡើងថា ជាការទ្រុស្តសីល ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា “អវិញ្ញត្តិជាការទ្រុស្តសីល ព្រោះសំដៅយក*

*ការសន្សំវត្ថុដែលមិនមែនបុណ្យ គឺមិនប្រកបដោយចិត្ត និងសំដៅយកការសម្បូណ៌នៃអន្តបន្ទាប់ក្នុងបាណាតិបាតជាដើម" ដូច្នេះ, ពាក្យសួររបស់សកវាទី ព្រោះសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថាជា* ***"បាណាតិបាត"*** *ជាដើម ដើម្បីចោទដោយពាក្យថា "បើអវិញ្ញត្តិនោះ គប្បីជាការទ្រុស្តសីល យ៉ាងណាមួយ ក្នុងបាណាតិបាតជាដើមមែន" ។ ពាក្យថា* ***"បុគ្គលសមាទានបាបកម្ម"*** *អធិប្បាយថា ធ្វើការសមាទានបាបយ៉ាងនេះថា* ***"យើងនឹងសម្លាប់បុគ្គលឈ្មោះឯណោះ, យើងនឹងលួចភណ្ឌៈឯណោះ"*** *ជាដើម ។ ត្រូវសកវាទីសួរថា "បុណ្យ និងបាបទាំង ២ យ៉ាងចម្រើនឬ ?" បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកការមិនកើតឡើងនៃបាបក្នុងខណៈឲ្យទាន ។ ត្រូវសកវាទីសួរគ្រាទី ២ ក៏ឆ្លើយតប សំដៅយកការសន្សំបាបដែលមិនប្រកបនឹងចិត្ត ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមន័យដែលពោលទុក ក្នុងរឿងបុណ្យសម្រេចអំពីការបរិភោគន៍ុះចុះ ។ សូម្បីការតាំងលទ្ធិរបស់បរវាទីនោះ រមែងសម្រេចក្នុងចំណែកខាងដើម គឺក្នុងការសមាទានបាប, តែមិនមែនភាពជាអ្នកទ្រុស្តសីល ព្រោះអវិញ្ញត្តិទេ៕*

ចប់អវិញ្ញត្តិ ទុស្សីល្យន្តិកថា

**រួមកថាដែលមានក្នុងវគ្គនេះ គឺ**

១.និរោធកថា, ២.រូបំមគ្គោតិកថា, ៣.បញ្ចវិញ្ញាណសមង្គិមគ្គ-ភាវនាកថា, ៤.បញ្ចវិញ្ញាណាកុសលាបីតិកថា, ៥.បញ្ចវិញ្ញាណាសាភោគាតិ-កថា, ៦.ទ្វិសីលេសមន្នាគតោតិកថា, ៧.សីលំអចេតសិកន្តិកថា, ៨.សីលំន ចិត្តានុបរិវត្តីតិកថា, ៩.សមាទានហេតុកកថា, ១០.វិញ្ញត្តិ សីលន្តិកថា, ១១.អវិញ្ញត្តិ ទុស្សីល្យន្តិកថា ។

**ចប់វគ្គទី ១០**

**នៃបណ្ណាសកៈទី ២**

## វគ្គទី ១១

## ១-៣.តិស្សោបិ អនុសយកថា

## សម្ដែងអំពីអនុស័យជាធម៌ទាំង ៣

ឥឡូវនេះ ឈ្មោះថា រឿងអនុស័យជាធម៌ទាំង ៣ គឺជាអព្យាក្រឹត, អហេតុកៈ និងចិត្តវិប្បយុត្ត ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈ និងសមិតិយៈថា "បុថុជ្ជន កាលចិត្ត ជាកុសលនិងអព្យាក្រឹតដែលកំពុងប្រព្រឹត្តទៅ គប្បីពោលថា "ជាអ្នកមានអនុស័យ" ; ម្យ៉ាងទៀត ហេតុឯណា គប្បីមានក្នុងខណៈនោះ អនុស័យទាំងឡាយ មិន

ប្រព្រឹត្តទៅជាមួយនឹងហេតុដូច្នោះផង មិនសម្បយុត្តជាមួយនឹងចិត្តដូងនោះផង ព្រោះហេតុណា, ព្រោះហេតុនោះ អនុស័យទាំងនោះ ទើបជាអព្យាក្រឹត, អហេតុកៈ និងចិត្តវិប្បយុត្ត” ដូច្នេះ ពាក្យសួររបស់សកវាទីសួម្បីក្នុងកថាទាំង ៣ ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតប ជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ អាចដឹងបានតាមលំដាប់នៃព្រះបាលីនុ៎ះឯង ព្រោះជាន័យដែលពោលទុកហើយក្នុងពេលមុនដែរ ព្រោះហេតុដូច្នោះទើបខ្ញុំមិនបានឲ្យពិស្តារទេ ៕

ចប់តិស្សោបិ អនុសយកថា

## ៤.ញាណកថា សម្តែងអំពីញាណ

ឥឡូវនេះ ឈ្មោះថា រឿងញាណ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា “កាលបើអញ្ញាណ គឺមោហៈ សូម្បីប្រាសទៅហើយ ដោយមគ្គញ្ញាណ, កាលចិត្តមិនប្រកបដោយញាណដែលកំពុងប្រព្រឹត្តទៅ ចក្ខុវិញ្ញាណជាដើម ប្រព្រឹត្តទៅទៀត, មគ្គចិត្តនោះ ក៏មិនមែនកំពុងប្រព្រឹត្តទៅទេ ព្រោះហេតុណា, ព្រោះហេតុនោះ មិនគួរពោលថា “មានញាណ” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា

***“កាលរាគៈប្រាសទៅហើយ”*** ជាដើម ដើម្បីចោទដោយពាក្យថា “បើកាល អញ្ញាណ គឺមោហៈប្រាសទៅហើយ បញ្ញត្តិថា ‘អ្នកមានញាណ” ដូច្នេះ មិនគប្បីមានទេ, គ្រាកាលរាគៈជាដើម ប្រាសទៅហើយ សូម្បីបញ្ញត្តិថា “មានរាគៈជាដើម ប្រាសទៅហើយ” ក៏មិនគប្បីមាន ព្រោះហេតុនោះ បុគ្គលអ្នកមិនមានសេចក្ដីក្រោធ គប្បីជាអ្នកមានសេចក្ដីក្រោធ ក្នុងបញ្ញត្តិថា “បុគ្គលនោះ គប្បីមានឬ ?” បរវាទីកាលមិនឃើញនូវការគួរក្នុងភាព ជាអ្នកមានរាគៈជាដើម ក្នុងធម៌ទាំងនោះ ដែលមានរាគៈជាដើម ប្រាសទៅ ហើយ ទើបឆ្លើយបដិសេធ ។ ក្នុងទីបំផុតនៃបញ្ហា បរវាទីសួរបញ្ហា ដែលគួរសួរថា “ឈ្មោះថា អ្នកមានការដឹង ដោយការដឹងដែលជាអតីត” ជាដើម, ព្រោះហេតុដូច្នោះ ទើបសកវាទីឆ្លើយបដិសេធថា ***“មិនគប្បី ពោលយ៉ាងនេះទេ”*** ៕

ចប់ញាណកថា

## ៥.ញាណំ ចិត្តវិប្បយុត្តន្តិកថា

## សម្ដែងអំពីញាណជាចិត្តវិប្បយុត្ត

ឥឡូវនេះ ឈ្មោះថា រឿងញាណដែលមិនប្រកបជាមួយចិត្ត គឺ មិនប្រកបនឹងចិត្ត ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិ

*របស់និកាយបុព្វសេលិយៈថា “ព្រះអរហន្តអ្នកព្រមព្រៀងដោយចក្ខុវិញ្ញាណជាដើម គឺសំដៅសេចក្ដីថា ចក្ខុវិញ្ញាណចិត្តជាដើម កើតឡើងហើយលោកហៅថា ‘អ្នកមានញាណ’ ព្រោះសំដៅយកមគ្គញ្ញាណដែលលោកបានហើយ, តែថា ញាណរបស់ព្រះអរហន្តនោះ មិនសម្បយុត្តដោយចក្ខុ-វិញ្ញាណចិត្តនោះទេ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបញាណ មិនប្រកបនឹងចិត្ត” ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***“ជារូប”*** *ជាដើម ដើម្បីចោទដោយពាក្យថា “បើញាណមិនប្រកបនឹងចិត្តមែន, ញាណរបស់ព្រះអរហន្តនោះ ក៏នឹងគប្បីជាធម៌យ៉ាងណាមួយ មានរូបជាដើម ដែលមិនប្រកបនឹងចិត្ត” ដូច្នេះ, បរវាទីឆ្លើយបដិសេធ ។ ពាក្យដ៏សេស មានន័យដូចពោលទុកហើយ ក្នុងពេលមុននុ៎ះឯង ។ ក៏ក្នុងបរិយោសាន ត្រូវសកវាទីសួរថា “ព្រះអរហន្តអ្នកព្រមព្រៀងដោយចក្ខុ-វិញ្ញាណ សំដៅសេចក្ដីថា ចក្ខុវិញ្ញាណកំពុងប្រព្រឹត្តទៅ គប្បីពោលថា* ***‘អ្នកមានបញ្ញាឬ ?”*** *បរវាទីរមែងប្រាថ្នានូវពាក្យបញ្ញត្តិនោះ ដោយអំណាចនៃការបានចំពោះហើយនូវបញ្ញា, ព្រោះហេតុដូច្នោះ ទើបឆ្លើយតប ៕*

ចប់ញាណំ ចិត្តវិប្បយុត្តន្តិកថា

========================

## ៦.៨ធំ ទុក្ខនិទ្ទេសកថា សម្តែងអំពីការបញ្ចេញវាចាថា នេះទុក្ខ

*ឥឡូវនេះ ឈ្មោះថា រឿងការបញ្ចេញវាចាថា "នេះទុក្ខ" ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា "ក្នុងខណៈនៃលោកុត្តរមគ្គកើត យោគាវចរ រមែងបញ្ចេញវាចាថា 'នេះទុក្ខ' យ៉ាងណា, ញាណថា 'នេះទុក្ខ' រមែងប្រព្រឹត្តទៅដល់យោគាវចរអ្នកពោលវាចាថា 'នេះទុក្ខ" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ ពាក្យឆ្លើយតបជារបស់បរវាទី សំដៅយកការពោលវាចាដូច្នោះ និងការប្រព្រឹត្តទៅនៃញាណក្នុងខណៈនៃមគ្គ ។ម្យ៉ាងទៀត បរវាទីនោះប្រាថ្នាថា "បុថុជ្ជនរមែងពោលវាចាដែលប្រកបដោយសច្ចៈដ៏សេស" , តែថា ញាណដូច្នោះ រមែងមិនប្រព្រឹត្តទៅដល់គេព្រោះហេតុណា, ព្រោះហេតុនោះ ទើបលោកបដិសេធក្នុងបញ្ហាមានសមុទ័យជាដើម ។*

*ពាក្យថា "កាលពោលវាចាថា '**រូបមិនទៀង**" ជាដើម លោកពោលដោយអំណាចនៃការសម្តែងបរិយាយនៃទុក្ខ ។ ក៏កាលបរវាទីមិនឃើញវោហារដូច្នោះ ក្នុងលទ្ធិរបស់ខ្លួន ទើបឆ្លើយបដិសេធ ។*

*ពាក្យថា "ញាណថា '**ន**' ញាណថា '**ធំ**' ជាដើម លោកពោលហើយ ដើម្បីសម្តែងពាក្យថា 'បើញាណក្នុងទុក្ខរបស់បុថុជ្ជនរមែងប្រព្រឹត្តទៅបានមែន, ក៏រមែងប្រព្រឹត្តទៅដោយញាណ ៤ តាមលំដាប់នៃអក្សរ* **ន**

*អក្សរ* **ធំ** *អក្សរ* **ទុ** *អក្សរ* **ខំ** *(ឥទំ ទុក្ខំ)” , តែបរវាទីមិនប្រាថ្នា ដូច្នោះទេ ព្រោះហេតុនោះ ទើបឆ្លើយបដិសេធ ៕*

ចប់ឥទំ ទុក្ខន្តិកថា

## ៧.ឥទ្ធិពលកថា សម្តែងអំពីកម្លាំងនៃឫទ្ធិ

*ឥឡូវនេះ ឈ្មោះថា រឿងកម្លាំងនៃឫទ្ធិ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា “អ្នកប្រកបដោយកម្លាំងនៃឫទ្ធិ គប្បីតាំងនៅបានរហូតកប្ប” ព្រោះកាន់យកអត្ថនៃអានិសង្សរបស់ឥទ្ធិបាទភាវនា ដោយមិនពិចារណា, ពាក្យសួររបស់សកវាទីថា* ***“អ្នកប្រកបដោយកម្លាំងនៃឫទ្ធិ គប្បីតាំងនៅបានរហូតកប្បឬ ?”*** *ព្រោះសំដៅដល់ជនទាំងនោះ ។*

*ក្នុងបញ្ហានោះ ឈ្មោះថា* ***កប្ប*** *មាន ៣ យ៉ាង គឺមហាកប្ប, កប្បឯកទេស និងអាយុកប្ប ។ មែនពិត មហាកប្បប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់ហៅថា* ***កប្ប*** *ដែលមានមកក្នុងព្រះបាលីថា* ***“ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យនៃកប្បទាំង ៤ នេះ”*** [១៦] *។ ក្នុងព្រះបាលីថា “កប្បដែលជាប្រមាណនៃអាយុទេពជាន់ព្រហ្មទាំងឡាយ” លោកហៅថា*

[១៦] អំ. ចតុក្ក. ។

***កប្បឯកទេស*** ។ ព្រះបាលីថា “រមែងឆេះក្នុងនរករហូតកប្ប, រមែងរីករាយក្នុងសួគ៌រហូតកប្ប”[១៧] នេះ លោកហៅថា ***អាយុកប្ប***, អធិប្បាយថា ការតាំងនៅនៃអាយុដ៏សមគួរដល់អាយុ ឈ្មោះថា ការកំណត់អាយុ ដោយអំណាចនៃផលរបស់កម្ម ឬដោយការរាប់ឆ្នាំ ។ ក្នុងបញ្ហាទាំងនោះ សកវាទីរមែងសួរសំដៅយកមហាកប្ប, បរវាទីក៏ឆ្លើយតប ។ លំដាប់នោះ ទើបសកវាទីពោលនឹងបរវាទីថា “***អាយុនោះ សម្រេចដោយឫទ្ធិ***” ជាដើម ដើម្បីចោទដោយពាក្យថា “បើអ្នកប្រកបដោយកម្លាំងនៃឫទ្ធិ គប្បីជាអ្នករស់នៅរហូត ១ មហាកប្ប ឬរហូតមួយចំណែកនៃមហាកប្បដែលច្រើនជាងអាយុកប្ប ដែលលោកកំណត់ទុកយ៉ាងនេះថា ‘អ្នកណាជាអ្នករស់នៅយូរ, អ្នកនោះ ក៏គប្បីជាអ្នកមានអាយុនៅរហូតរយឆ្នាំ ឬច្រើនជាងបន្តិចបន្តួច’[១៨] ដូច្នេះ ក៏អាយុរបស់អ្នកនោះ គប្បីសម្រេចដោយឫទ្ធិឬ ?” ។ បរវាទីឆ្លើយបដិសេធ ព្រោះព្រះមានព្រះភាគបានត្រាស់ទុកថា “ឈ្មោះថា ឥន្ទ្រិយ គឺជីវិតដែលសម្រេចដោយឫទ្ធិ រមែងមិនមាន, មានតែការកើតឡើងដោយកម្មប៉ុណ្ណោះ” ។ មានពាក្យសួរថា “ក៏ក្នុងសេចក្តីនេះ មានអ្វីប្លែកអំពីអ្នកមានឫទ្ធិ, ព្រោះសូម្បីអ្នកមិនមានឫទ្ធិ ក៏គប្បីតាំងនៅរហូតអាយុកប្ប មិនមែនឬ ?” ឆ្លើយថា គប្បីជ្រាបសេចក្តី

---

[១៧] វិនយ. ។

[១៨] សំ. និ. ។

*ផ្សេងគ្នានៃជនទាំងនោះដូច្នេះ អ្នកមានឫទ្ធិនោះ អាចហាមអន្តរាយិកធម៌ទាំងឡាយ មិនឲ្យកើត មិនឲ្យប្រព្រឹត្តទៅដល់ជីវិត រហូតជីវិត ដោយកម្លាំងនៃឫទ្ធិ និងរមែងអាចដើម្បីហាមអកាលមរណៈ គឺការស្លាប់ក្នុងវេលាមិនសមគួរ ដែលនឹងមានក្នុងចន្លោះ, តែកម្លាំងដូច្នេះ មិនមានដល់អ្នកដែលមិនមានឫទ្ធិឡើយ; សេចក្ដីនេះ ជាការប្លែកគ្នារវាងអ្នកមានឫទ្ធិ និងអ្នកមិនមានឫទ្ធិទាំងនោះ ។ ពាក្យថា* ***“គប្បីតាំងនៅរហូតកប្បដែលជាអតីត... អនាគត”*** *នេះ សេចក្ដីថា សកវាទីរមែងចោទ ព្រោះការឆ្លើយតបរបស់បរវាទីសំដៅយកថា គប្បីតាំងនៅរហូតកប្ប ដោយមិនប្លែកគ្នា ។ ពាក្យថា* ***“គប្បីតាំងនៅ រហូត ២ កប្ប”*** *ជាដើម សកវាទីពោលដើម្បីចោទដោយពាក្យថា “ប្រសិនបើអ្នកមានឫទ្ធិ អាចឈានកន្លងការកំណត់ជីវិតបានមែន, ក៏មិនអាចឈានកន្លងការកំណត់ជីវិតត្រឹមតែមួយកប្បប៉ុណ្ណោះ, គេគប្បីឈានកន្លង ហើយតាំងនៅរហូតកប្ប មិនមែនសូម្បីបន្តិចបន្តួចឡើយ” ។*

*ពាក្យថា* ***“បុគ្គលគប្បីបានដើម្បីផ្ដងទុកដោយឫទ្ធិថា ផស្សៈកើតឡើងហើយ កុំរលត់ទៅដូច្នេះឬ ?”*** *សកវាទីពោលដើម្បីសម្ដែងថា* ***“វត្ថុទាំងពួងមិនគប្បីបានដោយឫទ្ធិ, សូម្បីវត្ថុដែលនៅខាងលើអំណាចឫទ្ធិ ក៏មាន”*** *ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕*

ចប់ឥទ្ធិពលកថា

## ៨.សមាធិកថា សម្តែងអំពីសមាធិ

ឥឡូវនេះ ឈ្មោះថា រឿងសមាធិ ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយសព្វត្ថិកវាទៈ និងឧត្តរាបថកៈថា "ការបន្តនៃចិត្តជា សមាធិ" ព្រោះអាស្រ័យពុទ្ធវចនៈថា ***"ព្រះតថាគតរមែងអាចដើម្បីនៅជាសុខ ក្នុងពាក្យថា ' តថាគតជាអ្នកសេពសោយនូវសេចក្តីសុខ ដោយចំណែកតែមួយ រហូត ៧ រាត្រី និង ៧ ថ្ងៃ"*** [១៩] ជាដើម ដោយមិនកាន់យកពាក្យថា "ឯកគ្គតាចេតសិក សូម្បីកើតឡើងហើយក្នុងខណៈនៃចិត្តមួយដួង ឈ្មោះថា ***សមាធិ*** ព្រោះអត្ថថា ការតាំងចិត្ត" ដូច្នេះ ពាក្យសួររបស់សកវាទីថា "ការបន្តនៃចិត្តដែលជាអតីតខ្លះ, ដែលជាអនាគតខ្លះ; រមែងមានចំណែកបន្តនៃចិត្តដែលជាបច្ចុប្បន្ននុ៎ះឯង មិនមាន; សូម្បីការបន្តនៃចិត្តទាំងអស់នោះ រមែងជាសមាធិតាមលទ្ធិរបស់លោកឬ ?" , បរវាទីនោះ កាលមិនប្រាថ្នាដូច្នោះ ទើបឆ្លើយបដិសេធ ។ ពាក្យថា ***"អតីត ក៏រលត់ទៅហើយ"*** ជាដើម សកវាទីពោលដើម្បីសម្តែងថា ចិត្តដែលកើតឡើងចំពោះមុខនោះឯង រមែងធ្វើនូវកិច្ចក្នុងការបន្តនៃចិត្ត, ចិត្តដែលជាអតីត និងអនាគត ឈ្មោះថា រមែងមិនមាន ព្រោះជាចិត្តដែលរលត់ទៅហើយ និង

---

[១៩] ម. មូ. ។

ព្រោះជាចិត្តដែលនៅមិនទាន់បានកើតឡើង ព្រោះហេតុដូច្នោះ ចិត្តនោះនឹងឈ្មោះថា ជាសមាធិបាន ដូចម្ដេច ? ពាក្យសួរថា ***"សមាធិប្រព្រឹត្តទៅក្នុងខណៈនៃចិត្តមួយដួង"*** ជារបស់បរវាទី ។ តអំពីនោះ ក៏ជាពាក្យឆ្លើយតបរបស់សកវាទីក្នុងលទ្ធិរបស់ខ្លួន ដោយសំដៅយកព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា ***សមាធិ*** គឺឯកគ្គតាសម្បយុត្តដោយកុសលចិត្តដែលកើតឡើងហើយក្នុងបច្ចុប្បន្ន ត្រង់បាលីថា ***"ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចម្រើនសមាធិនោះ"*** ។ ពាក្យថា "បុគ្គលដែលប្រកបព្រមដោយចក្ខុវិញ្ញាណ" ជាដើម បរវាទីពោលដោយការកន្លង ព្រោះកាន់យកហេតុត្រឹមតែថា អ្នកមានខណៈនៃចិត្តមួយដួង ។ ព្រោះហេតុនោះឯង ទើបសកវាទីឆ្លើយបដិសេធ ។ ព្រះសូត្រថា ***"ព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ... មិនមែនឬ ?"*** សេចក្ដីនេះ រមែងសម្រេចនូវភាវៈនៃចិត្តនោះ ជាធម្មជាតមិនប្រឡូកប្រឡំដល់សមាធិដែលកំពុងប្រព្រឹត្តទៅដោយអំណាចនៃការកើតមុន និងក្រោយ, តែមិនសម្រេចនូវការបន្តនៃចិត្តថាជាសមាធិ, ព្រោះហេតុដូច្នោះ ទើបមិនជាការពិសោធន៍ថា "ការបន្តនៃចិត្តជាសមាធិ" ដូច្នេះទេ ៕

ចប់សមាធិកថា

## ៩.ធម្មដ្ឋិតតាកថា សម្តែងអំពីការតាំងនៅនៃធម៌

*ឥឡូវនេះ ឈ្មោះថា រឿងការតាំងនៅនៃធម៌ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា "ឈ្មោះថា ការតាំងនៅនៃធម៌ ពោលគឺបដិច្ចសមុប្បាទ ១ រមែងមាន, ធម៌នោះ ជារបស់សម្រេចហើយ" ព្រោះអាស្រ័យព្រះបាលីថា* ***"ធាតុនោះ តាំងនៅហើយមែនពិត"*** *ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលនឹងបរវាទីនោះថា "ការតាំងនៅនៃធម្មដ្ឋិតិនោះ ក៏ជាការសម្រេចហើយឬ ?" ដើម្បីចោទដោយពាក្យថា "ប្រសិនបើឈ្មោះថា ការតាំងនៅដទៃទៀត សម្រេចដល់ធម៌ទាំងឡាយ មានអវិជ្ជាជាដើម ដែលសម្រេចហើយ រមែងមានមែន, ការតាំងនៅ ដទៃទៀតសូម្បីសម្រេចហើយដល់ការតាំងនៅនោះ រមែងប្រាកដតាមលទ្ធិរបស់លោកឬ ?" , បរវាទីឆ្លើយបដិសេធ ព្រោះមិនមានលទ្ធិយ៉ាងនោះ ។ ត្រូវសកវាទីសួរគ្រាទីពីរ ក៏ឆ្លើយតបសំដៅយកភាវៈជាអនន្តរប្បច្ច័យ និងភាពជាអញ្ញមញ្ញប្បច្ច័យ ។ ពាក្យដ៏សេស មានអត្ថងាយស្រួលមែនពិត ព្រោះមានន័យដូចដែលខ្ញុំពោលទុកហើយ ក្នុងពេលមុននុ៎ះឯង៕*

**ចប់ធម្មដ្ឋិតតាកថា**

## ១០.អនិច្ចតាកថា សម្តែងអំពីការមិនទៀង

*ឥឡូវនេះ ឈ្មោះថា រឿងការមិនទៀង ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា "សូម្បីការមិនទៀងនៃរូបជាដើម ក៏ជាភាវៈសម្រេចហើយ គឺសំដៅសេចក្តីថា ដូចរូបកើតឡើងជាដើម" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលនឹង បរវាទីនោះថា* ***"ភាពនៃការមិនទៀងនោះ ក៏សម្រេចហើយ គឺកើតឡើងហើយឬ ?"*** *ដើម្បីចោទថា "ការមិនទៀង ជារបស់សម្រេចហើយ ដូចរូបជាដើម តាមលទ្ធិរបស់លោកមានមែន, គឺភាពមិនទៀង ដែលសម្រេចហើយយ៉ាងដទៃ ក៏គប្បីមានសូម្បីដល់ការមិនទៀងនោះ" ដូច្នេះ ។ បរវាទីនោះ បដិសេធដោយការមិនមានភាពមិនទៀង ២ យ៉ាង រួមគ្នា, តែឆ្លើយតប ព្រោះការមិនទៀងនោះ មិនមានភាពមិនទៀងទៀតឡើយ សំដៅសេចក្តីថា ការមិនទៀងនោះរមែងអន្តរធានទៅជាមួយភាព មិនទៀងនោះឯង ។ លំដាប់នោះ សកវាទីមិនឲ្យឱកាសដែលមានលេសន័យដល់បរវាទីនោះ ទើបលើកទោស គឺការមិនចូលទៅកាត់វត្ថុៈ ដោយអំណាចនៃធម៌ដទៃៗ ថា ការមិនទៀងទី ២ លោកមិនយល់ព្រមតាមលទ្ធិរបស់លោក ដោយភាពមិនទៀងនោះៗ ខ្លះ, ដោយភាវៈមិនទៀង ដទៃអំពីនោះខ្លះ ទើបពោលពាក្យថា "ការមិនទៀង*

*នោះឯង មិនអាចធ្វើនូវទីបំផុតនៃទុក្ខ” ជាដើម ។ ពាក្យថា “ជរា ជាភាវៈដែលសម្រេចហើយ គឺកើតឡើងហើយ” ជាដើម សកវាទីពោលដោយអំណាចនៃការប្រកបរឿយៗ នូវការចែកភាពមិនទៀង ព្រោះដែលឈ្មោះថាការមិនទៀងដទៃ អំពីជរា និងមរណៈនៃធម៌ដែលកើតឡើងហើយ រមែងមិនមាន ។ បណ្ឌិតគប្បីជ្រាបពាក្យឆ្លើយតប និងពាក្យបដិសេធរបស់បរវាទីសូម្បីក្នុងបញ្ហានោះ ដោយន័យដែលពោលទុកហើយ ក្នុងពេលមុនទុំះចុះ ។ ពាក្យថា* ***“រូបជាភាវៈដែលសម្រេចហើយ គឺកើតឡើងហើយ”*** *ជាដើម សកវាទីពោលដើម្បីប្រៀបធៀបការមិនទៀងនៃធម៌ មានរូបជាដើមនោះជាមួយនឹងការមិនទៀងទាំងនុ៎ះ ។ ក្នុងសេចក្តីនោះ បរវាទី កាលសម្គាល់ថា “ការមិនទៀង ជរា និងមរណៈនៃធម៌ទាំងឡាយ មានរូបជាដើម ដែលសម្រេចហើយ យ៉ាងណា, ធម៌ទាំងនោះ មិនមានដល់ធម៌ទាំងឡាយ មានការមិនទៀងជាដើម ដែលសម្រេចហើយដូច្នោះឡើយ” ទើបឆ្លើយបដិសេធដោយចំណែកមួយដូច្នេះ ៕*

ចប់អនិច្ចតាកថា

## រួមកថាដែលមានក្នុងវគ្គនេះ គឺ

*១-៣.តិស្សោបិ អនុសយកថា, ៤.ញាណកថា, ៥.ញាណំ ចិត្តវិប្បយុត្តន្តិកថា, ៦.ឥទំ ទុក្ខន្តិកថា, ៧.ឥទ្ធិពលកថា, ៨.សមាធិកថា, ៩.ធម្មដ្ឋិតតាកថា, ១០.អនិច្ចតាកថា ។*

**ចប់វគ្គទី ១១**

## វគ្គទី ១២

## ១.សំវរោ កម្មន្តិកថា សម្តែងអំពីការសង្រួមជាកម្ម

*ឥឡូវនេះ ឈ្មោះថា រឿងការសង្រួមជាកម្ម ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា "ការសង្រួមក្តី ការមិនសង្រួមក្តី ជាកម្ម" ព្រោះអាស្រ័យព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ទុកថា "ភិក្ខុឃើញរូបដោយចក្ខុហើយ ជាអ្នកកាន់យកដោយនិមិត្ត... មិនកាន់យកដោយនិមិត្ត" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលថា* ***"ការសង្រួមក្នុងចក្ខុន្ទ្រិយ ជាចក្ខុកម្មឬ ?"*** *ជាដើម ដើម្បីចោទដោយពាក្យថា "ការពោលពាក្យឯណា ដែលសកវាទីពោលទុកក្នុងលទ្ធិរបស់ខ្លួនថា 'ចេតនា ជាកម្ម' ការពោលនោះ ប្រព្រឹត្តទៅក្នុងកាយទ្វារ វចីទ្វារ និងមនោទ្វារ រមែងមានឈ្មោះថា ជាកាយកម្មជាដើម យ៉ាងណា, បើការសង្រួមជាកម្ម តាមលទ្ធិរបស់លោកមែន, សូម្បីការសង្រួមនោះ កាលបើប្រព្រឹត្តទៅក្នុងចក្ខុន្ទ្រិយជាដើម ក៏គប្បីមានឈ្មោះថា ចក្ខុកម្មជាដើម" ដូច្នេះ ។ ចំណែកបរវាទី កាលមិនឃើញបទព្រះសូត្រដូច្នោះ ទើបឆ្លើយបដិសេធក្នុងទ្វារទាំង ៤ និងរមែងបដិសេធដោយសំដៅយកកាយបសាទក្នុងកាយទ្វារទី ៥, តែឆ្លើយតបសំដៅយកវិញ្ញត្តិកាយ ។ មែនពិត បរវាទីនោះ រមែងប្រាថ្នាកាយបសាទ*

ខ្លះ, វិញ្ញត្តិកាយខ្លះថា ជាកាយិន្ទ្រិយនោះឯង ។ រមែងឆ្លើយបដិសេធ សំដៅយកវិបាកទ្វារ សូម្បីជាមនោទ្វារ ។ រមែងឆ្លើយតប សំដៅយកកម្មទ្វារ ។ សូម្បីក្នុងការមិនសង្រួម ក៏មានន័យដូចគ្នានេះដែរ ។

ព្រះសូត្រថា " ភិក្ខុក្នុងធម៌វិន័យនេះ ឃើញរូបដោយចក្ខុហើយ" ជាដើមនេះ រមែងសម្ដែងចំពោះការសង្រួម និងការមិនសង្រួមក្នុងទ្វារទាំងឡាយប៉ុណ្ណោះ, មិនមែនសម្ដែងនូវការដែលសង្រួម និងការមិនសង្រួមជាកម្មទេ, ព្រោះហេតុដូច្នោះ ព្រះសូត្រដែលលើកមកនោះ ទើបមិនមែនជាការអាងក្នុងទីនេះឡើយ ៕

ចប់សំវរោ កម្មន្តិកថា

.........................

## ២.កម្មកថា សម្ដែងអំពីកម្ម

ឥឡូវនេះ ឈ្មោះថា រឿងកម្ម ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា "កម្មទាំងពួង ជាសវិបាក គឺមាន វិបាក" ព្រោះអាស្រ័យព្រះសូត្រថា ***"ម្នាលភិក្ខុទាំងឡាយ តថាគតមិនហៅការអស់ទៅនៃវិបាក ព្រោះតែមិនសោយកម្មដែលប្រកបដោយសញ្ចេតនា គឺបំណងក្នុងចិត្ត ដែលខ្លួនធ្វើហើយ សន្សំហើយ"*** [២០] ជាដើម ពាក្យសួររបស់

---

[២០] អំ. ទសក. ។

សកវាទីថា "កម្មទាំងពួង" ជាដើម ដើម្បីសម្ដែងវិភាគនេះ ដល់ជនទាំងនោះថា "ចេតនា ព្រះមានព្រះភាគត្រាស់ហៅថា '**កម្ម**' ដោយមិនប្លែកគ្នា ក្នុងពាក្យថា 'ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនាថា ជាតួកម្ម"[២១] ដូច្នេះ, សូម្បីចេតនានោះ ជាកុសលក្ដី ជាអកុសលក្ដី ក៏មានវិបាកដែរ, ចំណែកចេតនាដែលជាអព្យាក្រឹត មិនមានវិបាកទេ ដូច្នេះពាក្យឆ្លើយតបជារបស់បរវាទី ។ ក្នុងបញ្ហាទាំងឡាយថា "**ចេតនាទាំងពួង**" ទៀត បរវាទីឆ្លើយបដិសេធសំដៅយកចេតនាដែលជាអព្យាក្រឹត និងគប្បីជ្រាបការឆ្លើយ តបដោយសំដៅយកចេតនាដែលជាកុសល និងអកុសល ។ ពាក្យថា "**ចេតនាដែលជាវិបាក និងអព្យាក្រឹត**" ជាដើម សកវាទីពោលដើម្បីសម្ដែងចេតនាដែលមានវិបាក និងមិនមានវិបាកដោយសង្ខេប ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ។

ព្រះសូត្រថា "**ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលការអស់ទៅនៃវិបាកទេ**" ជាដើម ដែលបរវាទីនាំមកពោលនោះ សំដៅដល់ការសោយវិបាកក្នុងភពទាំងឡាយ មានភពដែលសត្វគប្បីឃើញបានជាដើម បានដល់ភពបច្ចុប្បន្ន ក្នុងកាលបច្ចុប្បន្ននៅមាន, ព្រោះហេតុដូច្នោះ ព្រះសូត្រនោះទើបមិនមែនជាសាធកៈក្នុងរឿងនេះ ដោយប្រការដូច្នេះ ៕

ចប់កម្មកថា

---

[២១] អំ. ឆក្ក. ។

# ៣.សទ្ទោ វិបាកោតិកថា

## សម្តែងអំពីសំឡេងជាវិបាក [២២]

*ឥឡូវនេះ ឈ្មោះថា រឿងសំឡេងជាវិបាក ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា "សំឡេងជាវិបាក" ព្រោះមិនពិចារណាការកាន់យកព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ទុកថា "តថាគតនោះ ជាអ្នកមានសំឡេងដូចព្រហ្ម... ព្រោះធ្វើកម្មនោះ ដែលបានធ្វើហើយ បានសន្សំទុកហើយ បានបង្កើតឡើងហើយ ជាកម្មចម្រើន"*[២៣] *ដូច្នេះ ពាក្យសួររបស់សកវាទី ពោលដើម្បីសម្តែងដល់ជនទាំងនោះថា "អរូបធម៌ទាំងឡាយ គឺនាមក្ខន្ធ ៤ មានកម្មជាសមុដ្ឋាន រមែងមានឈ្មោះថា វិបាក, តែវោហារនេះ មិនមានក្នុងរូបធម៌ទាំងឡាយទេ" , ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា* ***"សំឡេងជាផលដែលបុគ្គលសោយជាសុខ"*** *ជាដើម សកវាទីពោលដើម្បីសម្តែងថា "តាមធម្មតា ឈ្មោះថា វិបាករមែងមានតែយ៉ាងនេះឯង" ។*

---

[២២] ពាក្យថា **វិបាក** បានដល់ វិបាកចិត្ត ៣៦, ចេតសិក ៣៨; វិបាកនេះ ហៅថា ផលដែរ, តែពាក្យថា ផលមានពីរ គឺមុខយផល និងសាមញ្ញផល, ចំពោះសាមញ្ញផល = កម្មជ្ជរូប មិនចាត់ជាវិបាកទេ ។

[២៣] ទី. បា. ។

*ព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ទុកថា* ***“តថាគតនោះ ជាអ្នកមានសំឡេងដូចព្រហ្ម ព្រោះកម្មនោះ បានធ្វើទុកហើយ”*** *ជាដើម ដែលបរវាទីនាំមកពោលនោះ ក៏ដើម្បីសម្តែងឲ្យជ្រាបដល់ការមានលក្ខណៈ គឺភាវៈដែលល្អពិត មហាបុរស សូម្បីជាអ្នកមានបរិវារដែលល្អ ក៏ព្រោះធ្វើកម្មទុកក្នុងកាលមុន, ទាំងបរិវារនោះ ក៏មិនមែនជាវិបាក, ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនមែនសាធកៈថា សំឡេងជាវិបាកឡើយ ៕*

ចប់សទ្ទោ វិបាកោតិកថា

---

## ៤.សឡាយតនកថា សម្តែងអំពីសឡាយតនៈ

*ឥឡូវនេះ ឈ្មោះថា រឿងសឡាយតនៈ គឺអាយតនៈខាងក្នុង ៦ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា “សឡាយតនៈកើតឡើង ព្រោះធ្វើកម្មទុក ព្រោះហេតុណា, ព្រោះហេតុនោះ ទើបសឡាយតនៈជាវិបាក” ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***“ចក្ខាយតនៈជាវិបាកឬ ?”*** *ជាដើម សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេស មានន័យដូចដែលពោលហើយ ក្នុងពេលមុនន៉ុះឯង ។*

*ក៏ប៉ុន្តែ មនាយតនៈ គប្បីជាវិបាកបាន ក្នុងពាក្យថា* ***“សឡាយតនៈជាវិបាក”*** *នេះ, ចំណែកអាយតនៈដ៏សេសក្រៅពីនេះ មានកម្មជាសមុដ្ឋាន*

*តែមុវ៉ាង, មិនមែនជាវិបាកឡើយ, ព្រោះហេតុដូច្នោះ សេចក្តីនេះ ទើបមិនមែនជាខអាងថា សឡាយតនៈជាវិបាកទាំងអស់ទេ៕*

ចប់សឡាយតនកថា

## ៥.សត្តក្ខត្តុំបរមកថា

## សម្តែងអំពីបុគ្គលជាសត្តក្ខត្តុំបរមៈ

*ឥឡូវនេះ ឈ្មោះថា រឿងបុគ្គលអ្នកជាសត្តក្ខត្តុំបរមៈ គឺបុគ្គលដែលមានការកើត ៧ ជាតិទៀតជាយ៉ាងក្រៃលែង ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា "ព្រះមានព្រះភាគត្រាស់ទុកថា 'សត្តក្ខត្តុំ-បរមបុគ្គល មាន ព្រោះហេតុណា, ព្រោះហេតុនោះ បុគ្គលជាសត្តក្ខត្តុំ-បរមៈនោះ ទើបឈ្មោះថា ជាអ្នកទៀង ព្រោះភាពជាអ្នកមានការកើត ៧ ជាតិទៀត ជាយ៉ាងក្រៃលែង" ដូច្នេះ ពាក្យសួររបស់សកវាទី ដើម្បីសម្តែងវិភាគនេះ ដល់ជនទាំងនោះថា "វៀរអរិយមគ្គហើយ ការកំណត់ពិតប្រាកដយ៉ាងដទៃ មិនមានដល់បុគ្គលនោះទេ, បុគ្គលនោះ គប្បីជាអ្នកទៀង ព្រោះជាអ្នកកើត ៧ ជាតិទៀត ជាយ៉ាងក្រៃលែង ដោយហេតុណា" ដូច្នេះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ក្នុងពាក្យទាំងនោះ ពាក្យថា* ***" បុគ្គលជាសត្តក្ខត្តុំបរមៈ បានសម្លាប់***

***ជីវិតមាតា"*** *ជាដើម គប្បីជ្រាបពាក្យអធិប្បាយយ៉ាងនេះថា* ***និយាម***[២៤] *គឺធម៌ដែលកំណត់ពិតប្រាកដ មាន ២ យ៉ាង បានដល់សម្មត្តនិយាម បានដល់ធម៌ដែលកំណត់ពិតប្រាកដក្នុងផ្លូវត្រូវ ១ និងមិច្ឆត្តនិយាម បានដល់ធម៌ដែលកំណត់ពិតប្រាកដក្នុងផ្លូវខុស ១; អរិយមគ្គ ឈ្មោះថា* ***សម្មត្ត-និយាម*** *ក៏អរិយមគ្គនោះ រមែងកំណត់នូវភាវៈជាវិបាកធម៌ និងការកើតឡើងនៃផលធម៌; ចំណែកមិច្ឆត្តនិយាម រមែងកំណត់ពិតប្រាកដនូវអនន្តរិយកម្ម គឺការកើតឡើងក្នុងនរកដែលមិនមានភពដទៃខណ្ឌក្នុងចន្លោះ; ក្នុងបញ្ហានោះ សត្តក្ខត្តុំបរមបុគ្គលរមែងជាអ្នកដែលសោតាបត្តិមគ្គកំណត់ហើយ ព្រោះជាសភាវធម៌ដែលមិនធ្លាក់ទៅកាន់អបាយ និងដោយភាវៈកើតឡើងនៃផលធម៌, ចំណែកនិយាមនៃមគ្គដ៏សេស រមែងមិនមានដល់សត្តក្ខត្តុំ-បរមបុគ្គលនោះទេ ព្រោះមិនមែនជាធម៌ដែលលោកសម្រេចហើយ, សូម្បីសត្តក្ខត្តុំបរមបុគ្គលនោះ ក៏មិនអាចធ្វើអនន្តរិយកម្មបាន, ក៏ប៉ុន្តែលោកបរវាទីប្រាថ្នានិយាមនៃសត្តក្ខត្តុំបរមបុគ្គលនោះ ព្រោះហេតុដូច្នោះ ទើបខ្ញុំសួរលោកថា "សត្តក្ខត្តុំបរមបុគ្គលនោះ ជាអ្នកដែលមិច្ឆត្តនិយាមនេះ កំណត់ហើយតាមលទ្ធិរបស់លោកឬ ?" ក្នុងបញ្ហាទាំងឡាយថា* ***"បុគ្គលជាសត្តក្ខត្តុំបរមៈ ជាអ្នកមិនគួរដើម្បីត្រាស់ដឹងធម៌ក្នុងចន្លោះឬ ?"***

---

[២៤] បាលីព្រះអភិធម្មបិដក មិនប្រើពាក្យថា **និយាមោ** ទេ, តែអដ្ឋកថា ប្រើពាក្យថា **និយ-មោ** = ការទៀងទាត់ គឺការកំណត់ទៀងទាត់ដូចគ្នា ឬនឹងប្រែប្រថាប់សព្ទថា និយម, និយាមក៏បាន ។

*បរវាទីឆ្លើយតបសំដៅយក ការមិនមានធម៌ដទៃរារាំងក្នុងរវាងចន្លោះ រមែង យល់ព្រមការកើត ៧ ជាតិទៀត ជាយ៉ាងក្រៃលែង ។*

*ក្នុងបញ្ហាទាំងឡាយថា **"និយាមដែលកំណត់សត្តក្ខត្តុំបរមបុគ្គលទុក ដោយការកើត ៧ ដង ជាយ៉ាងក្រៃលែងមិនមែនឬ ?"** បរវាទីកាល មិនឃើញនិយាមនៃភាពជាសត្តក្ខត្តុំបរមបុគ្គល ទើបឆ្លើយបដិសេធ ។ ពាក្យថា **"សតិបដ្ឋានដែលកំណត់សត្តក្ខត្តុំបរមបុគ្គល"** ជាដើម សកវាទី ពោលដើម្បីសម្តែងនូវមគ្គធម៌ទាំងឡាយ ដែលលោកហៅថា **និយាម** ។ម្យ៉ាងទៀត ធម៌មានសតិបដ្ឋានជាដើមនោះ រមែងមិនមាន ព្រោះការមិន កើតឡើងនៃបឋមមគ្គរបស់សត្តក្ខត្តុំបរមបុគ្គលនោះម្តងទៀត ព្រោះហេតុ ដូច្នោះ ទើបលោកឆ្លើយបដិសេធ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថ ងាយស្រួលមែនពិត ។*

*ក្នុងពាក្យថា **"បុគ្គលនោះ ជាសត្តក្ខត្តុំបរមៈ មិនមែនឬ ?"** ដែល បរវាទីនាំមកនេះ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ព្យាករបុគ្គលទាំងនោះ ដោយកម្លាំងនៃញាណរបស់ព្រះអង្គថា "បុគ្គលនេះ អន្ទោលទៅអស់ភព មានប្រមាណប៉ុណ្ណេះៗ ហើយនឹងបរិនិព្វាន" ជាដើម ក៏ពាក្យអ្វីៗ ដែលព្រះ អង្គត្រាស់ថា "សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល និងឯកពីជីបុគ្គល" ដូច្នេះ ឈ្មោះថា ជានិយាមនៃភពមិនមាន ព្រោះហេតុដូច្នោះ ព្រះសូត្រ នេះ ទើបមិនសម្រេចប្រយោជន៍ឡើយ ៕*

ចប់សត្តក្ខត្តុំបរមកថា

## ៦-៧.គោលំគោលឯកពីជីកថា

*សូម្បីការពណ៌នាកថាពោលអំពី* ***បុគ្គលជាគោលំគោលៈ និងឯកពីជី*** *បណ្ឌិតគប្បីជ្រាបអត្ថ ដោយឧបាយនេះចុះ ៕*

---

## ៨.ជីវិតាវោរោបនកថា សម្តែងអំពីការក្លែងផ្តាច់ជីវិត

*ឥឡូវនេះ ឈ្មោះថា រឿងការក្លែងផ្តាច់ជីវិត គឺចេតនាឲ្យស្លាប់ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈថា "បាណាតិបាតរមែងមានដោយចិត្ត ដែលសម្បយុត្តដោយទោសៈ, ក៏ព្រះអរិយបុគ្គលដែលសម្បូណ៌ដោយទិដ្ឋិ គឺព្រះសោតាបន្នលះទោសៈនោះ មិនទាន់បាន ព្រោះហេតុណា, ព្រោះហេតុនោះព្រះអរិយបុគ្គលអ្នកសម្បូណ៌ដោយទិដ្ឋិនោះ គប្បីក្លែងផ្តាច់ជីវិតសត្វ" ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***"បុគ្គលអ្នកមានទិដ្ឋិសម្បត្តិ"*** *ជាដើម សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ក្នុងបញ្ហាទាំងឡាយ មានពាក្យថា* ***"បុគ្គលអ្នកសម្បូណ៌ដោយទិដ្ឋិគប្បីក្លែងផ្តាច់ជីវិតមាតា"*** *ជាដើម បរវាទីឆ្លើយបដិសេធ ព្រោះខ្លាចខុសចាកព្រះសូត្រ ដែលព្រះមានព្រះភាគត្រាស់ទុកថា* ***"ក៏ពាក្យថា ព្រះអរិយ–បុគ្គលដែលសម្បូណ៌ដោយទិដ្ឋិ ក្លែងផ្តាច់ជីវិតមាតា"*** *នេះ ជាអឋានៈ គឺ*

*ប្រព្រឹត្តទៅមិនមាន មិនមែនឳកាស ។ ពាក្យថា* ***“ បុគ្គលដែលមានទិដ្ឋិ-សម្បត្តិ ជាអ្នកមិនគោរពក្នុងព្រះសាស្តា”*** *ជាដើម សកវាទីពោលដើម្បីសម្តែងការមិនឈានកន្លងសិក្ខាបទរបស់អ្នកមានសេចក្តីគោរព ក្នុងព្រះសាស្តាជាដើម ។ បរវាទីឆ្លើយបដិសេធក្នុងពាក្យថា “ឈ្មោះថា ការមិនគោរពរបស់ព្រះអរិយៈដែលសម្បូណ៌ដោយទិដ្ឋិនោះ រមែងមិនមាន ដោយអំណាចនៃអកុសលចិត្ត” ទីងឆ្លើយយល់ព្រមនូវភាវៈនៃលោកជាអ្នកមានសេចក្តីគោរព ។ ត្រូវសកវាទីសួរទៀតថា* ***“ ជាអ្នកមិនគោរព”*** *ជាដើម បរវាទីឆ្លើយតបដោយសំដៅយកការមិនធ្វើអភិវាទន៍ និងការប្រទក្សិណចេតិយព្រោះមិនមានមនសិការដោយសតិ របស់អ្នកមានចិត្តរវើរវាយ ព្រោះរវល់តែខ្វល់ខ្វាយក្នុងកិច្ចការទាំងពួងនោះៗ ។ ត្រូវសកវាទីសួរដោយន័យថា* ***“ បើយ៉ាងនោះ បុគ្គលអ្នកសម្បូណ៌ដោយទិដ្ឋិ ក៏គប្បីបន្ទោបង់ឧច្ចារៈ”*** *ជាដើមទៀត បរវាទីឆ្លើយបដិសេធ ព្រោះមិនធ្វើការក្លែងដោយកិរិយាដូច្នោះទេ ។ ពាក្យដ៏សេស មានអត្ថងាយស្រួលមែនពិត ៕*

ចប់ជីវិតាវោរោបនកថា

.......................................

## ៩.ទុគ្គតិកថា សម្តែងអំពីទុគ្គតិ [២៥]

---

[២៥] ពាក្យថា **ទុគ្គតិ** មាន ២ គឺទុគ្គតិ និងតណ្ហាដែលមានរូបជាដើម ជាអារម្មណ៍ សម្គាល់សេចក្តីថា តណ្ហានោះ មានឈ្មោះថា ទុគ្គតិដែរ ។

*ឥឡូវនេះ ឈ្មោះថា រឿងទុគ្គតិ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា កាន់យកទុគ្គតិសូម្បីទាំង ២ គឺ ទុគ្គតិ ១ និងតណ្ហាដែលមានរូបជាដើម ជាអារម្មណ៍របស់ទុគ្គតិសត្វ ១ ព្រោះមិនចែកប្រភេទទាំងនោះ ទើបពោលថា* ***“បុគ្គលអ្នកមានទិដ្ឋិសម្បត្តិលះទុគ្គតិបានដោយមិនសល់ឡើយ”*** *ដូច្នេះ ដូចលទ្ធិនិកាយខត្តរាបថកៈទាំងឡាយ, ពាក្យសួររបស់បរវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ពាក្យថា* ***“បុគ្គលអ្នកមានទិដ្ឋិសម្បត្តិ សំដៅដល់ព្រះសោតាបន្ន គប្បីត្រេកអរក្នុងរូបដែលញ៉ាំងសត្វឱ្យកើតក្នុងអបាយ”*** *ជាដើម សកវាទីពោលដើម្បីចោទដោយអំណាចនៃលទ្ធិរបស់បរវាទីថា “ព្រះសោតាបន្នលះទុគ្គតិមិនបាន” ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ។*

*ពាក្យថា* ***“បុគ្គលអ្នកមានទិដ្ឋិសម្បត្តិ គប្បីចូលដល់នរក”*** *ជាដើម អធិប្បាយថា លោករមែងសម្តែងការលះទុគ្គតិ គឺអបាយភូមិ ៤ ប៉ុណ្ណោះ រមែងសម្តែងការលះតណ្ហាដែលជាហេតុនាំទៅកាន់ទុគ្គតិ, មិនមែនសម្តែងដល់ការលះតណ្ហា មានរូបជាដើម ជាអារម្មណ៍របស់ទុគ្គតិសត្វទាំងឡាយទេ, ព្រោះហេតុដូច្នោះ សេចក្តីនេះ ទើបមិនសម្រេចប្រយោជន៍ឡើយ ៕*

ចប់ទុគ្គតិកថា

## ១០.សត្តមភវិកកថា

## សម្តែងអំពីព្រះសោតាបន្នមានភពទី ៧

*សូម្បីក្នុងការពណ៌នាកថាពោលអំពីព្រះសោតាបន្ន អ្នកមានភពទី ៧ ក៏មានន័យដូចគ្នានេះដែរ គឺដូចគ្នាជាមួយរឿងបុគ្គលអ្នកមានទិដ្ឋិសម្បត្តិនុ៎ះឯង ៕*

ចប់សត្តមភវិកកថា

## រួមកថាដែលមានក្នុងវគ្គនេះ គឺ

*១.សំវរោ កម្មន្តិកថា, ២.កម្មកថា, ៣.សទ្ទោ វិបាកោតិកថា, ៤.សឡាយតនកថា, ៥.សត្តក្ខត្តុំបរមកថា, ៦-៧.កោលំកោលឯកពីជីកថា, ៨.ជីវិតាវោរោបនកថា, ៩.ទុគ្គតិកថា, ១០.សត្តមភវិកកថា ៗ*

**ចប់វគ្គទី ១២**

## វគ្គទី ១៣

## ១.កប្បដ្ឋកថា សម្តែងអំពីអ្នកតាំងនៅរហូតកប្ប

*ឥឡូវនេះ ឈ្មោះថា រឿងកប្បដ្ឋៈ គឺអ្នកតាំងនៅរហូតកប្ប ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយរាជគិរិកៈថា "អ្នកធ្វើសង្ឃភេទ រមែងតាំងនៅក្នុងនរករហូត*

*កប្បទាំងអស់” ដូច្នេះ ព្រោះកាន់យកព្រះសូត្រថា “អ្នកធ្វើសង្ឃភេទនោះ រមែងឆេះនៅក្នុងនរករហូតកប្ប ព្រោះទម្លាយសង្ឃដែលព្រមព្រៀងគ្នា” , ពាក្យសួររបស់សកវាទីថា* ***“អ្នកតាំងនៅរហូតកប្ប”*** *ដូច្នេះ ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ពាក្យថា* ***“កប្បតាំងនៅបានផង ព្រះពុទ្ធឧប្បត្តិឡើងក្នុងលោកផង”*** *នេះ សកវាទីពោលហើយដើម្បីសម្តែងការមិនមានសង្ឃភេទ ដោយវៀរចាកការឧប្បត្តិឡើងរបស់ព្រះពុទ្ធ ។ ពាក្យថា* ***“កប្បតាំងនៅបានផង សង្ឃបែកគ្នាបានផង”*** *ជាដើម សកវាទីពោលដើម្បីសម្តែងថា “បើបុគ្គលអ្នកតាំងនៅអស់កប្បនោះ រមែងតាំងនៅអស់កប្បទាំងអស់មែន, គេក៏ត្រូវធ្វើកម្មនោះ តាំងអំពីកប្បដែលកំពុងកកើតឡើងមកហើយ ក៏កើតក្នុងនរកនោះ” ។ ពាក្យថា* ***“គប្បីតាំងនៅរហូតកប្បចំណែកដែលជាអតីត”*** *ជាដើម មានអធិប្បាយដូចពាក្យដែលពោលទុកហើយ ក្នុងពេលមុននុ៎ះឯង ។*

*ក្នុងបញ្ហាថា* ***“បុគ្គលអ្នកតាំងនៅរហូតកប្បជាអ្នកមានឫទ្ធិឬ ?”*** *បរវាទីឆ្លើយបដិសេធ ព្រោះសំដៅយកឫទ្ធិដែលសម្រេចដោយការចម្រើនភាវនា ។ តែរមែងឆ្លើយតបក្នុងលទ្ធិរបស់បរវាទី សំដៅយកឫទ្ធិដែលសម្រេចដោយការកើតរបស់អ្នកតាំងនៅរហូតកប្បនោះ ។ ពាក្យថា* ***“បុគ្គលអ្នកតាំងនៅរហូតកប្ប បានចម្រើនឆន្ទិទ្ធិបាទ”*** *ជាដើម ពាក្យនេះ ត្រឹមតែជាលទ្ធិថា “ឈ្មោះថា អ្នកមានឫទ្ធិ ព្រោះជាឫទ្ធិដែលសម្រេចអំពីការកើត” ,*

*សកវាទីពោលដើម្បីចោទថា “បើឫទ្ធិរបស់អ្នកមានឫទ្ធិសម្រេចអំពីការកើតមានមែន បុគ្គលទាំងនេះ ក៏គប្បីចម្រើនឥទ្ធិបាទបាន” ។ ព្រះសូត្រថា* ***“អ្នកទម្លាយសង្ឃឱ្យបែកបាក់គ្នា នឹងត្រូវទៅអបាយ ឬនរក”*** *លោកពោលសំដៅយកអាយុកប្ប គឺថា លោកចែកកប្ប ១ ចេញជា ៨០ ចំណែក, សត្វនរកនោះ គប្បីតាំងនៅអស់កាល ប្រមាណចំណែកមួយ អំពី ៨០ ចំណែកនោះ, ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនសម្រេចប្រយោជន៍ក្នុងរឿងនេះទេ ៕*

ចប់កប្បដ្ឋកថា

# ២.កុសលចិត្តប្បដិលាភកថា

## សម្ដែងអំពីការត្រឡប់បានកុសលចិត្ត

*ឥឡូវនេះ ឈ្មោះថា រឿងការត្រឡប់បានកុសលចិត្ត របស់អ្នកតាំងនៅរហូតកប្ប បានដល់ អ្នកកើតក្នុងនរក; ក្នុងលទ្ធិរបស់សកវាទីរមែងបានចំពោះកាមាវចរចិត្តប៉ុណ្ណោះ; ក៏បុគ្គលណាមិនគប្បីរារាំងការកើតក្នុងនរកនោះ, បុគ្គលនោះ រមែងមិនបានចំពោះមហគ្គតកុសល ឬលោកុត្តរកុសលឡើយ; ម្យ៉ាងទៀត ជនទាំងឡាយណា មិនធ្វើការវិភាគនេះ មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា* ***“បុគ្គលអ្នកតាំងនៅរហូតកប្បនោះ គឺអ្នកកើតក្នុងនរក រមែងមិនមានកុសលចិត្ត”*** *ដោយ*

មិនប្លែកគ្នាឡើយ, ពាក្យសួររបស់បរវាទី ដើម្បីទម្លាយលទ្ធិនោះ ដោយការសម្តែងវិភាគ គឺការញែកប្រភេទនៃកុសលតែម្យ៉ាងៗ អំពីកុសលចិត្តទាំងនោះ ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕

ចប់កុសលចិត្តប្បដិលាភកថា

## ៣.អនន្តរាបយុត្តកថា

## សម្តែងអំពីបុគ្គលអ្នកប្រើឱ្យធ្វើអនន្តរិយកម្ម

ឥឡូវនេះ ឈ្មោះថា រឿងបុគ្គលអ្នកប្រើឲ្យធ្វើអនន្តរិយកម្ម គឺអ្នកបង្គាប់ឲ្យធ្វើនូវអនន្តរិយកម្ម ៖

ក្នុងរឿងនោះ បុគ្គលណាបង្គាប់ឲ្យធ្វើអនន្តរិយកម្ម មានការសម្លាប់មាតាជាដើម ដែលឲ្យផលដោយមិនមានភពជាទៃខណ្ឌក្នុងចន្លោះ ដោយប្រភេទនៃខន្ធ បុគ្គលនោះ ឈ្មោះថា អ្នកប្រើឲ្យធ្វើអនន្តរិយកម្ម; ក្នុងរឿងនេះ សកវាទីធ្វើការសន្និដ្ឋាន គឺការយល់ឃើញក្នុងលទ្ធិរបស់ខ្លួនថា "បុគ្គលណានឹងធ្វើកម្មនោះ ដែលគេបញ្ជាដោយពាក្យបង្គាប់ដែលពិតប្រាកដ, បុគ្គលនោះជាអ្នកទៀង ក្នុងផ្លូវដែលខុស គេរមែងជាអ្នកមិនគួរដើម្បីចុះកាន់សម្មត្តនិយាម ព្រោះភាវៈនៃចេតនាដែលញុំាងប្រយោជន៍ឲ្យសម្រេចកើតឡើងហើយ; តែថា បុគ្គលណានឹងធ្វើនូវកម្មដែលគេបញ្ជានោះ ដោយពាក្យ

*បន្ទាប់ដែលមិនពិត, បុគ្គលនោះ មិនឈ្មោះថា ជាអ្នកទៀងក្នុងផ្លូវដែលខុសទេ គេរមែងជាអ្នកគួរដើម្បីចុះកាន់សម្មត្តនិយាម ព្រោះភាវៈនៃចេតនាដែលសម្រេចប្រយោជន៍នោះ នៅមិនទាន់កើតឡើង” ។*

*ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា “បុគ្គលឈ្មោះថា ជាអ្នកមិនគួរដើម្បីចុះកាន់សម្មត្តនិយាមទាំងនោះ សូម្បីពាក្យបន្ទាប់នោះ ពិតក៏ដោយ មិនពិតក៏ដោយ” ដូច្នេះ, ដើម្បីទម្លាយលទ្ធិនៃជនទាំងនោះ ទើបសកវាទីឲ្យបរវាទីសួរខ្លួនមុនថា* ***“បុគ្គលអ្នកប្រើឱ្យធ្វើអនន្តរិយកម្ម”*** *ជាដើម ព្រោះហេតុនោះ ពាក្យសួរដំបូងក្នុងបញ្ហានេះ ទើបជារបស់បរវាទី, ពាក្យឆ្លើយតបសំដៅយកការមិនមានចេតនាដែលញ៉ាំងប្រយោជន៍ឲ្យសម្រេច ជារបស់សកវាទី ។ លំដាប់នោះ បរវាទីអ្នកសម្គាល់ថា បុគ្គលនោះ ជាអ្នកទៀងក្នុងផ្លូវដែលខុស ព្រោះការបន្ទាប់ឲ្យធ្វើកម្ម មានការសម្លាប់មាតាជាដើមនោះមែន, ព្រោះហេតុដូច្នោះ ទើបសួរបញ្ហាថា* ***“(គេ) គប្បីចុះកាន់មិច្ឆត្តនិយាម”*** *ជាដើម; សកវាទីឆ្លើយបដិសេធថា* ***“មិនគប្បីពោលយ៉ាងនេះទេ”*** *ដោយសំដៅយកការមិនចុះកាន់និយាមទាំងពីររបស់បុគ្គលតែម្នាក់ ។ ពាក្យថា* ***“កម្មនោះ”*** *បានដល់អនន្តរិយកម្ម មានការសម្លាប់មាតាជាដើម ។ ក្នុងបញ្ហានោះ សកវាទីឆ្លើយតបថា* ***“មែន”*** *សំដៅយកពាក្យដែលបន្ទាប់មិនប្រាកដ ។ ព្រោះថា សេចក្តីធុញទ្រាន់ និងសេចក្តីក្តៅក្រហាយ រមែងកើតឡើងដល់អ្នកបបួល*

ដឹកនាំធ្វើពាក្យបង្គាប់មិនប្រាកដថា ***"យើងធ្វើកម្មដែលមិនសមគួរមែនពិត"*** ដូច្នេះ ។ ពាក្យថា ***"ប្រសិនបើ"*** ជាដើម ដែលបរវាទីពោល ក៏ដើម្បីនឹងឲ្យលទ្ធិតាំងទុកដោយការកាន់យកនូវហេតុ ត្រឹមតែការកើតឡើងនៃសេចក្ដីមិនពេញចិត្ត ។

ឥឡូវនេះ ជាពាក្យសួររបស់សកវាទីថា ***"បុគ្គលអ្នកប្រើឱ្យធ្វើអនន្តរិយកម្ម ជាអ្នកមិនគួរដើម្បីចុះកាន់សម្មត្តនិយាម"*** ព្រោះកាន់យកបុគ្គលនោះឯង ដែលបរវាទីឆ្លើយបដិសេធដល់ការចុះកាន់សម្មត្តនិយាម របស់អ្នកបបួលដឹកនាំក្នុងការធ្វើអនន្តរិយកម្ម សូម្បីដោយពាក្យបង្គាប់ដែលមិនប្រាកដ ។ ពាក្យឆ្លើយតបជារបស់បរវាទី រមែងមានដោយអំណាចនៃលទ្ធិរបស់ខ្លួន ។ លំដាប់នោះ សកវាទីដើម្បីចោទបរវាទីនោះថា "បុគ្គលអ្នកមិនគួរចុះកាន់សម្មត្តនិយាម ជាអ្នកធ្វើកម្ម មានការសម្លាប់មាតាជាដើម, ក៏កម្មទាំងនោះ បុគ្គលនោះធ្វើហើយឬ ?" ទើបពោលពាក្យថា ***"គេបានធ្វើការផ្ដាច់ជីវិតមាតា"*** ជាដើម ។ បរវាទីកាលមិនឃើញការធ្វើដូច្នោះ ព្រោះការមិនបៀតបៀនជនទាំងនោះ ទើបឆ្លើយបដិសេធថា "មិនគប្បីពោលយ៉ាងនេះទេ" ។

ពាក្យថា ***"លើកលែងកម្មនោះចេញ"*** លោកពោលសំដៅយកកម្មជាពាក្យបង្គាប់ដែលមិនប្រាកដ អធិប្បាយថា បុគ្គលអ្នកហាមពាក្យបង្គាប់ថា ***"ក៏កម្មនុ៎ះឯង យើងបង្គាប់ហើយ សូមលោកកុំធ្វើ"*** ដូច្នេះ ឈ្មោះថា

*ពាក្យបន្តាប់នោះ ខ្លួនលុបបំបាត់ចេញហើយ ព្រោះពាក្យបន្តាប់នោះ ខ្លួនដកចេញហើយនុ៎ះឯង, ទើបឈ្មោះថា ខ្លួនកម្ចាត់ភាពមិនពេញចិត្ត និងសេចក្តីក្តៅក្រហាយចិត្តបាន ក្នុងបញ្ហានេះ; កាលបើមាន សេចក្តីយ៉ាងនេះ បរវាទីអ្នកសម្គាល់នូវពាក្យបន្តាប់ដំបូងប៉ុណ្ណោះ ជាសទ្ទជាតិបន្តាប់ប្រាកដក្នុងបញ្ហានោះ ទើបត្រូវឆ្លើយតបថា “ មែន” ។ លំដាប់នោះ ទើបសកវាទីឲ្យបរវាទីទទួលពាក្យដែលសភាពនៃកម្មនោះ ជាកម្មដែលដកហើយ ទើបពោលពាក្យថា* ***“ ប្រសិនបើ”*** *ជាដើម ដើម្បីញ៉ាំងលទ្ធិរបស់ខ្លួនឲ្យតាំងទុក ។ ក្នុងបញ្ហាទីបំផុតថា* ***“ បុគ្គលអ្នកប្រើឱ្យធ្វើអនន្តរិយកម្ម”*** *ម្តងទៀត ជាពាក្យសួររបស់បរវាទីដែលដូចបញ្ហាដំបូង, ពាក្យឆ្លើយតបជារបស់សកវាទី ។ ពាក្យសាកសួរថា* ***“ គេបានប្រើឱ្យធ្វើអនន្តរិយកម្មនោះហើយ មិនមែនឬ ?”*** *ជារបស់បរវាទី, ពាក្យឆ្លើយតបជារបស់សកវាទី សំដៅយកការដឹកនាំហើយក្នុងកាលមុនអំពីការដកពាក្យ ។ ការតាំងលទ្ធិរបស់បរវាទី ដោយពាក្យថា* ***“ ប្រសិនបើ”*** *ជាដើម បានដល់ ដោយអំណាចនៃពាក្យបន្តាប់ដែលមិនប្រាកដ ព្រោះកាន់យកហេតុត្រឹមតែភារៈជាអ្នកបន្តាប់មុនរបស់អ្នកដឹកនាំប៉ុណ្ណោះ ។ ក៏លទ្ធិនេះ រមែងតាំងនៅមិនបានឡើយ ព្រោះតាំងទុកដោយមិនពិចារណា ៕*

ចប់អនន្តរាបយុត្តកថា

## ៤.និយតស្ស និយាមកថា

## សម្តែងអំពីនិយាមរបស់បុគ្គលអ្នកទៀងហើយ

ឥឡូវនេះ ឈ្មោះថា រឿងនិយាមរបស់បុគ្គលអ្នកទៀងហើយ ៖

ក្នុងរឿងនោះ និយាម គឺការទៀង មាន ២ គឺអនន្តរិយកម្ម ឈ្មោះថា មិច្ឆត្តនិយាម និងអរិយមគ្គ ឈ្មោះថា សម្មត្តនិយាម, វៀរនិយាម ២ នេះចេញ ធម៌ដទៃ ឈ្មោះថា និយាមរមែងមិនមាន ។ មែនពិត តេភូមិកធម៌ គឺធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស សូម្បីទាំងអស់ ឈ្មោះថា អនិយតធម៌ គឺធម៌ដែលមិនទៀង, សូម្បីតែធម៌ដែលប្រកបដោយតេភូមិកធម៌ទាំងនោះ ក៏ឈ្មោះថា អនិយតធម៌ទាំងអស់ ។ ម្យ៉ាងទៀត ព្រះពុទ្ធជាម្ចាស់ទាំងឡាយ មិនព្យាករការចុះកាន់និយាមធម៌ដោយពាក្យថា ***“សត្វនេះនឹងសម្រេចពោធិញ្ញាណក្នុងអនាគតកាល”*** ដោយកម្លាំងនៃញាណរបស់ព្រះអង្គ, តែព្រះពោធិសត្វ លោកហៅថា ***និយតបុគ្គល*** ព្រោះជាអ្នកមានបុណ្យច្រើន ។ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិរបស់និកាយបុព្វសេលិយៈថា “ និយតពោធិសត្វ រមែងចុះកាន់និយាម” ដូច្នេះ ព្រោះបំណងយកពាក្យថា “ព្រះពោធិសត្វដែលកើតក្នុងភពចុងក្រោយ ជាអ្នកអាចដើម្បីត្រាស់ដឹងក្នុងជាតិនោះបាន” ដោយកាន់យកវោហារនេះ មានប្រការដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។

*ពាក្យថា **"បុគ្គលអ្នកទៀងហើយ ក្នុងមិច្ឆត្តៈ"** ជាដើម សកវាទី ពោលដើម្បីសម្ដែងភាវៈជានិយាមម្យ៉ាង របស់អ្នកទៀងហើយ ដោយនិយាមម្យ៉ាង ។ ពាក្យថា **"ញ៉ាំងមគ្គឱ្យកើតមុន"** ជាដើម សកវាទីពោលដើម្បីសម្ដែងប្រភេទនៃនិយាម ។ ពាក្យថា **"បុគ្គលញ៉ាំងសតិបដ្ឋាន"** ជាដើម សកវាទីពោលដើម្បីសម្ដែងប្រភេទនៃធម៌ក្នុងនិយាម សូម្បីតែម្យ៉ាង ។ ពាក្យថា **"ព្រះពោធិសត្វជាអ្នកគួរ"** ជាដើម លោកសម្ដែងនូវភាវៈនៃព្រះពោធិសត្វ ជាអ្នកអាចត្រាស់ដឹងតែម្យ៉ាង, មិនមែនសម្ដែងការចុះកាន់និយាមរបស់និយតបុគ្គលទេ, ព្រោះហេតុដូច្នោះ ពាក្យនេះ ទើបមិនសម្រេចប្រយោជន៍ឡើយ ។ មែនពិត ព្រះពោធិសត្វនោះ ជាអ្នកមិនទៀងដោយនិយតធម៌ម្យ៉ាង ក្នុងពេលមុនមក ក៏ពិតមែនហើយ, ប៉ុន្តែ លោកក៏ចុះកាន់សម្មត្តនិយាមហើយ ដោយការឃើញសច្ចៈត្រង់គល់ពោធិ៍ មានប្រការដូច្នេះ ៕*

ចប់និយតស្ស និយាមកថា

## ៥.នីវុតកថា

## សម្ដែងអំពីអ្នកមានចិត្តដែលនីវរណៈគ្របសង្កត់ហើយ

*ឥឡូវនេះ ឈ្មោះថា រឿងរបស់អ្នកមានចិត្តដែលនីវរណៈគ្របសង្កត់ហើយ ៖*

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយខុត្តរាបថកៈថា "បុគ្គលដែលត្រូវនីវរណៈទាំងឡាយ គ្របសង្កត់ហើយ បិទបាំងហើយ រារាំងហើយ រមែងលះនីវរណៈ ព្រោះភាវៈនៃបុគ្គលដែលបរិសុទ្ធហើយ មិនមានវត្ថុដែលគួរធ្វើឲ្យបរិសុទ្ធ" ដូច្នេះ, ពាក្យសួររបស់សកវាទីថា ***"បុគ្គលអ្នកមានចិត្តដែលនីវរណៈគ្របសង្កត់ហើយ"*** ជាដើម សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា ***"បុគ្គលជាអ្នកមានចិត្តដែលរាគៈគ្របសង្កត់ហើយ"*** ជាដើម សកវាទីពោលដើម្បីសម្តែងទោសក្នុងការលះនីវរណៈ របស់អ្នកមានចិត្តដែលនីវរណៈគ្របសង្កត់ហើយ ។ ពាក្យថា ***"បុគ្គលអ្នកមានចិត្តបរិសុទ្ធផូរផង់"*** ជាដើម សកវាទីពោលដើម្បីសម្តែងសមុច្ឆេទវិសុទ្ធិ នៃអ្នកបរិសុទ្ធហើយក្រៅអំពីវិក្ខម្ភនវិសុទ្ធិ ។ ពាក្យថា ***"កាលភិក្ខុនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ"*** ជាដើម លោករមែងសម្តែងការអស់ទៅនៃអាសវៈរបស់អ្នកដឹង អ្នកឃើញយ៉ាងនេះ, មិនមែនសម្តែងដល់ការលះនីវរណៈរបស់អ្នកមានចិត្តដែលនីវរណៈកំពុងគ្របសង្កត់, ព្រោះហេតុដូច្នោះ សេចក្តីនេះ ទើបមិនសម្រេចប្រយោជន៍ដោយប្រការដូច្នេះឡើយ ៕

ចប់នីវុតកថា

## ៦.សម្មុខីភូតកថា

## សម្ដែងអំពីអ្នកមានចិត្តសម្បូណ៌ដោយសញ្ញោជនៈ

*ឥឡូវនេះ ឈ្មោះថា រឿងអ្នកមានចិត្តសម្បូណ៌ដោយសញ្ញោជនៈ ៖*

*ក្នុងរឿងនោះ បុគ្គលអ្នកមានសញ្ញោជនៈ រមែងជាអ្នកចូលដល់នូវភាពជាអ្នកមានចិត្តសម្បូណ៌ដោយសញ្ញោជនៈទាំងឡាយ គឺជាអ្នកបរិបូណ៌ដោយសញ្ញោជនៈទាំងនោះ ។ ពាក្យដ៏សេសក្នុងទីនេះ ដូចនឹងរឿងអ្នកត្រូវនីវរណៈគ្របសង្កត់ហើយនុ៎ះដែរ ៕*

ចប់សម្មុខីភូតកថា

---

## ៧.សមាបន្នោ អស្សាទេតិកថា

## សម្ដែងអំពីអ្នកចូលសមាបត្តិរមែងត្រេកអរ

*ឥឡូវនេះ ឈ្មោះថា រឿងអ្នកចូលសមាបត្តិ រមែងត្រេកអរ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា "អ្នកចូលឈានរមែងត្រេកអរ និងការត្រេកអរក្នុងឈាននោះ របស់អ្នកនោះ ជាអារម្មណ៍របស់ឈាន" ព្រោះអាស្រ័យព្រះបាលីថា "ភិក្ខុក្នុងធម្មវិន័យនេះ... សម្រេចបឋមជ្ឈាន, អ្នកត្រេកអរក្នុងឈាននោះ"[២៦] ដូច្នេះ ពាក្យសួររបស់សកវាទីថា "អ្នកចូលសមាបត្តិ"*

---

[២៦] អំ. ចតុក្ក. ។

*ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ក្នុងបញ្ហាទាំងឡាយថា* ***"ឈាននោះ ជាអារម្មណ៍របស់ឈាននោះឬ ?"*** *បរវាទីកាលមិនឃើញនូវសភាពនៃឈាននោះឯង ជាអារម្មណ៍របស់ឈាននោះ ទើបឆ្លើយបដិសេធដោយខ្លាចខុសចាកព្រះសូត្រ, រមែងឆ្លើយតបដោយពាក្យក្នុងព្រះសូត្រថា* ***"អ្នកសម្រេចបឋមជ្ឈាន អ្នកត្រេកអរក្នុងឈាននោះ"*** *ដូច្នេះ ។ ព្រះសូត្រថា* ***"អ្នកត្រេកអរក្នុងឈាននោះ"*** *សេចក្ដីថា ចេញចាកឈានហើយ ទើបញ៉ាំងការត្រេកអរក្នុងឈាននោះ ឲ្យសម្រេចបាន, មិនមែនសំដៅដល់ការត្រេកអរក្នុងឈាន ក្នុងខណៈដែលកំពុងចូលឈាន មានឈានជាអារម្មណ៍ទេ, ព្រោះហេតុដូច្នោះ ព្រះសូត្រនេះទើបមិនមែនជាខអាងថា "អ្នកកំពុងចូលឈាន ដែលមានឈាននោះជាអារម្មណ៍ រមែងត្រេកអរក្នុងឈាននោះមាន ព្រោះពេលកំពុងចូលឈានមានឈាននោះជាអារម្មណ៍ហើយ នឹងមានអារម្មណ៍កើតឡើងមកព្រមៗ គ្នាទៀតមិនបានឡើយ"៕*

ចប់សមាបន្នោ អស្សាទេតិកថា

---

## ៨.អសាតរាគកថា

## សម្ដែងអំពីការត្រេកអរក្នុងវត្ថុដែលមិនពេញចិត្ត

*ឥឡូវនេះ ឈ្មោះថា រឿងការត្រេកអរក្នុងវត្ថុដែលមិនពេញចិត្ត*

គឺការត្រេកអរក្នុងទុក្ខវេទនា ៖

ក្នុងរឿងនោះ ព្រះសូត្រថា "បុគ្គល... សោយវេទនាយ៉ាងណាមួយ សុខក៏ដោយ ទុក្ខក៏ដោយ មិនមែនទុក្ខ មិនមែនសុខក៏ដោយ, គេត្រេកត្រអាល ងប់ជ្រប់ ជាប់ជំពាក់ នឹងវេទនានោះ"[២៧] ដូច្នេះ ព្រះមានព្រះភាគត្រាស់ហើយដោយអំណាចនៃការត្រេកត្រអាល ក្នុងវត្ថុដែលបុគ្គលធ្លាប់ប្រសព្វ (យល់ឃើញ) មកហើយ ។

ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា "សូម្បីការត្រេកត្រអាលក្នុងទុក្ខវេទនា ដោយអំណាចនៃការពេញចិត្តក្នុងរាគៈ" ព្រោះអាស្រ័យពាក្យក្នុងព្រះសូត្រថា "បុគ្គលនោះ ប្រសព្វការត្រេកអរក្រៃលែង រមែងមាន ព្រោះហេតុណា, ព្រោះហេតុនោះ ការត្រេកអរក្នុងវត្ថុដែលពេញចិត្ត ក៏ត្រូវតែមាន" ដូច្នេះ, ពាក្យសួររបស់សកវាទីថា "ការត្រេកអរក្នុងវត្ថុដែលមិនពេញចិត្ត" ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា "ការត្រេកអរក្នុងវត្ថុដែលមិនពេញចិត្ត" សេចក្ដីថា បរវាទីឆ្លើយតបថា "**មែន**" ដោយអំណាចនៃលទ្ធិ ព្រោះកិលេសជាគ្រឿងធ្វើចិត្តឲ្យសៅហ្មង ក្នុងបទថា "ឱហ្ន៎ ! ការត្រេកអរនុ៎ះឯង គប្បីមានដល់

[២៧] ម. មូ. ។

*យើង ក្នុងការសោយទុក្ខដែលមិនពេញចិត្ត” ។ ពាក្យដ៏សេសក្នុងទីនេះមានអត្ថងាយស្រួលមែនពិត ។*

*ម្យ៉ាងទៀត ក្នុងព្រះសូត្រថា “គេត្រេកត្រអាល ងប់ជ្រប់ ជាប់ជំពាក់នឹងវេទនានោះ” អធិប្បាយថា ក៏ឈ្មោះថា ការកើតឡើងនៃរាគៈ រមែងត្រឡប់មកប្រារព្ធទុក្ខវេទនានោះឯង រមែងមិនមាន, តែកាលបើកាន់យកដោយចំណែករួមហើយ បុគ្គលកាលពិចារណាឃើញនូវធម៌ ដែលមានការសោយអារម្មណ៍ជាលក្ខណៈ ឬនូវទុក្ខវេទនានោះឯង ដោយភាវៈជាអត្តា គេរមែងត្រេកអរនឹងវេទនានោះ ដោយការត្រេកអរចំពោះវត្ថុដែលខ្លួនជ្រាបហើយ មិនមែនត្រេកអរក្នុងការប្រែប្រួលមកជាទុក្ខវេទនាទេ, បុគ្គលដែលត្រូវទុក្ខវេទនាគ្របសង្កត់ហើយ សូម្បីប្រាថ្នានូវកាមសុខដែលជាចំណែកផុយគ្នានឹងទុក្ខវេទនានោះ ក៏ឈ្មោះថា រមែងត្រេកអរចំពោះទុក្ខវេទនាដែរ ។ ការត្រេកអរក្នុងទុក្ខវេទនានៃបញ្ហានេះ រមែងមានដោយប្រការដូច្នេះ; ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនមែនជាខសាកល្បងការត្រេកអរក្នុងវត្ថុដែលមិនពេញចិត្ត ដោយប្រការដូច្នេះឡើយ ។*

ចប់អសាតរាគកថា

.............................................

## ៩.ធម្មតណ្ហា អព្យាកតាតិកថា

## សម្តែងអំពីធម្មតណ្ហាជាអព្យាក្រឹត

*ឥឡូវនេះ ឈ្មោះថា រឿងធម្មតណ្ហាជាអព្យាក្រឹត ៖*

*ក្នុងបញ្ហានោះ បណ្ដាតណ្ហាទាំង ៦ នេះ គឺរូបតណ្ហា ។ល។ ធម្មតណ្ហា តណ្ហាដែលជាខចុងបំផុតនៃតណ្ហាទាំងអស់នេះ លោកហៅថា* ***ធម្មតណ្ហា*** *ព្រោះហេតុណា, ព្រោះហេតុនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈថា "ធម្មតណ្ហា គប្បីជាអព្យាក្រឹត" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ អត្ថនៃបញ្ហាទាំងឡាយដ៏សេស គប្បីជ្រាបតាមព្រះបាលីចុះ ។ សូម្បីតណ្ហាទាំង ៦ លោកសម្ដែងទុកបំប្រួញជា ៣ ប្រភេទ មានកាមតណ្ហាជាដើម ។ តណ្ហាដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ដោយអំណាចនៃការត្រេកអរក្នុងកាម ឈ្មោះថា* ***កាមតណ្ហា*** *។ តណ្ហាដែលកើតព្រមជាមួយនឹងសស្សតទិដ្ឋិក្នុងការយល់ឃើញថា "អត្តា និងលោក មាន" ដូច្នេះ ឈ្មោះថា* ***ភវតណ្ហា*** *។ តណ្ហាដែលកើតព្រមជាមួយនឹងឧច្ឆេទទិដ្ឋិក្នុងការយល់ឃើញថា "អត្តា និងលោក មិនមាន" ដូច្នេះ ឈ្មោះថា* ***វិភវតណ្ហា*** *។ បទថា* ***"វាជាតណ្ហាក្នុងធម៌ មិនមែនឬ ?"*** *នេះ រមែងសម្ដែងដល់ការប្រព្រឹត្តទៅរបស់តណ្ហា ដោយប្រារព្ធធម្មារម្មណ៍, មិនមែនសម្ដែងដល់សភាពនៃធម្មតណ្ហានោះ ជាអព្យាក្រឹតទេ, ព្រោះហេតុដូច្នោះ ពាក្យនេះ ទើបមិនមែនជាខអាងថា "តណ្ហាជាអព្យាក្រឹត" ដូច្នេះឡើយ ៕*

ចប់ធម្មតណ្ហាអព្យាកតាតិកថា

## ១០.ធម្មតណ្ហា នទុក្ខសមុទយោតិកថា

## សម្តែងអំពីធម្មតណ្ហាមិនមែនជាទុក្ខសមុទ័យទេ

*ឥឡូវនេះ ឈ្មោះថា រឿងធម្មតណ្ហាមិនមែនជាហេតុឲ្យកើតទុក្ខទេ ៖*

*សូម្បីក្នុងរឿងនេះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈនុ៎ះឯងថា “ព្រះមានព្រះភាគត្រាស់ថា ‘តណ្ហានោះ ជាធម្មតណ្ហា’ ព្រោះហេតុណា, ព្រោះហេតុនោះ តណ្ហានោះ ទើបមិនមែនជាហេតុឲ្យកើតទុក្ខទេ” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងមុននោះឯង ៕*

ចប់ធម្មតណ្ហា នទុក្ខសមុទយោតិកថា

## រួមកថាដែលមានក្នុងវគ្គនេះ គឺ

*១.កប្បដ្ឋកថា, ២.កុសលចិត្តប្បដិលាភកថា, ៣.អនន្តរាបយុត្តកថា, ៤.និយតស្ស និយាមកថា, ៥.នីវុតកថា, ៦.សម្មុខីភូតកថា, ៧.សមាបន្នោ អស្សាទេតិកថា, ៨.អសាតរាគកថា, ៩.ធម្មតណ្ហា អព្យាកតាតិកថា, ១០.ធម្មតណ្ហា នទុក្ខសមុទយោតិកថា ។*

**ចប់វគ្គទី ១៣**

## វគ្គទី ១៤

# ១.កុសលាកុសលបដិសន្ធានកថា

## សម្តែងអំពីការបន្តរបស់កុសល និងអកុសល

*ឥឡូវនេះ ឈ្មោះថា រឿងការបន្តរបស់កុសល និងអកុសល ៖*

*ក្នុងរឿងនោះ កុសល ឈ្មោះថា កើតឡើងក្នុងលំដាប់នៃអកុសល ឬអកុសល ឈ្មោះថា កើតឡើងក្នុងលំដាប់នៃកុសល រមែងមិនមាន ព្រោះហេតុដូច្នោះ ការបន្តរបស់កុសល និងអកុសលទាំងនោះ ទើបមិនប្រកបនូវគ្នានឹងគ្នា គឺមិនលាយគ្នាឡើយ ។*

*ម្យ៉ាងទៀត ជនទាំងឡាយណា កាន់លទ្ធិដូចលទ្ធិនិកាយមហាសង្ឃិកៈថា "តម្រេក និងការបន្តយនូវតម្រេក មានតែក្នុងវត្ថុមួយ ជាមួយគ្នានោះឯង ព្រោះហេតុណា, ព្រោះហេតុនោះ ធម៌នោះ ទើបឈ្មោះថា បន្តនូវគ្នានឹងគ្នា" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។*

*ពាក្យទាំងពីរ គឺ* **អាវជ្ជនា** *= ការនឹក,* **បណិធិ** *= ការតាំងចិត្ត, ជាឈ្មោះរបស់អាវជ្ជនចិត្តនោះឯង ។ មែនពិត ឈ្មោះថា* ***អាវជ្ជនៈ*** *ព្រោះអត្ថថា ញ៉ាំងភវង្គចិត្តនោះ ឲ្យឃ្លាតទៅ ។ ឈ្មោះថា* ***បណិធិ*** *ព្រោះអត្ថថា រមែងតម្រង់ គឺតាំងចិត្តទុកក្នុងអារម្មណ៍ដទៃ ក្រៅអំពីអារម្មណ៍ របស់ភវង្គ ។ ពាក្យថា* ***"កុសលកើតឡើង បានដល់ អ្នកមិននឹកដល់"*** *សេចក្តីថា សកវាទី*

*រមែងសួរដោយពាក្យថា “កុសលដែលកើតបន្តក្នុងលំដាប់ នៃអកុសលនោះឯង, កុសលនោះ រមែងកើតដល់អ្នកមិននឹកឬ ?” ចំណែកបរវាទីកាលមិនឃើញការកើតឡើងនៃកុសល ដោយវៀរចាកការនឹក ទើបឆ្លើយបដិសេធ ។ ពាក្យថា* ***“កុសលកើតឡើង បានដល់ អ្នកធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយនៃប្រាជ្ញាឬ ?”*** *ដូច្នេះ លោកពោលដើម្បីចោទថា “បើកុសលគប្បីកើតក្នុងលំដាប់នៃអកុសលមែន, កុសលនោះ ក៏គប្បីកើតព្រោះមនសិការដោយឧបាយដ៏ត្រូវទំនងនៃប្រាជ្ញា ដោយអាវជ្ជនៈរបស់អកុសលមែនពិត” ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ។ ពាក្យថា* ***“តម្រេកក្នុងវត្ថុណា ការបន្ធូរតម្រេក ក្នុងវត្ថុនោះ”*** *ជាដើម រមែងសម្តែងនូវការកើតឡើងនៃចិត្តមានរាគៈ និងចិត្តដែលប្រាសចាករាគៈក្នុងអារម្មណ៍តែម្យ៉ាងជាមួយគ្នា, មិនមែនសម្តែងនូវសភាពនៃកុសល និងអកុសលមានក្នុងលំដាប់នៃគ្នានឹងគ្នាទេ, ព្រោះហេតុដូច្នោះ ពាក្យនេះ ទើបមិនមែនជាឧសាធកៈថា កុសលមានក្នុងលំដាប់នៃអកុសល ឬអកុសលមានក្នុងលំដាប់នៃកុសល ដោយប្រការដូច្នេះ ៕*

ចប់កុសលាកុសលបដិសន្ធហានកថា

## ២.សឡាយតនុប្បត្តិកថា

### សម្តែងអំពីការកើតឡើងនៃសឡាយតនៈ

ផ្លូវនេះ ឈ្មោះថា រឿងការកើតឡើងនៃសឡាយតនៈ គឺអាយតនៈ ខាងក្នុង ៦ ៖

ក្នុងរឿងនោះ អាយតនៈខាងក្នុង ៦ របស់ឱបបាតិកៈកំណើត ទាំងឡាយ រមែងកើតឡើងប្រកបជាមួយបដិសន្ធិចិត្តដែលស្វែងរកការកើត នោះឯង ។ ក្នុងបណ្ដាអាយតនៈខាងក្នុង ៦ សម្រាប់គព្ភសេយ្យកៈទាំង ឡាយ មាន ***មនាយតនៈ*** និង ***កាយាយតនៈ*** ប៉ុណ្ណោះ កើតឡើងព្រម ជាមួយបដិសន្ធិចិត្ត, ចំណែកអាយតនៈ ៤ ដ៏សេស រមែងកើតឡើង ក្នុង រាត្រី ៧ និង ៧ (សំដៅសេចក្ដីថា រៀងរាល់សប្ដាហ៍), លទ្ធិរបស់សកវាទីថា "អាយតនៈទាំងនោះ កាន់យកកំណើតថ្មី ដោយកម្មបែបណា, ព្រោះសភាព នៃកម្មបែបនោះឯង ឬថា កម្មយ៉ាងដទៃដែលខ្លួនធ្វើហើយ" ។

ម្យ៉ាងទៀត ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិ នៃនិកាយបុព្វសេលិយៈ និងអបរសេលិយៈថា "អាយតនៈខាងក្នុង ៦ ដែលជាពូជ រមែងកើតក្នុងផ្ទៃរបស់មាតា ក្នុងខណៈនៃបដិសន្ធិនោះឯង ព្រោះកើតអំពីកម្មជាមួយគ្នា ដូចពន្លកនៃដើមឈើជាដើម ដែលបែកមែក បែកធាងសម្បូណ៌ហើយ" ដូច្នេះ, ពាក្យសួររបស់សកវាទីថា ***"អាយតនៈ ៦"*** ជាដើម សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យថា ***"បុគ្គលមានអវយវៈតូចធំគ្រប់គ្រាន់"*** ជាដើម សកវាទីពោល ដើម្បីចោទដោយពាក្យថា "កាលបើសឡាយតនៈមាន សត្វអ្នកកើតក្នុងគភ៌

ក៏គប្បីមាន" ដូច្នេះ ហើយទើបចុះកាន់ផ្ទៃមាតា ។ ពាក្យសួរថា "***ចក្ខាយតនៈកើតឡើងដល់សត្វអ្នកនៅក្នុងគភ៌នៃមាតាខាងក្រោយ***" ជារបស់បរវាទី ។ ពាក្យសួរខាងមុខថា "មិនគប្បីពោលថា '***សក់ រោម***' ***ធម្មតា កើតដល់សត្វអ្នកនៅក្នុងគភ៌នៃមាតាខាងក្រោយឬ ?***" ជារបស់សកវាទី; ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕

ចប់សឡាយតនុប្បត្តិកថា

---

## ៣.អនន្តរប្បច្ចយកថា សម្តែងអំពីអនន្តរប្បច្ច័យ

*ឥឡូវនេះ ឈ្មោះថា រឿងអនន្តរប្បច្ច័យ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា "វិញ្ញាណទាំងនេះ កើតជាប់តគ្នានឹងគ្នា មិនមានចន្លោះទេ" ព្រោះឃើញការផ្លាស់ប្តូរដោយលឿនរហ័ស ក្នុងការឃើញរូបការឮសំឡេងជាដើម និងក្នុងការរាំច្រៀងជាដើម, ពាក្យសួររបស់សកវាទីថា* "***សោតវិញ្ញាណកើតឡើង ក្នុងលំដាប់នៃចក្ខុវិញ្ញាណឬ ?***" *ព្រោះសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ សកវាទីពោលពាក្យថា* "***សោតវិញ្ញាណមានរូបជាអារម្មណ៍តែម្យ៉ាង***" *(តាមពិត សោតវិញ្ញាណនោះ មានសំឡេងជាអារម្មណ៍ដែរ) ដើម្បីចោទដោយពាក្យថា បើសោតវិញ្ញាណគប្បីកើតក្នុងលំដាប់នៃចក្ខុវិញ្ញាណមែន, សោតវិញ្ញាណនោះ*

ក៏គប្បីមានរូបជាអារម្មណ៍ ដូចវិបាកមនោធាតុ គឺសម្បដិច្ឆន្នចិត្តដែលកើត ក្នុងលំដាប់នៃចក្ខុវិញ្ញាណ ។ ក្នុងបញ្ហាទាំងឡាយថា ***"សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុ និងរូបឬ ?"*** បរវាទីឆ្លើយបដិសេធ ព្រោះមិនមានក្នុងព្រះសូត្រ, តែកាលបរវាទីនោះកំណត់ដល់ការកើតឡើងនៃអនន្តរ-ប្បច្ច័យ ទើបឆ្លើយតបដោយអំណាចនៃលទ្ធិ ។

បទថា ***"ចក្ខុវិញ្ញាណយ៉ាងនោះ សោតវិញ្ញាណ ក៏យ៉ាងនោះដែរឬ ?"*** សេចក្ដីថា សកវាទីរមែងសួរប្រៀបធៀបការកើតជាប់គ្នា របស់បឋមជវន និងទុតិយជវននោះឯង រមែងប្រព្រឹត្តទៅ ព្រោះជាមនោ-វិញ្ញាណ យ៉ាងណា, ចក្ខុវិញ្ញាណនោះឯង កើតជាប់គ្នាជាមួយសោត-វិញ្ញាណដូច្នោះឬ ? គប្បីជ្រាបអត្ថក្នុងចន្លោះទាំងពួង ដោយន័យនេះចុះ ។

ពាក្យថា ***"បុគ្គលខ្លះ រាំច្រៀង"*** ជាដើម រមែងសម្ដែងដល់ការកើតរួមគ្នានៃវិញ្ញាណ ព្រោះការផ្លាស់ប្ដូរទៅដោយល្បឿនរហ័ស ក្នុងការប្រជុំនៃអារម្មណ៍, តែមិនមែនសម្ដែងដល់សភាពនៃវិញ្ញាណទាំងនោះ ជាអនន្តរ-ប្បច្ច័យ គឺកើតជាប់គ្នា ឬកើតក្នុងលំដាប់នៃគ្នានឹងគ្នាទេ, ព្រោះហេតុដូច្នោះបញ្ហានេះ ទើបមិនមែនជាសាធកៈ ដល់សភាពនៃចក្ខុវិញ្ញាណ ជាអនន្តរ-ប្បច្ច័យជាមួយនឹងសោតវិញ្ញាណ ៕

ចប់អនន្តរប្បច្ចយកថា

## ៤.អរិយរូបកថា សម្តែងអំពីអរិយរូប

*ឥឡូវនេះ ឈ្មោះថា រឿងអរិយរូប គឺរូបរបស់ព្រះអរិយៈ ឬរូបជាអរិយៈ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយឧត្តរាបថកៈថា "សម្មាវាចា សម្មាកម្មន្តៈ ជាឧបាទាយរូប គឺរូបជាទីអាស្រ័យ" ព្រោះព្រះបាលីថា* ***"ម្នាលភិក្ខុទាំងឡាយ រូបយ៉ាងណាមួយ គឺមហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ គឺឧបាទាយរូប ២៤"***[២៨] *ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***"អរិយរូបអាស្រ័យមហាភូតរូប"*** *ដូច្នេះ សំដៅដល់ជនទាំងនោះ, បណ្ឌិតគប្បីជ្រាបនូវបទវិគ្រោះនៃពាក្យថា* ***"អរិយរូប"*** *ក្នុងបញ្ហានោះ ដូច្នេះថា រូបនៃព្រះអរិយៈទាំងឡាយ ឈ្មោះថា អរិយរូប, ឬរូប គឺអរិយៈ ឈ្មោះថា* ***អរិយរូប*** *។ ក្នុងបញ្ហានោះ បរវាទីឆ្លើយតបថា* ***មែន*** *ព្រោះតាំងនៅក្នុងលទ្ធិ ។ ត្រូវសកវាទីសួរថា អរិយរូបជាកុសលឬ ក៏ឆ្លើយតបដោយអំណាចនៃលទ្ធិនោះឯង; សូម្បីក្នុងពាក្យថា អរិយរូប ជាអនាសវៈ ជាអាសវៈជាដើម ក៏មានន័យដូចគ្នានេះដែរ ។*

*ព្រះសូត្រថា* ***"រូបយ៉ាងណានីមួយ"*** *ជាដើម អធិប្បាយថា វៀរមហាភូតរូបចេញហើយ រមែងសម្តែងដល់សភាពនៃរូបទាំងឡាយដ៏សេស*

---

[២៨] ម. ឧ. ។

*ជាខបាទាយរូប, មិនមែនសម្ដែងដល់ភាវៈនៃសម្មាវាចា សម្មាកម្មន្តៈទាំងនោះ ជារូបទេ; មែនពិត ភាវៈនៃសម្មាវាចា សម្មាកម្មន្តៈទាំងនោះ មិនសម្រេចជារូបតែម្យ៉ាងទេ, ភាវៈនៃខបាទាយរូបរបស់សម្មាវាចាជាដើមនោះ នឹងមានមកអំពីណា ? ព្រោះហេតុដូច្នោះ ព្រះសូត្រនេះ ទើបមិនសម្រេចដូចពាក្យដែលអាងមកនោះឡើយ ៕*

ចប់អរិយរូបកថា

---

## ៥.អញ្ញា អនុសយោគិកថា សម្ដែងអំពីអនុស័យមានម្យ៉ាង

*ឥឡូវនេះ ឈ្មោះថា រឿងអនុស័យមានម្យ៉ាង គឺដទៃអំពីបរិយុដ្ឋាន ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណាមានការយល់ឃើញខុសដូចលទ្ធិនិកាយអន្ធកៈថា "បុថុជ្ជន កាលចិត្តជាកុសល ឬអព្យាក្រឹត កំពុងប្រព្រឹត្តទៅ គប្បីពោលបានថា គេមានអនុស័យ តែមិនគប្បីពោលថា ជាអ្នកមានបរិយុដ្ឋាន ព្រោះហេតុណា, ព្រោះហេតុនោះ អនុស័យ ក៏មានម្យ៉ាង, បរិយុដ្ឋាន ក៏មានម្យ៉ាង" ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***"កាមរាគានុ-ស័យម្យ៉ាង"*** *ជាដើម ព្រោះសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយក្នុងរឿងអនុសយកថា ក្នុងពេលមុននោះឯង ។*

*ម្យ៉ាងទៀត ពាក្យថា* ***"អ្នកមានអនុស័យ"*** *ជាដើម លោករមែង*

*សម្ដែងនូវសភាពនៃពាក្យដែលបុគ្គលគប្បីពោលថា "បុថុជ្ជន ឈ្មោះថាជាអ្នកមានអនុស័យ ព្រោះភាវៈនៃបុគ្គលនោះ នៅមិនទាន់បានលះអនុស័យក្នុងខណៈនោះ" និងរមែងសម្ដែងនូវសភាពនៃពាក្យដែលបុគ្គលគប្បីពោលថា "បុគ្គលជាអ្នកមានបរិយុដ្ឋាន ព្រោះកិលេសអនុស័យនៅមិនទាន់បានកើតឡើង" , មិនមែនសម្ដែងដល់ភាវៈនៃអនុសយកិលេស និងបរិយុដ្ឋានកិលេសដែលមានសភាពផ្សេងៗ គ្នាទេ, ព្រោះហេតុដូច្នោះ ពាក្យដែលលើកមកអាងនោះ ទើបមិនមែនជាខសាធកៈថា អនុស័យ និងបរិយុដ្ឋាន មានសភាពដទៃពីគ្នាឡើយ ៕*

ចប់អញ្ញោ អនុសយោតិកថា

---

## ៦.បរិយុដ្ឋានចិត្តវិប្បយុត្តន្តិកថា

## សម្ដែងអំពីបរិយុដ្ឋានកិលេសមិនប្រកបនឹងចិត្ត

*ឥឡូវនេះ ឈ្មោះថា រឿងបរិយុដ្ឋានកិលេសមិនប្រកបនឹងចិត្ត ៖*

*ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា " កិលេសទាំងឡាយ មានរាគៈជាដើមរមែងកើតឡើង សូម្បីមនសិការក្នុងភាពជារបស់មិនទៀង" ដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក្នុងគ្រាខ្លះនោះឯង បុគ្គលរមែងមនសិការក្នុងភាពជារបស់ស្អាត ដោយគិតថា 'យើងនឹងមនសិការក្នុងភាពជារបស់*

*មិនល្អ”[២៩] ដូច្នេះ ព្រោះហេតុណា, ព្រោះហេតុនោះ បរិយុដ្ឋានក្កិលេស ទើបមិនប្រកបជាមួយនឹងចិត្ត, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ព្រោះមានន័យដូចដែលបានពោលមកហើយ ក្នុងពេលមុននុ៎ះឯង ៕*

ចប់បរិយុដ្ឋានចិត្តវិប្បយុត្តន្តិកថា

## ៧.បរិយាបន្នកថា សម្តែងអំពីធម៌ដែលរាប់បញ្ចូលគ្នា

*ឥឡូវនេះ ឈ្មោះថា រឿងធម៌ដែលរាប់បញ្ចូលគ្នា ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសដូចលទ្ធិរបស់និកាយអន្ធកៈថា “កាមរាគៈ គឺការត្រេកអរក្នុងកាម ព្រះមានព្រះភាគត្រាស់ថា ‘ដេកត្រាំក្នុងកាមធាតុ, រាប់បញ្ចូលក្នុងកាមធាតុ’ ព្រោះហេតុណា, ព្រោះហេតុនោះ សូម្បីរូបរាគៈ គឺការត្រេកអរក្នុងរូប ក៏ឈ្មោះថា ដេកត្រាំក្នុងរូបធាតុ និងអរូបធាតុ ទើបឈ្មោះថា រាប់បញ្ចូលក្នុងរូបធាតុ និងអរូបធាតុ” ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***“រូបរាគៈ”*** *ជាដើម ព្រោះសំដៅដល់ជនទាំងនោះ ពាក្យឆ្លើយតបជារបស់បរវាទី ។ ក្នុងពាក្យទាំងនោះ ពាក្យថា* ***“ដេកត្រាំ”*** *អធិប្បាយថា សកវាទីរមែងសួរថា*

---

[២៩] សំ. សឡា. ។

*"កាមរាគៈ រមែងដេកត្រាំ ដោយអំណាចនៃការកើតព្រមជាមួយកាមធាតុ ពោលគឺកាមវិតក្កៈ យ៉ាងណា, សូម្បីរូបរាគៈ ក៏ជារូបធាតុតាមលទ្ធិរបស់លោកយ៉ាងនេះឬ ?" ពាក្យថា* ***រាប់បញ្ចូល*** *អធិប្បាយថា សកវាទីរមែងសួរថា ដូចជាការរាប់បញ្ចូលនោះ ឈ្មោះថា រាប់បញ្ចូលគ្នាដោយកាមធាតុ ព្រោះរាប់បញ្ចូលគ្នាដោយអំណាចនៃកិលេសកាមរបស់កាមធាតុ ៣ យ៉ាងណា, សូម្បីរូបរាគៈ ក៏ជាសភាពដែលរាប់បញ្ចូលដោយរូបធាតុតាមលទ្ធិរបស់លោកយ៉ាងនេះឬ ? ចំណែកបរវាទីកាលមិនកំណត់បំណងរបស់សកវាទីនោះ ទើបឆ្លើយតបថា* ***"មែន"*** *ដោយអំណាចនៃលទ្ធិតែម្យ៉ាងប៉ុណ្ណោះ ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា "ជាធម៌ស្វែងរកសមាបត្តិ" ជាដើម ដើម្បីឲ្យបរវាទីកំណត់អត្ថនោះ និងដើម្បីសួរប្រៀបធៀបចិត្តដែលស្វែងរកសមាបត្តិ ដែលបណ្ឌិតយល់ព្រម (យក) ហើយថា ជាកុសល វិបាក និងកិរិយាចិត្ត ។ ពាក្យដ៏សេសក្នុងទីនេះគប្បីជ្រាបអត្ថតាមព្រះបាលីនុ៎ះចុះ ។ សូម្បីពាក្យថា* ***"កាមរាគៈដេកត្រាំក្នុងកាមធាតុ រាប់បញ្ចូលដោយកាមធាតុមិនមែនឬ ?"*** *នេះ រមែងសម្ដែងដល់សភាពនៃកាមរាគៈនោះឯង ជាធម្មជាតិដែលដេកត្រាំក្នុងកាមធាតុផង ជាសភាពដែលរាប់បញ្ចូលក្នុងកាមធាតុផង, មិនមែនសម្ដែងដល់សភាពនៃធាតុក្រៅពីនេះ ដេកត្រាំ និងរាប់បញ្ចូលក្នុងធាតុក្រៅពីនេះទេ៕*

ចប់បរិយាបន្នកថា

# ៨.អព្យាកតកថា សម្តែងអំពីអព្យាក្រឹត

*ឥឡូវនេះ ឈ្មោះថា រឿងអព្យាក្រឹត គឺទិដ្ឋិដែលព្រះមានព្រះភាគទ្រង់មិនព្យាករ ៖*

*ក្នុងរឿងនោះ អព្យាក្រឹតមាន ៤ គឺវិបាក កិរិយា រូប និងនិព្វាន, ទិដ្ឋិ លោកហៅថា អព្យាក្រឹត ព្រោះភាវៈជាធម៌មិនឲ្យផល គឺមិនឲ្យប្រយោជន៍ ។ ព្រះមានព្រះភាគត្រាស់ទុកថា* ***“ម្នាលវច្ឆៈ ទិដ្ឋិ គឺការយល់ថា លោកទៀងជាដើមនេះឯង តថាគតមិនព្យាករទេ”***[៣០] *ព្រោះសភាពនៃលោកនោះ ជារបស់ដែលតថាគតមិនពោលដោយភាវៈជារបស់ទៀងជាដើម ។ តែជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិនិកាយអន្ធកៈ និងឧត្តរាបថកៈថា “ទិដ្ឋិជាអព្យាក្រឹត មានដូចអព្យាក្រឹតដំបូង គឺវិបាកអព្យាក្រឹត ព្រោះមិនកាន់យកវិភាគនេះ” ដូច្នេះ, ពាក្យសួររបស់សកវាទីថា* ***“ទិដ្ឋិជាអព្យាក្រឹតឬ ?”*** *ជាដើម ក៏ដើម្បីបែកអត្ថនោះដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះគប្បីជ្រាបតាមព្រះបាលីនុ៎ះឯង ៕*

ចប់អព្យាកតកថា

[៣០] សំ. សឡា. ។

## ៩.អបរិយាបន្នកថា សម្តែងអំពីលោកុត្តរធម៌

*ឥឡូវនេះ ឈ្មោះថា រឿងអបរិយាបន្នៈ គឺលោកុត្តរ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយបុព្វសេលិយៈថា “បុថុជ្ជនអ្នកបានឈាន គប្បីពោលបានថា ‘ជាអ្នកមានរាគៈទៅប្រាសហើយក្នុងកាមទាំងឡាយ’ , តែមិនបានពោលថា ‘ជាអ្នកមានទិដ្ឋិទៅប្រាសហើយ’ ទេ ព្រោះហេតុណា, ព្រោះហេតុនោះ ទិដ្ឋិ ទើបជាអបរិយាបន្នៈ គឺលោកុត្តរធម៌” ដូច្នេះ, ពាក្យរបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ៕*

ចប់អបរិយាបន្នកថា

### រួមកថាដែលមានក្នុងវគ្គនេះ គឺ

*១.កុសលាកុសលបដិសន្ទហនកថា, ២.សឡាយតនុប្បត្តិកថា, ៣.អនន្តរប្បច្ចយកថា, ៤.អរិយរូបកថា, ៥.អញ្ញោ អនុសយោតិកថា, ៦.បរិយុដ្ឋានចិត្តវិប្បយុត្តនិកថា, ៧.បរិយាបន្នកថា, ៨.អព្យាកតកថា, ៩.អបរិយាបន្នកថា ។*

**ចប់វគ្គទី ១៤**

## វគ្គទី ១៥

## ១.បច្ចយតាកថា សម្តែងអំពីភាវៈជាបច្ច័យ

*ឥឡូវនេះ ឈ្មោះថា រឿងភាវៈជាបច្ច័យ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា "ធម៌ណា ជាបច្ច័យដោយហេតុប្បច្ច័យហើយ, ធម៌នោះ ក៏ជាបច្ច័យដោយហេតុប្បច្ច័យដល់ធម៌ពួកណា, ធម៌ពួកនោះប៉ុណ្ណោះ រមែងមិនជាបច្ច័យដោយអារម្មណប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ, ឬថា ធម៌ណាជាបច្ច័យដល់ធម៌ពួកណា ដោយអារម្មណប្បច្ច័យហើយ, ធម៌នោះ រមែងមិនជាបច្ច័យដល់ធម៌ពួកនោះឯង ដោយអនន្តរប្បច្ច័យ និង សមនន្តរប្បច្ច័យ ព្រោះហេតុណា, ព្រោះហេតុនោះ ភាពជាបច្ច័យលោកកំណត់ទុកហើយ" ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនុ៎ះឯង ដោយប្រការដូច្នេះ ៕*

ចប់បច្ចយតាកថា

## ២.អញ្ញមញ្ញប្បច្ចយកថា សម្តែងអំពីអញ្ញមញ្ញប្បច្ច័យ

*ឥឡូវនេះ ឈ្មោះថា រឿងអញ្ញមញ្ញប្បច្ច័យ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា "សង្ខារទាំងឡាយរមែងកើត ព្រោះអវិជ្ជាជាបច្ច័យនេះប៉ុណ្ណោះ" ជាបែបផែន, ពាក្យថា "អវិជ្ជារមែងកើត សូម្បីព្រោះសង្ខារជាបច្ច័យមិនមានក្នុងលទ្ធិ ព្រោះហេតុដូច្នោះ អវិជ្ជាប៉ុណ្ណោះទើបជាបច្ច័យដល់សង្ខារទាំងឡាយ, តែសង្ខារទាំងឡាយ មិនបានជាបច្ច័យដល់អវិជ្ជាឡើយ" ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ដើម្បីសម្តែងអត្ថថា "សូម្បីភាវៈជាបច្ច័យដល់គ្នានឹងគ្នារបស់បច្ច័យទាំងឡាយ មានអវិជ្ជា និងសង្ខារជាដើម" ដូច្នេះ, ពាក្យឆ្លើយតប ជារបស់បរវាទី ។ ក្នុងពាក្យថា* ***"អវិជ្ជាកើតប្រកបជាមួយនឹងសង្ខារមិនមែនឬ ?"*** *នេះ លោកកាន់យកអបុញ្ញាភិសង្ខារតែម្យ៉ាង, ព្រោះហេតុដូច្នោះ ក្នុងពាក្យថា* ***"សូម្បីព្រោះសង្ខារជាបច្ច័យ ក៏កើតអវិជ្ជាបាន"*** *នេះ បណ្ឌិតគប្បីជ្រាបភាវៈជាបច្ច័យដោយអំណាចនៃសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ អត្ថិ-ប្បច្ច័យ អវិគតប្បច្ច័យ និងសម្បយុត្តប្បច្ច័យ ។*

*ក្នុងពាក្យថា* ***"សូម្បីក្នុងឧបាទានជាបច្ច័យ ក៏កើតតណ្ហា"*** *នេះ អធិប្បាយថា វៀរកាមុបាទានចេញហើយ បណ្ឌិតគប្បីជ្រាបថា ឧបាទាន*

ដ៏សេស ៣ រមែងជាបច្ច័យដល់តណ្ហា ដូចសង្ខារទាំងឡាយ ជាបច្ច័យដល់អវិជ្ជា ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ។ ពាក្យសួរថា ***"ព្រោះជរា និងមរណៈជាបច្ច័យ"*** ជាដើម ជារបស់បរវាទី ។ ពាក្យសួរថា ***"ព្រោះវិញ្ញាណជាបច្ច័យ ទើបកើតនាមរូប"*** ជាដើម ជារបស់សកវាទី ៕

ចប់អញ្ញមញ្ញប្បច្ចយកថា

------------

## ៣.អទ្ធាកថា សម្តែងអំពីរយៈកាល

*ឥឡូវនេះ ឈ្មោះថា រឿងរយៈកាល ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុសថា "ឈ្មោះថា* ***កាល*** *ពោលគឺវេលា ជាសភាវៈសម្រេចហើយ" ព្រោះអាស្រ័យព្រះសូត្រថា "ម្នាលភិក្ខុទាំងឡាយ កថាវត្ថុទាំងនេះ មាន ៣ គឺរឿងដែលពោលប្រារព្ធអតីត អនាគត និងបច្ចុប្បន្ន"[៣១] ដូច្នេះ ពាក្យសួររបស់សកវាទីថា* ***"អទ្ធា គឺអតីតកាល អនាគតកាល និងបច្ចុប្បន្នកាល ជាសភាវៈដែលសម្រេចហើយ"*** *ដូច្នេះ ដើម្បីសម្តែងវិភាគ គឺការចែកដល់ជនទាំងនោះថា "ឈ្មោះថា កាលអ្វីៗ ជាសភាវៈសម្រេចហើយ មិនមានទេ, តែខន្ធទាំងឡាយណាមួយ មានរូបក្ខន្ធជាដើម ដែលត្រឹមតែ*

---

[៣១] អំ. តិក. ។

*ជាបញ្ញត្តិ ព្រោះកាលជារបស់សម្រេចហើយ គឺកើតឡើងហើយ” ដូច្នេះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* **“ជារូប”** *ជាដើម ដើម្បីចោទថា “បើកាលនោះ ជារបស់សម្រេចហើយមែន, កាលនោះ ក៏គប្បីមានដូចខន្ធណាទីមួយ មានរូបក្ខន្ធជាដើម” ។ បរវាទីឆ្លើយបដិសេធ ។ ពាក្យដ៏សេស គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ដោយប្រការដូច្នេះ ៕*

ចប់អទ្ធាកថា

## ៤.ខណលយមុហុត្តកថា

## សម្តែងអំពីខណៈ លយៈ និងមុហុត្តៈ

*ឥឡូវនេះ ឈ្មោះថា រឿងខណៈ គឺគ្រាមួយ ឬពេលមួយ, លយៈ គឺមួយស្របក់ និងមុហុត្តៈ គឺមួយភ្លែត ។ សូម្បីក្នុងរឿងខណៈ លយៈ និងមុហុត្តៈ ក៏មានន័យដូចគ្នានេះដែរ គឺមានន័យតែមួយដូចអទ្ធា ព្រោះខណៈ-លយៈ និងមុហុត្តៈទាំងនេះ សូម្បីទាំងអស់ជាវេវចនៈរបស់វេលានោះឯង៕*

ចប់ខណលយមុហុត្តកថា

## ៥.អាសវកថា សម្តែងអំពីអាសវៈ

*ឥឡូវនេះ ឈ្មោះថា រឿងអាសវៈ ៤ ៖*

*ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយហេតុវាទថា “ឈ្មោះថា អាសវៈដទៃ ក្រៅលែងជាងអាសវៈ ៤ មិនមានទេ, អាសវៈ ៤ នឹងគប្បីជាអារម្មណ៍របស់អាសវៈបាន ដោយអាសវៈណាទៅ, ព្រោះអាសវៈទាំង ៤ នោះ មិនជាអាសវៈទេ” ដូច្នេះ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតប ជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលពាក្យថា* ***“ជាមគ្គ”*** *ជាដើម ដើម្បីចោទដោយពាក្យថា “បើអាសវៈទាំងនោះ មិនជាអាសវៈទេ, កាលបើមានហេតុយ៉ាងនេះ អាសវៈទាំងនោះ ក៏គប្បីសម្រេចភាពនៃមគ្គជាដើមបានដែរ” ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ៕*

ចប់អាសវកថា

.......................

## ៦.ជរាមរណកថា សម្ដែងអំពីជរា និងមរណៈ

*ឥឡូវនេះ ឈ្មោះថា រឿងជរា និងមរណៈ ៖*

*ក្នុងរឿងនោះ ធម្មតា ជរា និងមរណៈ មិនគួរពោលថា ជាលោកិយ ឬលោកុត្តរទេ ព្រោះមិនមែនជាសភាវៈដែលសម្រេចហើយ គឺមិនមែនជាសភាវៈដែលកើតឡើងហើយ ដូចធម៌ទាំងឡាយ មានរូបជាដើមឡើយ ។ ពិតមែន ក្នុងទុកមាតិកាថា* **“លោកិយា ធម្មា លោកុត្តរា ធម្មា”** *ដូច្នេះ*

*ជរា និងមរណៈ មិនសម្រេចក្នុងលោកិយបទ (បានដល់ លោកិយចិត្ត ៨១ ចេតសិក ៥២ និងរូប ២៨), និងលោកុត្តរបទ (បានដល់ លោកុត្តរចិត្ត ៨ ចេតសិក ៣៦ និងនិព្វាន) ។ ក្នុងបញ្ហានោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយមហាសង្ឃិកៈថា "ជរា និងមរណៈរបស់លោកុត្តរធម៌ ជាលោកុត្តរ ព្រោះមិនកាន់យកសភាវៈនេះ" , ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតប ជារបស់បរវាទី; ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ៕*

ចប់ជរាមរណកថា

.............................

## ៧.សញ្ញាវេទយិតកថា

### សម្តែងអំពីសញ្ញាវេទយិតនិរោធសមាបត្តិទី ១

*ឥឡូវនេះ ឈ្មោះថា រឿងសញ្ញាវេទយិតនិរោធសមាបត្តិ គឺសមាបត្តិដែលរំលត់សញ្ញា និងវេទនា ៖*

*ក្នុងរឿងនោះ ធម៌អ្វីៗ ឈ្មោះថា សញ្ញាវេទយិតនិរោធសមាបត្តិរមែងមិនមាន, មានតែការរំលត់ខន្ធទាំង ៤; ព្រោះហេតុដូច្នោះ សញ្ញា-វេទយិតនិរោធសមាបត្តិនោះ ទើបមិនមែនលោកិយ មិនមែនលោកុត្តរ; ក៏ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយហេតុវាទ*

នុ៎ះឯងថា “សញ្ញាវេទយិតនិរោធសមាបត្តិ មិនមែនជាលោកិយ, ព្រោះជាលោកុត្តរ” ដូច្នេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងមុននុ៎ះដែរ ៕

ចប់សញ្ញាវេទយិតកថា

..................................

## ៨.ទុតិយសញ្ញាវេទយិតកថា

## សម្តែងអំពីសញ្ញាវេទយិតនិរោធទី ២

*ឥឡូវនេះ ជនទាំងឡាយណា មានការយល់ឃើញខុសថា “សញ្ញា-វេទយិតនិរោធសមាបត្តិមិនមែនជាលោកុត្តរ ព្រោះជាលោកិយ” ដូច្នេះ ដូចលទ្ធិរបស់និកាយហេតុវាទទាំងឡាយ, ពាក្យសួររបស់សកវាទី សំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងមុននុ៎ះដែរ ៕*

ចប់ទុតិយសញ្ញាវេទយិតនិរោធកថា

.......................

## ៩.តតិយសញ្ញាវេទយិតកថា

## សម្តែងអំពីសញ្ញាវេទយិតនិរោធទី ៣

*ឥឡូវនេះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិ*

របស់និកាយរាជគិរិកៈថា "សូម្បីអ្នកចូលសញ្ញាវេទយិតនិរោធសមាបត្តិ គប្បីធ្វើកាលកិរិយាបាន ដោយកាន់យកគោលថា 'ឈ្មោះថា ការទៀង មិនមាន ព្រោះសភាពនៃសត្វទាំងឡាយមានសេចក្តីស្លាប់ជាធម្មតា ដូចពាក្យថា 'អ្នកណាស្លាប់, អ្នកឯណោះ នៅមិនទាន់ស្លាប់" ដូច្នេះ, ពាក្យសួររបស់សកវាទីដើម្បីសម្តែងដល់វេលាស្លាប់ និងមិនមែនវេលាស្លាប់ ព្រោះសភាពនៃបុគ្គលសូម្បីចូលសមាបត្តិ ក៏មានសេចក្តីស្លាប់ជាធម្មតា, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ ទើបសកវាទីពោលនឹងបរវាទីនោះថា "***ផស្សៈដែលកើតក្នុងសម័យមានសេចក្តីស្លាប់ជាទីបំផុត***" ជាដើម ដើម្បីចោទដោយអាការថា "ផស្សៈដែលកើតក្នុងវេលាដែលមានសេចក្តីស្លាប់ជាធម្មតា ឈ្មោះថា គប្បីមានដល់អ្នកធ្វើកាលកិរិយា ដោយអាការនោះឬ ?" ។

ត្រូវសកវាទីសួរថា "***បុគ្គលអ្នកមិនមានផស្សៈ មានការធ្វើកាលកិរិយា***" ជាដើម បរវាទីឆ្លើយបដិសេធ ដោយសំដៅយកសត្វដ៏សេសគឺក្រៅអំពីអ្នកចូលសមាបត្តិនោះ ។

ត្រូវសកវាទីសួរពាក្យថា "***ថ្នាំពិសគប្បីចូលទៅ***" ជាដើម ក៏ឆ្លើយបដិសេធ ដោយសំដៅយកអានុភាពនៃសមាបត្តិ ។ តែឆ្លើយតប ក្នុងគ្រាទី ២ ដោយសំដៅយកសរីរៈប្រក្រតី ។ ក៏កាលបើមានសភាពយ៉ាងនេះ

ឈ្មោះថា អានុភាពនៃសមាបត្តិ ក៏មិនមាន, ព្រោះហេតុនោះឯង ទើបសកវាទីសួរបរវាទីថា "មិនបានចូលនិរោធឬ ?" ។

ពាក្យសួរថា ***"បុគ្គលអ្នកចូលសញ្ញាវេទយិតនិរោធ មិនគប្បីធ្វើកាលកិរិយាឬ ?"*** ជារបស់បរវាទី ។ ក្នុងបញ្ហារបស់បរវាទីថា ***"និយាមដែលជាហេតុកំណត់ដោយទៀង មាន, តែឈ្មោះថា និយាមយ៉ាងនេះ មិនមានទេ"*** ព្រោះហេតុណា, ព្រោះហេតុនោះ ទើបសកវាទីឆ្លើយបដិសេធ ។ ពាក្យថា ***"អ្នកព្រមព្រៀងដោយចក្ខុវិញ្ញាណ"*** ជាដើម ដែលសកវាទីពោលក៏ដើម្បីសម្តែងថា "សូម្បីកាលនិយាមដូច្នេះ មិនមាន សត្វក៏ត្រូវស្លាប់តាមវេលាប៉ុណ្ណោះ, រមែងមិនស្លាប់ដោយខុសវេលាឡើយ" ។

ក្នុងបញ្ហានោះ មានពាក្យអធិប្បាយថា បើការធ្វើកាលកិរិយា គប្បីមាន ព្រោះការមិនមាននិយាមមែន, ការធ្វើកាលកិរិយានោះ ក៏នឹងគប្បីមាន សូម្បីដល់អ្នកដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ ព្រោះសត្វ រមែងមិនស្លាប់ រមែងមិនកើតដោយចក្ខុវិញ្ញាណ ៥ ដូច្នេះទេ, ព្រោះហេតុដូច្នោះ ការឃៀងឃាតក្នុងព្រះសូត្រ គប្បីមាន ដូចការធ្វើកាលកិរិយា រមែងមិនមានដល់អ្នកព្រមព្រៀងដោយចក្ខុវិញ្ញាណ យ៉ាងណា, ការធ្វើកាលកិរិយា ក៏រមែងមិនមាន សូម្បីដល់អ្នកចូលនិរោធសមាបត្តិ យ៉ាងនេះ ដោយប្រការដូច្នេះឯង ៕

ចប់តតិយសញ្ញាវេទយិតកថា

# ១០.អសញ្ញសត្តូបិកាកថា

## សម្តែងអំពីសមាបត្តិដែលឱ្យចូលដល់ភពអសញ្ញសត្វ

*ឥឡូវនេះ ឈ្មោះថា រឿងសមាបត្តិដែលឲ្យចូលដល់ភពអសញ្ញសត្វ ៖*

*ក្នុងរឿងនោះ ភាវនាដែលប្រព្រឹត្តទៅដោយអំណាចនៃសញ្ញាវិរាគៈ ជាអសញ្ញសមាបត្តិ ខ្លះ ជានិរោធសមាបត្តិខ្លះ ឈ្មោះថា សញ្ញាវេទយិត-និរោធសមាបត្តិ ។ ព្រោះហេតុដូច្នោះ សញ្ញាវេទយិតនិរោធសមាបត្តិ ទើបមាន ២ គឺជាលោកិយ និងលោកុត្តរ ។ បណ្តាសមាបត្តិទាំងនោះ សមាបត្តិដែលជាហេតុឲ្យចូលដល់អសញ្ញសត្វរបស់បុថុជ្ជន ជាលោកិយ, ដែលជារបស់ព្រះអរិយៈទាំងឡាយ ជាលោកុត្តរ, តែសមាបត្តិដែលជារបស់ព្រះអរិយៈនោះ មិនមែនជាសមាបត្តិដែលជាហេតុឲ្យចូលដល់ភាពជាអសញ្ញសត្វឡើយ ។*

*ក៏ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយហេតុវាទថា "សញ្ញាវេទយិតនិរោធសមាបត្តិ ជាសមាបត្តិដែលឲ្យចូលដល់ភាពជាអសញ្ញសត្វដោយមិនប្លែកគ្នា" ព្រោះមិនធ្វើវិភាគយ៉ាងនេះ, ពាក្យសួររបស់សកវាទីសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទដោយអំណាចនៃ* ***កុសលមូល គឺអលោភៈ*** *ជាដើមថា មានដល់អ្នកចូលអសញ្ញសមាបត្តិ, តែមិនមានដល់អ្នកចូល*

និរោធសមាបត្តិទេ ទើបពោលពាក្យថា **“អត្ថិ** = កុសលមូល... រមែងមានឬ ?” ជាដើម ។

ក្នុងបញ្ហាថា ***“សូម្បីក្នុងនិរោធសមាបត្តិនេះ អ្នកចូលក៏មិនមានសញ្ញា”*** បានដល់ ភាពជាអ្នកមិនមានសញ្ញា ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ព្រោះការចូលសមាបត្តិក្នុងធម្មវិន័យនេះ ដោយអំណាចនៃសញ្ញាវិរាគៈ ។ ពាក្យថា ***“សូម្បីក្នុងភពនៃអសញ្ញសត្វនោះ”*** ក៏ត្រាស់ដោយភាពជាអសញ្ញសត្វនោះឯង; ព្រោះហេតុដូច្នោះ បរវាទីអ្នកកាន់យកបដិញ្ញានេះហើយ ទើបឲ្យលទ្ធិតាំងទុក, តែក៏តាំងទុកដោយឧបាយបួម ។ ម្យ៉ាងទៀត បានដល់ ភាពជាអ្នកមិនមានសញ្ញា ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាត សំដៅយកនិរោធសមាបត្តិក្នុងធម្មវិន័យនេះ, ពាក្យថា ***“សូម្បីក្នុងភពអសញ្ញសត្វនោះ”*** បានដល់ និរោធសមាបត្តិរបស់អនាគាមី អ្នកឃ្លាតចាកលោកនេះមែនពិត; ព្រោះហេតុនោះឯង លទ្ធិដែលបរវាទីបដិញ្ញាតាំងទុកនេះ រមែងមិនតាំងនៅបានឡើយ ៕

ចប់អសញ្ញសត្តូបិកាកថា

.....................................

## ១១.កម្មូបចយកថា សម្តែងអំពីការសន្សំកម្ម

ឥឡូវនេះ ឈ្មោះថា រឿងការសន្សំកម្ម ៖

ក្នុងរឿងនោះ ជនទាំងឡាយណា មានការយល់ឃើញខុស ដូចលទ្ធិរបស់និកាយអន្ធកៈថា "ឈ្មោះថា ការសន្សំកម្មម្យ៉ាង ក្រៅអំពីកម្ម ទាំងជាចិត្តវិប្បយុត្ត ជាអព្យាក្រឹត ជាអនារម្មណ៍" ។ ពាក្យសួររបស់សកវាទីថា ***"កម្មមានម្យ៉ាង"*** ជាដើម ដោយសំដៅដល់ជនទាំងនោះ, ពាក្យឆ្លើយតបជារបស់បរវាទី ។ លំដាប់នោះ សកវាទីដើម្បីចោទដោយពាក្យថា ***"ផស្សៈមានម្យ៉ាង"*** ជាដើម ។ បរវាទីឆ្លើយបដិសេធ ព្រោះមិនមានក្នុងលទ្ធិ ។ ក្នុងបញ្ហាទាំងឡាយថា ***"ការសន្សំកម្មកើតព្រមជាមួយនឹងកម្មឬ ?"*** បរវាទីឆ្លើយបដិសេធសំដៅយកការមិនប្រកបជាមួយនឹងចិត្ត, តែឆ្លើយតប សំដៅយកការសម្បយុត្តជាមួយនឹងចិត្ត ។ ក្នុងបញ្ហាថា ***"ការសន្សំកម្ម... ជាកុសលឬ ?"*** ក៏ឆ្លើយបដិសេធសំដៅយកវិប្បយុត្ត, និងឆ្លើយតបសំដៅយកសម្បយុត្ត; សូម្បីក្នុងបញ្ហាទាំងឡាយថា ***"ការសន្សំកម្ម... ជាអកុសលឬ ?"*** ខាងមុខ ក៏មានន័យដូចគ្នានេះដែរ ។ ត្រូវសកវាទីសួរថា "ការសន្សំកម្ម... មានអារម្មណ៍ឬ ?" បរវាទីប្រាថ្នាការមិនមានអារម្មណ៍ដោយចំណែកតែម្យ៉ាងប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ ទើបឆ្លើយបដិសេធ ។ ពាក្យថា "កាលបើចិត្តរលត់" សេចក្ដីថា កាលបើចិត្តកំពុងរលត់ ក្នុងកាលណា, កម្មក៏កំពុងរលត់ ក្នុងពេលនោះ; ម្យ៉ាងទៀត ពាក្យថា ***"ចិត្ត"*** នេះ

លោកប្រកបដោយបឋមាវិភត្តិ តែចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ អធិប្បាយថា កាលបើចិត្តកំពុងរលត់ ។

**ម្យ៉ាងវិញទៀត គប្បីជ្រាបព្រះបាលីនោះប៉ុណ្ណោះថា ៖**

***ការសន្សំកម្មដែលសម្បយុត្តជាមួយនឹងចិត្ត រមែងរលត់, ដែលវិប្បយុត្ត រមែងមិនរលត់*** ក្នុងបញ្ហានោះ, ព្រោះហេតុដូច្នោះ ទើបបរវាទីឆ្លើយតបដង ឆ្លើយបដិសេធដង ។ ពាក្យថា ***“កាលបើកម្មមាន ការសន្សំកម្មក៏មាន”*** សេចក្ដីថា គ្រាកម្មមានការសន្សំកម្ម ក៏មាន; ម្យ៉ាងទៀត ការសន្សំកម្ម តាំងនៅចំពោះក្នុងកម្ម វិបាករមែងកើត ព្រោះការសន្សំកម្មនោះឯង ។ លទ្ធិរបស់បរវាទីថា “ក៏គ្រាកម្មនោះរលត់ហើយ ការសន្សំកម្ម រមែងតាំង នៅរហូតដល់ការកើតឡើងនៃវិបាក ដូចពូជរមែងតាំងនៅ ព្រោះការកើត ឡើងនៃពន្លករបស់ពូជ” , ព្រោះហេតុដូច្នោះ ទើបឆ្លើយតប ។ ពាក្យថា ***“កម្មយ៉ាងនេះ ការសន្សំកម្ម ក៏យ៉ាងនេះឯង វិបាកនៃកម្ម ក៏យ៉ាងនេះដែរ”*** សេចក្ដីថា លទ្ធិរបស់បរវាទីនោះថា ការសន្សំកម្ម មាននៅក្នុងកម្ម, ការ សន្សំកម្មនោះ រមែងតាំងនៅត្រឹមណា អំពីការកើតឡើងនៃវិបាក ព្រោះ ហេតុណា, ព្រោះហេតុនោះ ទើបសកវាទីសួរដល់ធម៌ទាំង ៣ នោះថា “ជាសភាវៈតែមួយដូចគ្នាឬ ?” ; សកវាទីរមែងសួរដើម្បីចោទ ដោយ ពាក្យថា “សប្បវិបាកធម្មធម៌ គឺធម៌ដែលជាហេតុឲ្យវិបាកកើតឡើង ជាធម៌ ភ្ជាប់ដោយអារម្មណ៍នោះពិត ដូចវិបាកក្នុងបទថា ‘ ***ទាំងវិបាក ក៏មាន***

***អារម្មណ៍ឬ ?"*** ចំណែកបរវាទីឆ្លើយតបខមួយ, បដិសេធខមួយ ដោយអំណាចនៃលទ្ធិ ។ សូម្បីក្នុងបដិលោមបញ្ហា ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបតាមព្រះបាលីនុ៎ះចុះ ៕

ចប់កម្មូបចយកថា

**រួមកថាដែលមានក្នុងវគ្គនេះ គឺ**

១.បច្ចយតាកថា, ២.អញ្ញមញ្ញប្បច្ចយកថា, ៣.អទ្ធាកថា, ៤.ខណលយមុហុត្តកថា, ៥.អាសវកថា, ៦.ជរាមរណកថា, ៧.សញ្ញាវេទយិតកថា, ៨.ទុតិយសញ្ញាវេទយិតកថា, ៩.តតិយសញ្ញាវេទយិតកថា, ១០.អសញ្ញសត្តូបិកាកថា, ១១.កម្មូបចយកថា ។

**ចប់វគ្គទី ១៥**

**ចប់បណ្ណាសកៈទី ៣**

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ បញ្ចបករណ៍

## តតិយភាគ ១០ ចប់

ដោះពុម្ពលើកទី ២

រក្សាសិទ្ធិ (ហាមថតចម្លង)

ដោះពុម្ពលើកទី ២

រក្សាសិទ្ធិ (ហាមថតចម្លង)